Public Disclosure Authorized
Public Disclosure Authorized
Public Disclosure Authorized
Public Disclosure Authorized

# បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា



## កម្ពុជានៅក្នុងកាលៈទេសៈមានវិបត្តិកូវីដ 19

### អត្ថបទផ្តោតពិសេស៖

### គណនេយ្យភាពរបស់គ្រូបង្រៀន និងលទ្ធផលនៃការសិក្សារបស់សិស្ស

ខែ ឧសភា ឆ្នាំ 2020

ក្រុមធនាគារពិភពលោក



# បច្ចុប្បន្នភាព សេដ្ឋកិច្ច កម្ពុជា

ខែ ឧសភា ឆ្នាំ 2020

## កម្ពុជានៅក្នុង កាលៈទេសៈមានវិបត្តិ កូវីដ 19

ក្រុមធនាគារពិភពលោក

# មាតិកា


**សេចក្តីថ្លែងអំណរគុណ** ...... ១

**អក្សរកាត់** ...... ២

**សេចក្តីសង្ខេប** ...... ៣

**ការអភិវឌ្ឍសេដ្ឋកិច្ចថ្មីៗ និងទស្សនវិស័យ** ...... ១១

**ការអភិវឌ្ឍថ្មីៗ** ...... ១១

សកម្មភាពសេដ្ឋកិច្ចបានថយចុះយ៉ាងឆាប់រហ័សដោយសារការផ្ទុះជំងឺកូវីដ 19 ទូទាំងពិភពលោក ...... ១១

បើទោះជាកម្ពុជាបានចៀសផុតពីវិបត្តិសុខភាពនាពេលកន្លងមក ប៉ុន្តែ កម្ពុជាមិនអាចគេចផុតពីវិបត្តិសេដ្ឋកិច្ចសកលដែលកំពុងកើតឡើងនៅលើពិភពលោកឡើយ ...... ១២

ឧស្សាហកម្មទេសចរណ៍ និងបដិសណ្ឋារកិច្ច ប្រឈមនឹងទាំងការថយចុះផ្នែករចនាសម្ព័ន្ធ និងរងផលប៉ះពាល់ធ្ងន់ធ្ងរដោយសារការផ្ទុះជំងឺកូវីដ 19 ...... ១២

ជំងឺកូវីដ 19 បានធ្វើឲ្យមានការប៉ះទង្គិចលើតម្រូវការនាំចេញដែលមិនធ្លាប់មាន ...... ១៤

កំណើននៃការនាំចេញសម្លៀកបំពាក់ ស្បែកជើង និងទំនិញធ្វើដំណើរ បានថយចុះយ៉ាងខ្លាំងនៅត្រីមាសទីមួយក្នុងឆ្នាំ 2020 ...... ១៥

ការនាំចេញទំនិញធ្វើដំណើរ (និងផលិតផលវាយនភណ្ឌផ្សេងទៀត)មានចំនួនច្រើនជាងការនាំចេញស្បែកជើងនៅឆ្នាំ 2019 ...... ១៥

សហរដ្ឋអាមេរិកបានក្លាយជាទីផ្សារធំជាងគេសម្រាប់ការនាំចេញសម្លៀកបំពាក់ ទំនិញធ្វើដំណើរ និងស្បែកជើងរបស់កម្ពុជា ...... ១៥

ការនាំចេញសម្លៀកបំពាក់ទៅកាន់ទីផ្សារសហភាពអឺរ៉ុប បានថយចុះជាលើកដំបូងចាប់តាំងពីពេលមានវិបត្តិហិរញ្ញវត្ថុសកលនៅអំឡុងឆ្នាំ 2008-09 ...... ១៦

ទីផ្សារជប៉ុនហាក់មានភាពល្អប្រសើរសម្រាប់ការនាំចេញគ្រឿងបន្លាស់អេឡិចត្រូនិក គ្រឿងបន្លាស់យានយន្ត និងគ្រឿងបង្គុំរបស់កម្ពុជា ...... ១៦

បរិមាណទឹកប្រាក់នៃគម្រោងវិនិយោគផ្ទាល់ពីបរទេសដែលត្រូវបានអនុម័ត ថយចុះចំនួន 52.2 ភាគរយក្នុងរយៈពេលពីរខែដំបូងក្នុងឆ្នាំ 2020 ...... ១៧

ភាគច្រើននៃការវិនិយោគផ្ទាល់ពីបរទេសដែលត្រូវបានអនុម័ត នៅបន្តផ្តោតលើវិស័យសំណង់ និងអចលនទ្រព្យ ...... ១៧

នៅដើមឆ្នាំ 2020 សកម្មភាពសាងសង់បានថយចុះយ៉ាងខ្លាំងដោយសារការផ្ទុះជំងឺកូវីដ 19 ទូទាំងពិភពលោក ...... ១៨

ការផ្ទុះជំងឺកូវីដ 19 ជាសកល បានធ្វើឱ្យអាក់ខានដល់តម្រូវការ និងការប្រើប្រាស់ក្នុងស្រុក ...... ១៩

ឱនភាពគណនីចរន្តនៅតែមានស្ថិរភាព និងទទួលបានហិរញ្ញប្បទានទាំងស្រុងពីលំហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេសកាលពីឆ្នាំមុន ...... ១៩

លំហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេសបានថយចុះនៅឆ្នាំ 2019 ...... ១៩

ការរួមចំណែករបស់វិស័យកសិកម្មដល់កំណើន ផសស បានថយចុះនៅឆ្នាំ 2019 ...... ២០

វិស័យកសិកម្មហាក់មិនអាចស្រូបយកកម្មករនិយោជិតដែលត្រូវបានរំសាយពីការងារក្នុងវិស័យទេសចរណ៍បានច្រើនទេ ...... ២០

ពលករចំណាកស្រុកដែលវិលត្រឡប់មកស្រុកវិញ នឹងដាក់សម្ពាធបន្ថែមទៀតលើទីផ្សារការងារដែលកំពុងតែរួមតូចនៅកម្ពុជា ...... ២១

ដោយសារតែការផ្ទុះជំងឺកូវីដ 19 អតិផរណាមានកម្រិតទាបនៅត្រីមាសទីមួយក្នុងឆ្នាំ 2020 ...... ២១

កំណើនរូបិយវត្ថុទូលាយបានថយចុះដោយសារតែចំនួនប្រាក់បញ្ញើជារូបិយប័ណ្ណបរទេសថយចុះ ...... ២៤

សម្ពាធកាន់តែខ្លាំងលើអត្រាប្តូរប្រាក់ ...... ២៤

គិតត្រឹមបំណាច់ឆ្នាំ 2019 កំណើន (សរុប) នៃការផ្តល់ឥណទានធនាគារដល់អាជីវកម្ម បានថយចុះជាលើកដំបូងចាប់តាំងពីពាក់កណ្តាលឆ្នាំ 2018 ...... ២៥

ការផ្តល់ឥណទានធនាគារក្នុងស្រុកដល់វិស័យសំណង់ អចលនទ្រព្យ និងការបញ្ចាំនៅតែមានកំណើន ...... ២៥

ការប៉ះពាល់ដល់ចំណូលក្នុងស្រុក ...... ២៦

ការប្រមូលចំណូលកើនឡើងខ្ពស់កាលពីឆ្នាំមុន ...... ២៧

ការចំណាយក៏បានកើនឡើងកាលពីឆ្នាំមុន ...... ២៧

ជាការឆ្លើយតបនឹងការផ្ទុះជំងឺកូវីដ 19 អាជ្ញាធរកម្ពុជាបានប្រកាសថវិកាឆ្នាំ 2020 ថាជាថវិការឹតត្បិត.......... ២៧
ដើម្បីផ្តល់ហិរញ្ញប្បទានដល់ឱនភាពសារពើពន្ធកាន់តែច្រើន បំណុលសាធារណៈត្រូវបានរំពឹងថានឹងកើនដល់ 35 ភាគរយនៃ ផសស គិតត្រឹមឆ្នាំ 2022 .......... ២៨
ចិននៅតែជាប្រភពផ្តល់កម្ចីច្រើនជាងគេ ហើយបំណុលដែលកម្ពុជាជំពាក់ចិនមានជិតពាក់កណ្តាលនៃបំណុលសរុប .......... ២៩
ទស្សនវិស័យ.......... ២៩
សេដ្ឋកិច្ចកម្ពុជាកំពុងទទួលរងការប៉ះពាល់យ៉ាងខ្លាំងដោយសារការផ្ទុះជំងឺកូវីដ 19 .......... ២៩
ក្រោមសេណារីយ៉ូគោល កំណើនពិតត្រូវបានព្យាករណ៍ថានឹងថយចុះអវិជ្ជមាន 1 ភាគរយនៅឆ្នាំ 2020 .......... ២៩
នៅក្នុងសេណារីយ៉ូទាបបំផុត ផសស ពិត ត្រូវបានព្យាករណ៍ថានឹងថយចុះអវិជ្ជមាន 2.9 ភាគរយនៅឆ្នាំ 2020.......... ៣១
ជម្រើសគោលនយោបាយ .......... ៣១
អត្ថបទផ្តោតពិសេស៖ គណនេយ្យភាពរបស់គ្រូបង្រៀន និងលទ្ធផលនៃការសិក្សារបស់សិស្ស .......... ៣៥
ករណីសិក្សាអំពីប្រភេទសាលារៀន .......... ៣៥
ការពង្រឹងគណនេយ្យភាពដើម្បីកែលម្អគុណភាពអប់រំ .......... ៣៥
សេចក្តីផ្តើម .......... ៣៥
កិច្ចខិតខំប្រឹងប្រែងដើម្បីលើកវិស័យអប់រំឲ្យខ្ពស់មួយកម្រិត .......... ៣៧
១.បានពង្រីកឱកាសទទួលការអប់រំ.......... ៣៧
២.ការដំឡើងប្រាក់ខែគ្រូបង្រៀន និងបុគ្គលិកអប់រំ.......... ៣៧
៣.ទោះជាយ៉ាងណាក៏ដោយ លទ្ធផលនៃការសិក្សារបស់សិស្សមិនមានភាពប្រសើរឡើងនោះទេ .......... ៣៨
៤.សាលារៀនជំនាន់ថ្មីអនុវត្តគោលការណ៍ថ្មីគណនេយ្យភាព ស្វ័យភាព និងគុណភាពសេវាអប់រំ .......... ៤០
៥.ការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផលបានលើកកម្ពស់គណនេយ្យភាពសម្រាប់សហគមន៍ .......... ៤២
បញ្ហាប្រឈមចម្បងៗក្នុងការកែលម្អលទ្ធផលសិក្សារបស់សិស្សនៅតាមសាលារដ្ឋ .......... ៤៥
១.អភិបាលកិច្ចសាលារៀន និងគណនេយ្យភាពចំពោះសហគមន៍នៅតែគ្មានប្រសិទ្ធភាព.......... ៤៥
២.លាភការលើកទឹកចិត្តគ្រូបង្រៀនមិនអនុវត្តតាមគោលការណ៍គុណផលការងារអាចនាំឱ្យមានគម្លាតគុណភាពអប់រំកាន់តែធំរវាងសាលារៀនរដ្ឋ និងសាលារៀនឯកជន.......... ៤៧
៣.លើសចំនួនគ្រូបង្រៀន និងខ្វះគ្រូបង្រៀនប៉ះពាល់ដល់លទ្ធផលសិក្សារបស់សិស្សយ៉ាងអវិជ្ជមាន .......... ៥០
៤.វិនិយោគតិចតួចរបស់រដ្ឋាភិបាលសម្រាប់អភិវឌ្ឍន៍វិជ្ជាជីវៈនាយក និងគ្រូបង្រៀន .......... ៥១
សេចក្តីសន្និដ្ឋាន.......... ៥៣
ឧបសម្ព័ន្ធ ១ ៖ គុណសម្បត្តិ គុណវិបត្តិ និងជម្រើសគោលនយោបាយសម្រាប់គំរូសាលារៀននីមួយៗ .......... ៥៤
ឧបសម្ព័ន្ធ ២ ៖ សូចនាករសំខាន់ៗនៅប្រទេសកម្ពុជាក្រោមសេណារីយ៉ូគោល .......... ៥៦
គន្ថនិទ្ទេស .......... ៥៧
ឯកសារយោងផ្សេងទៀត.......... ៥៨

# សេចក្តីថ្លែងអំណរគុណ

របាយការណ៍ស្តីពីបច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា ខែ ឧសភា ឆ្នាំ ២០២០ (CEU) ត្រូវបានរៀបចំឡើងដោយលោក លី សូដេត ដោយមានការរួមចំណែកពីលោកស្រី Claire Honore Hollweg លោក សូ សុខប៊ុនធឿន Donna Andrews លោក ទុ ឃី និង លោក យូ សុគន្ធបញ្ញា។ អ្នកចូលរួមចំណែកផ្សេងទៀត រួមមាន ណូ ហ្វាតា លោកស្រី Ekaterine Vashakmadze លោក បេង ស៊ីម៉េត លោក ផ្លុង ពិសិទ្ធ លោកស្រី គី លីនណា លោក តុង គឹមស៊ុន និងលោក ភឹម រុនស៊ីណារិទ្ធ។ លោក ប៊ូ សារឿន និង លោកស្រី ហ៊ាវ ចាន់កេសី បានជួយលើការងារផ្សព្វផ្សាយតាមសារព័ត៌មាន ភ័ស្តុភារ ការបង្ហាញតាមគេហទំព័រ និងពិធីផ្សព្វផ្សាយរបាយការណ៍នេះ។

ក្រុមការងារនេះបានធ្វើការក្រោមការដឹកនាំរួមរបស់ លោក Deepak Mishra។ ក្រុមការងារសូមថ្លែងអំណរគុណចំពោះដំបូន្មាន និងយោបល់របស់លោកស្រី Inguna Dobraja លោកស្រី Mariam Sherman និង លោក Hassan Zaman។ សហសេវិករបស់ធនាគារពិភពលោកមួយចំនួនដែលរួមមាន លោក Aaditya Mattoo លោក Andrew Mason លោកស្រី Ekaterine Vashakmadze និង លោក Ergys Islamaj និងលោក Vera Kehayova បានផ្តល់យោបល់លើ សេចក្តីព្រាងចុងក្រោយនៃរបាយការណ៍នះ។

ក្រុមការងារសូមអរគុណដល់អាជ្ញាធរកម្ពុជា ជាពិសស ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា សម្រាប់កិច្ចសហការ និងការគាំទ្រកន្លងមក។ របាយការណ៍នេះក៏ទទួលបានផលប្រយោជន៍ពីដំបូន្មាន យោបល់ និងទស្សនៈរបស់អ្នកពាក់ព័ន្ធនានានៅក្នុងប្រទេសកម្ពុជា រួមទាំងអ្នកអាន និងអ្នករិះគន់ផងដែរ។

ក្រុមធនាគារពិភពលោកសូមថ្លែងអំណរគុណចំពោះហិរញ្ញប្បទានពីមូលនិធិម្ចាស់ជំនួយរួម (Multi-Donor Trust Fund) ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ និងការផ្តល់សេវា ដែលប្រទេសអូស្ត្រាលី និងសហភាពអឺរ៉ុបបានរួមចំណែកសម្រាប់ការរៀបចំផ្នែកស្តីពីអត្ថបទផ្តោតពិសេសនៃរបាយការណ៍នេះ។

របាយការណ៍នេះត្រូវបានរៀបចំឡើងចំនួនពីរដងក្នុងមួយឆ្នាំ និងផ្តល់បច្ចុប្បន្នភាពស្តីពីការអភិវឌ្ឍម៉ាក្រូសេដ្ឋកិច្ចនៅកម្ពុជា។ ឯកសារនេះត្រូវបានចែកចាយ និងពិភាក្សាយ៉ាងទូលំទូលាយ រួមទាំងក្នុងចំណោមអាជ្ញាធរកម្ពុជា ដៃគូអភិវឌ្ឍន៍ វិស័យឯកជន ស្ថាប័នស្រាវជ្រាវ និងផ្តល់យោបល់ អង្គការសង្គមស៊ីវិល និងសាកលវិទ្យាល័យនានា។

សម្រាប់ព័ត៌មានអំពីធនាគារពិភពលោក និងសកម្មភាពរបស់ធនាគារពិភពលោកនៅកម្ពុជា សូមមើលគេហទំព័ររបស់យើងតាមរយៈអាស័យដ្ឋាន www.worldbank.org/cambodia។

ដើម្បីស្ថិតនៅក្នុងបញ្ជីស្ថាប័នដែលទទួលបានរបាយការណ៍នេះតាមអ៊ីមែល និងឯកសារបោះពុម្ពផ្សាយពាក់ព័ន្ធផ្សេងទៀត សូមទាក់ទងមកលោកស្រី ហ៊ាវ ចាន់កេសី (cheav @ worldbank .org)។ បើមានសំណួរពីខ្លឹមសារនៃរបាយការណ៍នេះ សូមទាក់ទងមកលោក ប៊ូ សារឿន (sbou@ worldbank.org) ។

របកគំហើញ ការបកស្រាយ និងសេចក្តីសន្និដ្ឋានដែលមានក្នុងរបាយការណ៍នេះ មិនប្រាកដថាឆ្លុះបញ្ចាំងពីទស្សនៈរបស់នាយកប្រតិបត្តិនៃធនាគារពិភពលោក ឬរដ្ឋាភិបាលដែលធនាគារពិភពលោកតំណាងនោះទេ។ ធនាគារពិភពលោកមិនធានាទៅលើភាពត្រឹមត្រូវនៃទិន្នន័យដែលមានក្នុងឯកសារនេះទេ។

# អក្សរកាត់

| | |
|---|---|
| **ASEAN** | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| **Bac** | សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ |
| **Brexit** | ការដកខ្លួនរបស់ចក្រភពអង់គ្លេសចេញពីសហភាពអឺរ៉ុប |
| **CBOE** | អត្រាប្តូរប្រាក់នៅ Chicago |
| **CEU** | បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា |
| **CR** | ប្រាក់រៀល |
| **DOE** | ការិយាល័យអប់រំស្រុក |
| **DSA** | ការវិភាគអំពីនិរន្តរភាពបំណុល |
| **EAP** | អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក |
| **EC** | គណៈកម្មការអឺរ៉ុប |
| **EMDEs** | ទីផ្សារដែលងើបឡើង និងប្រទេសកំពុងអភិវឌ្ឍន៍ |
| **EU** | សហភាពអឺរ៉ុប |
| **FCD** | ប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស |
| **GDP** | ផលិតផលក្នុងស្រុកសរុប |
| **HRMIS** | ប្រព័ន្ធគ្រប់គ្រងព័ត៌មានធនធានមនុស្ស |
| **ILO** | អង្គការអន្តរជាតិខាងការងារ |
| **IMF** | មូលនិធិរូបិយវត្ថុអន្តរជាតិ |
| **KPIs** | សូចនាករស្តីពីការអនុវត្តការងារសំខាន់ៗ |
| **LPCO** | ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា |
| **MoEYS** | ក្រសួងអប់រំ យុវជន និងកីឡា |
| **NBPTS** | គណៈកម្មការជាតិដើម្បីវិជ្ជាជីវៈគ្រូបង្រៀន |
| **NCD** | វិញ្ញាបនប័ត្របញ្ញើដែលអាចជួញដូរបាន |
| **NGS** | សាលារៀនជំនាន់ថ្មី |
| **NPL** | កម្ចីមិនដំណើរការ |
| **OECD** | អង្គការសម្រាប់ការអភិវឌ្ឍ និងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច |
| **PMI** | សន្ទស្សន៍ស្តីពីការទិញរបស់អ្នកគ្រប់គ្រង |
| **PISA** | កម្មវិធីសម្រាប់ការវាយតម្លៃសិស្សអន្តរជាតិ |
| **POE** | មន្ទីរអប់រំ |
| **PTTC** | មជ្ឈមណ្ឌលគរុកោសល្យខេត្ត |
| **q/q** | ធៀបនឹងត្រីមាសមុន |
| **RTTC** | មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ |
| **SAAR** | អត្រាប្រចាំឆ្នាំដែលត្រូវបានកែសម្រួលតាមរដូវកាល |
| **SBM** | ថ្នាក់គ្រប់គ្រងសាលារៀន |
| **SMC** | គណៈកម្មាធិការគ្រប់គ្រងសាលារៀន |
| **SME** | សហគ្រាសធុនតូច និងមធ្យម |
| **SSC** | គណៈកម្មាធិការទ្រទ្រង់សាលារៀន |
| **UK** | ចក្រភពអង់គ្លេស |
| **U.S.** | សហរដ្ឋអាមេរិក |
| **US$** | ដុល្លារអាមេរិក |
| **VAT** | ពន្ធលើតម្លៃបន្ថែម |
| **VIX** | សន្ទស្សន៍ស្តីពីភាពងាយប្រែប្រួល |
| **WBG** | ក្រុមធនាគារពិភពលោក |
| **WDI** | សូចនាករអភិវឌ្ឍន៍ពិភពលោក |
| **WTTC** | ក្រុមប្រឹក្សាវិស័យធ្វើដំណើរ និងទេសចរណ៍ពិភពលោក |
| **y/y or yoy** | ធៀបនឹងឆ្នាំមុន |

# សេចក្តីសង្ខេប

*វិបត្តិជំងឺឆ្លង និងវិបត្តិសេដ្ឋកិច្ចទូទាំងសកលលោកដែលបង្កឡើងដោយជំងឺកូវីដ 19 បានធ្វើឲ្យមានការគំរាមកំហែងយ៉ាងខ្លាំងបំផុតចំពោះការអភិវឌ្ឍរបស់កម្ពុជា ដែលមិនធ្លាប់មានក្នុងប្រវត្តិសាស្ត្រសម័យទំនើបរបស់កម្ពុជាក្នុងរយៈពេល 30 ឆ្នាំកន្លងមក។ វិស័យ 3 ដែលរងផលប៉ះពាល់ធ្ងន់ធ្ងរបំផុត គឺ វិស័យទេសចរណ៍ វិស័យផលិតកម្មសម្រាប់នាំចេញ និងវិស័យសំណង់ ដែលរួមចំណែកជាង 70 ភាគរយដល់កំណើន និង 39.4 ភាគរយដល់ការងារសរុបដែលទទួលបានប្រាក់កម្រៃនៅឆ្នាំ 2019។ ដូច្នេះ នៅអំឡុងឆ្នាំនេះ សេដ្ឋកិច្ចកម្ពុជាអាចនឹងមានកំណើនក្នុងល្បឿនតិចបំផុតដែលមិនធ្លាប់មានចាប់តាំងពីឆ្នាំ 1994 ដោយថយចុះក្នុងចន្លោះពី - 1 ភាគរយ (សេណារីយ៉ូគោល) ទៅ - 2.9 ភាគរយ (សេណារីយ៉ូទាបបំផុត)។ ភាពក្រីក្រអាចកើនឡើងក្នុង ចន្លោះពី 3 ទៅ 11 ភាគរយ ដោយសារតែការបាត់បង់ប្រាក់ចំណូល 50 ភាគរយក្នុងរយៈពេល 6 ខែសម្រាប់គ្រួសារដែលពាក់ព័ន្ធនឹងវិស័យទេសចរណ៍ ពាណិជ្ជកម្មលក់ដុំ និងលក់រាយ កាត់ដេរ សំណង់ ឬកម្មន្តសាល។ ឱនភាពសារពើពន្ធអាចកើនដល់កម្រិតខ្ពស់បំផុតក្នុងរយៈពេល 22 ឆ្នាំកន្លងមក ចំណែកបំណុលសាធារណៈត្រូវបានរំពឹងថានឹងកើនដល់ 35 ភាគរយ នៃ ផសស គិតត្រឹមឆ្នាំ 2022។ អាជ្ញាធរកម្ពុជាបានលើកឡើងពីវិធានការបន្ទាន់ដើម្បីទប់ទល់នឹងការផ្ទុះជំងឺ កូវីដ 19 និងបានផ្តល់ជំនួយសារពើពន្ធដល់គ្រួសារ កម្មករនិយោជិត និងសហគ្រាសដែលរងការប៉ះពាល់។ ដើម្បីសម្រួលឱ្យសេដ្ឋកិច្ចអាចងើបឡើងវិញបាន រដ្ឋាភិបាលកម្ពុជាត្រូវបន្តធានាឲ្យមានស្ថិរភាពវិស័យម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងពន្លឿនកំណែទម្រង់ពាណិជ្ជកម្ម និងការវិនិយោគ ព្រមទាំងជំរុញឱ្យមានការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលឲ្យបានលឿន។*

## ការប៉ះទង្គិចដែលមិនធ្លាប់មានកន្លងមក

**ករណីវីរុសក្សូណាត្រូវបានរកឃើញដំបូងនៅកម្ពុជានៅថ្ងៃទី 27 ខែ មករា ឆ្នាំ 2020 និងបានកើនដល់ 122 ករណី គិតត្រឹមថ្ងៃទី 12 ខែ ឧសភា ឆ្នាំ 2020[1]។** អាជ្ញាធរកម្ពុជាបានចាត់វិធានការជាបន្ទាន់មួយចំនួនក្នុងការកំណត់អត្តសញ្ញាណ និងទប់ស្កាត់ការផ្ទុះការឆ្លងក្នុងសហគមន៍ ដោយធ្វើការហាមឃាត់ការធ្វើដំណើររបស់ភ្ញៀវទេសចរមកពីប្រទេសដែលមានការឆ្លងជំងឺនេះច្រើន ការបិទសាលារៀន ការជំរុញឱ្យប្រជាពលរដ្ឋចៀសពីការជួបជុំគ្នាច្រើន និងការផ្អាកការប្រារព្ធពិធីបុណ្យចូលឆ្នាំខ្មែរកាលពីពាក់កណ្តាលខែ មេសា រួមទាំងការប្រកាសហាមមិនឲ្យធ្វើដំណើរឆ្លងកាត់តំបន់រយៈពេល 3 ថ្ងៃនៃពិធីបុណ្យចូលឆ្នាំខ្មែរ (សម្រាប់ព័ត៌មានបន្ថែម សូមមើលប្រអប់ 1)។ នៅខែមេសា ឆ្នាំ 2020 ច្បាប់ស្តីពី “ការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន” ត្រូវបានអនុម័តជាបន្ទាន់ (និងត្រៀមរួចរាល់សម្រាប់ការប្រកាសឱ្យប្រើប្រាស់ ប្រសិនបើមានស្ថានភាពអាសន្នផ្នែកសុខភាពសាធារណៈ)។

**បើទោះជាកន្លងមកកម្ពុជាបានរួចផុតពីវិបត្តិសុខភាពក្តី ប៉ុន្តែកម្ពុជាមិនបានរួចផុតពីការរងការប៉ះពាល់ពីវិបត្តិសេដ្ឋកិច្ចដែលរាលដាលពាសពេញពិភពលោកឡើយ។** ផលប៉ះពាល់នៃជំងឺកូវីដ 19 លើកំណើន អាស្រ័យលើ ការឆ្លងរាលដាល ភាពធ្ងន់ធ្ងរ និងរយៈវេលានៃការផ្ទុះឡើង ការឆ្លើយតបរបស់សង្គម និងវិសាលភាព និងប្រសិទ្ធភាពនៃវិធានការគោលនយោបាយ។ ការចំណាយផ្ទាល់លើវិធានការដើម្បីទប់ស្កាត់ការផ្ទុះឡើងក្នុងសហគមន៍បច្ចុប្បន្ន ហាក់ដូចជាអាចរ៉ាប់រងបាន។ យ៉ាងណាក៏ដោយ ការផ្ទុះឡើងនៃជំងឺកូវីដ 19 បានធ្វើឱ្យវិស័យសំខាន់ៗដែលជាក្បាលម៉ាស៊ីនសេដ្ឋកិច្ចរបស់កម្ពុជា ធ្លាក់ចុះយ៉ាងខ្លាំងនៅត្រីមាសទីមួយក្នុងឆ្នាំ 2020 រួមទាំង ការថយចុះនៃវិស័យទេសចរណ៍ (និងបដិសណ្ឋារកិច្ច) និងសកម្មភាពសាងសង់ ហើយថ្មីៗនេះ វិស័យនាំចេញផងដែរ។

## ប្រភពនៃការប៉ះពាល់

**ឥទ្ធិពលនៃជំងឺកូវីដ 19 ត្រូវបានបង្ហាញតាមរយៈការប៉ះពាល់នៅក្នុងវិស័យសំខាន់ៗចំនួន 3 គឺ ទេសចរណ៍ ការនាំចេញ និងការវិនិយោគផ្ទាល់ពីបរទេស** (តារាង ES.1)។ កម្ពុជាពឹងផ្អែកខ្លាំងលើភ្ញៀវទេសចរមកពីតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ជាពិសេសភ្ញៀវទេសចរជនជាតិចិន ដែលមានចំនួន 35 ភាគរយនៃចំនួនភ្ញៀវទេសចរអន្តរជាតិសរុបនៅកម្ពុជា។ ចំនួនភ្ញៀវទេសចរអន្តរជាតិបានថយចុះយ៉ាងឆាប់រហ័សក្រោយមានការផ្ទុះជំងឺកូវីដ 19 នៅប្រទេសចិន។ សកម្មភាពទេសចរបានជាប់គាំង នៅពេលដែលវីរុសនេះ បានឆ្លងរាលដាលពីប្រទេសចិនទៅបណ្តាប្រទេសផ្សេងៗទៀតនៅជុំវិញពិភពលោក។

**តារាង ES.1 ៖ កម្ពុជាមានទំនាក់ទំនងផ្នែកសេដ្ឋកិច្ចរឹងមាំជាមួយបណ្តាប្រទេសដែលរងការប៉ះពាល់ដោយសារជំងឺកូវីដ 19**

ទីផ្សារធំៗ 5 សម្រាប់ទំនិញនាំចេញរបស់កម្ពុជា, ចំនួនភ្ញៀវទេសចរ និងប្រភពនៃការវិនិយោគផ្ទាល់ពីបរទេស (2019, ភាគរយ)

1 អង្គការសុខភាពពិភពលោក https://www.who.int/cambodia/news/detail/12-05-2020-who-works-closely-with-the-royal-government-of-cambodia-in-the-fight-against-covid-19.

| ទំនិញនាំចេញ | | វិស័យទេសចរណ៍ | | លំហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេស | |
|---|---|---|---|---|---|
| សហរដ្ឋអាមេរិក | 26.8 | ចិន | 32.6 | ចិន | 40.0 |
| សហភាពអឺរ៉ុប | 25.0 | វៀតណាម | 12.9 | ហុងកុង | 10.9 |
| ជប៉ុន | 7.7 | ឡាវ | 6.9 | សាធារណរដ្ឋកូរ៉េ | 7.8 |
| កាណាដា | 6.2 | ថៃ | 6.2 | សិង្ហបុរី | 7.1 |
| ចក្រភពអង់គ្លេស | 6.1 | សាធារណរដ្ឋកូរ៉េ | 4.9 | ជប៉ុន | 6.2 |
| ប្រទេសផ្សេងៗទៀត | 38.2 | ប្រទេសផ្សេងៗទៀត | 36.5 | ប្រទេសផ្សេងៗទៀត | 28.0 |

*ប្រភព* ៖ U.S. Comtrade; អាជ្ញាធរកម្ពុជា; និងការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក

*កំណត់សម្គាល់* ៖ ទំនិញនាំចេញសរុប = 25,199.39 លានដុល្លារអាមេរិក (2019); ចំនួនភ្ញៀវទេសចរបរទេស = 6.61 លាននាក់ (2019); លំហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេស = 2,845 លានដុល្លារសហរដ្ឋអាមេរិក (2019e)

**ការថយចុះនៃតម្រូវការខាងក្រៅកាន់តែជាបញ្ហាដោយសារតែការនាំចេញរបស់កម្ពុជា ជាផលិតផល និងប្រទេសជាគោលដៅនៃការនាំចេញ មានចំនួនតិចតួច។** ផលិតផលនាំចេញសំខាន់ៗ រួមមាន សម្លៀកបំពាក់ ស្បែកជើង ទំនិញធ្វើដំណើរ និងអង្ករ។ ទីផ្សារសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប រួមគ្នា មានចំនួន 52 ភាគរយនៃទំនិញនាំចេញសរុបរបស់កម្ពុជា។ លើសពីនេះទៀត ការនាំចេញរបស់កម្ពុជាពឹងផ្អែកលើការនាំចូលទំនិញពាក់កណ្តាលសម្រេច (វត្ថុធាតុដើមសម្រាប់វិស័យកាត់ដេរ និងស្បែកជើង និងឧស្សាហកម្មទំនិញធ្វើដំណើរ) ដែលពីមុនជួបប្រទះការរាំងស្ទះសង្វាក់ផ្គត់ផ្គង់។ ការដួលរលំពាណិជ្ជកម្មសកលបានធ្វើឲ្យមានការប៉ះពាល់អវិជ្ជមានផ្ទាល់ និងប្រយោលយ៉ាងខ្លាំងមកលើកម្ពុជា។

**ជាចុងក្រោយ លំហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេស ដែលថ្មីៗនេះភាគច្រើនបានសម្រុកទៅវិស័យសំណង់ មានប្រភពពីបណ្តាប្រទេសមួយចំនួនតូចក្នុងតំបន់ ជាពិសេសប្រទេសចិន។** មហាតំបន់ចិនដែលរួមទាំងតំបន់រដ្ឋបាលពិសេសហុងកុង ចិន និងតៃវ៉ាន់ មានចំនួនជាង 50 ភាគរយនៃលំហូរសរុបនៃការវិនិយោគផ្ទាល់ពីបរទេសក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ។ ប៉ុន្មានឆ្នាំកន្លងមកនេះ តាមការប៉ាន់ស្មាន លំហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេសប្រមាណ 50 ភាគរយ គឺជាការវិនិយោគក្នុងវិស័យសំណង់ និងអចលនទ្រព្យ។ ក្រោយពីមានការផ្ទុះជំងឺកូវីដ 19 នៅប្រទេសចិន តម្លៃនៃគម្រោងវិនិយោគផ្ទាល់ពីបរទេសដែលត្រូវបានអនុម័ត បានថយចុះយ៉ាងខ្លាំង។

### ១. វិស័យទេសចរណ៍ ៖ វិស័យដែលរងផលប៉ះពាល់ខ្លាំងជាងគេ

**តម្រូវការសេវាទេសចរណ៍ និងបដិសណ្ឋារកិច្ច បានធ្លាក់ចុះយ៉ាងខ្លាំងក្នុងរយៈពេលប៉ុន្មានខែកន្លងមកនេះ។** ការឆ្លើយតបជាសកលដើម្បីទប់ស្កាត់ការផ្ទុះជំងឺកូវីដ 19 បានបណ្តាលឱ្យមានការអូសបន្លាយការរឹតត្បិតលើការធ្វើដំណើរអន្តរជាតិ និងការហាមឃាត់ការធ្វើដំណើរក្នុងប្រទេស។ នៅរយៈពេលពីរខែដំបូងក្នុងឆ្នាំ 2020 ចំនួនភ្ញៀវទេសចរមកកម្ពុជាបានថយចុះចំនួន 25.1 ភាគរយ (ធៀបនឹងឆ្នាំមុន)។ នេះជាការថយចុះលើកដំបូងចាប់តាំងពីពេលមានវិបត្តិហិរញ្ញវត្ថុសកលនៅអំឡុងឆ្នាំ 2008-2009។ ចំនួនភ្ញៀវទេសចរមកកាន់ខេត្តសៀមរាបដែលជាគោលដៅទេសចរណ៍ដ៏មានប្រជាប្រិយភាពបំផុតនៅកម្ពុជា បានថយចុះចំនួន 45.6 ភាគរយ នៅត្រីមាសទីមួយ និងថយចុះចំនួន 99.6 ភាគរយ (ធៀបនឹងឆ្នាំមុន) នៅអំឡុងខែ មេសា ឆ្នាំ 2020[2]។

**វិស័យទេសចរណ៍ (រួមទាំងបដិសណ្ឋារកិច្ច) គឺជាក្បាលម៉ាស៊ីនជំរុញកំណើនសំខាន់បំផុតទីពីរ ហើយត្រូវបានប៉ាន់ស្មានថា រួមចំណែកចំនួន 18.7 ភាគរយ ដល់កំណើន ផសស ពិតនៅឆ្នាំ 2019** (តារាង ES.2)[3]។ វិស័យទេសចរណ៍ជាវិស័យដែលទទួលប្រាក់ពីបរទេសដ៏សំខាន់មួយ ដែលមានចំនួនជាង 3/4 នៃការនាំចេញផ្នែកសេវាកម្មរបស់កម្ពុជា និងប្រមាណ 1/5 នៃការនាំចេញទំនិញ និងសេវាសរុប។

**តារាង ES.2 ៖ ផលប៉ះពាល់នៃការផ្ទុះជំងឺកូវីដ 19 លើវិស័យដែលជំរុញកំណើនសំខាន់ៗ និងការងារនៅកម្ពុជា**

| វិស័យដែលជំរុញកំណើន | ទេសចរណ៍ | កាត់ដេរ និង ស្បែកជើង | សំណង់ | សរុប |
|---|---|---|---|---|
| **ការរួមចំណែកដល់កំណើន ផសស** (2019, ភាគរយ) | 18.7 | 17.0 | 35.7 | 71.4 |
| **ការងារផ្ទាល់** ('000) | 620 | 941 | 200 | 1,761 |
| **ភាគរយនៃការងារទទួលបានប្រាក់កម្រៃ**[1] | 13.9 | 21.0 | 4.5 | 39.4 |
| **ភាគរយនៃការងារក្រៅពីកសិកម្ម** | 11.2 | 17.0 | 3.6 | 31.9 |
| **ភាគរយនៃការងារសរុប** | 7.1 | 10.7 | 2.3 | 20.1 |

*ប្រភព* ៖ អាជ្ញាធរកម្ពុជា និងការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក

*សម្គាល់* ៖ [1]. ការងារទទួលបានប្រាក់កម្រៃ

### ២. វិស័យពាណិជ្ជកម្ម

**ជំងឺកូវីដ 19 ក៏បានធ្វើឲ្យមានការប៉ះទង្គិចលើតម្រូវការនាំចេញដែលមិនធ្លាប់មានកន្លងមក បន្ទាប់ពីបានធ្វើឱ្យមានការអាក់ខានដល់សង្វាក់ផ្គត់ផ្គង់។** ជាលទ្ធផល ការបញ្ជាទិញសម្លៀកបំពាក់ ស្បែកជើង និងទំនិញធ្វើដំណើរ ភាគច្រើនពីទីផ្សារសំខាន់ៗទាំងពីរ គឺ សហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប ត្រូវបានផ្អាក ឬលុបចោល។ បញ្ហានេះបានកើតឡើងបន្ទាប់ពីឧស្សាហកម្មផលិតទំនិញនាំចេញរបស់កម្ពុជា ជួបប្រទះការរាំងស្ទះសង្វាក់ផ្គត់ផ្គង់ ដែលបានបង្ខំឱ្យរោងចក្រកាត់ដេរមួយចំនួនបិទទ្វារនៅដើមខែ មីនា ឆ្នាំ 2020។ ដូចបានបង្ហាញនៅក្នុងតារាង ES.2 ឧស្សាហកម្មកាត់ដេរ និងស្បែកជើង បានរួមចំណែកជិត 1/5 នៃកំណើន ផសស នៅឆ្នាំ 2019។ លើសពី

2 សេចក្តីប្រកាសព័ត៌មានស្តីពីចំនួនភ្ញៀវទេសចរអន្តរជាតិ និងស្ថិតិប្រាក់ចំណូលពីតំបន់អង្គរ ថ្ងៃទី1 ខែ មេសា ឆ្នាំ 2020 សហគ្រាសអង្គរ

3 យោងតាមក្រុមប្រឹក្សាវិស័យធ្វើដំណើរ និងទេសចរណ៍ពិភពលោក (WTTC) វិស័យធ្វើដំណើរ និងទេសចរណ៍បានរួមចំណែកប្រមាណ 33 ភាគរយ ដល់ ផសស របស់កម្ពុជានៅឆ្នាំ 2019 ចំណែកទិន្នន័យគណនីជាតិផ្លូវការបង្ហាញថា វិស័យសេវាទាំងមូលបានរួមចំណែក 38.8 ភាគរយ ដល់ ផសស របស់កម្ពុជា។ យោងតាម WTTC វិស័យធ្វើដំណើរ និងទេសចរណ៍ផ្តល់ការងារចំនួន 2.9 លាន។

នេះទៀត សហភាពអឺរ៉ុបបានប្រកាសពីការដកការអនុគ្រោះពន្ធ និងជំនួសដោយស្តង់ដារពន្ធរបស់សហភាពអឺរ៉ុប (ប្រទេសដែលទទួលបានការអនុគ្រោះច្រើនបំផុត-MFN) ដែលនឹងប៉ះពាល់ដល់ផលិតផលសម្លៀកបំពាក់ និងស្បែកជើងមួយចំនួន និងទំនិញធ្វើដំណើរ និងផលិតផលស្ករទាំងអស់ ដែលមានទំហំទឹកប្រាក់ប្រមាណ 1 ពាន់លានដុល្លារ ឬស្មើនឹង 1/5 នៃការនាំចេញប្រចាំឆ្នាំរបស់កម្ពុជាទៅកាន់សហភាពអឺរ៉ុប[4]។

**ព័ត៌មានថ្មីៗពីឧស្សាហកម្មបង្ហាញថា រោងចក្រភាគច្រើននឹងទទួលបានការបញ្ជាទិញតិចតួចប៉ុណ្ណោះបន្ទាប់ពីឆមាសទីមួយក្នុងឆ្នាំ 2020។** នេះក៏ដោយសារតែការបញ្ជាទិញមួយចំនួនត្រូវបានផ្អាក ឬលុបចោល ដែលធ្វើឲ្យរោងចក្រសម្លៀកបំពាក់ និងស្បែកជើងចំនួន 130 រោងចក្រ (12 ភាគរយនៃចំនួនរោងចក្រសរុប) បានផ្អាកប្រតិបត្តិការ ដោយផ្នែក ឬទាំងស្រុង ចាប់តាំងពីពាក់កណ្ដាលខែ មេសា ឆ្នាំ 2020 និងធ្វើឱ្យកម្មករជិត 100,000 នាក់បាត់បង់ការងារ[5]។ ទិន្នន័យផ្លូវការបង្ហាញថា នៅខែ កុម្ភៈ ឆ្នាំ 2020 រោងចក្រដែលផលិតសម្លៀកបំពាក់ ស្បែកជើង និងទំនិញធ្វើដំណើរសម្រាប់ការនាំចេញ មានចំនួន 1,087 រោងចក្រ និងផ្ដល់ការងារដល់កម្មករនិយោជិតចំនួន 941,000 នាក់ ដែលមានមានចំនួន 21 ភាគរយនៃការងារទទួលបានប្រាក់កម្រៃ 17 ភាគរយនៃការងារក្រៅពីកសិកម្ម និង 10.7 ភាគរយនៃការងារសរុប[6]។

**វិស័យកាត់ដេរជាផ្លូវការគឺជាប្រភពចំណូលដ៏សំខាន់របស់រដ្ឋាភិបាល ជាពិសេសចំណូលផ្ទាល់។** វិស័យនេះគឺជាឧស្សាហកម្មដែលផ្ដល់ការងារផ្លូវការ និងការងារទទួលបានប្រាក់កម្រៃច្រើនជាងគេក្នុងសេដ្ឋកិច្ចកម្ពុជា ទោះបីជាវិស័យនេះស្ថិតក្នុងលំដាប់ទី 3 ក្នុងការរួមចំណែកដល់កំណើនសេដ្ឋកិច្ច ដោយរួមចំណែកប្រមាណ 17 ភាគរយនៃកំណើន ផសស ពិត នៅឆ្នាំ 2019។

## ៣.វិស័យសំណង់ និងលំហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេស

**វិស័យសំណង់ (និងអចលនទ្រព្យ) បានក្លាយជាក្បាលម៉ាស៊ីនជំរុញកំណើននៅកម្ពុជាក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ។** នៅឆ្នាំ 2019 វិស័យសំណង់ និងអចលនទ្រព្យ បានរួមចំណែកជាង 1/3 នៃកំណើន ផសស (តារាង ES.2)។ វិស័យនេះ រួមនឹងវិស័យនាំចេញ បានក្លាយជាប្រភពចំណូលដ៏សំខាន់មួយរបស់រដ្ឋាភិបាលតាមរយៈពន្ធប្រយោល និងពន្ធលើពាណិជ្ជកម្មអន្តរជាតិ។ ថ្មីៗនេះ ឧស្សាហកម្មសំណង់ទទួលបានហិរញ្ញប្បទានកាន់តែច្រើនពីលំហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេស។ តាមការប៉ាន់ស្មានថា កម្ពុជាទទួលបានលំហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេសចំនួន 40 ភាគរយ ពីប្រទេសចិន ដែលភាគច្រើន ផ្ដោតលើវិស័យសំណង់។

**ក្នុងរយៈពេលពីរខែដំបូងក្នុងឆ្នាំ 2020 ទាំងសកម្មភាពសំណង់ និងលំហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេស (ដែលត្រូវបានអនុម័ត) បានថយចុះយ៉ាងខ្លាំង។** ការនាំចូលដែកថែប ដែលប្រើប្រាស់ភាគច្រើនសម្រាប់ការសាងសង់ បានថយចុះចំនួន 47.4 ភាគរយ (ធៀបនឹងឆ្នាំមុន) ក្នុងរយៈពេលពីរខែដំបូងក្នុងឆ្នាំ 2020។ ក្នុងអំឡុងពេលជាមួយគ្នានេះ គម្រោងវិនិយោគផ្ទាល់ពីបរទេសដែលត្រូវបានអនុម័តសម្រាប់ វិស័យសំណង់ បានថយចុះចំនួន 40.2 ភាគរយ (ធៀបនឹងឆ្នាំមុន)។ ការថយចុះនេះនឹងធ្វើឱ្យកំណើនសេដ្ឋកិច្ចរួមថយចុះយ៉ាងខ្លាំង បើទោះជាមានផលប៉ះពាល់តិចតួចលើការងារ ដោយសារតែកំណើនវិស័យសំណង់សំខាន់បំផុតភាគច្រើនជាអគារប្រណិតខ្ពស់ៗ និងប្រើប្រាស់មូលធនច្រើន។

## ផលប៉ះពាល់លើសេដ្ឋកិច្ច និងសង្គម

**កម្ពុជាត្រូវបានរំពឹងថាមានអត្រាកំណើនទាបបំផុតដែលមិនធ្លាប់មាន ចាប់តាំងពីឆ្នាំ 1994។** ការប៉ះទង្គិចនៃជំងឺកូវីដ 19 ដែលធ្វើឱ្យមានតម្រូវការសកលថយចុះ ការរាំងស្ទះសង្វាក់ផ្គត់ផ្គង់ និងការហាមឃាត់ការធ្វើដំណើរក្នុងប្រទេស កំពុងវាយប្រហាយ៉ាងខ្លាំងទៅលើវិស័យដែលជាក្បាលម៉ាស៊ីនជំរុញកំណើនរបស់កម្ពុជា។ ទោះជាកំណើន ផសស ពិត មានចំនួន 7.1 ភាគរយ នៅឆ្នាំ 2019 កម្ពុជាត្រូវបានព្យាករថានឹងមានអត្រាកំណើនអវិជ្ជមាន នៅចន្លោះពី -1 ភាគរយ ទៅ -2.9 ភាគរយ នៅឆ្នាំ 2020 (រូប ES.1)។

**បច្ចុប្បន្ន ការងារយ៉ាងតិច 1.76 លាន កំពុងប្រឈមនឹងហានិភ័យដោយសារតែការផ្ទុះជំងឺកូវីដ 19។** ការដួលរលំនៃវិស័យដែលជាក្បាលម៉ាស៊ីនជំរុញកំណើនមិនត្រឹមតែប៉ះពាល់ធ្ងន់ធ្ងរដល់កំណើនសេដ្ឋកិច្ចប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធ្វើឱ្យមានភាពគ្មានការងារធ្វើកើនឡើងរហូតដល់ជិត 20 ភាគរយ ផងដែរ។ តាមការប៉ាន់ស្មាន វិស័យដែលជាក្បាលម៉ាស៊ីនជំរុញកំណើន (ទេសចរណ៍ ឧស្សាហកម្មផលិតនាំចេញ និងសំណង់) ដែលរួមចំណែក 71 ភាគរយនៃកំណើន និងផ្ដល់ការងារ 20 ភាគរយនៃចំនួនការងារសរុប បាន និងកំពុងរងការប៉ះពាល់ដោយផ្ទាល់ខ្លាំងដោយសារតែជំងឺកូវីដ 19។

**បើគ្មានវិធានការសំខាន់ក្នុងការកាត់បន្ថយផលប៉ះពាល់ ជំងឺកូវីដ 19 អាចធ្វើឱ្យភាពក្រីក្រកើនឡើងយ៉ាងខ្លាំង។** វិធានប្រដូចនៃភាពក្រីក្របង្ហាញថា ភាពក្រីក្រនឹងកើនឡើងក្នុងចន្លោះពី 1 ភាគរយ ទៅ 5 ភាគរយ ដោយសារការបាត់បង់ប្រាក់ចំណូលចំនួន 50 ភាគរយ ក្នុងរយៈពេលបីខែកន្លងមកនៅក្នុងចំណោមគ្រួសារដែលពាក់ព័ន្ធនឹងវិស័យទេសចរណ៍ ពាណិជ្ជកម្មលក់ដុំ និងលក់រាយ កាត់ដេរ សំណង់ ឬកម្មន្តសាល ឬចន្លោះពី 3 ភាគរយ ទៅ 11 ភាគរយដោយសារតែការបាត់បង់ប្រាក់ចំណូលរយៈពេល 6 ខែ[7]កន្លងមក។ ពលករដែលវិលត្រឡប់ពីប្រទេសថៃ[8] និងក្រុមគ្រួសាររបស់ពួកគេដែលពឹងផ្អែកលើប្រាក់បញ្ញើរបស់ពលករទាំងនេះ ក៏ប្រឈមនឹងការបាត់បង់ប្រាក់ចំណូល និងហានិភ័យកាន់តែខ្លាំងក្នុងការធ្លាក់ចូលទៅក្នុងភាពក្រីក្រ។

## ផលប៉ះពាល់ដែលអាចកើតមានឡើងចំពោះទីផ្សារហិរញ្ញវត្ថុ

**ផលប៉ះពាល់ដោយសារការថយចុះនៃវិស័យផលិតកម្មលើវិស័យធនាគារ និងហិរញ្ញវត្ថុ អាចមានទំហំធំ។** ការថយចុះនៃលំហូរចូលមូលធនកំពុងធ្វើឱ្យតម្លៃទីផ្សារអចលនទ្រព្យថយចុះ ដែលអាចនឹងធ្វើឱ្យ វិស័យសំណង់លែងមានកំណើនខ្ពស់តទៅទៀត។ ដោយសារមានបំណុលឥណទានយ៉ាងច្រើនក្នុងវិស័យសំណង់ អចលនទ្រព្យ និងការបញ្ចាំ (សម្រាប់ខ្លឹមសារលម្អិត

4 សម្រាប់ព័ត៌មានលម្អិត សូមចូលទៅកាន់ ៖ https://trade.ec.europa.eu/doclib/press/index.cfm?id=2113។

5 សន្និសីទប្រកាសព័ត៌មានផ្លូវការ ថ្ងៃទី 27 ខែ មេសា ឆ្នាំ 2020 ស្ដីពីការធ្វើចត្តាឡីស័កកម្មកររោងចក្រកាត់ដេរដែលវិលត្រឡប់មកវិញ ដោយក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ។

6 របាយការណ៍ខែ កុម្ភៈ ឆ្នាំ 2020 ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

7 បច្ចុប្បន្នភាពសេដ្ឋកិច្ចអាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ខែ មេសា ឆ្នាំ 2020 ធនាគារពិភពលោក។

8 មានការប៉ាន់ស្មានថា គិតត្រឹមខែ មេសា ឆ្នាំ 2020 ពលករចំណាកស្រុកចំនួន 80,000 នាក់បានវិលត្រឡប់មកកម្ពុជា ចាប់តាំងពីការផ្ទុះជំងឺកូវីដ ១៩។

សូមមើលការពិភាក្សាពីវិស័យរូបិយវត្ថុខាងក្រោម) កម្ចីមិនដំណើរការត្រូវបានរំពឹងថានឹងកើនឡើង។ ចំណែកនៃឥណទានជំពាក់ធនាគារ (មិនគិតឥណទានមីក្រូហិរញ្ញវត្ថុ និងឥណទានធនាគារស្រមោល) ដែលផ្តល់ហិរញ្ញប្បទានដល់វិស័យសំណង់ អចលនទ្រព្យ និងការរកស៊ីបញ្ចាំ បានកើនឡើងដល់ 31.1 ភាគរយ ឬស្មើនឹង 7.7 ពាន់លានដុល្លារអាមេរិក (28.6 ភាគរយ នៃ ផសស) គិតត្រឹមបំណាច់ឆ្នាំ 2019។ ផលប៉ះពាល់ដែលអាចកើតមានលើវិស័យមីក្រូហិរញ្ញវត្ថុ បណ្តាលមកពីការបាត់បង់ប្រាក់ចំណូលគ្រួសារ ដោយសារតែការរំសាយកម្មករនិយោជិតកាន់តែច្រើនក្នុងវិស័យទេសចរណ៍ កាត់ដេរ និងសំណង់។ ចំណុចសំខាន់គឺថា ការកែតម្រូវទីផ្សារអចលនទ្រព្យបានចាប់ផ្តើមឡើងបន្ទាប់ពីមានកំណើនដ៏យូរនៃវិស័យសំណង់ កំណើនការផ្តល់ឥណទានដល់វិស័យសំណង់/អចលនទ្រព្យ/ការបញ្ចាំ និងកំណើនឥណទានដែលមិនទាន់សង។

**នៅក្នុងការអនុវត្តគោលនយោបាយរូបិយវត្ថុដែលមានលក្ខណៈបន្ធូរបន្ថយ ធនាគារជាតិបានបញ្ចុះអត្រាកំណត់ប្រាក់បម្រុងកាតព្វកិច្ចមកត្រឹម 7 ភាគរយ** សម្រាប់ទាំង រូបិយវត្ថុក្នុងស្រុក និងរូបិយវត្ថុបរទេស ក្នុងរយៈពេល 6 ខែ ចាប់ពីខែ មេសា ឆ្នាំ 2020 (បញ្ចុះពីអត្រា 8 ភាគរយ សម្រាប់ប្រាក់រៀល និង 12.5 ភាគរយ សម្រាប់រូបិយប័ណ្ណបរទេស)។ ធនាគារជាតិកំពុងណែនាំឱ្យធនាគារពាណិជ្ជ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ធ្វើការពិនិត្យមើលការសងប្រាក់កម្ចីរបស់គ្រួសារដែលរងផលប៉ះពាល់ដោយសារការផ្ទុះជំងឺកូវីដ 19។ ការពន្យារពេលសងប្រាក់ និងការកែសម្រួលការផ្តល់កម្ចីឡើងវិញ អាចនឹងត្រូវពិចារណា។ ការផ្ទុះជំងឺកូវីដ 19 នៅទូទៅពិភពលោក បានធ្វើឱ្យទីផ្សារហិរញ្ញវត្ថុកាន់តែងាយប្រែប្រួល រួមទាំងក្នុងទីផ្សារហ៊ុននៅទូទាំងតំបន់អាស៊ី។ ទីផ្សាររូបិយវត្ថុ និងតម្លៃទំនិញ ក៏កំពុងទទួលរងផលប៉ះពាល់ផងដែរ ដោយថ្មីៗនេះ តម្លៃប្រេងបានថយចុះយ៉ាងខ្លាំង។ នៅឆ្នាំ 2019 កម្ពុជាមានលំហូរមូលធនថយចុះបន្តិចទៅហើយ ដែលធ្វើឱ្យកំណើនរូបិយវត្ថុទូលាយថយចុះផងដែរ។

## ផលប៉ះពាល់ចំពោះចំណូលក្នុងស្រុក និងទុនបម្រុងផ្លាស់ប្តូរអន្តរជាតិ

**ការផ្ទុះជំងឺកូវីដ 19 កំពុងធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់មូលដ្ឋានចំណូលរបស់កម្ពុជា។** ដូចបានលើកឡើងនៅខាងលើ វិស័យនាំចេញ និងវិស័យសំណង់ គឺជាប្រភពដ៏សំខាន់ដែលផ្តល់ចំណូលផ្ទាល់ និងប្រយោល (ពាណិជ្ជកម្មអន្តរជាតិ)។ វិស័យកសិកម្ម ដែលរងផលប៉ះពាល់តិចតួចបំផុត មិនជាប់ពន្ធទេ។ ការប្រមូលចំណូលនៅឆ្នាំ 2020 អាចនឹងមានកម្រិតទាបជាងគោលដៅថវិកាខ្លាំងណាស់។ ឱនភាពសារពើពន្ធជារួម (រួមទាំងជំនួយឥតសំណង) ត្រូវបានព្យាករណ៍ថានឹងកើនដល់ 9 ភាគរយ នៃផសស នៅឆ្នាំ 2020 ថយពីអតិរេកចំនួន 0.5 ភាគរយ នៅឆ្នាំ 2019 (មើលឧបសម្ព័ន្ធ 2 ស្តីពីសូចនាករម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗរបស់កម្ពុជា)។ ការថយចុះនៃការប្រមូលចំណូលក្នុងស្រុកនឹងធ្វើឲ្យអាជ្ញាធរកម្ពុជាប្រើប្រាស់ប្រាក់សន្សំរបស់រដ្ឋាភិបាល ហើយតម្រូវការហិរញ្ញប្បទានក្នុងស្រុកត្រូវបានព្យាករណ៍ថានឹងមានចំនួន 5.3 ភាគរយនៃ ផសស។ នៅឆ្នាំ 2019 ប្រាក់សន្សំរបស់រដ្ឋាភិបាលមានចំនួន 20.2 ភាគរយ នៃ ផសស (ឬស្មើនឹង 22.2 ទ្រីលលានរៀល) បន្ទាប់ពីធ្វើការសន្សំទុកជាច្រើនឆ្នាំកន្លងមក។ ដោយសារតែសន្ទនីយភាពយ៉ាងច្រើនរបស់អាជ្ញាធរកម្ពុជា មិនមានការរំពឹងថា មានដំណោះស្រាយដោយប្រើប្រាស់ហិរញ្ញប្បទានក្នុងស្រុក (ធនាគារជាតិ) ដើម្បីបំពេញឱនភាពសារពើពន្ធជារួមដែលកើនឡើងនោះទេ។

**ស្ថានភាពទុនបម្រុងអន្តរជាតិរបស់កម្ពុជាក៏ត្រូវបានព្យាករណ៍ថាថយចុះផងដែរ** ដោយសារតែវិស័យរកប្រាក់ចំណូលពីបរទេសសំខាន់ៗរបស់កម្ពុជា (វិស័យទេសចរណ៍ និងវិស័យនាំចេញ) កំពុងរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយសារតែការផ្ទុះជំងឺកូវីដ 19 នៅខណៈដែលលំហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេសក៏មានល្បឿនយឺតដែរនោះ។ ក្នុងឆ្នាំ 2020 ទុនបម្រុងសម្រាប់ការដោះដូរអន្តរជាតិរបស់កម្ពុជា ត្រូវបានរំពឹងថានឹងថយចុះមកត្រឹម 16.9 ពាន់លានដុល្លារអាមេរិក (រយៈពេល 6.8 ខែ នៃការនាំចូលរំពឹងទុក) ចុះពីទំហំទឹកប្រាក់ 18.7 ពាន់លានដុល្លារអាមេរិក (រយៈពេល 7.6 ខែនៃការនាំចូលរំពឹងទុក)។

## ទស្សនវិស័យ និងហានិភ័យ

**ការផ្ទុះជំងឺកូវីដ 19 នឹងប៉ះពាល់សេដ្ឋកិច្ចកម្ពុជាយ៉ាងធ្ងន់ធ្ងរ។** ការផ្ទុះជំងឺកូវីដ 19 នេះបានធ្វើឱ្យអាក់ខានយ៉ាងខ្លាំងដល់សកម្មភាពសេដ្ឋកិច្ចភាគច្រើន និងបានផ្តល់វិស័យមួយចំនួនដែលជាក្បាលម៉ាស៊ីនជំរុញកំណើនសេដ្ឋកិច្ចរបស់កម្ពុជា។ ទន្ទឹមនឹងនេះ ទំហំ និងល្បឿននៃការងើបឡើងវិញ នៅតែមានភាពមិនប្រាកដប្រជា និងពឹងផ្អែកយ៉ាងខ្លាំងលើការវិវឌ្ឍនៃវីរុសនេះ។ ក្នុងសេណារីយ៉ូគោល ដែលកំណត់ថា ការងើបឡើងនៃកំណើនសកលនឹងកើតមានតាមរយៈកំណើនតម្រូវការសកលបន្តិចម្តងៗ នៅពេលដែលមានការដកបម្រាមលើការធ្វើដំណើរចេញចូលជាបណ្តើរៗនៅឆមាសទីពីរក្នុងឆ្នាំ 2020 ខណៈដែលស្ថានភាពសេដ្ឋកិច្ចក្នុងប្រទេសនឹងមានភាពប្រសើរឡើងដោយគ្មានផលប៉ះពាល់អវិជ្ជមានយូរអង្វែង ដោយសារតែការដាក់បម្រាមលើការធ្វើដំណើរចេញចូល លើវិស័យសាជីវកម្ម វិស័យធនាគារ ឬតុល្យភាពនៃការទូទាត់ ដោយកំណើនពិតត្រូវបានព្យាករណ៍ថានឹងថយចុះអវិជ្ជមាន 1 ភាគរយ នៅឆ្នាំ 2020។ សេដ្ឋកិច្ចកម្ពុជាត្រូវបានរំពឹងថានឹងងើបឡើងវិញយ៉ាងលឿន ដោយមានកំណើនចំនួន 6 ភាគរយ នៅឆ្នាំ 2021 ដោយសារតែមានកំណើនលឿននៃតម្រូវការសកល។ សេណារីយ៉ូដែលទាបបំផុត កំណត់ថា ការដាក់បម្រាមលើការធ្វើដំណើរចេញចូល និងការរឹតត្បិតជាសកលនឹងនៅតែបន្តរហូតដល់ត្រីមាសទីបីក្នុងឆ្នាំ 2020 និងប៉ះពាល់ក្នុងកម្រិតមធ្យម និងខ្ពស់ ដែលធ្វើឲ្យមានបញ្ហាសន្ទនីយភាពក្លាយទៅជាបញ្ហាសោធនភាព ដែលនឹងប៉ះពាល់ដល់សាជីវកម្ម និងតុល្យភាពនៃការទូទាត់។ ផសស ពិត ក្រោមសេណារីយ៉ូនេះត្រូវបានព្យាករណ៍ថានឹងថយចុះអវិជ្ជមាន 2.9 ភាគរយ នៅឆ្នាំ 2020 និងងើបឡើងបន្តិចម្តងៗមកត្រឹម 3.9 ភាគរយ នៅឆ្នាំ 2021។ យ៉ាងណាក៏ដោយ សេណារីយ៉ូដែលទាបបំផុតនេះមិនបានពិចារណាលើហានិភ័យហិរញ្ញវត្ថុ ដែលអាចកើតឡើងដោយសារតែទំនាក់ទំនងជាមួយម៉ាក្រូហិរញ្ញវត្ថុនោះទេ។

**មានហានិភ័យច្រើនដោយសារតែការគ្មានលទ្ធភាពសងប្រាក់នៅក្នុងវិស័យហិរញ្ញវត្ថុ។** បញ្ហាមួយចំនួននៃវិស័យហិរញ្ញវត្ថុអាចធ្វើឱ្យវិបត្តិជំងឺកូវីដ 19 កាន់តែមានភាពធ្ងន់ធ្ងរ។ បញ្ហាទាំងនេះរួមមាន ការប្រមូលផ្តុំឥណទានច្រើន ហានិភ័យប្រាក់កម្ចីរបស់ភាគីពាក់ព័ន្ធ កង្វះការត្រួតពិនិត្យរួមគ្នាតាមព្រំដែន និងកង្វះការ

ត្រួតពិនិត្យផ្អែកតាមហានិភ័យ[9]។ ហានិភ័យសន្ទនីយភាពក៏នៅតែមានកម្រិតខ្ពស់ផងដែរ នៅពេលដែលគ្រឹះស្ថានហិរញ្ញវត្ថុពឹងផ្អែកលើការផ្តល់ហិរញ្ញប្បទានពីបរទេស រួមទាំងការផ្តល់ហិរញ្ញប្បទានពីធនាគារមេ (ដល់ធនាគារនានា)។ ការប្រមូលផ្តុំនៃលំហូរការវិនិយោគផ្ទាល់ពីបរទេសក្នុងវិស័យមួយចំនួនតូច (គឺវិស័យធនាគារ សំណង់ និងអចលនទ្រព្យ) រួមជាមួយនឹងកម្ចីធនាគារជាសំខាន់សម្រាប់វិស័យសំណង់ និងអចលនទ្រព្យ បានបង្កជាប្រភពហានិភ័យបន្ថែមទៀត។

## ជម្រើសគោលនយោបាយ

**ជម្រើសគោលនយោបាយផ្សេងៗសម្រាប់ការឆ្លើយតបនឹងការផ្ទុះជំងឺកូវីដ 19 ត្រូវមានគោលបំណង ១) ផ្តល់ការជួយសង្គ្រោះភ្លាមៗ និងបន្ទាន់ដល់សេដ្ឋកិច្ច និងការការពារសុខភាពសាធារណៈ ២) ធ្វើឲ្យមានការស្តារសេដ្ឋកិច្ចឡើងវិញក្នុងរយៈពេលខ្លី និង ៣) បង្កើនភាពរឹងមាំផ្នែកម៉ាក្រូសារពើពន្ធ និងសង្គមក្នុងរយៈពេលមធ្យម។** វិធានការបន្ទាន់បំផុតគឺត្រូវផ្តល់ជំនួយដល់គ្រួសារនានាដើម្បីកាត់បន្ថយភាពក្រីក្រ។ វិធានការនេះរួមមាន ការប្រើប្រាស់កម្មវិធី និងការជួយសង្គ្រោះដែលមានស្រាប់ ក៏ដូចជាការកំណត់យន្តការផ្សេងៗ ដើម្បីជួយដល់គ្រួសារក្រីក្រ និងងាយរងគ្រោះតាមរយៈជំនួយសង្គម ដើម្បីរក្សាជីវភាពរស់នៅរបស់ពួកគេ។ គោលនយោបាយអន្តរាគមន៍នេះកំពុងត្រូវបានអនុវត្តជាមួយនឹងវិធានការឧបត្ថម្ភប្រាក់ឈ្នួល (សូមមើលប្រអប់ 1)។ ដើម្បីពង្រីកជំនួយសង្គម និងរបបធានារ៉ាប់រងសង្គមដែលមានស្រាប់របស់កម្ពុជាបន្ទាប់ពីការផ្តល់កម្មវិធីសង្គ្រោះបន្ទាន់មក ជាការសំខាន់ ត្រូវពង្រឹងយន្តការដែលមានស្រាប់ ដើម្បីកំណត់អត្តសញ្ញាណគ្រួសារក្រីក្រតាមរយៈកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ។ ជាការសំខាន់ត្រូវបន្តធ្វើការឆ្លើយតបសំខាន់ៗក្នុងវិស័យសុខាភិបាលនាពេលបច្ចុប្បន្ន ដូចជា ការស្វែងរកករណីឆ្លង ការដាក់ឱ្យនៅដាច់តែឯង ចត្តាឡីស័ក ដើម្បីស្វែងរកអ្នកមានទំនាក់ទំនងនាពេលកន្លងមក។ ក្រៅពីនេះ អនាម័យដៃ របៀបរបបក្អកក្រដាស និងការរក្សាគម្លាតពីគ្នា គួរបន្តអនុវត្តជាវិធានការទប់ស្កាត់សំខាន់មួយ។ អាជ្ញាធរកម្ពុជាបានធ្វើការឆ្លើយតបបានយ៉ាងល្អទៅលើរលកទីមួយនៃការផ្ទុះជំងឺនេះ ប៉ុន្តែ ដោយសារតែជំងឺកូវីដ ១៩ មិនទាន់ចាកចេញទៅនោះ កម្ពុជាត្រូវត្រៀមខ្លួនក្នុងការឆ្លើយតបទៅនឹងការផ្ទុះឡើងដែលអាចកើតឡើងនៅពេលអនាគត។

**ចាំបាច់ត្រូវមានផែនការបន្តប្រតិបត្តិការការងារប្រកបដោយប្រសិទ្ធភាព និងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ដើម្បីធានាការផ្តល់កម្មវិធី និងសោសង្គ្រោះដោយគ្មានការរអាក់ខាន។** ផែនការទាំងនេះកំណត់ពីវិធានការត្រៀមក្នុងការកាត់បន្ថយការរអាក់ខានដល់ប្រតិបត្តិការរបស់អង្គភាព ក្នុងករណីមានវិបត្តិ តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល និងព័ត៌មានថ្មីៗ។ អាស្រ័យលើវិសាលភាព និងភាពធ្ងន់ធ្ងរនៃផលប៉ះពាល់នៃការផ្ទុះជំងឺកូវីដ 19 ការអនុវត្តផែនការទាំងនេះជាជំហានៗ ដែលបញ្ចូលមុខងារសំខាន់ៗទាំងអស់របស់រដ្ឋាភិបាល (រដ្ឋបាល ហិរញ្ញវត្ថុ និងសុខាភិបាល) គួររក្សាប្រតិបត្តិការជាមូលដ្ឋាន ដែលជួយដល់ការផ្តល់ជំនួយស្បៀងអាហារសង្គ្រោះបន្ទាន់ ជំនួយដល់សេដ្ឋកិច្ច និងជំនួយដល់សុខភាពសាធារណៈដោយគ្មានការរអាក់ខាន។

**ប្រសិទ្ធភាពនៃអន្តរាគមន៍របស់រដ្ឋាភិបាលនឹងមានសារៈសំខាន់ក្នុងការជួយសម្រួលដល់ការស្តារសេដ្ឋកិច្ចឡើងវិញ។** ជំងឺកូវីដ 19 អាចនឹងបង្កផលវិបាកច្រើនលើដំណើរការពាណិជ្ជកម្ម និងការវិនិយោគក្នុងតំបន់ និងទូទាំងសកលលោក ដោយរំពឹងថានឹងមានការកែប្រែសំខាន់ៗក្នុងគោលនយោបាយពាណិជ្ជកម្ម គោលនយោបាយអន្តោប្រវេសន៍ និងលំហូរទំនិញ និងសេវា។ អ្វីដែលចាំបាច់នោះគឺថា អាជ្ញាធរកម្ពុជាត្រូវពិចារណាពីការបង្កើនតម្រូវការក្នុងស្រុកនាពេលអនាគត ការពារអំណាចទិញរបស់អ្នកប្រើប្រាស់ក្នុងស្រុកនៅពេលដែលមានការប៉ះទង្គិចពីខាងក្រៅដោយសារសុខភាពសាធារណៈ និង/ឬ គ្រោះមហន្តរាយធម្មជាតិ និងការបង្កើនផលិតកម្មសម្រាប់ការប្រើប្រាស់ក្នុងស្រុក។ ត្រង់ចំណុចនេះ វិធានការអន្តរាគមន៍ដែលអាជ្ញាធរកម្ពុជាបានចាប់ផ្តើមអនុវត្ត រួមមាន ការបន្ធូរបន្ថយពន្ធ និងការបង្កើនលទ្ធភាពរបស់អាជីវកម្មខ្នាតតូច និងសហគ្រាសគ្រួសារ ក្នុងការទទួលបានឥណទានដែលមានការប្រាក់ទាបដោយប្រើប្រាស់គម្រោងសហហិរញ្ញប្បទានរវាងធនាគារសហគ្រាសធុនតូច និងមធ្យមនៃកម្ពុជា ដែលទើបត្រូវបានបង្កើតឡើង និងអ្នកផ្តល់កម្ចីសម្រាប់ពាណិជ្ជកម្ម (ធនាគារ និងមីក្រូហិរញ្ញវត្ថុ)។ ទន្ទឹមនឹងនេះ មានការផ្តល់មូលធនចំនួន 50 លានដុល្លារអាមេរិកដល់ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម ដើម្បីគាំទ្រដល់ក្រុមហ៊ុនកែច្នៃកសិផល និងកសិឧស្សាហកម្មថ្មីៗ។ យ៉ាងណាក៏ដោយ ភាពជោគជ័យនៃវិធានការទាំងនេះពឹងផ្អែកលើ ការកំណត់គោលដៅទៅក្រុមហ៊ុន និងសហគ្រាសខ្នាតតូច ខ្នាតមធ្យម និងខ្នាតធំ ដែលដំណើរការដោយប្រសិទ្ធផល និងរលូន ប៉ុន្តែ ខ្វះប្រភពហិរញ្ញប្បទានដែលយកការប្រាក់ទាប ដើម្បីបង្កើតការងារ ដំណើរការដោយទទួលបានប្រាក់ចំណេញ និងនាំចេញ។ ការជួយសម្រួលនេះក៏រួមទាំងក្រុមហ៊ុនជាលក្ខណៈគ្រួសារ និងក្រុមហ៊ុនខ្នាតតូចដែលដំណើរការក្នុងការលក់រាយ និងមានតម្លៃថោកនៅក្នុងវិស័យទេសចរណ៍ ដែលក្រុមហ៊ុនផ្លូវការ និងពាក់កណ្តាលផ្លូវការជាច្រើនរងផលប៉ះពាល់ដោយសារជំងឺកូវីដ 19 ឬក៏មិនរងផលប៉ះពាល់។

**វិធានការចុងក្រោយគឺការធានានូវភាពរឹងមាំនៃសេដ្ឋកិច្ច និងសង្គមក្នុងរយៈពេលមធ្យម បន្ទាប់ពីមានលទ្ធភាពអាចគ្រប់គ្រងជំងឺកូវីដ 19 បាន។** ជាការសំខាន់ត្រូវផ្តោតឡើងវិញ និងបង្កើនកិច្ចខិតខំប្រឹងប្រែង និងប្រភព ដែលអាចត្រូវបានអាក់ខាន ឬប្រើប្រាស់ដើម្បីដោះស្រាយទៅនឹងការផ្ទុះជំងឺកូវីដ 19 ដើម្បីធ្វើដំណើរឆ្ពោះទៅរកកំណែទម្រង់សំខាន់ៗផ្នែករចនាសម្ព័ន្ធ និងសង្គម។ ត្រង់ចំណុចនេះ ត្រូវផ្តោតការយកចិត្តទុកដាក់ និងបង្កើនកិច្ចខិតខំប្រឹងប្រែងលើការបង្កើនភាពរឹងមាំនៃម៉ាក្រូសារពើពន្ធ ដោះស្រាយភាពងាយរងគ្រោះក្នុងវិស័យហិរញ្ញវត្ថុ ពង្រឹងភាពប្រកួតប្រជែងក្រៅប្រទេស និងការធ្វើពិពិធកម្ម ដើម្បីកាត់បន្ថយផលប៉ះពាល់នៃវិបត្តិខាងក្រៅដែលអាចកើតឡើង ក៏ដូចជាការធានាឲ្យមានកម្មវិធីសង្គ្រោះ និងកម្មវិធីកិច្ចគាំពារសង្គម ដែលអាចដាក់ឲ្យដំណើរការ និង/ឬពង្រីកយ៉ាងឆាប់រហ័សក្នុងគ្រាអាសន្ន។ ដើម្បីសម្រេចបានសេដ្ឋកិច្ចរឹងមាំ ចាំបាច់ត្រូវបង្កើនការសម្រួលដល់ការធ្វើអាជីវកម្ម បរិយាកាសវិនិយោគ និងការកាត់បន្ថយតម្លៃថាមពល និងភស្តុភារបន្ថែមទៀត ដើម្បីត្រឡប់ទៅចូលរួមជាមួយសង្វាក់តម្លៃក្នុងតំបន់ និងសកល ក្រោយពេលមានការរអាក់ខានដោយសារតែការផ្ទុះជំងឺកូវីដ 19 នោះ។

---

9 របាយការណ៍បុគ្គលិកសម្រាប់ឆ្នាំ 2019 អត្ថបទទី 4 ការពិគ្រោះយោបល់, IMF។ សូមមើល ៖ https://www.imf.org/en/Publications/CR/Issues/2019/12/23/Cambodia-2019-Article-IV-Consultation-Press-Release-Staff-Report-and-Statement-by-the-48912។

# រូប ES.1 ៖ និន្នាការរួមស្ដីពីការអភិវឌ្ឍថ្មីៗនៅកម្ពុជា

**កំណើនពិត ដែលមានភាពរឹងមាំរហូតដល់ឆ្នាំមុន បានរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយសារការផ្ទុះជំងឺកូវីដ 19 នៅទូទាំងពិភពលោក**

*កំណើនពិត (ភាគរយ)*




**..ព្រោះថា ការនាំចេញសំខាន់ៗដែលបានថយចុះបន្តិចកាលពីឆ្នាំមុន កំពុងរងផលប៉ះពាល់ដោយសារការប៉ះទង្គិចតម្រូវការខាងក្រៅ**

*ការនាំចេញសម្លៀកបំពាក់ និងស្បែកជើង (ការប្រែប្រួលជាភាគរយធៀបនឹងឆ្នាំមុន)*



**...ហើយវិស័យទេសចរណ៍បានដួលរលំ ដោយសារតែការហាមឃាត់ការធ្វើដំណើរអន្តរជាតិ និងការដាក់បម្រាមធ្វើដំណើរចេញចូលក្នុងប្រទេស**

*ចំនួនភ្ញៀវទេសចរអន្តរជាតិ (ការប្រែប្រួលជាភាគរយធៀបនឹងឆ្នាំមុន)*




**...សកម្មភាពសំណង់ បានថយចុះបន្តិច ដែលត្រូវបានបង្ហាញដោយការថយចុះនៃការនាំចូលដែកថែប**

*ការនាំចូលសម្ភារសាងសង់ និងដែកថែប (ការប្រែប្រួលជាភាគរយធៀបនឹងឆ្នាំមុន)*




**ដោយមានការថយចុះនៃលំហូរចូលមូលធន និងកំណើនរូបិយវត្ថុទូលាយបានថយចុះ..**

*រូបិយវត្ថុទូលាយ (ការប្រែប្រួលជាភាគរយធៀបនឹងឆ្នាំមុន)*



**...កំណើននៃការផ្ដល់ឥណទានធនាគារដល់វិស័យឯកជន បានថយចុះ**

*ការផ្ដល់ឥណទានដល់វិស័យឯកជន (ការប្រែប្រួលជាភាគរយធៀបនឹងឆ្នាំមុន)*



*ប្រភព ៖* អាជ្ញាធរកម្ពុជា, ការប៉ាន់ស្មាន និងការព្យាកររបស់បុគ្គលិកធនាគារពិភពលោក

*សម្គាល់ ៖* GFC = វិបត្តិហិរញ្ញវត្ថុសកល



Image credit: ©Morgan Havet, Hanuman Films



## ផ្នែកទី ១

# ការអភិវឌ្ឍសេដ្ឋកិច្ចថ្មីៗ និងទស្សនៈវិស័យ

# ការអភិវឌ្ឍសេដ្ឋកិច្ចថ្មីៗ និងទស្សនៈវិស័យ

## ការអភិវឌ្ឍថ្មីៗ

### សកម្មភាពសេដ្ឋកិច្ចបានថយចុះយ៉ាងឆាប់រហ័សដោយសារការផ្ទុះជំងឺកូវីដ 19 ទូទាំងពិភពលោក

**ចលករកំណើនបានបាត់បង់យ៉ាងលឿននៅដើមឆ្នាំ 2020 ដោយសារតែការផ្ទុះជំងឺកូវីដ 19 ជាសកល។** ទោះបីជាមានកំណើនមានភាពរឹងមាំ ដោយកើនដល់ 7.1 ភាគរយនៅឆ្នាំ 2019 (រូប 1) ប៉ុន្តែការផ្ទុះជំងឺកូវីដបានធ្វើឱ្យវិស័យដែលជាក្បាលម៉ាស៊ីនជំរុញកំណើនរបស់កម្ពុជា បានយថយចុះយ៉ាងខ្លាំងនៅត្រីមាសទីមួយក្នុងឆ្នាំ 2020 រួមទាំង ការថយចុះនៃវិស័យទេសចរណ៍ (និងបដិសណ្ឋារកិច្ច) និងសកម្មភាពសំណង់ និងវិស័យនាំចេញនាពេលថ្មីៗនេះ។ ទេសចរណ៍ជាវិស័យជំរុញកំណើនទីមួយ និងរងផលប៉ះពាល់ខ្លាំងជាងគេ ចាប់តាំងពីការផ្ទុះជំងឺកូវីដ 19 នៅប្រទេសចិនមក។ បន្ទាប់មក ការប៉ះទង្គិចនៃតម្រូវការខាងក្រៅដែលបង្កឡើងដោយការផ្ទុះជំងឺកូវីដ 19 បានធ្វើឱ្យមានការផ្អាក និងលុបចោលការបញ្ជាទិញសម្លៀកបំពាក់ និងស្បែកជើង។ កត្តានេះបានធ្វើឱ្យរោងចក្រសម្លៀកបំពាក់ និងស្បែកជើង ចាប់ផ្ដើមផ្អាកប្រតិបត្តិការរបស់ខ្លួន ដោយផ្នែក ឬទាំងស្រុង។ ថ្មីៗនេះ ឧស្សាហកម្មសំណង់ បានទទួលហិរញ្ញប្បទានកាន់តែច្រើនពីលំហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេស (FDI)។ តាមការប៉ាន់ស្មានថា កម្ពុជាទទួលបាន 40% នៃលំហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេសពីប្រទេសចិន ហើយភាគច្រើននៃការវិនិយោគផ្ទាល់ទាំងនេះត្រូវបានប្រើប្រាស់ក្នុងវិស័យសំណង់។ នៅរយៈពេលប៉ុន្មានខែដំបូងក្នុងឆ្នាំ 2020 ទាំងសកម្មភាពសំណង់ (ដែលត្រូវបានអនុម័ត) និងលំហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេស បានថយចុះយ៉ាងខ្លាំង។

**ការផ្ទុះជំងឺកូវីដ 19 ទូទាំងពិភពលោក បានបង្កការអាក់ខានយ៉ាងខ្លាំងដល់សកម្មភាពសេដ្ឋកិច្ចក្នុងតំបន់ និងពិភពលោក។** នៅក្នុងឆ្នាំ 2019 សកម្មភាពសេដ្ឋកិច្ចបានទទួលការគាំទ្រដោយការប្រើប្រាស់ឯកជនដែលមានភាពរឹងមាំ និងគោលនយោបាយសម្របសម្រួលសារពើពន្ធ និងគោលនយោបាយរូបិយវត្ថុ។ សំខាន់ជាងនេះទៀតនោះគឺថា ពិភពលោកបានស្វាគមន៍កិច្ចព្រមព្រៀងពាណិជ្ជកម្មដំណាក់កាលទីមួយ ដែលចុះហត្ថលេខាដោយសហរដ្ឋអាមេរិក និងប្រទេសចិន នៅខែ មករា ឆ្នាំ 2020 ក្រោយពីមានការបង្កើនពន្ធនាំចូលជាង 2 ឆ្នាំកន្លងទៅ។ ទោះជាយ៉ាងណាក្ដី សន្ទុះកំណើនសកល និងក្នុងតំបន់ បានជាប់គាំងភ្លាមៗដោយសារការរីករាលដាលនៃជំងឺកូវីដ 19 (សូមមើលប្រអប់ 2 និង 3 ស្ដីពីការអភិវឌ្ឍថ្មីៗជាសកល និងក្នុងតំបន់ និងទស្សនៈវិស័យ)។ យោងតាមរបាយការណ៍បច្ចុប្បន្នភាពសេដ្ឋកិច្ចអាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ខែ មេសា ឆ្នាំ 2020 របស់ធនាគារពិភពលោក ផសស ជាសកល ត្រូវបានរំពឹងថានឹងថយចុះចំនួន 2.1 ភាគរយ ខណៈដែល ផសស របស់បណ្ដាប្រទេសកំពុងអភិវឌ្ឍន៍ត្រូវបានរំពឹងថានឹងថយចុះ 2.5 ភាគរយ ចំណែក ផសស របស់បណ្ដាប្រទេសមានប្រាក់ចំណូលខ្ពស់ត្រូវបានរំពឹងថានឹងថយចុះចំនួន 1.9 ភាគរយ (រូប 2)។ នៅក្នុងសេណារីយ៉ូនៃជំងឺឆ្លងជាសកល មានការរំពឹងថា ការថយចុះ ផសស យ៉ាងច្រើននឹងកើតឡើងនៅតាមបណ្ដាប្រទេសអាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ដោយសារសមាហរណកម្មស៊ីជម្រៅតាមរយៈពាណិជ្ជកម្ម និង

**រូប 1 ៖ ការរួមចំណែកតាមវិស័យដល់កំណើនពិត**




*ប្រភព* ៖ អាជ្ញាធរកម្ពុជា និងការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក
*សម្គាល់* ៖ e= ប៉ាន់ស្មាន, p/proj.= ព្យាករណ៍

**រូប 2 ៖ ផសស និងផលប៉ះពាល់លើការនាំចេញនៅក្នុងសេណារីយ៉ូនៃការផ្ទុះឆ្លងជំងឺកូវីដ 19 ជាសកល**




*ប្រភព* ៖ ធនាគារពិភពលោក ឆ្នាំ 2020a

ផលប៉ះពាល់ផ្ទាល់លើវិស័យទេសចរណ៍[10]។ ចាប់តាំងពីពេលនោះមក កំណើនសកល និងក្នុងតំបន់ បានថយចុះថែមទៀត។ នៅប្រទេសចិន ការព្យាករលើកំណើនត្រូវបានកែសម្រួលឡើងវិញមកត្រឹម 1 ភាគរយនៅឆ្នាំ 2020 ដោយតួលេខនេះមានចំនួន 5.9 ភាគរយ នៅមុនពេលមានការផ្ទុះជំងឺកូវីដ 19។

**បន្ទាប់ពីការឆ្លងរាលដាលនៃជំងឺកូវីដ 19 ករណីឆ្លងដំបូងនៅកម្ពុជាត្រូវបានរកឃើញនៅថ្ងៃទី 27 ខែ មករា ឆ្នាំ 2020។** ត្រឹមថ្ងៃទី 12 ខែ ឧសភា ឆ្នាំ 2020 កម្ពុជាមានករណីឆ្លងរហូតដល់ 122 ករណី។ អាជ្ញាធរកម្ពុជាបានចាត់វិធានការជាបន្ទាន់ក្នុងការកំណត់រក និងទប់ស្កាត់ការផ្ទុះការឆ្លងក្នុងសហគមន៍តាមរយៈការហាមឃាត់ការធ្វើដំណើររបស់ភ្ញៀវទេសចរមកពីប្រទេសដែលមានករណីឆ្លងច្រើន ការបិទសាលារៀន ការទទូចឱ្យពលរដ្ឋចៀសវាងការជួបជុំគ្នាទ្រង់ទ្រាយធំ និងការផ្អាកការប្រារព្ធពិធីបុណ្យចូលឆ្នាំខ្មែរនៅពាក់កណ្ដាលខែ មេសា រួមទាំងចាត់វិធានការដាក់បម្រាមមិនឱ្យធ្វើដំណើរចេញចូលក្នុងរយៈពេល 3 ថ្ងៃនៃពិធីបុណ្យចូលឆ្នាំខ្មែរ។ ច្បាប់ស្ដីពី “ការគ្រប់គ្រងប្រទេសជាតិក្នុងភាពអាសន្ន” ក៏ត្រូវបានអនុម័តយ៉ាងប្រញាប់ប្រញាល់។

### បើទោះជាកម្ពុជាបានចៀសផុតពីវិបត្តិសុខភាពនាពេលកន្លងមក ប៉ុន្តែ កម្ពុជាមិនអាចគេចផុតពីវិបត្តិសេដ្ឋកិច្ចសកលដែលកំពុងកើតឡើងនៅលើពិភពលោកឡើយ

**ផលប៉ះពាល់លើកំណើនដោយសារជំងឺកូវីដ 19 អាស្រ័យលើការឆ្លងរាលដាល ភាពធ្ងន់ធ្ងរ និងរយៈពេលនៃការផ្ទុះឆ្លង ការឆ្លើយតបរបស់សង្គម និងវិសាលភាព និងប្រសិទ្ធភាពនៃវិធានការគោលនយោបាយ។** ការចំណាយផ្ទាល់លើការទប់ស្កាត់ការផ្ទុះឆ្លងក្នុងសហគមន៍បច្ចុប្បន្ន ហាក់ដូចជាអាចដោះស្រាយបាន។ ប៉ុន្តែការផ្ទុះជំងឺកូវីដ 19 បានធ្វើឱ្យវិស័យដែលជាក្បាលម៉ាស៊ីនជំរុញសេដ្ឋកិច្ចរបស់កម្ពុជាមានការធ្លាក់ចុះយ៉ាងខ្លាំងនៅត្រីមាសទីមួយក្នុងឆ្នាំ 2020 រួមទាំង ការថយចុះនៃវិស័យទេសចរណ៍ (និងបដិសណ្ឋារកិច្ច) និងសកម្មភាពសំណង់ និងនាពេលថ្មីៗនេះ វិស័យនាំចេញ។

### ឧស្សាហកម្មទេសចរណ៍ និងបដិសណ្ឋារកិច្ច ប្រឈមនឹងទាំងការថយចុះផ្នែកចនាសម្ព័ន្ធ និងរងផលប៉ះពាល់ធ្ងន់ធ្ងរដោយសារការផ្ទុះជំងឺកូវីដ 19

**ទេសចរណ៍ជាវិស័យដែលរងផលប៉ះពាល់ខ្លាំងជាងគេ។** ក្នុងរយៈពេលប៉ុន្មានខែថ្មីៗនេះ តម្រូវការសម្រាប់សេវាទេសចរណ៍ និងបដិសណ្ឋារកិច្ចបានថយចុះយ៉ាងខ្លាំង។ ការឆ្លើយតបជាសកលដើម្បីទប់ស្កាត់ការផ្ទុះជំងឺកូវីដ 19 បានធ្វើឱ្យមានការអូសបន្លាយការរឹតត្បិតការធ្វើដំណើរអន្តរជាតិ និងការដាក់បម្រាមធ្វើដំណើរចេញចូលក្នុងប្រទេស។ នៅរយៈពេលពីរខែដំបូងក្នុងឆ្នាំ 2020 ចំនួនភ្ញៀវទេសចរបានថយចុះចំនួន 25.1 ភាគរយ (ធៀបនឹងឆ្នាំមុន) ដោយនេះជាការថយចុះលើកដំបូងចាប់តាំងពីមានវិបត្តិហិរញ្ញវត្ថុសកលនៅឆ្នាំ 2008-2009 (រូប 3)។ ចំនួនភ្ញៀវទេសចរមកកាន់ខេត្តសៀមរាប ដែលជាគោលដៅទេសចរណ៍ដ៏មានប្រជាប្រិយភាពបំផុតនៅកម្ពុជា បានថយចុះចំនួន 45.6 ភាគរយ នៅត្រីមាសទីមួយ និងថយចុះចំនួន 99.6 ភាគរយ (ធៀបនឹងឆ្នាំមុន) នៅអំឡុងខែ មេសា ឆ្នាំ 2020[11]។

**វិស័យទេសចរណ៍ (រួមទាំងបដិសណ្ឋារកិច្ច) គឺជាក្បាលម៉ាស៊ីនជំរុញធំបំផុតទីពីរ ដែលត្រូវបានប៉ាន់ស្មានថាបានរួមចំណែកប្រមាណ 18.7 ភាគរយ ដល់កំណើន ផសស ពិតនៅឆ្នាំ 2019[12]។** វិស័យទេសចរណ៍ជា វិស័យដែលរកប្រាក់ចំណូល

**រូប 3 ៖ ចំនួនភ្ញៀវទេសចរអន្តរជាតិសរុប និងចំនួនភ្ញៀវទេសចរមកកាន់ខេត្តសៀមរាប**

(ការប្រែប្រួលជាភាគរយធៀបនឹងឆ្នាំមុន)




*ប្រភព* ៖ អាជ្ញាធរកម្ពុជា

**រូប 4 ៖ ចំនួនភ្ញៀវទេសចរអន្តរជាតិ**

(ការប្រែប្រួលជាភាគរយធៀបនឹងឆ្នាំមុន)




*ប្រភព* ៖ អាជ្ញាធរកម្ពុជា

*សម្គាល់* ៖ RHS=ខាងស្តាំ

10 ធនាគារពិភពលោក ឆ្នាំ 2020។

11 សេចក្ដីប្រកាសព័ត៌មានស្ដីពីចំនួនភ្ញៀវទេសចរអន្តរជាតិ និងស្ថិតិប្រាក់ចំណូលពីតំបន់អង្គរ ថ្ងៃទី 1 ខែ មេសា ឆ្នាំ 2020 សហគ្រាសអង្គរ។

12 យោងតាមក្រុមប្រឹក្សាវិស័យធ្វើដំណើរ និងទេសចរណ៍ពិភពលោក (WTTC) វិស័យធ្វើដំណើរ និងទេសចរណ៍បានរួមចំណែកប្រមាណ 33 ភាគរយ ដល់ ផសស របស់កម្ពុជានៅឆ្នាំ 2019 ចំណែកទិន្នន័យគណនីជាតិផ្លូវការបង្ហាញថា វិស័យសេវាទាំងមូលបានរួមចំណែក 38.8 ភាគរយ ដល់ ផសស របស់កម្ពុជា។ យោងតាម WTTC វិស័យធ្វើដំណើរ និងទេសចរណ៍ផ្ដល់ការងារចំនួន 2.9 លាន។

**ប្រអប់ 1 ៖**

## វិធានការផ្នែកសុខភាពសាធារណៈ និងគោលនយោបាយសេដ្ឋកិច្ចរបស់កម្ពុជាក្នុងការឆ្លើយតបទៅនឹងការផ្ទុះជំងឺកូវីដ ១៩

**ករណីឆ្លង និងករណីជាសះស្បើយដែលត្រូវបានបញ្ជាក់ ៖** ករណីទីមួយត្រូវបានរកឃើញនៅខេត្តព្រះសីហនុ គឺបុរសជនជាតិចិនអាយុ 60 ឆ្នាំ ដែលបានធ្វើដំណើរមកពីខេត្តវូហាន ក្រុងហ៊ឺប៉ី ជាមួយក្រុមគ្រួសាររបស់គាត់កាលពីថ្ងៃទី 27 ខែ មករា ឆ្នាំ 2020។ នៅចន្លោះថ្ងៃទី 27 ខែ មករា និង ថ្ងៃទី 17 ខែ មេសា ឆ្នាំ 2020 ចំនួនអ្នកឆ្លងជំងឺកូវីដ 19 បានកើនឡើងដល់ 122 នាក់ ក្នុងនោះ អ្នកជំងឺ 87.7 ភាគរយបានជាសះស្បើយ (រូប B1.1 និង B1.2)។ គិតត្រឹមថ្ងៃទី 16 ខែ ឧសភា ឆ្នាំ 2020 អ្នកជំងឺកូវីដ 19 ទាំងអស់បានជាសះស្បើយ។ ការឆ្លងភាគច្រើនគឺជាករណីឆ្លងពីក្រៅប្រទេស។ ការបែងចែកតាមតំបន់ភូមិសាស្ត្របង្ហាញថា ទីតាំងបីដែលរកឃើញករណីជំងឺកូវីដ 19 ច្រើនជាងគេ រួមមាន ខេត្តព្រះសីហនុ ក្រុងភ្នំពេញ និងខេត្តកំពង់ចាម ដោយមាន 32.5 ភាគរយសម្រាប់ខេត្តព្រះសីហនុ, 22.8 ភាគរយសម្រាប់ក្រុងភ្នំពេញ និង 13.8 ភាគរយសម្រាប់ខេត្តកំពង់ចាម (រូប B1.3)។

**រូប B1.1 ៖ ករណីជំងឺកូវីដ 19**




**រូប B1.2 ៖ ជំងឺកូវីដ 19**




**រូប B1.3 ៖ ជំងឺកូវីដ 19**




*ប្រភព* ៖ បុគ្គលិកធនាគារពិភពលោក ផ្អែកលើទិន្នន័យរបស់ក្រសួងសុខាភិបាល

**ការទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ 19 ៖** មានការអនុវត្តវិធានការបីក្នុងពេលតែមួយ គឺ 1) វិធានការប្រឆាំងនឹងករណីឆ្លងពីក្រៅប្រទេស ដែលមានចំនួន 80 ភាគរយនៃការឆ្លង តាមរយៈការហាមឃាត់អ្នកធ្វើដំណើរពីប្រទេសបារាំង អាល្លឺម៉ង់ អ៊ីតាលី អេស្ប៉ាញ និងសហរដ្ឋអាមេរិក មិនឲ្យចូលមកក្នុងប្រទេសកម្ពុជា 2) ការលើកកម្ពស់ការយល់ដឹងអំពីស្វ័យការពារ ការរក្សាគម្លាតសង្គម ការបិទសាលារៀនមុនពេលវិស្សមកាល ការហាមឃាត់ការជួបជុំគ្នា និងជាពិសេស ការលុបចោលការប្រារព្ធពិធីបុណ្យចូលឆ្នាំខ្មែរ រួមនឹងការរឹតត្បិតការធ្វើដំណើរពីខេត្តមួយទៅខេត្តមួយជាបណ្ដោះអាសន្ន។ល។ និង 3) ការខិតខំផ្ដល់ការព្យាបាលប្រកបដោយប្រសិទ្ធភាព ដែលបានធ្វើឱ្យអ្នកជំងឺបានជាសះស្បើយ។ ក្នុងការត្រៀមប្រយុទ្ធនឹងករណីឆ្លងទ្រង់ទ្រាយធំជាងមុន កម្ពុជាបានរៀបចំបន្ទប់ចំនួន 3,000 នៅទូទាំងប្រទេស និងមានការកៀរគរបុគ្គលិកបន្ថែមចំនួន 422 នាក់។

**ការឆ្លើយតបផ្នែកគោលនយោបាយសង្គម និងសារពើពន្ធ ៖** វិធានការគោលនយោបាយសំខាន់ៗដែលត្រូវបានអនុវត្តរួមមាន 1) ការពង្រីករបបគាំពារសង្គមដែលមានស្រាប់ តាមរយៈការផ្ទេរប្រាក់ដល់គ្រួសារក្រីក្រ និងងាយរងគ្រោះ 2) ការបន្ធូរបន្ថយពន្ធសម្រាប់វិស័យទេសចរណ៍ និងឧស្សាហកម្មផលិតសម្រាប់ការនាំចេញ (សម្លៀកបំពាក់/ស្បែកជើង/ទំនិញធ្វើដំណើរ) 3) កម្មវិធីបណ្ដុះបណ្ដាល និងបង្កើនជំនាញសម្រាប់កម្មករនិយោជិតដែលត្រូវបានរំសាយ 4) ការឧបត្ថម្ភប្រាក់ឈ្នួល 70 ដុល្លារអាមេរិក (40 ដុល្លារផ្ដល់ដោយរដ្ឋាភិបាល និង 30 ដុល្លារផ្ដល់ដោយក្រុមហ៊ុន/រោងចក្រ) សម្រាប់កម្មករនិយោជិតដែលត្រូវបានព្យួរការងារ 5) ការលើកលែងពន្ធផ្ទេរកម្មសិទ្ធិសម្រាប់ទ្រព្យសម្បត្តិដែលមានតម្លៃមិនលើសពី 70,000 ដុល្លារអាមេរិក 6) ការផ្ដល់មូលធនបន្ថែមចំនួន 50 លានដុល្លារអាមេរិកដល់ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម ដើម្បីគាំទ្រដល់ក្រុមហ៊ុនកែច្នៃកសិផល 7) ការបង្កើតធនាគារសហគ្រាសធុនតូច និងមធ្យមនៃកម្ពុជា ដែលមានទុនដំបូង 100 លានដុល្លារអាមេរិក 8) ការបង្កើនការសម្រួលដល់ដំណើរការធ្វើអាជីវកម្ម ការសម្របសម្រួលពាណិជ្ជកម្ម រួមទាំងការធ្វើសវនកម្មគយបន្ទាប់ពីទំនិញបានបញ្ចេញ។

**ការឆ្លើយតបផ្នែកគោលនយោបាយរូបិយវត្ថុ ៖** ធនាគារជាតិបានណែនាំគោលនយោបាយរូបិយវត្ថុដែលផ្ដល់ការអនុគ្រោះ។ លក្ខខណ្ឌអត្រាទុនបម្រុងកាតព្វកិច្ចត្រូវបានបន្ថយមកត្រឹម 7 ភាគរយ ទាំងសម្រាប់រូបិយវត្ថុក្នុងស្រុក និងរូបិយវត្ថុអន្តរជាតិ ចុះពី 8 ភាគរយសម្រាប់រូបិយវត្ថុក្នុងស្រុក និង 12.5 ភាគរយសម្រាប់រូបិយវត្ថុអន្តរជាតិ ដោយចាប់អនុវត្តពីខែ មេសា ឆ្នាំ 2020 តទៅ។ អត្រាកំណត់សម្រាប់ប្រតិបត្តិការផ្ដល់សន្ទនីយភាព ដោយមានការធានាសម្រាប់គ្រប់រយៈពេលកំណត់សងប្រាក់ទាំងអស់ក៏ត្រូវបានបញ្ចុះ 0.5 ភាគរយផងដែរ។ ធនាគារជាតិក៏បានសម្រេចផ្អាកការអនុវត្តពេញលេញនូវទ្រនាប់ដើមទុនខុនស៊ើវេសិន និងរក្សាលក្ខខណ្ឌតម្រូវបច្ចុប្បន្ន 50 ភាគរយដដែល បញ្ចុះអត្រាការប្រាក់លើវិញ្ញាបនប័ត្របញ្ញើដែលអាចជួញដូរបាន ទាំងសម្រាប់ប្រាក់រៀល និងប្រាក់ដុល្លារអាមេរិក មកត្រឹមកម្រិតសមស្របមួយ និងកាត់បន្ថយលក្ខខណ្ឌតម្រូវអប្បបរមានៃអត្រាគ្របដណ្ដប់សន្ទនីយភាព មកត្រឹមកម្រិតសមស្របមួយ។ ធនាគារជាតិបានណែនាំឱ្យធនាគារពាណិជ្ជ (និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ) កែសម្រួលកាលវិភាគសងប្រាក់សម្រាប់អ្នកខ្ចីដែលរងផលប៉ះពាល់ធ្ងន់ធ្ងរ ដូចជា ភោជនីយដ្ឋាន សណ្ឋាគារ ផ្ទះសំណាក់ ហាងលក់ភេសជ្ជៈ។ល។

**ដើម្បីអនុវត្តវិធានការឆ្លើយតបខាងលើ** អាជ្ញាធរកម្ពុជាបានបង្កើតក្រុមការងារអន្តរក្រសួងដូចតទៅ គឺ 1) ក្រុមការងារគ្រប់គ្រងសម្ភារផ្គត់ផ្គង់ និងតម្លៃរបស់ទំនិញជាយុទ្ធសាស្ត្រ 2) គោលនយោបាយថវិកាស្ដីពីហិរញ្ញប្បទាន និងជំនួយសង្គម និង 3) ក្រុមការងារពហុវិស័យដែលមានតួនាទីសិក្សា និងរៀបចំវិធានការរូបិយវត្ថុ និងធនាគារ។

*សម្គាល់* ៖ ប្រអប់នេះត្រូវបានរៀបចំឡើងដោយ លោក ភឹម រុនស៊ីណារិទ្ធ និងលោក លី សូដេត។

បរទេសយ៉ាងសំខាន់ ដែលរួមចំណែកជាង 3/4 នៃការនាំចេញផ្នែកសេវារបស់កម្ពុជា និងប្រមាណ 1/5 នៃការនាំចេញទំនិញនិងសេវាសរុប។ នៅឆ្នាំ 2019 កម្ពុជាទទួលបានភ្ញៀវទេសចរចំនួន 6.61 លាននាក់ កើនឡើង 6.6 ភាគរយធៀបនឹងឆ្នាំ 2018។

**ការថយចុះផ្នែកចរន្តសាច់ប្រាក់ក្នុងវិស័យទេសចរណ៍ បានកើតមានឡើងក្នុងរយៈពេលពីរបីឆ្នាំកន្លងមក ដោយចំនួនភ្ញៀវដែលត្រឡប់មកលេងម្តងទៀតមានតិចជាង 20 ភាគរយ។** យ៉ាងណាក៏ដោយ ដំបូងឡើយ វិស័យនេះទទួលបានការជួយជំរុញយ៉ាងខ្លាំងពីគម្រោងផ្តួចផ្តើម "ប្រទេសចិនបានរៀបចំរួចរាល់" របស់អាជ្ញាធរកម្ពុជាដែលបានណែនាំនៅឆ្នាំ 2016។ គម្រោងនេះបានធ្វើឱ្យចំនួនភ្ញៀវទេសចរចិនកើនឡើងខ្លាំង ដោយកើនឡើងចំនួន 35.7 ភាគរយនៅឆ្នាំ 2019 ហើយជួយបំពេញការថយចុះជារួមនៃចំនួនភ្ញៀវទេសចរមកពីបណ្តាប្រទេសផ្សេងៗទៀត។ ចំនួនភ្ញៀវទេសចរអន្តរជាតិ (មិនរាប់បញ្ចូលភ្ញៀវទេសចរចិន) បានថយចុះកំណើនយ៉ាងខ្លាំងតាំងពីឆ្នាំ 2014 និងមានចំនួនតិចជាងឆ្នាំមុនៗនៅឆ្នាំ 2018 (រូប 4)។ នៅឆ្នាំ 2019 ចំនួនភ្ញៀវទេសចរអន្តរជាតិមកពីប្រទេសវៀតណាម ថៃ និងឡាវ នៅតែច្រើនជាងគេ ដោយភ្ញៀវមកពីប្រទេសវៀតណាមមានចំនួន 13.7 ពីប្រទេសថៃមានចំនួន 7.1 ភាគរយ និងពីប្រទេសឡាវ មានចំនួន 5.5 ភាគរយ នៃចំនួនភ្ញៀវទេសចរសរុប។ ចំនួនភ្ញៀវទេសចរមកពីតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក មានចំនួនប្រមាណ 80 ភាគរយនៃចំនួនភ្ញៀវទេសចរអន្តរជាតិសរុបដែលមកកាន់កម្ពុជា។

**ជាការឆ្លើយតប អាជ្ញាធរកម្ពុជាបានណែនាំវិធានការបន្ធូរបន្ថយពន្ធដើម្បីគាំទ្រដល់ឧស្សាហកម្មទេសចរណ៍** (និងលើកលែងការបង់វិភាគទានលើរបបគាំពារសង្គម) ដើម្បីសម្រួលដល់លំហូរសាច់ប្រាក់ ខណៈដែលធនាគារជាតិបានណែនាំឱ្យធនាគារពាណិជ្ជ (និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ) ឲ្យកែសម្រួលកាលវិភាគសងប្រាក់សម្រាប់អ្នកខ្ចីដែលរងផលប៉ះពាល់ធ្ងន់ធ្ងរ ដូចជា ភោជនីយដ្ឋាន សណ្ឋាគារ ផ្ទះសំណាក់ ហាងលក់ភេសជ្ជៈ[13]។ល។ ក្រៅពីនេះ មានកិច្ចខិតខំប្រឹងប្រែងជាច្រើនក្នុងការស្តារភាពទាក់ទាញនៃប្រាង្គប្រាសាទបុរាណ ដោយមានការអភិរក្ស និងស្តារប្រាង្គប្រាសាទឡើងវិញ និងការស្តារហេដ្ឋារចនាសម្ព័ន្ធរបវ័ន្ត ដូចជាគម្រោងបង្កើនសោភណ្ឌភាព ដើម្បីធ្វើឱ្យបរិយាកាសជុំវិញប្រាង្គប្រាសាទមានសម្រស់ខៀវស្រងាត់ និងមានការរៀបចំឲ្យកាន់តែល្អ[14]។ អាជ្ញាធរកម្ពុជាក៏កំពុងសិក្សាផែនការមេសម្រាប់វិស័យ ទេសចរណ៍នៅខេត្តសៀមរាបទាំងមូល និងបានរកឃើញផលិតផលទេសចរណ៍ថ្មីៗដែលមានសក្តានុពល ជាពិសេសនៅភ្នំគូលែន តំបន់ទន្លេសាប និងតំបន់ដែលស្ថិតក្នុងប្រាង្គប្រាសាទអង្គរវត្ត។

### ជំងឺកូវីដ 19 បានធ្វើឲ្យមានការប៉ះទង្គិចលើតម្រូវការនាំចេញដែលមិនធ្លាប់មាន

**ការប៉ះទង្គិចលើតម្រូវការនាំចេញដែលមិនធ្លាប់មាន បានបណ្តាលឱ្យមានការលុបចោលការបញ្ជាទិញភាគច្រើននៃផលិតផលសម្លៀកបំពាក់ ស្បែកជើង និងទំនិញធ្វើដំណើរពីប្រទេសគោលដៅធំៗពីរ គឺសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប។** ក្រៅពីនេះ សហភាពអឺរ៉ុបបានប្រកាសពីការព្យួរការអនុគ្រោះពន្ធ និងដាក់ជំនួសដោយការដាក់ពន្ធស្តង់ដារសហភាពអឺរ៉ុប (ប្រជាជាតិដែលទទួលបានការអនុគ្រោះបំផុត) ដែលនឹងធ្វើឱ្យប៉ះពាល់ដល់ផលិតផលសម្លៀកបំពាក់ និងស្បែកជើងមួយចំនួន ព្រមទាំងទំនិញធ្វើដំណើរ និងផលិតផលស្ករទាំងអស់ ដែលមានទំហំទឹកប្រាក់ប្រមាណ 1 ពាន់លានដុល្លារ ឬស្មើនឹង 1/5 នៃការនាំចេញប្រចាំឆ្នាំរបស់កម្ពុជាទៅកាន់សហភាពអឺរ៉ុប[15]។

**ព័ត៌មានថ្មីៗពីឧស្សាហកម្មកាត់ដេរ និងស្បែកជើងបង្ហាញថារោងចក្រភាគច្រើននឹងទទួលបានការបញ្ជាទិញតិចតួចក្រោយ**

**រូប 5 ៖ ទីផ្សារជាគោលដៅនៃការនាំចេញសម្លៀកបំពាក់ ស្បែកជើង និងទំនិញធ្វើដំណើរ**

(ការប្រែប្រួលជាភាគរយធៀបនឹងឆ្នាំមុន)




*ប្រភព ៖ អាជ្ញាធរកម្ពុជា*

**រូប 6 ៖ ទំនិញនាំចេញសំខាន់របស់កម្ពុជា តាមប្រភេទទីផ្សារគោលដៅធំៗ**

(ចំណែកជាភាគរយ)




*ប្រភព ៖ អាជ្ញាធរកម្ពុជា*

13 សារាចរណែនាំរបស់ធនាគារជាតិនៃកម្ពុជាចុះថ្ងៃទី 27 ខែ មីនា ឆ្នាំ 2020 ស្តីពីការកែសម្រួលរចនាសម្ព័ន្ធឥណទានក្នុងអំឡុងពេលវិបត្តិជំងឺកូវីដ ១៩។

14 សូមមើល គេហទំព័ររបស់អាជ្ញាធរអប្សរា ៖ http://apsaraauthority.gov.kh/?page=front&lg=en។

15 សម្រាប់ព័ត៌មានលម្អិត សូមចូលទៅកាន់ ៖ https://trade.ec.europa.eu/doclib/press/index.cfm?id=2113។

**ឆមាសទីមួយក្នុងឆ្នាំ 2020 នេះ ដោយសារតែការបញ្ជាទិញមួយចំនួនត្រូវបានផ្អាក ឬលុបចោល។** ជាលទ្ធផល រោងចក្រសម្លៀកបំពាក់ និងស្បែកជើងចំនួន 130 រោងចក្រ (12 ភាគរយនៃចំនួនរោងចក្រសរុប) បានផ្អាកដំណើរការ ដោយផ្នែក ឬទាំងស្រុង ចាប់តាំងពីពាក់កណ្តាលខែ មេសា ឆ្នាំ 2020 និងធ្វើឱ្យកម្មករជិត 100,000 នាក់បាត់បង់ការងារ[16]។ ទិន្នន័យផ្លូវការបង្ហាញថា នៅខែ កុម្ភៈ ឆ្នាំ 2020 រោងចក្រដែលផលិតសម្លៀកបំពាក់ ស្បែកជើង និងទំនិញធ្វើដំណើរ សម្រាប់ការនាំចេញមានចំនួន 1,087 រោងចក្រ និងផ្តល់ការងារដល់កម្មករចំនួន 941,000 នាក់ដែលមានចំនួន 21 ភាគរយនៃការងារទទួលបានប្រាក់កម្រៃ 17 ភាគរយនៃការងារក្រៅពីកសិកម្ម និង 10.7 ភាគរយនៃការងារសរុប[17]។ វិស័យឧស្សាហកម្មផលិតសម្រាប់ការនាំចេញជាផ្លូវការគឺជាប្រភពចំណូលដ៏សំខាន់របស់រដ្ឋាភិបាល ជាពិសេសសម្រាប់ចំណូលផ្ទាល់។ វិស័យនេះជាឧស្សាហកម្មដែលផ្តល់ការងារជាផ្លូវការ និងជាការងារទទួលបានប្រាក់កម្រៃច្រើនជាងគេក្នុងសេដ្ឋកិច្ចកម្ពុជា ទោះបីជាវិស័យនេះឈរនៅលំដាប់ទី 3 បើគិតពីការរួមចំណែកដល់កំណើនសេដ្ឋកិច្ចពិតក្តី (ប្រមាណ 17 ភាគរយនៃកំណើន ផសស ពិត នៅឆ្នាំ 2019)។

### កំណើននៃការនាំចេញសម្លៀកបំពាក់ ស្បែកជើង និងទំនិញធ្វើដំណើរ បានថយចុះយ៉ាងខ្លាំងនៅត្រីមាសទីមួយក្នុងឆ្នាំ 2020

**ដោយសារតែការផ្ទុះជំងឺកូវីដ 19 ទូទាំងពិភពលោក ការនាំចេញសម្លៀកបំពាក់ ស្បែកជើង និងទំនិញធ្វើដំណើរ មានកំណើនតែ 7.5 ភាគរយប៉ុណ្ណោះនៅត្រីមាសទីមួយក្នុងឆ្នាំ 2020 នេះ ថយចុះពីកំណើន 17.7 ភាគរយនៅឆ្នាំ 2019។** មុនការផ្ទុះជំងឺកូវីដ 19 កំណើននៃការនាំចេញសម្លៀកបំពាក់ ស្បែកជើង និងទំនិញធ្វើដំណើរសរុប បានថយចុះមកត្រឹម 13.6 ភាគរយ នៅឆ្នាំ 2019 ថយចុះពីកំណើន 17.7 ភាគរយនៅឆ្នាំ 2018។ ការថយចុះនេះបណ្តាលមកពីការថយចុះនៃការនាំចេញសម្លៀកបំពាក់ ស្បែកជើង និងទំនិញធ្វើដំណើរសរុប ទៅកាន់ទីផ្សារសហភាពអឺរ៉ុប (មិនរាប់បញ្ចូលការនាំចេញទៅចក្រភពអង់គ្លេស) ចំនួន 0.5 ភាគរយ (រូប 5) ដែលជាការថយចុះលើកដំបូងចាប់តាំងពីមានវិបត្តិហិរញ្ញវត្ថុសកលនៅឆ្នាំ 2008-2009។ កំណើននៃការនាំចេញទៅកាន់ទីផ្សារសហរដ្ឋអាមេរិកបានជួយបំពេញមួយផ្នែកដល់ការថយចុះនៃការនាំចេញទៅកាន់ទីផ្សារសហភាពអឺរ៉ុប។

### ការនាំចេញទំនិញធ្វើដំណើរ (និងផលិតផលវាយនភណ្ឌផ្សេងទៀត) មានចំនួនច្រើនជាងការនាំចេញស្បែកជើងនៅឆ្នាំ 2019

**ការនាំចេញទំនិញធ្វើដំណើរសរុបរបស់កម្ពុជា (និងផលិតផលវាយនភណ្ឌផ្សេងទៀត) បានកើនឡើងយ៉ាងលឿន** ដែលមានទឹកប្រាក់សរុបចំនួន 1.29 ពាន់លានដុល្លារអាមេរិក (កើន 96.3 ភាគរយ) នៅឆ្នាំ 2019 ដែលកើនឡើងលើសការនាំចេញស្បែកជើងសរុប ដែលមានចំនួនទឹកប្រាក់ចំនួន 1.26 ពាន់លានដុល្លារអាមេរិក (កំណើន 21.6 ភាគរយ)។ ការកើនឡើងយ៉ាងឆាប់រហ័សនៃការនាំចេញទំនិញធ្វើដំណើរ បណ្តាលមកពីការអនុគ្រោះពន្ធលើការនាំចូលទៅកាន់ទីផ្សារសហរដ្ឋអាមេរិក ដែលបានផ្តល់ជូនកម្ពុជានៅឆ្នាំ 2016។

### សហរដ្ឋអាមេរិកបានក្លាយជាទីផ្សារធំជាងគេសម្រាប់ការនាំចេញសម្លៀកបំពាក់ ទំនិញធ្វើដំណើរ និងស្បែកជើងរបស់កម្ពុជា

**បច្ចុប្បន្ន សហរដ្ឋអាមេរិកជាទីផ្សារធំជាងគេសម្រាប់ការនាំចេញសម្លៀកបំពាក់ ទំនិញធ្វើដំណើរ និងស្បែកជើងរបស់កម្ពុជា។** នៅឆ្នាំ 2019 ចំណែកនៃទីផ្សារសហរដ្ឋអាមេរិកបានកើនដល់

**រូប 7 ៖ ផលិតផលសំខាន់ៗរបស់កម្ពុជាដែលនាំចេញទៅកាន់ទីផ្សារសហរដ្ឋអាមេរិក**

(ចំណែកជាភាគរយ)




*ប្រភព* ៖ អាជ្ញាធរកម្ពុជា

*សម្គាល់* ៖ (1) ទំនិញធ្វើដំណើរ និងផលិតផលវាយនភណ្ឌផ្សេងទៀត

**រូប 8 ៖ ផលិតផលសំខាន់ៗរបស់កម្ពុជាដែលនាំចេញទៅកាន់ទីផ្សារសហភាពអឺរ៉ុប**

(ចំណែកជាភាគរយ)




*ប្រភព* ៖ អាជ្ញាធរកម្ពុជា

*សម្គាល់* ៖ (1) ទំនិញធ្វើដំណើរ និងផលិតផលវាយនភណ្ឌផ្សេងទៀត

16 សន្និសីទប្រកាសព័ត៌មានផ្លូវការ ថ្ងៃទី 27 ខែ មេសា ឆ្នាំ 2020 ស្តីពីការធ្វើចត្តាឡីស័កកម្មកររោងចក្រកាត់ដេរដែលវិលត្រឡប់មកវិញ ដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

17 របាយការណ៍ខែ កុម្ភៈ ឆ្នាំ 2020 ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

31.8 ភាគរយ (រូប 6)។ ទីផ្សារសហភាពអឺរ៉ុប (មិនរាប់បញ្ចូលចក្រភពអង់គ្លេស) ឈរនៅលំដាប់ទីពីរ មានចំណែកទីផ្សារចំនួន 30.1 ភាគរយនៃទីផ្សារនាំចេញសរុប។ ដូចបង្ហាញក្នុងរូប 5 ការនាំចេញផលិតផលសម្លៀកបំពាក់ ទំនិញធ្វើដំណើរ និងស្បែកជើង ទៅកាន់ទីផ្សារសហរដ្ឋអាមេរិកកើនដល់ 38.1 ភាគរយធៀបនឹងឆ្នាំមុន នៅឆ្នាំ 2019 កើនពីចំនួន 29.1 ភាគរយនៅឆ្នាំ 2018។ ការបែងចែកទិន្នន័យនៃនាំចេញទៅកាន់ទីផ្សារសហរដ្ឋអាមេរិក បង្ហាញថា ការនាំចេញសម្លៀកបំពាក់នៅតែមានកំណើនកាលពីឆ្នាំមុន ក្រោមទំហំទឹកប្រាក់ 2.3 ពាន់លានដុល្លារអាមេរិក ឬស្មើនឹងកំណើន 16.8 ភាគរយ។ ក្រោមការអនុគ្រោះមិនយកពន្ធ និងមិនកំណត់កូតា ការនាំចេញទំនិញធ្វើដំណើរ (និងផលិតផលវាយនភណ្ឌផ្សេងទៀត) កើនឡើងយ៉ាងខ្លាំង និងបានក្លាយជាផលិតផលនាំចេញធំជាងគេទីពីរ (ដែលមានទំហំទឹកប្រាក់ 860 លានដុល្លារអាមេរិកនៅឆ្នាំ 2019 ឬស្មើនឹងកំណើន 143.5 ភាគរយ) បន្ទាប់ពីសម្លៀកបំពាក់។ ការនាំចេញផលិតផលស្បែកជើង ឈរនៅលំដាប់ទីបី ក្រោមទំហំទឹកប្រាក់ 300 លានដុល្លារអាមេរិក ឬស្មើនឹងកំណើន 60.1 ភាគរយនៅឆ្នាំ 2019។ ក្នុងទីផ្សារសហរដ្ឋអាមេរិក ចំណែកនៃការនាំចេញសម្លៀកបំពាក់បានថយចុះមកត្រឹម 60 ភាគរយ នៅខែ មករា ឆ្នាំ 2020 ចុះពីចំណែក 88.6 ភាគរយនៅខែ មករា ឆ្នាំ 2017 ដែលមួយផ្នែកធំបណ្តាលមកពីកំណើននៃការនាំចេញទំនិញធ្វើដំណើរ (រូប 7)។ ក្នុងបរិបទនេះ ចំណែកនៃទំនិញធ្វើដំណើរ (និងការនាំចេញផលិតផលវាយនភណ្ឌផ្សេងទៀត) កើនឡើងចំនួន 29 ភាគរយ កើនពីចំនួន 3.6 ភាគរយក្នុងអំឡុងពេលដូចគ្នា។

### ការនាំចេញសម្លៀកបំពាក់ទៅកាន់ទីផ្សារសហភាពអឺរ៉ុប បានថយចុះជាលើកដំបូងចាប់តាំងពីពេលមានវិបត្តិហិរញ្ញវត្ថុសកលនៅអំឡុងឆ្នាំ 2008-09

**ការបែងចែកការនាំចេញរបស់កម្ពុជាទៅកាន់ទីផ្សារសហភាពអឺរ៉ុប (មិនរាប់បញ្ចូលចក្រភពអង់គ្លេស) បង្ហាញថា នៅឆ្នាំ 2019 ការនាំចេញសម្លៀកបំពាក់ បានថយចុះចំនួន 0.7 ភាគរយ ដោយមានទឹកប្រាក់សរុបចំនួន 2.61 ពាន់លានដុល្លារអាមេរិក** ថយចុះពីទឹកប្រាក់ចំនួន 2.63 ពាន់លានដុល្លារអាមេរិកនៅឆ្នាំ 2018។ នេះជាការថយចុះលើកដំបូងចាប់តាំងពីពេលមានវិបត្តិហិរញ្ញវត្ថុសកលឆ្នាំ 2008-09។ ផ្ទុយទៅវិញ ការនាំចេញស្បែកជើងទៅកាន់ទីផ្សារសហភាពអឺរ៉ុបនៅតែមានភាពរឹងមាំ ដោយមានទឹកប្រាក់សរុបចំនួន 478.8 លានដុល្លារអាមេរិក ហើយមានកំណើន 19.7 ភាគរយ។ ជាលទ្ធផល ចំណែកនៃការនាំចេញសម្លៀកបំពាក់ថយចុះមកត្រឹម 78 ភាគរយនៅខែ មករា ឆ្នាំ 2020 ថយពីចំនួន 84.4 ភាគរយនៅខែ មករា ឆ្នាំ 2017 (រូប 8)។ ការនាំចេញទំនិញធ្វើដំណើររបស់កម្ពុជាទៅកាន់ទីផ្សារសហភាពអឺរ៉ុបនៅតែមានចំនួនតិចជាង ដោយមានទឹកប្រាក់សរុបចំនួន 155.5 លានដុល្លារអាមេរិក (ស្មើនឹង 18 ភាគរយនៃការនាំចេញទំនិញនេះទៅកាន់ទីផ្សារសហរដ្ឋអាមេរិក)។ ចំណែកនៃទីផ្សារសហរដ្ឋអាមេរិក និងទីផ្សារសហភាពអឺរ៉ុបបញ្ចូលគ្នាស្ទើរតែស្មើនឹងការនាំចេញទំនិញធ្វើដំណើរទាំងអស់ពីកម្ពុជា ខណៈដែលការនាំចេញសម្លៀកបំពាក់ និងស្បែកជើងរបស់កម្ពុជាទៅកាន់ទីផ្សារសហភាពអឺរ៉ុប មានចំនួន 15 ភាគរយច្រើនជាងការនាំចេញសម្លៀកបំពាក់ទៅកាន់ទីផ្សារសហរដ្ឋអាមេរិក និង 60 ភាគរយច្រើនជាងការនាំចេញស្បែកជើងទៅកាន់ទីផ្សារសហរដ្ឋអាមេរិក។

### ទីផ្សារជប៉ុនហាក់មានភាពល្អប្រសើរសម្រាប់ការនាំចេញគ្រឿងបន្លាស់អេឡិចត្រូនិក គ្រឿងបន្លាស់យានយន្ត និងគ្រឿងបង្គុំរបស់កម្ពុជា

**ទីផ្សារធំជាងគេពីរបន្ទាប់សម្រាប់ការនាំចេញរបស់កម្ពុជានៅឆ្នាំ 2019 គឺប្រទេសជប៉ុន (1.05 ពាន់លានដុល្លារអាមេរិក) និងចក្រភពអង់គ្លេស ( 945 លានដុល្លារអាមេរិក)។** នៅខណៈ

**រូប 9 ៖ កំណើននៃការនាំចេញគ្រឿងបន្លាស់អេឡិចត្រូនិក គ្រឿងបន្លាស់យានយន្ត និងគ្រឿងបង្គុំរបស់កម្ពុជាទៅកាន់ប្រទេសជប៉ុន**

(លានដុល្លារអាមេរិក)




*ប្រភព* ៖ អាជ្ញាធរកម្ពុជា

**រូប ១០ ៖ ផលិតផលសំខាន់ៗរបស់កម្ពុជាដែលនាំចេញទៅកាន់ទីផ្សារចក្រភពអង់គ្លេស**

(ឆ្នាំនេះ, ការប្រែប្រួលជាភាគរយធៀបនឹងឆ្នាំមុន)




*ប្រភព* ៖ អាជ្ញាធរកម្ពុជា

ដែលទីផ្សារទាំងពីរនេះមានចំណែកប្រហាក់ប្រហែលគ្នាសម្រាប់ការនាំចេញសម្លៀកបំពាក់របស់កម្ពុជាក្នុងទំហំទឹកប្រាក់ប្រមាណ 800 លានដុល្លារអាមេរិក ជប៉ុនហាក់ជាទីផ្សារល្អប្រសើរសម្រាប់ការនាំចេញគ្រឿងបន្លាស់អេឡិចត្រូនិក គ្រឿងបន្លាស់យានយន្ត និងគ្រឿងបង្គុំរបស់កម្ពុជា (រូប 9)។ ការនាំចេញគ្រឿងបន្លាស់អេឡិចត្រូនិក និងគ្រឿងបន្លាស់យានយន្ត និងគ្រឿងបង្គុំរបស់កម្ពុជា ទៅកាន់ប្រទេសជប៉ុន មានទំហំទឹកប្រាក់ 77.8 លានដុល្លារអាមេរិកនៅឆ្នាំ 2019 កើនពី 39.4 លានដុល្លារអាមេរិកនៅឆ្នាំ 2018។ កម្ពុជាគួរជំរុញផ្នែកនេះបន្ថែមទៀតដើម្បីធ្វើពិពិធកម្មការនាំចេញឲ្យលើសពីសម្លៀកបំពាក់។

**ផ្ទុយទៅវិញ ការនាំចេញកង់ទៅកាន់ទីផ្សារចក្រភពអង់គ្លេសបានថយចុះកាលពីឆ្នាំមុន។** ការនាំចេញសម្លៀកបំពាក់ ស្បែកជើង កង់ និងទំនិញធ្វើដំណើរសរុបរបស់កម្ពុជាទៅចក្រភពអង់គ្លេស បានថយចុះតាំងពីដើមឆ្នាំ 2019 ហើយនៅបំណាច់ឆ្នាំ 2019 ការនាំចេញបានថយចុះចំនួន 12.6 ភាគរយធៀបនឹងឆ្នាំមុន (រូប 10) ដោយមានទឹកប្រាក់សរុប 950 លានដុល្លារអាមេរិក។ ចក្រភពអង់គ្លេសបានចាកចេញពីសហភាពអឺរ៉ុបនៅថ្ងៃទី 31 ខែ មករា ឆ្នាំ 2020[18]។ ក្នុងស្ថានភាពនេះ កម្ពុជាអាចនឹងត្រូវចរចាជាមួយចក្រភពអង់គ្លេសដើម្បីបញ្ជាក់ថា ក្រោយពីចាកចេញពីសហភាពអឺរ៉ុប ចក្រភពអង់គ្លេសនៅតែបន្តផ្តល់ការអនុគ្រោះពន្ធដល់ការនាំចូលរបស់កម្ពុជា ដូចដែលបានអនុវត្តនាកន្លងមក ក្រោមប្រព័ន្ធ "អ្វីគ្រប់យ៉ាង លើកលែងតែអាវុធ"។

### បរិមាណទឹកប្រាក់នៃគម្រោងវិនិយោគផ្ទាល់ពីបរទេសដែលត្រូវបានអនុម័ត ថយចុះចំនួន 52.2 ភាគរយក្នុងរយៈពេលពីរខែដំបូងក្នុងឆ្នាំ 2020

**បរិមាណទឹកប្រាក់នៃគម្រោងវិនិយោគផ្ទាល់ពីបរទេសដែលត្រូវបានអនុម័ត បានថយចុះក្នុងរយៈពេលពីរខែដំបូងក្នុងឆ្នាំ 2020។** នៅឆ្នាំ 2019 បរិមាណទឹកប្រាក់នៃគម្រោងវិនិយោគផ្ទាល់ពីបរទេសដែលត្រូវបានអនុម័ត បានថយចុះចំនួន 9.6 ភាគរយ (ធៀបនឹងឆ្នាំមុន)។ ក្នុងបរិមាណទឹកប្រាក់សរុបនៃគម្រោងវិនិយោគផ្ទាល់ពីបរទេសដែលត្រូវបានអនុម័ត ដែលមានទឹកប្រាក់ 3.5 ពាន់លានដុល្លារអាមេរិក នៅឆ្នាំ 2019 គម្រោងវិនិយោគផ្ទាល់ពីបរទេសដែលត្រូវបានអនុម័តប្រមាណ 43 ភាគរយ មានប្រភពពីប្រទេសចិន ដែលនៅតែជាប្រភពធំជាងគេនៃការវិនិយោគផ្ទាល់ពីបរទេស (រូប 11)។ បើទោះជាក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ លំហូរចូលភាគច្រើននៃការវិនិយោគផ្ទាល់ពីបរទេសមានប្រភពពីតំបន់អាស៊ីបូព៌ា កាលពីឆ្នាំមុនបរិមាណទឹកប្រាក់នៃគម្រោងវិនិយោគផ្ទាល់ពីបរទេសដែលត្រូវបានអនុម័តច្រើនជាងគេទីពីរ មានប្រភពពីចក្រភពអង់គ្លេស ដែលមានចំនួន 23.6 ភាគរយនៃបរិមាណទឹកប្រាក់គម្រោងសរុប។ បន្ទាប់មកគឺតំបន់រដ្ឋបាលពិសេស ហុង កុង របស់ចិន ដែលមានចំនួន 20.4 ភាគរយនៃបរិមាណទឹកប្រាក់គម្រោងសរុប។

### ភាគច្រើននៃការវិនិយោគផ្ទាល់ពីបរទេសដែលត្រូវបានអនុម័ត នៅបន្តផ្តោតលើវិស័យសំណង់ និងអចលនទ្រព្យ

**នៅឆ្នាំ 2019 វិស័យសំណង់ និងអចលនទ្រព្យ ទទួលបានចំណែកច្រើនជាងគេនៃគម្រោងវិនិយោគផ្ទាល់ពីបរទេសដែលត្រូវបានអនុម័តសរុប ដែលមានចំនួន 51 ភាគរយ។** ទេសចរណ៍ជាវិស័យដែលទទួលបានចំណែកច្រើនទីពីរនៃបរិមាណទឹកប្រាក់នៃគម្រោងវិនិយោគផ្ទាល់ពីបរទេសដែលត្រូវបានអនុម័តសរុប ដែលមានចំនួន 24 ភាគរយ (ភាគច្រើនជាការវិនិយោគលើសកម្មភាពសំណង់ ដូចជា សំណង់សណ្ឋាគារ និងរមណីយដ្ឋាន)។ កម្មន្តសាលជាវិស័យដែលទទួលបានចំណែកច្រើនទីបីនៃបរិមាណទឹកប្រាក់គម្រោងវិនិយោគផ្ទាល់ពីបរទេសដែលត្រូវបានអនុម័តសរុប ដែលមានចំនួន 16 ភាគរយ (សម្លៀកបំពាក់ ស្បែកជើង និងទំនិញធ្វើដំណើរ) (រូប 12)។ ការវិនិយោគនៅតែបន្តពឹងផ្អែកលើវិស័យក្រៅពីផ្នែកពាណិជ្ជកម្ម ដោយសារតែវិស័យនាំ

**រូប 11 ៖ ការវិនិយោគផ្ទាល់ពីបរទេសដែលត្រូវបានអនុម័ត តាមប្រទេសប្រភព**

(ចំណែកជាភាគរយ 2019)




*ប្រភព* ៖ អាជ្ញាធរកម្ពុជា និងការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក

**រូប 12 ៖ បរិមាណទឹកប្រាក់នៃគម្រោងការវិនិយោគផ្ទាល់ពីបរទេសដែលត្រូវបានអនុម័ត**

(ភាគរយនៃចំនួនសរុប 2019)




*ប្រភព* ៖ អាជ្ញាធរកម្ពុជា និងការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក

18 សូមមើល https://ec.europa.eu/info/european-union-and-united-kingdom-forging-new-partnership_en.

ចេញ (លើកលែងតែឧស្សាហកម្មសម្លៀកបំពាក់ ស្បែកជើង និងទំនិញធ្វើដំណើរ) នៅតែមិនសូវមានភាពទាក់ទាញ។ ចំណុចនេះបង្ហាញថា ចាំបាច់ត្រូវមានកិច្ចខិតខំប្រឹងប្រែងកាន់តែខ្លាំងក្នុងការបង្កើនភាពប្រកួតប្រជែងរបស់កម្ពុជាក្រៅពីឧស្សាហកម្មសម្លៀកបំពាក់ និងស្បែកជើង។

### នៅដើមឆ្នាំ 2020 សកម្មភាពសាងសង់បានថយចុះយ៉ាងខ្លាំង ដោយសារការផ្ទុះជំងឺកូវីដ 19 ទូទាំងពិភពលោក

**ដោយសារតែការថយចុះនៃការនាំចូលសម្ភារសំណង់ ជាពិសេសការនាំចូលដែកថែប សកម្មភាពសំណង់ត្រូវបានរំពឹងថានឹងថយចុះយ៉ាងខ្លាំង។** ការនាំចូលដែកថែប ដែលត្រូវបានប្រើប្រាស់ភាគច្រើនក្នុងវិស័យសំណង់ បានថយចុះចំនួន 47.6 ភាគរយ (ធៀបនឹងឆ្នាំមុន) ក្នុងរយៈពេលបីខែដំបូងក្នុងឆ្នាំ 2020 ខណៈដែលបរិមាណទឹកប្រាក់នៃគម្រោងវិនិយោគផ្ទាល់ពីបរទេសដែលត្រូវបានអនុម័ត ដែលផ្តោតលើវិស័យសំណង់ (និងទេសចរណ៍) បានថយចុះចំនួន 40.2 ភាគរយក្នុងអំឡុងពេលដូចគ្នានេះ។ នៅឆ្នាំ 2019 បរិមាណទឹកប្រាក់សរុបនៃការនាំចូលដែកថែប ស៊ីម៉ង់ត៍ និងសម្ភារសំណង់សំខាន់ៗផ្សេងទៀត បានថយចុះមកត្រឹម 730 ពាន់លានរៀល (179 លានដុល្លារអាមេរិក) ចុះពី 830 ពាន់លានរៀល (204 លានដុល្លារអាមេរិក) នៅឆ្នាំ 2018 (រូប 13)។ ផ្ទុយទៅវិញ បរិមាណទឹកប្រាក់សំណង់ដែលត្រូវបានអនុម័ត បានកើនឡើងច្រើនបំផុត រហូតដល់ 11.4 ពាន់លានដុល្លារអាមេរិក (4,793 គម្រោង) នៅឆ្នាំ 2019 កើនពី 5.7 ពាន់លានដុល្លារអាមេរិក (3,294 គម្រោង) (រូប 14) នៅឆ្នាំ 2018 ដែលបង្ហាញពីការបន្តយកចិត្តទុកដាក់ខ្លាំងនៃការវិនិយោគនេះ។ នៅរយៈពេលពីរខែដំបូងក្នុងឆ្នាំ 2020 បរិមាណទឹកប្រាក់សំណង់ដែលត្រូវបានអនុម័ត និងទំហំផ្ទៃដី បានកើនឡើងចំនួន 46 ភាគរយសម្រាប់បរិមាណទឹកប្រាក់ និង 33 ភាគរយសម្រាប់ទំហំផ្ទៃដី ដែលបង្ហាញពីកំណើននៃការវិនិយោគលើអគារពាណិជ្ជកម្មប្រណិតៗ និងអគារលំនៅដ្ឋាន។

**ការថយចុះនៃវិស័យសំណង់ និងអចលនទ្រព្យ បានធ្វើឱ្យកំណើនសេដ្ឋកិច្ចថយតូចខ្លាំង។** វិស័យ សំណង់ (និងអចលនទ្រព្យ) បានក្លាយជាក្បាលម៉ាស៊ីនជំរុញសេដ្ឋកិច្ចធំជាងគេក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ។ នៅឆ្នាំ 2019 វិស័យសំណង់ និងអចលនទ្រព្យ រួមចំណែកជាង 1/3 នៃកំណើន ផសស។ វិស័យសំណង់ និងវិស័យនាំចេញ គឺជាប្រភពចំណូលដ៏សំខាន់របស់រដ្ឋាភិបាល តាមរយៈពន្ធប្រយោល និងពន្ធពាណិជ្ជកម្មអន្តរជាតិ។ ថ្មីៗនេះ ឧស្សាហកម្មសំណង់ទទួលបានហិរញ្ញប្បទានកាន់តែច្រើនពីលំហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេស។ តាមការប៉ាន់ស្មាន កម្ពុជាទទួលបានលំហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេសចំនួន 40 ភាគរយពីប្រទេសចិន ហើយលំហូរចូលភាគច្រើនផ្តោតលើវិស័យសំណង់។ សកម្មភាពសំណង់ថយចុះយ៉ាងខ្លាំងក្រោយពីមានការផ្អាកគម្រោងអភិវឌ្ឍន៍ធំៗ ដែលទទួលបានហិរញ្ញប្បទានពីលំហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេសដែលកំពុងអាក់ខានដោយសារការផ្ទុះជំងឺកូវីដ 19 ជាសកល។

**ការថយចុះនៃវិស័យសំណង់ និងអចលនទ្រព្យ អាចមានផលប៉ះពាល់តិចតួចដល់ការងារ ដោយសារតែកំណើនវិស័យសំណង់ក្នុងរយៈពេលថ្មីៗនេះភាគច្រើនជាសំណង់អគារប្រណិតខ្ពស់ៗ និងប្រើប្រាស់ដើមទុនច្រើន។** ខុសពីវិស័យសម្លៀកបំពាក់ ស្បែកជើង និងទំនិញធ្វើដំណើរ វិស័យសំណង់ (និងអចលនទ្រព្យ) ផ្តល់ការងារត្រឹមតែ 200,000 ប៉ុណ្ណោះ។ ដូច្នេះ ការថយចុះនៃវិស័យសំណង់បានបង្កផលប៉ះពាល់តិចជាងលើផ្នែកសង្គម។

**ជាផ្នែកមួយនៃការឆ្លើយតបទៅនឹងជំងឺកូវីដ 19 អាជ្ញាធរកម្ពុជាបានលើកលែងពន្ធផ្ទេរកម្មសិទ្ធិសម្រាប់ទ្រព្យសម្បត្តិដែលមានតម្លៃមិនលើសពី 70,000 ដុល្លារអាមេរិក[19]។** ទោះជាយ៉ាងណា ការផ្ទុះជំងឺកូវីដ 19 បានធ្វើឲ្យមានការប៉ះពាល់ផ្នែកតម្រូវការដែលមិនធ្លាប់មាន នៅខណៈដែលទីផ្សារទ្រព្យសម្បត្តិបានឈានដល់កម្រិតលែងឡើង បន្ទាប់ពីមានកំណើនខ្លាំងនៃវិស័យសំណង់ និងអចលនទ្រព្យក្នុងរយៈពេលជិតមួយទសវត្សរ៍កន្លងមក។

**រូប 13 ៖ ការនាំចូលសម្ភារសាងសង់សំខាន់ៗ**

(ពាន់លានរៀល)




*ប្រភព* ៖ អាជ្ញាធរកម្ពុជា

**រូប 14 ៖ អាជ្ញាប័ណ្ណសាងសង់ដែលត្រូវបានអនុញ្ញាត**

(លានដុល្លារអាមេរិក)




*ប្រភព* ៖ អាជ្ញាធរកម្ពុជា

19 លិខិតលេខ 1313 របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ថ្ងៃទី 25 ខែ កុម្ភៈ ឆ្នាំ 2020។

### ការផ្ទុះជំងឺកូវីដ 19 ជាសកល បានធ្វើឱ្យអាក់ខានដល់តម្រូវការ និងការប្រើប្រាស់ក្នុងស្រុក

**ការនាំចូលទំនិញបរិភោគ និងទំនិញប្រើប្រាស់ បានថយចុះនៅដើមឆ្នាំ 2020។** នៅក្នុងត្រីមាសទីមួយក្នុងឆ្នាំ 2020 ការនាំចូលគ្រឿងឧបភោគបរិភោគ និងម៉ូតូ បានថយចុះចំនួន 11.4 ភាគរយសម្រាប់គ្រឿងឧបភោគបរិភោគ និង 3.8 ភាគរយសម្រាប់ម៉ូតូ។ ស្របទៅនឹងការថយចុះនៃឧស្សាហកម្មផ្នែកធ្វើដំណើរ និងទេសចរណ៍ ការនាំចូលរថយន្តក្រុង ប្រេងឥន្ធនៈយន្តហោះ និងប្រេងឥន្ធនៈ បានថយចុះចំនួន 17.8 ភាគរយសម្រាប់រថយន្តក្រុង 40.7 ភាគរយសម្រាប់ប្រេងឥន្ធនៈយន្តហោះ និង 22.3 ភាគរយសម្រាប់ប្រេងឥន្ធនៈ។ នៅឆ្នាំ 2019 តម្រូវការទំនិញបរិភោគ ដូចជា គ្រឿងឧបភោគបរិភោគ និងផលិតផលប្រេងកាត មានការកើនឡើង ប៉ុន្តែ តម្រូវការទំនិញប្រើប្រាស់បានថយចុះ។ នៅឆ្នាំ 2019 ការនាំចេញប្រេងសាំង និងប្រេងម៉ាស៊ូត កើនចំនួន 49.4 ភាគរយសម្រាប់ប្រេងសាំង និង 65.3 ភាគរយសម្រាប់ប្រេងម៉ាស៊ូត។ ទន្ទឹមនឹងនេះដែរ ការនាំចូលគ្រឿងឧបភោគបរិភោគ គ្រឿងអេឡិចត្រូនិក និងឱសថ បានកើនចំនួន 30.6 ភាគរយសម្រាប់គ្រឿងឧបភោគបរិភោគ 14.8 ភាគរយសម្រាប់គ្រឿងអេឡិចត្រូនិក និង 14.4 ភាគរយសម្រាប់ឱសថ។ ផ្ទុយទៅវិញ ការនាំចូលរថយន្តអ្នកដំណើរ បានថយចុះមកត្រឹម 13.9 ភាគរយនៅឆ្នាំ 2019 ចុះពី 72.7 ភាគរយនៅឆ្នាំ 2018។ ការនាំចូលម៉ូតូ ថយចុះពី 21.4 ភាគរយនៅឆ្នាំ 2018 មកត្រឹម 11.4 ភាគរយនៅឆ្នាំ 2019។

### ឱនភាពគណនីចរន្តនៅតែមានស្ថិរភាព និងទទួលបានហិរញ្ញប្បទានទាំងស្រុងពីលំហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេសកាលពីឆ្នាំមុន

**ឱនភាពគណនីចរន្តត្រូវបានប៉ាន់ស្មានថានៅតែមានចំនួន 8.8 ភាគរយនៃ ផសស ដោយសារតែទាំងការនាំចេញ និងការនាំចូលបានថយចុះបន្តិចកាលពីឆ្នាំមុន។** ដូចបានពិភាក្សាខាងលើ ការនាំចេញទំនិញសំខាន់របស់កម្ពុជា បានថយចុះនៅឆ្នាំ 2019 សំខាន់ដោយសារតែការថយចុះនៃការនាំចេញទៅកាន់ទីផ្សារសហភាពអឺរ៉ុប។ ដូចគ្នានេះដែរ ការនាំចូលទំនិញ ជាពិសេសទំនិញប្រើប្រាស់យូរ ក៏បានថយចុះផងដែរដោយសារតម្រូវការក្នុងស្រុកថយចុះ។ នៅឆ្នាំ 2019 បើទោះជាកម្ពុជាមានកំណើនយឺត ប៉ុន្តែការនាំចេញទំនិញ និងសេវាសរុប ត្រូវបានប៉ាន់ស្មានថានៅតែមានភាពរឹងមាំ ដោយមានចំនួនស្មើនឹង 61.4 ភាគរយនៃ ផសស ទាបជាងចំនួន 61.6 ភាគរយនៃ ផសស នៅឆ្នាំ 2018 ដែលក្នុងនោះ ការនាំចេញសេវា ដែលភាគច្រើនប្រមូលផ្តុំក្នុងវិស័យទេសចរណ៍ មានចំនួន 15.2 ភាគរយនៃ ផសស ដែលទាបជាងបន្តិចនៃចំនួន 15.5 ភាគរយនៃ ផសស នៅឆ្នាំ 2018។ ការនាំចូលទំនិញ និងសេវា បានថយចុះចំនួន 62.8 ភាគរយនៃ ផសស ចុះពីចំនួន 63.3 ភាគរយនៃ ផសស នៅឆ្នាំ 2018។

### លំហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេសបានថយចុះនៅឆ្នាំ 2019

**ទោះបីជានៅតែមានភាពរឹងមាំក្តី លំហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេសត្រូវបានប៉ាន់ស្មានថាបានថយចុះមកចំនួន 10.8 ភាគរយនៃ ផសស នៅឆ្នាំ 2019** ថយពីចំនួន 12.6 ភាគរយនៃ ផសស នៅឆ្នាំ 2018 ជាពេលដែលលំហូរចូលការវិនិយោគផ្ទាល់ពីបរទេសមានចំនួនខ្ពស់បំផុតនោះ។ លំហូរចូលជាបន្តបន្ទាប់នៃការវិនិយោគផ្ទាល់ពីបរទេស និងការដាក់រូបិយវត្ថុក្នុងស្រុកបានជួយឱ្យធនាគារជាតិបន្តមានកំណើនទុនបម្រុងអន្តរជាតិ ដែលមានបរិមាណ 18.7 ពាន់លានដុល្លារអាមេរិក គិតត្រឹមខែ ធ្នូ ឆ្នាំ 2019 ឬមានកំណើន 28.3 ភាគរយធៀបនឹងឆ្នាំមុន ស្មើនឹងការនាំចូលរយៈពេលជាង 7 ខែ។ កិច្ចខិតខំប្រឹងប្រែងរបស់ធនាគារជាតិក្នុងការជំរុញការប្រើប្រាស់រូបិយប័ណ្ណក្នុងស្រុក (ប្រាក់រៀលកម្ពុជា) ក្នុងសេដ្ឋកិច្ចដែលមានកម្រិតដុល្លារូបនីយកម្មខ្ពស់ បានផ្តល់ផលវិជ្ជមាន។ ចរាចរណ៍ប្រាក់រៀលបានកើនចំនួន 31.3

**រូប 15 ៖ កំណើនវិស័យកសិកម្ម**

(គិតជាតម្លៃថេរនៅឆ្នាំ 2000, ភាគរយ)




*ប្រភព ៖* អាជ្ញាធរកម្ពុជា

**រូប 16 ៖ ផ្ទៃដីដាំដុះស្រូវ និងបរិមាណផល**




*ប្រភព ៖* អាជ្ញាធរកម្ពុជា

ភាគរយ ធៀបនឹងឆ្នាំមុន នៅឆ្នាំ 2019 កើនពីចំនួន 11.5 ភាគរយនៅ ឆ្នាំ 2018 ខណៈដែលអត្រាប្តូរប្រាក់រៀល និងប្រាក់ដុល្លារអាមេរិក នៅតែមានអត្រាថេរ (សូមមើលការបរិយាយលម្អិតស្តីពីវិធានការជំរុញរូបិយវត្ថុក្នុងស្រុកក្នុងវិស័យរូបិយវត្ថុខាងក្រោម)។

**យ៉ាងណាក៏ដោយ ស្ថានភាពទុនបម្រុងអន្តរជាតិរបស់កម្ពុជាដែលដូចគ្នាទៅនឹងស្ថានភាពនៃការប្រមូលចំណូលក្នុងស្រុក ក៏ត្រូវបានព្យាករណ៍ថា នឹងថយចុះនៅឆ្នាំនេះ** ដោយសារតែវិស័យទទួលបានប្រាក់បរទេសសំខាន់ៗរបស់កម្ពុជា (ទេសចរណ៍ និងការនាំចេញ) កំពុងរងផលប៉ះពាល់យ៉ាងខ្លាំងដោយសារតែការផ្ទុះជំងឺកូវីដ 19 ខណៈដែលលំហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេសក៏ថយចុះផងដែរ។ នៅឆ្នាំ 2020 ទុនបម្រុងបរទេសរបស់កម្ពុជាត្រូវបានរំពឹងថាមានចំនួន 16.8 ពាន់លានដុល្លារអាមេរិក (ស្មើនឹងការនាំចូលរយៈពេល 6.8 ខែ) ថយចុះពីចំនួន 18.7 ពាន់លានដុល្លារអាមេរិក (ស្មើនឹងការនាំចូលរយៈពេល 7.6 ខែ)។

### ការរួមចំណែករបស់វិស័យកសិកម្មដល់កំណើន ផសស បានថយចុះនៅឆ្នាំ 2019

**ការរួមចំណែករបស់វិស័យកសិកម្មដល់កំណើន ផសស បានថយចុះជាលើកដំបូងកាលពីឆ្នាំមុន ចាប់តាំងពីឆ្នាំ 2004 មក** (រូប 15)។ ការពីប៉ុន្មានឆ្នាំកន្លងទៅនេះ វិស័យកសិកម្មបានបន្ថយល្បឿនកំណើនក្នុងរយៈពេលជាច្រើនឆ្នាំមកហើយ។ ការរួមចំណែករបស់វិស័យកសិកម្មដល់ ផសស បានលែងកើនឡើង ដោយសារតែផលិតកម្មស្រូវបានរងផលប៉ះពាល់យ៉ាងខ្លាំងដោយសារគ្រោះរាំងស្ងួតដែលបានអូសបន្លាយនៅអំឡុងឆ្នាំ 2013-2015 (រូប 16) ដែលធ្វើឱ្យកសិករកម្ពុជាជាច្រើនត្រូវធ្វើចំណាកស្រុកទៅរកការងារធ្វើនៅប្រទេសជិតខាង ជាពិសេសទៅប្រទេសថៃ ដែលផ្តល់ប្រាក់ឈ្នួលខ្ពស់ជាងកម្ពុជាជាច្រើនដង។ ដោយសារតែស្ថានភាពធាតុអាកាសល្អប្រសើរ វិស័យកសិកម្មបានចាប់ផ្តើមមានការលូតលាស់ជាថ្មីនៅអំឡុងឆ្នាំ 2016-2018។

**ផលិតកម្មដំណាំ ជាពិសេសស្រូវ នៅតែជាចំណែកភាគច្រើន (60 ភាគរយ) នៃ ផសស កសិកម្ម។** កម្ពុជាសម្រេចបានជោគជ័យតិចតួចក្នុងការធ្វើពិពិធកម្មផលិតផលកសិកម្មទៅជាដំណាំជលផល និងបសុសត្វ ដែលមានតម្លៃបន្ថែមខ្ពស់ ដោយសារតែភាពយឺតយ៉ាវក្នុងការប្រើប្រាស់បច្ចេកវិទ្យាកសិកម្មទំនើប ដូចជាការប្រើប្រាស់ជី និងធារាសាស្ត្រ[20]។ ដើម្បីរក្សាកំណើនវិស័យកសិកម្ម ចាំបាច់ត្រូវបង្កើនទិន្នផល។ ដោយសារបច្ចុប្បន្ន ទិន្នផលបច្ចុប្បន្នមានចំនួន 3.3 តោន/ហិកតា ការបង្កើនកម្រិតទិន្នផលនេះកាន់តែលំបាក ខុសពីរយៈពេលមួយទសវត្សរ៍ ឬមួយទសវត្សរ៍ជាងមុន នៅពេលដែលទិន្នផលស្រូវមានត្រឹមតែប្រមាណ 2 តោន/ហិកតា។ លើសពីនេះទៀត ការពង្រីកផ្ទៃដីដាំដុះក៏ប្រឈមនឹងបញ្ហាផងដែរ ព្រោះកម្ពុជាមិនសូវសំបូរផ្ទៃដីដាំដុះទេ។

**កិច្ចខិតខំប្រឹងប្រែងនាពេលថ្មីៗនេះជាច្រើនក្នុងការធ្វើទំនើបកម្មវិស័យកសិកម្ម បានកើនឡើង ដោយសារតែកម្ពុជាខិតខំបង្កើនផលិតភាពនៃដំណាំសំខាន់ៗរបស់ខ្លួន។** លើចំណុចនេះ មានសញ្ញាបង្ហាញថា វិស័យកសិកម្មកំពុងធ្វើទំនើបកម្មបន្តិចម្តងៗ តាមរយៈការប្រើប្រាស់បច្ចេកទេសដាំដុះជឿនលឿន និងគ្រាប់ពូជថ្មីចេញពីការអនុវត្តបច្ចេកវិទ្យាដោយមានការវិនិយោគផ្ទាល់ពីបរទេស។ ទោះបីនេះមិនទាន់អាចធ្វើការសន្និដ្ឋានបាននៅពេលនេះក្តី ផលិតផលកសិកម្មកម្ពុជាដែលបាននាំចេញ ត្រូវបានពង្រីកបន្តិចម្តងៗ ដោយមានផលិតផលថ្មីៗ ដូចជា ចេក និងស្វាយ ទៅកាន់ទីផ្សារគោលដៅក្រៅពីប្រទេសថៃ និងវៀតណាម។

**ផលិតផលស្រូវឆ្នាំនេះមិនមានភាពប្រសើរ ដោយសារតែលក្ខខណ្ឌធាតុអាកាសមិនអំណោយផល។** ការបង្កបង្កើនផលស្រូវប្រាំងឆ្នាំនេះក៏មានភាពយឺតយ៉ាវ ដូចស្រូវវស្សាដែរ[21]។ ដូច្នេះ ផលិតផលស្រូវសរុបនៅអំឡុងរដូវប្រមូលផលឆ្នាំ 2019-20 មានចំនួន 10.885 លានតោន ដែលមានចំនួនតិចជាងផលស្រូវឆ្នាំ 2018-19[22] (10.892 លានតោន) បន្តិច។ លើសពីនេះទៀត ទិន្នផលស្រូវក៏បានថយចុះចំនួន 0.5 ភាគរយ ឬស្មើនឹង 3.09 តោន/ហិកតា។

### វិស័យកសិកម្មហាក់មិនអាចស្រូបយកកម្មករនិយោជិតដែលត្រូវបានរំសាយពីការងារក្នុងវិស័យទេសចរណ៍បានច្រើនទេ

**ភាពទន់ខ្សោយនៃវិស័យកសិកម្មធ្វើឱ្យវិស័យនេះលំបាកក្នុងការស្រូបយកកម្មករនិយោជិតដែលត្រូវបានរំសាយពីវិស័យទេសចរណ៍។** ការផ្ទុះជំងឺកូវីដ 19 ជាសកលបានប៉ះពាល់យ៉ាងធ្ងន់ធ្ងរលើវិស័យសេវាកម្ម ជាពិសេសឧស្សាហកម្មបដិសណ្ឋារកិច្ច និងទេសចរណ៍ ដែលផ្តល់ការងារចំនួន 620,000 នាក់។ ឧស្សាហកម្មដឹកជញ្ជូន និងធ្វើដំណើរ ស្ទើរតែដួលរលំទៅហើយ ដោយសារតែការរឹតត្បិតការធ្វើដំណើរបរទេស និងការហាមឃាត់ការធ្វើដំណើរចេញចូលទីក្រុង ដោយសារតែការផ្ទុះជំងឺកូវីដ 19។ ការថយចុះខ្លាំងនៃវិស័យទេសចរណ៍ និងបដិសណ្ឋារកិច្ច កំពុងប៉ះពាល់លើការងារ និងប្រាក់ចំណូលរបស់កម្មករនិយោជិត និងអាជីវកម្មក្នុងឧស្សាហកម្មទេសចរណ៍ និងបដិសណ្ឋារកិច្ចនេះ។ ក្នុងស្ថានភាពនេះ អាជ្ញាធរកម្ពុជាបានប្រាក់ឧបត្ថម្ភចំនួន 40 ដុល្លារអាមេរិក/ខែ ដល់បុគ្គលិកដែលគ្មានការងារធ្វើក្នុងវិស័យទេសចរណ៍ (និងវិស័យនាំចេញ) រួមទាំងកម្មករនិយោជិតដែលធ្វើការក្នុងសណ្ឋាគារ ផ្ទះសំណាក់ និងភោជនីយដ្ឋាន និងក្រុមហ៊ុនទេសចរណ៍[23]។ វិធានការនេះអាចរួមចំណែកទប់ស្កាត់មិនឱ្យពួកគាត់ធ្លាក់ចូលក្នុងភាពក្រីក្រ។

**នៅពេលគ្មានវិធានការសំខាន់ក្នុងការកាត់បន្ថយផលប៉ះពាល់**

20 សូមមើល ធនាគារពិភពលោក ឆ្នាំ 2015a។

21 ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ 2020a។

22 ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ 2020b របាយការណ៍ប្រចាំឆ្នាំ 2019-20 ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

23 ក្រសួងទេសចរណ៍ បានប្រកាសពីការផ្តល់ទឹកប្រាក់ 2.4 លានដុល្លារអាមេរិកសម្រាប់ការឧបត្ថម្ភប្រាក់ឈ្នួលដល់កម្មករនិយោជិតប្រមាណ 30,000 នាក់ ដែលបាត់បង់ការងារ ក្នុងចំណោមកម្មករនិយោជិតជិត 630,000 នាក់ដែលធ្វើការក្នុងវិស័យទេសចរណ៍ ក្នុងកាលៈទេសៈនៃវិបត្តិជំងឺកូវីដ ១៩។ សូមមើល៖ https://www.khmertimeskh.com/711331/covid-19-unemployment-response-now-extended-to-tourism-workers/។

**ការឆ្លងរាលដាលជំងឺកូវីដ 19 អាចធ្វើឱ្យភាពក្រីក្រកើនឡើងយ៉ាងខ្លាំង។** វិធានប្រដូចនៃភាពក្រីក្របង្ហាញថា ភាពក្រីក្រនឹងកើនឡើងពី 1 ភាគរយដល់ 5 ភាគរយ ដោយសារតែការបាត់បង់ប្រាក់ចំណូល 50 ភាគរយ រយៈពេល 3 ខែសម្រាប់គ្រួសារដែលពាក់ព័ន្ធក្នុងវិស័យទេសចរណ៍ ពាណិជ្ជកម្មលក់ដុំ និងលក់រាយ កាត់ដេរ សំណង់ ឬកម្មន្តសាល ឬចន្លោះពី 3 ភាគរយ ទៅ 11 ភាគរយ ដោយសារតែការបាត់បង់ប្រាក់ចំណូលក្នុងរយៈពេល 6 ខែ។

### ពលករចំណាកស្រុកដែលវិលត្រឡប់មកស្រុកវិញ នឹងដាក់សម្ពាធបន្ថែមទៀតលើទីផ្សារការងារដែលកំពុងតែរួមតូចនៅកម្ពុជា

**ពលករដែលវិលត្រឡប់ពីប្រទេសថៃ[24] និងក្រុមគ្រួសាររបស់ពួកគេ ដែលពឹងផ្អែកលើប្រាក់បញ្ញើរបស់ពលករទាំងនោះ ក៏អាចប្រឈមនឹងការបាត់បង់ប្រាក់ចំណូលយ៉ាងច្រើន និងហានិភ័យកាន់តែខ្ពស់ក្នុងការធ្លាក់ចូលក្នុងភាពក្រីក្រ។** លំហូរចូលនៃប្រាក់បញ្ញើត្រូវបានរំពឹងថានឹងមានល្បឿនយឺតខ្លាំង ដោយសារតែពលករចំណាកស្រុកបានវិលត្រឡប់មកកម្ពុជាវិញ (ហើយអ្នកដែលបន្តស្នាក់នៅបរទេស ប្រហែលជាមានប្រាក់ចំណូលតិច ដោយសារតែការធ្លាក់ចុះនៃសេដ្ឋកិច្ចសកល) (សូមមើលប្រអប់ 2)។ ដោយសារវិស័យកសិកម្មជារបរចិញ្ចឹមជីវិតរបស់ប្រជាជនក្រីក្រភាគច្រើន ចាំបាច់ត្រូវមានកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀតក្នុងការធ្វើពិពិធកម្មវិស័យកសិកម្ម និងប្រាក់ចំណូលរបស់គ្រួសារជនបទ និងជំរុញការកែច្នៃកសិផល ដើម្បីបន្តកាត់បន្ថយភាពក្រីក្រ ជាពិសេសនៅទីជនបទ។

### ដោយសារតែការផ្ទុះជំងឺកូវីដ 19 អតិផរណាមានកម្រិតទាបនៅត្រីមាសទីមួយក្នុងឆ្នាំ 2020

**អតិផរណា ដែលបានកើនដល់ 3.1 ភាគរយនៅបំណាច់ឆ្នាំ 2019 ជាសំខាន់ដោយការឡើងថ្លៃម្ហូបអាហារ (រូប 17) បានថយចុះវិញ។** គិតត្រឹមខែ មីនា ឆ្នាំ 2020 អតិផរណាបានថយចុះមកត្រឹម 2.8 ភាគរយធៀបនឹងឆ្នាំមុន សំខាន់ដោយសារការថយចុះតម្រូវការ និងការប្រើប្រាស់ក្នុងស្រុក ដោយសារតែការផ្ទុះជំងឺកូវីដ 19។ សន្ទស្សន៍រងទាំងអស់នៃសន្ទស្សន៍តម្លៃការប្រើប្រាស់របស់កម្ពុជា លើកលែងតែសន្ទស្សន៍រងម្ហូបអាហារ បានថយចុះដោយសារការធ្លាក់ចុះតម្រូវការក្នុងស្រុក។ គិតត្រឹមបំណាច់ឆ្នាំ 2019 សន្ទស្សន៍រងភេសជ្ជៈមិនមែនគ្រឿងស្រវឹង និងម្ហូបអាហារ ក្នុងផលិតផលអតិផរណារបស់កម្ពុជា បានកើនដល់ 3.4 ភាគរយ កើនពី 1.9 ភាគរយនៅខែ ធ្នូ ឆ្នាំ 2018។ ក្នុងអំឡុងពេលដូចគ្នានេះ សន្ទស្សន៍រងផ្សេងៗទៀត ដូចជា លំនៅដ្ឋាន និងទឹក/ភ្លើង និងការធ្វើដំណើរ និងទូរគមនាគមន៍ បានកើន 1.6 ភាគរយ សម្រាប់លំនៅដ្ឋាន និងទឹក/ភ្លើង និងកើនចំនួន 1.7 ភាគរយសម្រាប់ការធ្វើដំណើរ និងទូរគមនាគមន៍ កើនពី 0.4 ភាគរយសម្រាប់លំនៅដ្ឋាន និងទឹក/ភ្លើង និងកើនពី -2.4 ភាគរយសម្រាប់ការធ្វើដំណើរ និងទូរគមនាគមន៍។

**ទន្ទឹមនឹងនេះដែរ អតិផរណាក្នុងតំបន់ក៏ថយចុះផងដែរ បន្ទាប់ពីបានកើនឡើងបន្តិចនៅចុងឆ្នាំ 2019** (រូប 18)។ អតិផរណាក្នុងតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក បានថយចុះ និងមានការរំពឹងតិចតួចផ្នែកអតិផរណាដោយសារតែការរឹតបន្តឹងយ៉ាងលឿនលើលក្ខខណ្ឌហិរញ្ញវត្ថុ បន្ទាប់ពីមានការផ្ទុះជំងឺកូវីដ 19 នៅទូទាំងតំបន់ និងពិភពលោកមក។ ដើម្បីឆ្លើយតបនឹងការថយចុះនៃសកម្មភាពសេដ្ឋកិច្ចក្នុងពេលអតិផរណាថយចុះនេះ បណ្តាប្រទេសក្នុងតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ដូចជា ម៉ាឡេស៊ី ហ្វីលីពីន ថៃ និងឥណ្ឌូនេស៊ី បានងាកទៅអនុវត្តគោលនយោបាយរូបិយវត្ថុដែលមានភាពបន្ធូរបន្ថយ[25]។

**រូប 17 ៖ អតិផរណា ដែលកើនឡើងនៅចុងឆ្នាំ 2019 បានថយចុះមកវិញ**

(ការរួមចំណែកដល់អតិផរណារយៈពេល 12 ខែ (ភាគរយ)




*ប្រភព* ៖ អាជ្ញាធរកម្ពុជា

**រូប 18 ៖ សម្ពាធអតិផរណាបានកើនឡើងក្នុងចំណោមបណ្តាប្រទេសក្នុងតំបន់ និងប្រទេសមានសេដ្ឋកិច្ចជឿនលឿន**

(ចុងគ្រា ភាគរយប្រែប្រួលធៀបនឹងឆ្នាំមុន)




*ប្រភព* ៖ ធនាគារពិភពលោក 2019d (ខែ តុលា) ធនាគារពិភពលោក វ៉ាស៊ីនតោន ឌីស៊ី

24 នៅខែ មេសា ឆ្នាំ 2020 តាមការប៉ាន់ស្មាន កម្មករចំណាកស្រុកចំនួន 80,000 នាក់ បានវិលត្រឡប់មកប្រទេសកម្ពុជាចាប់តាំងពីការផ្ទុះជំងឺកូវីដ ១៩។
25 ធនាគារពិភពលោក ឆ្នាំ 2020។

**ប្រអប់ 2 ៖**

## ការអភិវឌ្ឍថ្មីៗទូទាំងពិភពលោក

កំណើនសកលថយចុះមកត្រឹម 2.4 ភាគរយនៅឆ្នាំ 2019 ដែលជាអត្រាកំណើនយឺតបំផុតចាប់តាំងពីវិបត្តិហិរញ្ញវត្ថុសកលឆ្នាំ 2008-09 (រូប B2.1)។ កំណើនសកលនៅតែមានភាពទន់ខ្សោយនៅត្រីមាសទីបួនក្នុងឆ្នាំ 2019 ដែលបង្ហាញពីដំណើរការខុសៗគ្នាក្នុងប្រទេសដែលមានសេដ្ឋកិច្ចជឿនលឿន។ សេដ្ឋកិច្ចសហរដ្ឋអាមេរិកកើន 2.1 ភាគរយនៅត្រីមាសទីបួនក្នុងឆ្នាំ 2019 (អត្រាប្រចាំឆ្នាំដែលត្រូវបានកែសម្រួលតាមរដូវកាល ធៀបនឹងត្រីមាសមុន) ប៉ុន្តែ កំណើនក្នុងតំបន់ចាយប្រាក់អឺរ៉ូបានថយចុះមកត្រឹម 0.4 ភាគរយនៅត្រីមាសទីបួននៃឆ្នាំ 2019 (អត្រាប្រចាំឆ្នាំដែលត្រូវបានកែសម្រួលតាមរដូវកាល ធៀបនឹងត្រីមាសមុន) ដែលជាកំណើនតិចបំផុតចាប់តាំងពីឆ្នាំ 2013។ សកម្មភាពសេដ្ឋកិច្ចក្នុងប្រទេសជប៉ុនបានថយចុះចំនួន 7.1 ភាគរយនៅត្រីមាសទីបួនក្នុងឆ្នាំ 2019 (អត្រាប្រចាំឆ្នាំដែលត្រូវបានកែសម្រួលតាមរដូវកាល ធៀបនឹងត្រីមាសមុន) ដោយសារតែការបង្កើនពន្ធលើតម្លៃបន្ថែមពី 8 ភាគរយរហូតដល់ 10 ភាគរយនៅថ្ងៃទី 1 ខែ តុលា និងផលប៉ះពាល់នៃព្យុះទីហ្វុង Hagibis។

នៅដើមឆ្នាំ 2020 សេដ្ឋកិច្ចសកលបានបង្ហាញសញ្ញាងើបឡើងវិញជាលើកដំបូង។ សន្ទស្សន៍ស្តីពីការទិញរបស់អ្នកគ្រប់គ្រងផ្សេងៗទូទាំងសកលលោក ( PMI) កើនដល់ 52.2 ដែលជាអត្រាខ្ពស់ក្នុងរយៈពេល 10 ខែ ចំណែកសន្ទស្សន៍នេះសម្រាប់វិស័យកម្មន្តសាលា កើនដល់ 50.4 ដែលជា អត្រាខ្ពស់ក្នុងរយៈពេល 9 ខែ នៅខែ មករា ឆ្នាំ 2020។ ពាណិជ្ជកម្មទំនិញសកលមានកំណើនវិជ្ជមានជាលើកដំបូងនៅខែ ធ្នូ ឆ្នាំ 2019 បន្ទាប់ពីការថយចុះក្នុងរយៈពេល 6 ខែជាប់ៗគ្នា ហើយសូចនាករក្នុងខែ មករា ដូចជា សន្ទស្សន៍ស្តីពីការបញ្ជាការនាំចេញថ្មី បានបង្ហាញពីសញ្ញានៃការងើបឡើងវិញជាលើកដំបូងក្នុងពាណិជ្ជកម្មសកល ដែលត្រូវបានគាំទ្រដោយការថយចុះភាពមិនប្រាកដប្រជានៃគោលនយោបាយពាណិជ្ជកម្ម នៅពេលមានវឌ្ឍនភាពនៃការចរចាពាណិជ្ជកម្មរវាងសហរដ្ឋអាមេរិក និងប្រទេសចិន។

ទោះជាយ៉ាងណា ការកើនឡើងនៃសកម្មភាពសេដ្ឋកិច្ចសកល ត្រូវបានរាំងស្ទះដោយជំងឺឆ្លងរាតត្បាតជាសកល និងវិធានការកាត់បន្ថយការចម្លងដែលត្រូវបានអនុវត្តដំបូងគេក្នុងប្រទេសចិន និងត្រូវបានអនុវត្តជាបន្តបន្ទាប់ក្នុងបណ្តាប្រទេសផ្សេងៗទៀតដើម្បីពន្យឺតការឆ្លងវីរុសក្លូរ៉ូណា។ មានការថយចុះផលិតផលយ៉ាងខ្លាំងនៅត្រីមាសទីមួយក្នុងប្រទេសចិន។ ករណីថ្មីបានកើនឡើងនៅពាក់កណ្តាលខែ កុម្ភៈ ហើយសកម្មភាពសេដ្ឋកិច្ចបានចាប់ផ្តើមងើបឡើងវិញនៅខែ មីនា បន្ទាប់ពីការបន្ធូរបន្ថយការហាមឃាត់ការចេញចូលក្នុងប្រទេស។ ក្នុងបណ្តាប្រទេសផ្សេងទៀត សកម្មភាពសេដ្ឋកិច្ចបានធ្លាក់ចុះយ៉ាងខ្លាំងនៅត្រីមាសទីមួយក្នុងឆ្នាំ 2020។ សន្ទស្សន៍ស្តីពីការទិញរបស់អ្នកគ្រប់គ្រងផ្សេងៗទូទាំងសកលលោក (មិនគិតចិន) ថយចុះពី 12.5 មកត្រឹម 37.6 នៅខែ មីនា។ នេះជាការថយចុះយ៉ាងលឿនបំផុតក្នុងរយៈពេលមួយខែ ដែលមិនធ្លាប់មាន ដែលធ្វើឱ្យសន្ទស្សន៍នេះមានកម្រិតទាបបំផុតចាប់តាំងពីខែ មករា ឆ្នាំ 2019 (រូប B2.2)។

**រូប B2.1 ៖ អត្រាកំណើនសេដ្ឋកិច្ចសកល 2010-20**




*ប្រភព* ៖ Haver Analytics; ធនាគារពិភពលោក

**រូប B2.2 ៖ សន្ទស្សន៍ PMI 2019-20**

សន្ទស្សន៍, 50+= កំណើន




*ប្រភព* ៖ Haver Analytics; ធនាគារពិភពលោក

ទិន្នន័យបឋមបង្ហាញពីការថយចុះនៃពាណិជ្ជកម្មសកល ដែលឆ្លុះបញ្ចាំងពីការរាំងស្ទះលើការធ្វើដំណើរអន្តរជាតិ វិស័យទេសចរណ៍ និងសង្វាក់ផ្គត់ផ្គង់។ ការផ្ទុះជំងឺកូវីដបានប៉ះពាល់យ៉ាងខ្លាំងដល់ពាណិជ្ជកម្មសកល ដែលបានងើបឡើងវិញពីកម្រិតទាបជាច្រើនឆ្នាំនៅឆ្នាំ 2019 ដោយសារតែភាពតានតឹងផ្នែកពាណិជ្ជកម្ម និងការធ្លាក់ចុះនៃកំណើនសេដ្ឋកិច្ចសកល។ សកម្មភាពតាមកំពង់ផែបានថយចុះនៅខែ កុម្ភៈ មកត្រឹមកម្រិតទាបជាច្រើនឆ្នាំ (រូប B2.3)។ ការរឹតត្បិតការធ្វើដំណើរ និងការបង្វែរហានិភ័យ បានដាក់សម្ពាធលើវិស័យទេសចរណ៍ និងការធ្វើដំណើរទូទាំងពិភពលោក។ សន្ទស្សន៍នៃការបញ្ជាទិញសម្រាប់ការនាំចេញថ្មីៗទូទាំងពិភពលោក មានចំនួន 46.6 ភាគរយនៅខែ មីនា ដោយថយចុះចំនួន 3.7 ភាគរយ ធៀបនឹងអត្រានៅខែ កុម្ភៈ ដែលមានចំនួន 45.2 ភាគរយ (រូប B2.4)។ បរិមាណទំនិញរបស់ក្រុមហ៊ុនផលិតបានថយចុះនៅខែ មីនា ចំណែករយៈពេលបញ្ជូនទំនិញរបស់ក្រុមហ៊ុនផ្គត់ផ្គង់ នៅតែកើនឡើង ដែលបង្ហាញពីការរាំងស្ទះក្នុងសង្វាក់ផ្គត់ផ្គង់។

ស្ថានភាពហិរញ្ញប្បទានទូទាំងពិភពលោកត្រូវបានរឹតបន្តឹងយ៉ាងលឿន។ ទីផ្សារសមធម៌សកលបានធ្លាក់ចុះយ៉ាងខ្លាំងដោយសារការផ្ទុះឡើងនៃវីរុសក្លូរ៉ូណាទូទាំងសកលលោក។ លំហូរនៃការហោះហើរធៀបនឹងសុវត្ថិភាព បានរុញផលនៃចំណុចគោលដៅរបស់រតនាគារសហរដ្ឋអាមេរិកក្នុងរយៈពេល 10 ឆ្នាំ មកត្រឹមក្រោម 1 ភាគរយជាលើកដំបូង នៅថ្ងៃទី 4 ខែ មីនា ខណៈដែលបំណុលដែលមានហានិភ័យខ្ពស់មានកាន់តែច្រើន។ ទីផ្សារ

**រូប B2.3 ៖ ពាណិជ្ជកម្មសកល 2016-19 បរិមាណកំណើនពាណិជ្ជកម្មសកល**

ភាគរយ




*ប្រភព ៖* Haver Analytics; ធនាគារពិភពលោក

**រូប B2.4 ៖ ការបញ្ជាទិញសម្រាប់ការនាំចេញថ្មីៗនៅទូទាំងពិភពលោក 2019-20**

សន្ទស្សន៍, 50+=កំណើន




*ប្រភព ៖* Haver Analytics; ធនាគារពិភពលោក

*សម្គាល់ ៖* សន្ទស្សន៍សកល Dow Jones (ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 1991=100. សន្ទស្សន៍ភាពងាយប្រែប្រួល CBOE របស់សហរដ្ឋអាមេរិក (VIX) [VIX].

នៅតែមានការប្រែប្រួលខ្លាំង ដោយសន្ទស្សន៍ស្តីពីភាពងាយប្រែប្រួលរបស់អគ្រាប្តូរប្រាក់ Chicago បានកើនឡើងមួយជាបីនៅខែ មីនា (រូប B2.5)។ ធនាគារជាតិនៅជុំវិញពិភពលោកបានអនុវត្តគោលនយោបាយរូបិយវត្ថុដែលផ្តល់ការអន្តរាគមន៍ និងផ្តល់ការគាំទ្រដល់សន្ទនីយភាព ដើម្បីបញ្ចៀសការខ្វះខាតក្នុងទីផ្សារឥណទាន។ ក្នុងកិច្ចប្រជុំស្តីពីស្ថានភាពអាសន្នចំនួនពីរ ប្រព័ន្ធធនាគារបានបន្ថយអត្រាការប្រាក់របស់ខ្លួនរហូតដល់ជិត 0 ភាគរយ។

**ថ្លៃទំនិញធ្លាក់ចុះយ៉ាងខ្លាំង។** តម្លៃប្រេងបានធ្លាក់ជាង 60 ភាគរយចាប់តាំងពីថ្ងៃទី 20 ខែ មករា (កាលបរិច្ឆេទដែលការចម្លងវីរុសកូរ៉ូណាពីមនុស្សទៅមនុស្ស ត្រូវបានរកឃើញជាសាធារណៈជាលើកដំបូង) ដោយ West Texas Intermediate (WTI) ដែលជាមូលដ្ឋានរបស់សហរដ្ឋអាមេរិក បានធ្លាក់ថ្លៃ 20 ដុល្លារអាមេរិកក្នុងមួយបារ៉ែលនៅពាក់ កណ្តាលខែ មីនា។ វិធានការទប់ស្កាត់ដែលបានធ្វើឡើងដើម្បីគ្រប់គ្រងការផ្ទុះជំងឺកូវីដ 19 បានធ្វើឱ្យការធ្វើដំណើរ និងតម្រូវការប្រេងថយចុះ។ តម្លៃប្រេងកាន់តែធ្លាក់ចុះដោយសារតែការបរាជ័យនៃកិច្ចព្រមព្រៀងផលិតកម្មរវាងអង្គការប្រទេសនាំចេញប្រេងឆៅ (OPEC) និងដៃគូ រួមទាំងប្រទេសរុស្ស៊ី។ តម្លៃលោហធាតុសម្រាប់ឧស្សាហកម្មក៏ធ្លាក់ចុះផងដែរ ជាពិសេសតម្លៃទង់ដែង និងស័ង្កសី (ធ្លាក់ថ្លៃចំនួន -25 ភាគរយ)។ តម្លៃកសិផលទទួលរងផលប៉ះពាល់តិចតួច ដោយក្នុងនោះ តម្លៃគ្រាប់ធុញ្ញជាតិសំខាន់ៗទាំងបីធ្លាក់ថ្លៃចំនួន 6-11 ភាគរយ (រូប B2.6)។

**រូប B2.5 ៖ សន្ទស្សន៍សកល Dow Jones និងសន្ទស្សន៍ស្តីពីភាពងាយប្រែប្រួល CBOE សហរដ្ឋអាមេរិក (VIX) 2007-20**

សន្ទស្សន៍




*ប្រភព ៖* Haver Analytics; ធនាគារពិភពលោក

*សម្គាល់ ៖* សន្ទស្សន៍សកល Dow Jones (ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 1991=100. សន្ទស្សន៍ភាពងាយប្រែប្រួល CBOE សហរដ្ឋអាមេរិក (VIX)

**រូប B2.6 ៖ សន្ទស្សន៍តម្លៃទំនិញ 2014-20**

សន្ទស្សន៍ ស្ថានភាពធម្មតា 2010=100




*ប្រភព ៖* Haver Analytics; ធនាគារពិភពលោក

*សម្គាល់ ៖* ប្រអប់នេះត្រូវបានរៀបចំឡើងដោយ Ekaterine Vashakmadze។

### កំណើនរូបិយវត្ថុទូលាយបានថយចុះដោយសារតែចំនួនប្រាក់បញ្ញើជារូបិយប័ណ្ណបរទេសថយចុះ

**ដោយសារតែការថយចុះនៃចំនួនប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស ដែលបណ្ដាលមកពីការថយចុះនៃលំហូរមូលធន កំណើនរូបិយវត្ថុទូលាយបានថយចុះមកត្រឹម 18 ភាគរយនៅបំណាច់ឆ្នាំ 2019 ថយពី 24 ភាគរយនៅឆ្នាំ 2018។** បើទោះជាប្រាក់បញ្ញើជារូបិយប័ណ្ណបរទេសនៅតែរួមចំណែកច្រើនជាងគេដល់កំណើនរូបិយវត្ថុទូលាយ ការរួមចំណែកនៃប្រាក់បញ្ញើជារូបិយប័ណ្ណបរទេសបានថយចុះជិតពាក់កណ្ដាលមកត្រឹម 12.7 ភាគរយនៅបំណាច់ឆ្នាំ 2019 ថយពី 22.06 ភាគរយនៅឆ្នាំ 2018 ដោយសារការថយចុះនៃលំហូរចូលមូលធន។ ដោយសារតែជោគជ័យនៅពេលដំបូងនៃគោលនយោបាយរបស់អាជ្ញាធរកម្ពុជាក្នុងការលើកកម្ពស់ការប្រើប្រាស់រូបិយប័ណ្ណក្នុងស្រុក ការរួមចំណែករបស់ប្រាក់រៀលដែលចរាចរណ៍នៅក្នុងស្រុកដល់កំណើនរូបិយវត្ថុទូលាយ កើនឡើងជិត 3 ដង កើនដល់ 3.2 ភាគរយ កើនពី 1.2ភាគរយនៅឆ្នាំ2018។ ទន្ទឹមនឹងនេះដែរ ការរួមចំណែកនៃប្រាក់បញ្ញើជាប្រាក់រៀលដល់កំណើនរូបិយវត្ថុទូលាយ កើន 2 ភាគរយ កើនពី 0.6 ភាគរយក្នុងអំឡុងពេលដូចគ្នានេះ (រូប 19)។

### សម្ពាធកាន់តែខ្លាំងលើអត្រាប្ដូរប្រាក់

**ដោយសារតែធនាគារជាតិបានដាក់រូបិយប័ណ្ណក្នុងស្រុកកាន់តែច្រើន** សម្ពាធលើអត្រាប្ដូរប្រាក់បានកាន់តែច្រើន ដែលអាចបង្ហាញពីការថយចុះនៃលំហូរចូលមូលធន (រូប 20) ទៅក្នុងសេដ្ឋកិច្ចដែលមានកម្រិតដុល្លារូបនីយកម្មខ្ពស់របស់កម្ពុជា។ នេះគឺជាបញ្ហាប្រឈមថ្មីមួយក្នុងអំឡុងមានវិបត្តិជំងឺកូវីដ 19 នៅពេលដែលការថយចុះនៃលំហូរចូលមូលធន រួមនឹងការថយចុះនៃប្រាក់ចំណូលពីបរទេសរបស់កម្ពុជា ដោយសារតែការធ្លាក់ចុះនៃវិស័យទេសចរណ៍ និងវិស័យនាំចេញ កំពុងដាក់សម្ពាធកាន់តែខ្លាំងលើទុនបម្រុងជារូបិយវត្ថុបរទេសរបស់កម្ពុជា។ ដោយសារតែធនាគារជាតិប្រតិបត្តិការទីផ្សារយ៉ាងប្រុងប្រយ័ត្ន ដើម្បីរក្សាស្ថិរភាពអត្រាប្ដូរប្រាក់ តម្រូវការប្រាក់ដុល្លារអាមេរិកនឹងកើនឡើង។ បើសិនជាគ្មានការដាក់រូបិយវត្ថុបរទេសសម្រាប់ផ្លាស់ប្ដូរបន្ថែមទេនោះ ប្រាក់រៀលនឹងធ្លាក់ថ្លៃធៀបនឹងប្រាក់ដុល្លារអាមេរិក។ ថ្មីៗនេះ ប្រតិបត្តិការផ្ដល់សន្ទនីយភាពដោយមានការធានា (LPCO) បានជួយបង្កើតជាអត្រាកំណត់នៃកម្ចីរូបិយប័ណ្ណក្នុងស្រុក និងការគាំទ្រដល់កំណើនតម្រូវការរូបិយប័ណ្ណក្នុងស្រុក ដោយសារតែធនាគារជាតិទទួលបានជោគជ័យក្នុងកិច្ចខិតខំប្រឹងប្រែងលើកកម្ពស់ការប្រើប្រាស់រូបិយប័ណ្ណក្នុងស្រុក។ ជាលទ្ធផល ការទាមទារប្រាក់បញ្ញើក្នុងធនាគារ កើនឡើងជិតដល់ 4,000 ទ្រីលានរៀល គិតត្រឹមបំណាច់ឆ្នាំ 2019 កើនពី 470 ទ្រីលានរៀលនៅបំណាច់ឆ្នាំ 2018។ ស្ថានភាពនេះបានជួយបង្កើនទុនបម្រុងអន្តរជាតិដុល ដែលមានចំនួន 18.7 ពាន់លានដុល្លារអាមេរិក ឬស្មើនឹងកំណើន 28 ភាគរយធៀបនឹងឆ្នាំមុន កើនពី 20 ភាគរយនៅឆ្នាំ 2018។ យ៉ាងណាក៏ដោយ ស្ថានភាពទុនបម្រុងអន្តរជាតិរបស់កម្ពុជានៅឆ្នាំ 2020 ត្រូវបានព្យាករណ៍ថានឹងថយចុះដោយសារវិស័យសំខាន់ៗរបស់កម្ពុជាដែលទទួលបានប្រាក់បរទេសគឺវិស័យ ទេសចរណ៍ និងការនាំចេញ កំពុងរងផលប៉ះពាល់យ៉ាងខ្លាំងដោយសារការផ្ទុះជំងឺកូវីដ 19 ខណៈលំហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេសក៏បានថយចុះដែរ។

**ក្នុងរយៈពេល 11 ខែដំបូងក្នុងឆ្នាំ 2019 ធនាគារជាតិបានផ្គត់ផ្គង់ប្រាក់រៀលចំនួន 3.4 ទ្រីលានរៀល** ដល់ធនាគារពាណិជ្ជ ដែលស្មើនឹងទឹកប្រាក់ 838 លានដុល្លារអាមេរិក ឬកំណើនជិត 4 ដងធៀបនឹងឆ្នាំ 2018[26]។ ប្រតិបត្តិការផ្ដល់សន្ទនីយភាពដោយមានការធានា កំណត់អត្រាការប្រាក់ 2.81 ភាគរយ

**រូប 19 ៖ ការរួមចំណែកដល់កំណើនរូបិយវត្ថុទូលាយ**

(ភាគរយ)




*ប្រភព* ៖អាជ្ញាធរកម្ពុជា

**រូប 20 ៖ ប្រាក់រៀលដែលចរាចរណ៍ និងអត្រាប្ដូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិក**

(ការប្រែប្រួលជាភាគរយធៀបនឹងឆ្នាំមុន)




*ប្រភព* ៖អាជ្ញាធរកម្ពុជា

26 ធនាគារជាតិនៃកម្ពុជា ឆ្នាំ 2019។

សម្រាប់រយៈពេល 3 ខែ, 2.84 ភាគរយសម្រាប់រយៈពេល 6 ខែ និង 3.08 ភាគរយសម្រាប់រយៈពេល 12 ខែ។ ដោយសារតែលំហូរចូលមូលធនថយចុះ ប្រាក់រៀលបានធ្លាក់ថ្លៃបន្តិចធៀបនឹងប្រាក់ដុល្លារអាមេរិក។ អត្រាប្តូរប្រាក់រៀល-ដុល្លារអាមេរិក គឺ 4,099 រៀលក្នុង 1 ដុល្លារអាមេរិក គិតត្រឹមខែ មេសា ឆ្នាំ 2020 ធៀបនឹងអត្រា 4,018 រៀលក្នុង 1 ដុល្លារអាមេរិកនៅបំណាច់ឆ្នាំ 2018។ នៅខែ មេសា ឆ្នាំ 2020 ប្រាក់រៀលឡើងថ្លៃបន្តិចធៀបនឹងប្រាក់បាតថៃ ប៉ុន្តែ ធ្លាក់ថ្លៃធៀបនឹងប្រាក់ដុងវៀតណាម (រូប 20)។ បើធៀបនឹងរូបិយប័ណ្ណរបស់ទីផ្សារនាំចេញសំខាន់ៗរបស់កម្ពុជា (ក្រៅពីសហរដ្ឋអាមេរិក) ប្រាក់រៀលឡើងថ្លៃបន្តិចធៀបនឹងប្រាក់អឺរ៉ូ ប្រាក់ដុល្លារកាណាដា និងប្រាក់ផោនអង់គ្លេស។ នៅឆ្នាំ 2019 អត្រាប្តូរប្រាក់រៀល ជាក់ស្តែង និងអត្រាប្តូរប្រាក់ពិតរបស់កម្ពុជា កើនឡើង ដែលបង្ហាញពីការឡើងថ្លៃរូបិយប័ណ្ណក្នុងស្រុកធៀបនឹងរូបិយប័ណ្ណរបស់ដៃគូពាណិជ្ជកម្មកម្ពុជា។

### គិតត្រឹមបំណាច់ឆ្នាំ 2019 កំណើន (សរុប) នៃការផ្តល់ឥណទានធនាគារដល់អាជីវកម្ម បានថយចុះជាលើកដំបូងចាប់តាំងពីពាក់កណ្តាលឆ្នាំ 2018

**ចាប់តាំងពីពាក់កណ្តាលឆ្នាំ 2018 នេះជាលើកដំបូងហើយដែលកំណើនការផ្តល់ឥណទានធនាគារក្នុងស្រុកសរុប[27] ដល់វិស័យឯកជន បានថយចុះមកត្រឹម 21.3 ភាគរយនៅឆ្នាំ 2019 ថយពី 24.2 ភាគរយនៅឆ្នាំ 2018។** ផ្អែកលើទិន្នន័យស្តីពីឥណទានធនាគារដែលត្រូវបានបែងចែកតាមប្រភេទអាជីវកម្ម ការថយចុះឥណទានធនាគារសំខាន់ដោយសារការថយចុះនៃការផ្តល់ឥណទានធនាគារសម្រាប់ 1) ឧស្សាហកម្មបដិសណ្ឋារកិច្ច (សណ្ឋាគារ និងភោជនីយដ្ឋាន) 2) វិស័យកម្មន្តសាល និង 3) វិស័យកសិកម្ម (រូប 22)។ នៅឆ្នាំ 2019 អត្រាកម្ចីមិនដំណើរការដែលបានរាយការណ៍មានចំនួន 2.2 ភាគរយសម្រាប់វិស័យធនាគារ និង 1.1 ភាគរយសម្រាប់វិស័យមីក្រូហិរញ្ញវត្ថុ[28]។ នៅឆ្នាំ 2019 ការរួមចំណែកនៃវិស័យបដិសណ្ឋារកិច្ច (សណ្ឋាគារ និងភោជនីយដ្ឋាន) កសិកម្ម និងអាជីវកម្មផលិត ដល់កំណើនឥណទានធនាគារ ថយចុះចំនួន 0.9 ភាគរយសម្រាប់វិស័យបដិសណ្ឋារកិច្ច, 0.5 ភាគរយសម្រាប់កសិកម្ម និង 0.2 ភាគរយសម្រាប់អាជីវកម្មផលិត ថយពី 1.4 ភាគរយសម្រាប់វិស័យបដិសណ្ឋារកិច្ច, 0.7 ភាគរយសម្រាប់កសិកម្ម និង 0.4 ភាគរយសម្រាប់អាជីវកម្មផលិតនៅឆ្នាំ 2018។

### ការផ្តល់ឥណទានធនាគារក្នុងស្រុកដល់វិស័យសំណង់ អចលនទ្រព្យ និងការបញ្ចាំនៅតែមានកំណើន

**កំណើននៃការផ្តល់ឥណទានធនាគារនៅតែត្រូវបានជំរុញដោយកំណើននៃការផ្តល់ប្រាក់កម្ចីដល់វិស័យសំណង់ អចលនទ្រព្យ និងការរកស៊ីបញ្ចាំ។** ការរួមចំណែកសរុបនៃវិស័យសំណង់ អចលនទ្រព្យ និងការរកស៊ីបញ្ចាំ ដល់កំណើនឥណទានធនាគារកើនឡើងចំនួន 11 ភាគរយ កើនពី 9 ភាគរយនៅបំណាច់ឆ្នាំ 2018។ ប្រហែលគ្នានេះដែរ ចំណែកនៃការផ្តល់ឥណទានធនាគារដល់វិស័យសំណង់ អចលនទ្រព្យ និងការរកស៊ីបញ្ចាំរួមគ្នា ក្នុងចំណោមឥណទានធនាគារដែលមិនទាន់សង កើន 31.1 ភាគរយ ឬស្មើនឹងទឹកប្រាក់ 7.7 ពាន់លានដុល្លារអាមេរិក គិតត្រឹមបំណាច់ឆ្នាំ 2019 កើនពី 27.9 ភាគរយ ឬស្មើនឹងទឹកប្រាក់ 5.6 ពាន់លានដុល្លារអាមេរិក គិតត្រឹមបំណាច់ឆ្នាំ 2018។ នេះជាកំណើនច្រើនជាងកំណើន 22.8 ភាគរយនៅពេលដែលវិស័យសំណង់ធ្លាក់ចុះដោយសារវិបត្តិហិរញ្ញវត្ថុសកលនៅឆ្នាំ

**រូប 21 ៖ អត្រាប្តូរប្រាក់ជាបរិមាណ**




*ប្រភព* ៖ អាជ្ញាធរកម្ពុជា

**រូប 22 ៖ ការរួមចំណែកដល់កំណើនឥណទានក្នុងស្រុក**

(ភាគរយ)




*ប្រភព* ៖ អាជ្ញាធរកម្ពុជា

27 ឥណទានធនាគារដុលជាការផ្តល់ឥណទានធនាគារក្នុងស្រុកសរុបដល់វិស័យឯកជន មិនគិតពី 1) ការផ្តល់កម្ចីពីអាជ្ញាធររូបិយវត្ថុដល់ប្រាក់បញ្ញើក្នុងធនាគារ និង 2) កម្ចីអន្តរធនាគារដោយប្រាក់បញ្ញើក្នុងធនាគារ។

28 ធនាគារជាតិនៃកម្ពុជា ឆ្នាំ 2019។

2008-09។ ក្រៅពីនេះ ចំណែកនៃការផ្តល់ឥណទានធនាគារដល់វិស័យឯកជន មានចំនួន 24.4 ភាគរយនៃ ផសស នៅឆ្នាំ 2009 (នៅពេលដែលវិបត្តិហិរញ្ញវត្ថុសកលប៉ះពាល់ដល់សេដ្ឋកិច្ច) បើធៀបនឹងចំនួន 83.4 ភាគរយនៃ ផសស នៅឆ្នាំ 2018 ជាអំឡុងពេលដែលមានការធ្លាក់ចុះហិរញ្ញវត្ថុនៅរយៈពេលប៉ុន្មានឆ្នាំនេះ។ ចំណុចនេះបង្ហាញពីហានិភ័យខ្ពស់នៃការចម្លងពីវិស័យផលិតទៅលើវិស័យធនាគារ។

**អត្រាការប្រាក់រយៈពេលខ្លីនៃប្រាក់បញ្ញើ និងប្រាក់កម្ចីជាប្រាក់រៀល និងប្រាក់ដុល្លារអាមេរិក (លើកលែងតែអត្រាការប្រាក់នៃការផ្តល់កម្ចីជាប្រាក់រៀល) មានអត្រាថេរគួរសម។** គិតត្រឹមបំណាច់ឆ្នាំ 2019 អត្រាការប្រាក់រយៈពេលខ្លីនៃប្រាក់បញ្ញើជាប្រាក់រៀល និងប្រាក់ដុល្លារអាមេរិក (12 ខែ) មានចំនួន 4.34 ភាគរយសម្រាប់ប្រាក់បញ្ញើជាប្រាក់រៀល និង 5.42 ភាគរយសម្រាប់ប្រាក់បញ្ញើជាប្រាក់ដុល្លារអាមេរិក ធៀបនឹងអត្រា 4.38 ភាគរយសម្រាប់ប្រាក់បញ្ញើជាប្រាក់រៀល និង 5.87 ភាគរយសម្រាប់ប្រាក់បញ្ញើជាប្រាក់ដុល្លារអាមេរិកនៅបំណាច់ឆ្នាំ 2018។ ក្នុងអំឡុងពេលជាមួយគ្នានេះ អត្រាការប្រាក់រយៈពេលខ្លីសម្រាប់ប្រាក់កម្ចីជាប្រាក់ដុល្លារអាមេរិក មានចំនួន 9.51 ភាគរយ ធៀបនឹងអត្រា 9.74 ភាគរយ។ ទោះជាយ៉ាងណាក៏ដោយ អត្រាការប្រាក់រយៈពេលខ្លីនៃប្រាក់កម្ចីជាប្រាក់រៀល ថយចុះចំនួន 10.62 ភាគរយ គិតត្រឹមបំណាច់ឆ្នាំ 2019 ថយពី 13.5 ភាគរយ គិតត្រឹមបំណាច់ឆ្នាំ 2018 ដោយសារតែជោគជ័យនៃគោលនយោបាយរបស់ធនាគារជាតិក្នុងការលើកកម្ពស់ការប្រើប្រាស់រូបិយប័ណ្ណក្នុងស្រុក។

**ជាការឆ្លើយតបនឹងការផ្ទុះជំងឺកូវីដ 19 ធនាគារជាតិនៃកម្ពុជាបានអនុវត្តគោលនយោបាយសម្រួលផ្នែករូបិយវត្ថុ និងវិធានការជាច្រើនផ្សេងទៀត។** នៅខែ មីនា ឆ្នាំ 2020 អត្រាប្រាក់បម្រុងកំណត់ បានថយចុះមក 7 ភាគរយ ទាំងសម្រាប់រូបិយប័ណ្ណក្នុងស្រុក និងរូបិយប័ណ្ណបរទេស ថយពី 8 ភាគរយសម្រាប់រូបិយប័ណ្ណក្នុងស្រុក និង 12.5 ភាគរយសម្រាប់រូបិយប័ណ្ណបរទេស ចាប់ពីខែ មេសា ឆ្នាំ 2020 តទៅ។ អត្រាកំណត់សម្រាប់ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (សូមមើលការបរិយាយលម្អិតស្តីពីប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានាខាងលើ) សម្រាប់រយៈពេលកំណត់សងប្រាក់កម្ចីទាំងអស់ ត្រូវបានបន្ថយមកត្រឹម 0.5 ភាគរយ។ ធនាគារជាតិនៃកម្ពុជាបានសម្រេចផ្អាកការអនុវត្តពេញលេញនូវទ្រនាប់ដើមទុនខនស៊ើវេសិន និងបានរក្សាលក្ខខណ្ឌតម្រូវបច្ចុប្បន្នអត្រា 50 ភាគរយ បញ្ជះអត្រាការប្រាក់លើវិញ្ញាបនបត្របញ្ញើដែលអាចជួញដូរបាន ទាំងសម្រាប់ប្រាក់រៀល និងប្រាក់ដុល្លារអាមេរិក ត្រឹមកម្រិតសមស្របមួយ និងកាត់បន្ថយលក្ខខណ្ឌតម្រូវអប្បបរមានៃអត្រាគ្របដណ្តប់សន្ទនីយភាពត្រឹមកម្រិតសមស្របមួយ[29]។

### ការប៉ះពាល់ដល់ចំណូលក្នុងស្រុក

**ការផ្ទុះជំងឺកូវីដ 19 កំពុងប៉ះពាល់យ៉ាងធ្ងន់ធ្ងរមកលើមូលដ្ឋានចំណូលរបស់កម្ពុជា។** វិស័យនាំចេញ និងវិស័យសំណង់ ជាប្រភពដ៏សំខាន់ចំណូលផ្ទាល់ និងចំណូលប្រយោល (និង

**រូប 23 ៖ ការផ្ទុះជំងឺកូវីដ 19 ត្រូវបានព្យាករណ៍ថានឹងប៉ះពាល់យ៉ាងខ្លាំងដល់ស្ថានភាពសារពើពន្ធនៅឆ្នាំនេះ**

ប្រតិបត្តិការទូទៅរបស់រដ្ឋាភិបាល (ភាគរយនៃ ផសស)




*ប្រភព* ៖ ច្បាប់ទូទាត់ថវិកា, ការប៉ាន់ស្មាន និងការព្យាកររបស់បុគ្គលិកធនាគារពិភពលោក

*សម្គាល់* ៖ e= ប៉ាន់ស្មាន, f= ព្យាករណ៍

**រូប 24 ៖ ចំណូល (រួមទាំងជំនួយឥតសំណង) កើនឡើងនៅឆ្នាំ 2019**

(ភាគរយនៃ ផសស)




*ប្រភព* ៖ អាជ្ញាធរកម្ពុជា, ការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក

*សម្គាល់* ៖ e=ការប៉ាន់ស្មាន

29 ទ្រនាប់ដើមទុនខនស៊ើវេសិនមានគោលបំណងធានាថា គ្រឹះស្ថាននានាបង្កើតទ្រនាប់ទុន ក្រោមស្ថានភាពហិរញ្ញវត្ថុធម្មតា ដែលអាចយកជាមូលដ្ឋាន នៅពេលមានការខាតបង់។ នៅពេល ទ្រនាប់ដើមទុនថយចុះ គ្រឹះស្ថានទាំងនោះត្រូវស្តារឡើងវិញឱ្យបានឆាប់បំផុត។ ប្រសិនបើមិនអាចស្តារឡើងវិញបានភ្លាមៗទេនោះ គ្រឹះស្ថានទាំងនោះត្រូវដាក់ “ផែនការគ្រប់គ្រងមូលធន” ទៅធនាគារជាតិនៃកម្ពុជាដោយពន្យល់ពីមធ្យោបាយ និងការកំណត់កាលបរិច្ឆេទដែលគ្រឹះស្ថានទាំងនោះចង់បង្កើតទ្រនាប់ដើមទុនខនស៊ើវេសិនរបស់ខ្លួន។ សូមមើលប្រកាសរបស់ធនាគារជាតិនៃកម្ពុជា ចុះថ្ងៃទី 2 ខែ កុម្ភៈ ឆ្នាំ 2018 ៖ https://www.nbc.org.kh/download_files/legislation/prakas_eng/3.Prakas_on_Capital_Buffer_in_BFIs_ENG.pdf។

ពាណិជ្ជកម្មអន្តរជាតិ)។ វិស័យកសិកម្មដែលរងការប៉ះពាល់តិចបំផុតមិនតម្រូវឲ្យបង់ពន្ធទេ។ ការប្រមូលចំណូលឆ្នាំ 2020 អាចនឹងមានកម្រិតទាបខ្លាំងជាងគោលដៅប្រមូលថវិកា។ ឱនភាពសារពើពន្ធជារួម (រួមទាំងជំនួយឥតសំណង) ត្រូវបានព្យាករណ៍ថានឹងកើនដល់ 9 ភាគរយនៃ ផសស នៅឆ្នាំ 2020 (រូប 23) ថយពីអតិរេក 0.5 ភាគរយនៅឆ្នាំ 2019 (សូមមើលឧបសម្ព័ន្ធ 2 ៖ សូចនាករម៉ាក្រូសេដ្ឋកិច្ចសំខាន់របស់កម្ពុជា)។ ការថយចុះនៃការប្រមូលចំណូលក្នុងស្រុកតម្រូវឱ្យអាជ្ញាធរកម្ពុជាយកប្រាក់សន្សំរបស់រដ្ឋាភិបាលមកប្រើ ហើយតម្រូវការហិរញ្ញប្បទានក្នុងស្រុកត្រូវបានព្យាករណ៍ថានឹងមានចំនួនប្រមាណ 5 ភាគរយនៃ ផសស។ នៅឆ្នាំ 2019 ប្រាក់សន្សំរបស់រដ្ឋាភិបាលមានចំនួន 20.2 ភាគរយនៃ ផសស (ឬ 22.2 ទ្រីលានរៀល) បន្ទាប់ពីការកើនឡើងជាច្រើនឆ្នាំ។ ដោយសារតែមានសន្ទនីយភាពយ៉ាងច្រើន អាជ្ញាធរកម្ពុជានឹងមិនប្រើប្រាស់ហិរញ្ញប្បទានក្នុងស្រុក (ធនាគារជាតិ) ដើម្បីបំពេញឱនភាពសារពើពន្ធរួមនោះទេ។

### ការប្រមូលចំណូលកើនឡើងខ្ពស់កាលពីឆ្នាំមុន

**នៅឆ្នាំ 2019 ចំណូលសរុប (រួមទាំងជំនួយឥតសំណង) កើនឡើងខ្ពស់ដល់ 25.4 ភាគរយនៃ ផសស (រូប 24) ដោយសារតែការបន្តគ្រប់គ្រងចំណូលបានល្អ។** តាមការប៉ាន់ស្មាន ចំណូលសរុប (និងជំនួយឥតសំណង) មានចំនួន 27.8 ទ្រីលានរៀល ឬ 6.9 ពាន់លានដុល្លារអាមេរិក។ ចំណូលភាគច្រើនបានមកពីពន្ធលើទំនិញ និងសេវា ដែលរួមមាន ពន្ធលើតម្លៃបន្ថែម និងពន្ធអាករពីអាជីវកម្ម និងការនាំចូលទំនិញក្នុងស្រុក (ម៉ូតូ និងគ្រឿងម៉ាស៊ីន ផលិតផលប្រេងកាត និងសម្ភារសំណង់)ដែលកើនចំនួន 12.6 ភាគរយនៃ ផសស (កំណើន 27.1 ភាគរយធៀបនឹងឆ្នាំមុន) នៅឆ្នាំ 2019 កើនពី 10.9 ភាគរយនៃ ផសស នៅឆ្នាំ 2018។ ចំណូលពីពន្ធផ្ទាល់មានចំនួន 4.4 ភាគរយ នៃ ផសស (កំណើន 20.4 ភាគរយធៀបនឹងឆ្នាំមុន) កើនពី 4 ភាគរយក្នុងអំឡុងពេលដូចគ្នា។ ចំណូលពីពន្ធពាណិជ្ជកម្មអន្តរជាតិ (ពន្ធអាករ និងកម្រៃសេវា) កើនឡើងតែបន្តិចប៉ុណ្ណោះ គឺ 2.7 នៃ ផសស នៅឆ្នាំ 2019 កើនពី 2.4 ភាគរយនៅឆ្នាំ 2018 ដោយសារការប្តេជ្ញាចិត្តក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន។

**ក្នុងរយៈពេលពីរខែដំបូងក្នុងឆ្នាំ 2020 ការប្រមូលចំណូលនៅតែមានភាពរឹងមាំ ទោះបីជាមានការផ្ទុះជំងឺកូវីដ 19 ដែលប៉ះពាល់យ៉ាងខ្លាំងលើសកម្មភាពសេដ្ឋកិច្ចក្នុងស្រុក និងការនាំចូលក្តី។** ការប្រមូលចំណូលរបស់រដ្ឋាភិបាលក្នុងរយៈពេលពីរខែដំបូងក្នុងឆ្នាំ 2020 កើនឡើងចំនួន 22.7 ភាគរយធៀបនឹងឆ្នាំមុន ដោយសារតែកំណើននៃចំណូលពន្ធលើទំនិញ និងសេវា និងចំណូលមិនមែនពន្ធ ខណៈដែលចំណូលផ្ទាល់ និងពន្ធលើពាណិជ្ជកម្មអន្តរជាតិ មានអត្រាថេរ។

### ការចំណាយក៏បានកើនឡើងកាលពីឆ្នាំមុន

**ប្រហាក់ប្រហែលគ្នាដែរ ចំណាយសាធារណៈកើនឡើងកាលពីឆ្នាំមុន។** ចំណាយសាធារណៈកើនឡើង ដោយសារតែចំណាយកាន់តែច្រើនលើទំនិញ និងសេវា (ចំណាយចរន្តក្រៅពីប្រាក់បៀវត្សរ៍) ហើយត្រូវបានប៉ាន់ស្មានថាមានចំនួន 24.9 ភាគរយនៃ ផសស កើនពី 23.4 ភាគរយនៃ ផសស នៅឆ្នាំ 2018 (រូប 25)។ ប្រាក់បៀវត្សរ៍ និងការផ្តល់សំណង ដែលកើនឡើងយ៉ាងលឿនក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមក (ដោយសារតែអាជ្ញាធរកម្ពុជាបង្កើនប្រាក់បៀវត្សរ៍អប្បបរមាប្រចាំខែសម្រាប់មន្ត្រីរាជការគ្រប់គ្នាឱ្យ បានយ៉ាងតិច 1 លានរៀល ឬស្មើនឹង 250 ដុល្លារអាមេរិក) បានថយចុះ និងត្រូវបានប៉ាន់ស្មានថាមានចំនួន 7 ភាគរយនៃ ផសស។ មួយផ្នែកនៃការថយចុះនេះបណ្តាលមកពីការធ្វើចំណាត់ថ្នាក់ឡើងវិញ។ ចំណាយថវិកាទៅលើអត្ថប្រយោជន៍ផ្នែកសង្គម ដែលរួមមាន របបសន្តិសុខសង្គម និងជំនួយសង្គម ដែលត្រូវបានធ្វើចំណាត់ថ្នាក់ឲ្យនៅក្រោមប្រភេទប្រាក់បៀវត្សរ៍ និងសំណង ត្រូវបានបែងចែកជាពីរ។

**ចំណាយមូលធន ត្រូវបានប៉ាន់ស្មានថាថយចុះកាលពីឆ្នាំមុន។** ដោយសារតែការថយចុះចំណាយក្នុងការវិនិយោគសាធារណៈដែលទទួលបានហិរញ្ញប្បទានពីខាងក្រៅ ចំណាយមូលធនត្រូវបានព្យាករណ៍ថាមានចំនួន 6.4 ភាគរយនៃ ផសស នៅឆ្នាំ 2019 ចុះពីចំនួន 6.7 ភាគរយនៅឆ្នាំ 2018។ កម្ពុជានៅតែពឹងផ្អែកលើការផ្តល់ហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ដល់ការវិនិយោគមូលធនរបស់ខ្លួន។ ដោយសារតែការកើនឡើងនៃចំណាយសាធារណៈ ចំណែកនៃចំណាយមូលធនដែលទទួលបានហិរញ្ញប្បទានពីខាងក្រៅធៀបនឹងចំណាយមូលធនសរុប ថយចុះមក 57 ភាគរយនៅឆ្នាំ 2019 ថយពី 65 ភាគរយនៅឆ្នាំ 2018។

**ក្នុងរយៈពេលពីរខែដំបូងក្នុងឆ្នាំ 20២0 ចំណាយកើនឡើងដោយសារអាជ្ញាធរកម្ពុជាបានចាត់វិធានការភ្លាមៗទប់ទល់នឹងការផ្ទុះជំងឺកូវីដ 19។** ចំណាយរបស់រដ្ឋាភិបាលក្នុងរយៈពេលពីរខែដំបូងកើនឡើងលឿនជាងកាលពីប៉ុន្មានឆ្នាំទៅមុន ដោយកើនចំនួន 33.7 ភាគរយ ធៀបនឹងឆ្នាំមុន ខណៈដែលចំណាយមូលធនកើនឡើងជិត 50 ភាគរយធៀបនឹងឆ្នាំមុន។

### ជាការឆ្លើយតបនឹងការផ្ទុះជំងឺកូវីដ 19 អាជ្ញាធរកម្ពុជាបានប្រកាសថវិកាឆ្នាំ 2020 ជាថវិការឹតត្បិត

**ដើម្បីឆ្លើយតបនឹងការផ្ទុះជំងឺកូវីដ 19 នៅខែ មេសា ឆ្នាំ 2020 អាជ្ញាធរកម្ពុជាបានប្រកាសថវិកាឆ្នាំ 2020 ជាថវិការឹតត្បិត ក្នុងនោះ ចំណាយសាធារណៈជាក់ស្តែងត្រូវបានរំពឹងថានឹងថយចុះមកត្រឹមចំនួន 25.5 ភាគរយនៃ ផសស ចុះពី 26.9 ភាគរយនៃថវិកាឆ្នាំ 2020 ដែលបានគ្រោងដំបូង។** ការកាត់បន្ថយចំណាយដែលបានគ្រោងទុកលើទំនិញ និងសេវា (ចំណាយចរន្តក្រៅពីប្រាក់បៀវត្សរ៍)ក្នុងទំហំទឹកប្រាក់918លានដុល្លារអាមេរិក ត្រូវបានប្រកាសនៅខែ មេសា ឆ្នាំ 2020[30]។ ប្រាក់សន្សំពីការកាត់បន្ថយថវិកានេះ នឹងត្រូវប្រើប្រាស់សម្រាប់ផ្តល់ហិរញ្ញប្បទាន

30 សារាចរណែនាំចុះថ្ងៃទី 8 ខែ មេសា ឆ្នាំ 2020 របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ដល់តម្រូវការអន្តរាគមន៍ផ្នែកសេដ្ឋកិច្ច និងសង្គមដែលបានកើនឡើង។ នៅដើមឆ្នាំនេះ ថវិកាឆ្នាំ 2020 ត្រូវបានប្រើប្រាស់ជាថវិកាជំរុញ ដើម្បីកាត់បន្ថយការប៉ះពាល់អវិជ្ជមានដែលរំពឹងថាកើតឡើងដោយសារតែការឲ្យការអនុគ្រោះពន្ធ "អ្វីគ្រប់យ៉ាងលើកលែងតែអាវុធ"។

### ដើម្បីផ្តល់ហិរញ្ញប្បទានដល់ឱនភាពសារពើពន្ធកាន់តែច្រើន បំណុលសាធារណៈត្រូវបានរំពឹងថានឹងកើនដល់ 35 ភាគរយនៃ ផសស គិតត្រឹមឆ្នាំ 2022

**ខណៈដែលផលធៀបរវាងបំណុលសាធារណៈ និង ផសស របស់កម្ពុជា នៅតែមានចំនួនក្រោម 30 ភាគរយនៃ ផសស រហូតដល់ឆ្នាំ 2019 ផលធៀបនេះត្រូវបានព្យាករណ៍ថានឹងកើនឡើងយ៉ាងលឿនចាប់ពីឆ្នាំនេះទៅ ដោយសារតែការកើនឡើងនៃឱនភាពសារពើពន្ធ។** ផលធៀបរវាងបំណុល និង ផសស របស់កម្ពុជាត្រូវបានរំពឹងថានឹងមានចំនួន 35 ភាគរយ គិតត្រឹមបំណាច់ឆ្នាំ 2022។ នៅឆ្នាំ 2020 អាជ្ញាធរកម្ពុជាគ្រោងនឹងប្រើប្រាស់ប្រាក់សន្សំរបស់រដ្ឋាភិបាល ហើយហិរញ្ញប្បទានក្នុងស្រុកត្រូវបានព្យាករណ៍ថានឹងមានចំនួន 5.3 ភាគរយនៃ ផសស។ នៅឆ្នាំ 2019 ប្រាក់សន្សំរបស់រដ្ឋាភិបាលមានចំនួន 20.2 ភាគរយនៃ ផសស (ឬស្មើនឹង 22.2 ទ្រីលានរៀល) បន្ទាប់ពីមានការកើនឡើងជាច្រើនឆ្នាំ។ ដោយសារតែមានសន្ទនីយភាពយ៉ាងច្រើន អាជ្ញាធរកម្ពុជានឹងមិនប្រើប្រាស់ហិរញ្ញប្បទានក្នុងស្រុក (ធនាគារជាតិ) ដើម្បីបំពេញឱនភាពសារពើពន្ធរួមនោះទេ។

**នៅឆ្នាំ 2019 ការវិភាគពីនិរន្តរភាពបំណុល ដោយប្រើប្រាស់ក្របខ័ណ្ឌនិរន្តរភាពបំណុលរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ/ធនាគារពិភពលោក សម្រាប់ប្រទេសដែលមានប្រាក់ចំណូលទាប (LIC-DSF) បង្ហាញថា កម្ពុជានៅតែមានហានិភ័យទាបផ្នែកវិបត្តិបំណុលខាងក្រៅ**[31]។ យ៉ាងណាក៏ដោយ ទិន្នន័យដើមគ្រាបានប្រែប្រួលចាប់តាំងពីការវិភាគពីនិរន្តរភាពបំណុលនៅឆ្នាំ 2019។ ផ្អែកតាមការប៉ាន់ស្មានថាឱនភាពសារពើពន្ធនឹងមានចំនួន 9 ភាគរយ និង 99.6 ភាគរយនៃបំណុលខាងក្រៅ (និងក្នុងរូបិយប័ណ្ណខាងក្រៅ) តម្រូវការហិរញ្ញប្បទានពីបរទេស នឹងមានចំនួនច្រើន ហើយអត្រាប្តូរប្រាក់នឹងទទួលរងសម្ពាធថែមទៀត។

**គិតត្រឹមបំណាច់ឆ្នាំ 2019 កម្ពុជាមានបំណុលសាធារណៈមិនទាន់សងចំនួន 7.6 ពាន់លានដុល្លារអាមេរិក** (រូប 26)[32] ក្នុងនោះ បំណុលសាធារណៈចំនួន 0.04 ភាគរយ ឬស្មើនឹងទឹកប្រាក់ 2.74 លានដុល្លារអាមេរិក ជាបំណុលសាធារណៈក្នុងស្រុក។ ជារួម លក្ខខណ្ឌកម្ចីនៅតែមានលក្ខណៈជាសម្បទានភាគច្រើន ដោយអត្រាការប្រាក់ (មធ្យម), រយៈពេលកំណត់សង និង រយៈពេលពន្យារពេលសង មានចំនួន 0.8 ភាគរយសម្រាប់អត្រាការប្រាក់, 28.51 ភាគរយសម្រាប់រយៈពេលកំណត់សង និង 7.87 ភាគរយសម្រាប់រយៈពេលពន្យារពេលសង។ គិតតាមរូបិយប័ណ្ណសំខាន់ៗ បំណុលមិនទាន់សងគិតជាប្រាក់ដុល្លារអាមេរិក មានចំនួនច្រើនជាងគេរហូតដល់ 43.9 ភាគរយនៃបំណុលមិនទាន់សងសរុប។ បំណុលសាធារណៈមិនទាន់សងជាសិទ្ធិដកប្រាក់ពិសេស និងប្រាក់យ័នចិន មានចំនួន 25.9 ភាគរយសម្រាប់សិទ្ធិដកប្រាក់ពិសេស និង 14.6 ភាគរយសម្រាប់ប្រាក់យ័នចិន។

**រូប 25 ៖ ចំណាយសាធារណៈក៏កើនឡើងដោយសារការចំណាយលើទំនិញ និងសេវា**

(ភាគរយនៃ ផសស)




*ប្រភព* ៖ អាជ្ញាធរកម្ពុជា និងការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក
*សម្គាល់* ៖ e=ប៉ាន់ស្មាន

**រូប 26 ៖ បំណុលសាធារណៈមិនទាន់សងរបស់កម្ពុជា តាមឥណទានយក**

(លានដុល្លារអាមេរិក និងភាគរយនៃបំណុលសរុប)




*ប្រភព* ៖ អាជ្ញាធរកម្ពុជា
*សម្គាល់* ៖ ADB= ធនាគារអភិវឌ្ឍន៍អាស៊ី; RoK=សាធារណរដ្ឋកូរ៉េ; WBG=ក្រុមធនាគារពិភពលោក

31 របាយការណ៍របស់បុគ្គលិកមូលនិធិរូបិយវត្ថុអន្តរជាតិ សម្រាប់ការពិគ្រោះអត្ថបទទី 4 ឆ្នាំ 2019, ការវិភាគពីនិរន្តរភាពបំណុល ៖ https://www.imf.org/en/Publications/CR/Issues/2019/12/23/Cambodia-2019-Article-IV-Consultation-Press-Release-Staff-Report-and-Statement-by-the-48912។

32 ព្រឹត្តិប័ត្រស្ថិតិបំណុលសាធារណៈរបស់កម្ពុជា លេខ 9 ខែ មីនា ឆ្នាំ 2020 ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

### ចិននៅតែជាប្រភពផ្តល់កម្ចីច្រើនជាងគេ ហើយបំណុលដែលកម្ពុជាជំពាក់ចិនមានជិតពាក់កណ្តាលនៃបំណុលសរុប

**គិតត្រឹមបំណាច់ឆ្នាំ 2019 បំណុលសាធារណៈដែលកម្ពុជាជំពាក់ចិនមានចំនួន 3.6 ពាន់លានដុល្លារអាមេរិក** ដែលស្មើនឹង 47.4 ភាគរយនៃបំណុលសរុប ឬ 66 ភាគរយនៃបំណុលទ្វេភាគី។ ប្រភពផ្តល់កម្ចីច្រើនជាងគេទីពីរ ដែលជាស្ថាប័នពហុភាគី គឺ ធនាគារអភិវឌ្ឍន៍អាស៊ី (18.8 ភាគរយ) ចំណែកប្រភពផ្តល់កម្ចីច្រើនជាងគេទីបី គឺ ធនាគារពិភពលោក (7.7 ភាគរយ)។ ជប៉ុនគឺជាប្រភពផ្តល់កម្ចីច្រើនជាងគេទីបួនរបស់កម្ពុជា (5.4 ភាគរយ) ចំណែកសាធារណរដ្ឋកូរ៉េ ជាប្រភពផ្តល់កម្ចីច្រើនជាងគេទីប្រាំ (5 ភាគរយ) នៅឆ្នាំ 2019។ បំណុលចាស់មានចំនួន 8.3 ភាគរយនៃបំណុលមិនទាន់សងសរុប (ក្នុងនោះ បំណុលចំនួន 1.8 ភាគរយត្រូវបានកំណត់កាលបរិច្ឆេទសងឡើងវិញ)។

## ទស្សនៈវិស័យ

### សេដ្ឋកិច្ចកម្ពុជាកំពុងទទួលរងការប៉ះពាល់យ៉ាងខ្លាំងដោយសារការផ្ទុះជំងឺកូវីដ 19

**សេដ្ឋកិច្ចកម្ពុជាដែលមានទំហំតូច និងបើកទូលាយ បានរងការប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយសារការផ្ទុះជំងឺកូវីដ 19 ជាសកល។** ដូចការពិភាក្សាខាងលើ ការផ្ទុះជំងឺកូវីដ 19 បានធ្វើឱ្យសកម្មភាពសេដ្ឋកិច្ចភាគច្រើនធ្លាក់ចុះយ៉ាងខ្លាំង ហើយការធ្លាក់ចុះនៃសកម្មភាពសេដ្ឋកិច្ចមួយចំនួន បានរាំងស្ទះដល់កំណើនសេដ្ឋកិច្ចរបស់កម្ពុជា។ ការព្យួរផ្នែកខ្លះនៃការអនុគ្រោះពន្ធពាណិជ្ជកម្ម "អ្វីគ្រប់យ៉ាងលើកលែងតែអាវុធ" របស់សហភាពអឺរ៉ុប បានដាក់សម្ពាធបន្ថែមទៀតលើវិស័យកម្មន្តសាលសម្រាប់ការនាំចេញរបស់កម្ពុជា។

**លើសពីនេះទៀត ការប៉ះពាល់ឆ្លងវិស័យដែលអាចកើតមានលើវិស័យមីក្រូហិរញ្ញវត្ថុ ក៏កំពុងធ្វើឲ្យមានការព្រួយបារម្ភដែរ។** ទិន្នន័យពីការអង្កេតសង្គមសេដ្ឋកិច្ចកម្ពុជាឆ្នាំ 2017 បង្ហាញថា គ្រួសារនៅជនបទចំនួន 40 ភាគរយ ជំពាក់បំណុលគេ។ ដោយសារតែកំណើននៃការផ្តល់សេវាហិរញ្ញវត្ថុក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមក អត្រាជំពាក់បំណុលបច្ចុប្បន្នរបស់គ្រួសារនៅជនបទក្នុងប្រទេសកម្ពុជាអាចនឹងមានកម្រិតជាង 40 ភាគរយ។ ខណៈដែលឧស្សាហកម្មសម្លៀកបំពាក់ ស្បែកជើង និងទំនិញធ្វើដំណើរ ផ្តល់ការងារយ៉ាងច្រើនដល់ពលករជនបទ (ស្ត្រី) គ្រួសារជនបទនឹងការប៉ះពាល់យ៉ាងខ្លាំងដោយសារតែការបាត់បង់ប្រាក់ចំណូលដោយសារការបិទរោងចក្រផលិតសម្លៀកបំពាក់ ស្បែកជើង និងទំនិញធ្វើដំណើរ។ ការអង្កេតសង្គមសេដ្ឋកិច្ចកម្ពុជាបង្ហាញថា កម្ចី និងឥណទានមិនទាន់សងពីវិស័យមីក្រូហិរញ្ញវត្ថុ (និងប្រតិបត្តិការឥណទាន) មានចំនួន 52.3 ភាគរយនៃបំណុលដែលគ្រួសារនៅជនបទជំពាក់[33]។

**ការធ្លាក់ចុះនៃវិស័យដែលជាក្បាលម៉ាស៊ីនជំរុញសេដ្ឋកិច្ចមិនត្រឹមតែធ្វើឱ្យប៉ះពាល់ដល់កំណើនសេដ្ឋកិច្ចប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធ្វើឱ្យអត្រានិកម្មភាពកើនជិត 20 ភាគរយទៀតផង។** ការងារយ៉ាងតិចចំនួន 1.76 លាន ដែលកំពុងប្រឈមនឹងហានិភ័យដោយសារការផ្ទុះជំងឺកូវីដ 19 គឺជាការងារផ្ទាល់។ ផលវិបាកចំពោះការងារមានទំហំធំធេងជាងនេះ ប្រសិនបើបញ្ចូលទាំងការងារប្រយោល (ការងារដែលជាផលនៃសកម្មភាពបន្ថែមក្នុងវិស័យទេសចរណ៍ វិស័យនាំចេញ និងវិស័យសំណង់) ការងារបន្ទាប់បន្សំ (ការងារបន្ថែមចេញពីប្រយោជន៍នៃវិស័យទាំងបីនេះ) និងផលប៉ះពាល់បន្ទាប់បន្សំ។

### ក្រោមសេណារីយ៉ូគោល កំណើនពិតត្រូវបានព្យាករណ៍ថានឹងថយចុះអវិជ្ជមាន 1 ភាគរយនៅឆ្នាំ 2020

**កំណើនក្រោមសេណារីយ៉ូគោល ត្រូវបានព្យាករណ៍ថានឹងថយចុះចំនួន 1 ភាគរយ** នៅឆ្នាំ 2020 ហើយនឹងកើនដល់ 6 ភាគរយនៅឆ្នាំ 2021 ដោយទទួលបានការគាំទ្រដោយកំណើនតម្រូវការសកល (តារាង 1)។ សេណារីយ៉ូគោលសន្មតពីការងើបឡើងនៃកំណើនសកលដោយសារតែកំណើនបន្តិចម្តងៗនៃតម្រូវការសកល នៅពេលដែលការហាមឃាត់ការធ្វើដំណើរចេញចូលត្រូវបានបន្ធូរបន្ថយនៅឆមាសទីពីរក្នុងឆ្នាំ 2020 ខណៈដែលស្ថានភាពសេដ្ឋកិច្ចក្នុងស្រុកមានភាពប្រសើរឡើងដោយមិនប៉ះពាល់ជាអវិជ្ជមានយូរអង្វែងដោយសារការហាមឃាត់ការធ្វើដំណើរចេញចូលលើវិស័យសាជីវកម្ម វិស័យធនាគារ ឬសមតុល្យនៃការទូទាត់។ ចំណុចសំខាន់គឺថា សេណារីយ៉ូគោលសន្មតពីការថយចុះបន្តិចនៃសសរស្តម្ភ ឬក្បាលម៉ាស៊ីនជំរុញសេដ្ឋកិច្ចសំខាន់ៗរបស់កម្ពុជា ជាពិសេសឧស្សាហកម្មទេសចរណ៍ និងបដិសណ្ឋារកិច្ច បានរងការប៉ះពាល់យ៉ាងធ្ងន់ធ្ងរ និងត្រូវបានព្យាករណ៍ថានឹងកើនឡើងបន្តិចនៅឆមាសទីពីរនៃឆ្នាំ 2020 ដោយសារតែការដកការរឹតត្បិតលើការធ្វើដំណើរ និងការហាមឃាត់ការធ្វើដំណើរចេញចូលក្នុងស្រុក ដែលធ្វើឱ្យវិស័យសេវាមានកំណើនទាប។ វិបត្តិតម្រូវការខាងក្រៅកាន់តែមានកម្រិតខ្ពស់ ហើយអាចនឹងធ្វើឱ្យមានការធ្លាក់ចុះនៃវិស័យសម្លៀកបំពាក់ស្បែកជើង និងទំនិញធ្វើដំណើរ នៅត្រីមាសទីបីក្នុងឆ្នាំ 2020។ ទោះជាយ៉ាងណាក៏ដោយ វិស័យនាំចេញត្រូវបានរំពឹងថានឹងងើបឡើងយឺតៗចាប់ត្រីមាសទីបួនក្នុងឆ្នាំ 2020 នេះតទៅ ដោយសារតែសេដ្ឋកិច្ចសកលកំពុងបង្ហាញពីសញ្ញាងើបឡើងវិញក្រោយពេលមានវិបត្តិ មុនការផ្ទុះវីរុសក្សូណា (សម្រាប់ព័ត៌មានលម្អិត សូមមើលប្រអប់ 3)។ លំហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេសត្រូវបានព្យាករណ៍ថានឹងមានកំណើនយឺតៗនៅឆមាសទីពីរក្នុងឆ្នាំ 2020។

33 ការអង្កេតសង្គមសេដ្ឋកិច្ចកម្ពុជា ឆ្នាំ 2017 វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ ៖ https://www.nis.gov.kh/nis/CSES/Final%20Report%20CSES%202017.pdf ។

## ទស្សនៈវិស័យ និងហានិភ័យនៅកម្រិតសកល និងតំបន់

**សេដ្ឋកិច្ចសកលកំពុងបង្ហាញពីការងើបឡើងវិញក្រោយការធ្លាក់ចូលក្នុងវិបត្តិហិរញ្ញវត្ថុសកល មុនពេលមានការផ្ទុះឡើងនៃវីរុសក្លូណានាពេលថ្មីៗនេះ។** ការងើបឡើងវិញនៃសេដ្ឋកិច្ចត្រូវបានគាំទ្រដោយការថយចុះភាពមិនប្រាកដប្រជានៃគោលនយោបាយពាណិជ្ជកម្ម និងការងើបឡើងនៃលំហូរ និងការវិនិយោគពាណិជ្ជកម្មសកល។ ការព្យាកររបស់ធនាគារពិភពលោកក្នុងឯកសារ “ទស្សនៈវិស័យសេដ្ឋកិច្ចសកល” ខែ មករា ឆ្នាំ2020 បានប៉ាន់ប្រមាណថា សេដ្ឋកិច្ចសកលនឹងកើនចំនួន 2.5 ភាគរយនៅឆ្នាំ 2020 និងបញ្ជាក់ថា កំណើននេះនឹងកើនដល់ 2.7 ភាគរយនៅឆ្នាំ 2022 ផ្អែកលើការងើបឡើងបន្តិច ម្ដងៗនៃការវិនិយោគ និងពាណិជ្ជកម្ម និងការងើបឡើងនៃបណ្ដាប្រទេសរីកចម្រើនជាច្រើនដែលកំពុងងើបឡើងវិញពីការធ្លាក់ចុះយ៉ាងខ្លាំងនោះ។ មុនការផ្ទុះជំងឺកូវីដ 19 កំណើនរបស់បណ្ដាប្រទេសជឿនលឿនត្រូវបានព្យាករណ៍ថាថយចុះចំនួន 1.4 ភាគរយនៅឆ្នាំ 2020 មុននឹងកើនចំនួន 1.5 ភាគរយនៅអំឡុងឆ្នាំ 2021-22។ កំណើនរបស់ទីផ្សារដែលងើបឡើង និងប្រទេសកំពុងអភិវឌ្ឍន៍ ត្រូវបានរំពឹងថានឹងកើនចំនួន 4.1 ភាគរយនៅឆ្នាំ 2020 និងមានកំណើនថេរចំនួន 4.4 ភាគរយនៅអំឡុងឆ្នាំ 2021-22 ដោយល្បឿននៃការងើបឡើងវិញត្រូវបានរាំងស្ទះដោយការថយចុះនៃតម្រូវការជាសកល និងឧបសគ្គផ្នែករចនាសម្ព័ន្ធ (ធនាគារពិភពលោក 2020a)។

**ការងើបឡើងវិញនេះត្រូវបានរាំងស្ទះដោយការផ្ទុះវីរុសក្លូណា។** ការរីករាលដាលយ៉ាងលឿននៃវីរុសក្លូណានៅក្រៅប្រទេសចិន បានបង្កការរាំងស្ទះយ៉ាងខ្លាំងលើទស្សនៈវិស័យសេដ្ឋកិច្ចសកល និងធ្វើឱ្យមានការកែសម្រួលឡើងវិញលើការព្យាករកំណើន ផសស ក្នុងបណ្ដាប្រទេសរីកចម្រើន និងក្នុងចំណោមទីផ្សារដែលងើបឡើង និងប្រទេសកំពុងអភិវឌ្ឍន៍ភាគច្រើន។ ជំងឺកូវីដ 19 កំពុងប៉ះពាល់យ៉ាងខ្លាំងលើតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ប៉ុន្តែ ជម្រៅ និងរយៈពេលនៃវិបត្តិនេះ មិនអាចស្មានដឹងបានទេ (ធនាគារពិភពលោក 2020b)។ ការប៉ះពាល់សរុបនៃវិបត្តិនេះលើលទ្ធផលកំណើននឹងអាស្រ័យលើ រយៈពេល និងជម្រៅនៃការផ្ទុះជំងឺកូវីដ 19 ការបន្តប៉ះពាល់ពីខាងក្រៅ និងទំហំ និងប្រសិទ្ធភាពនៃវិធានការកាត់បន្ថយផលប៉ះពាល់។

**ឯកសារដែលទើបបានបោះពុម្ពផ្សាយរបស់ធនាគារពិភពលោកដែលមានចំណងជើងថា “បច្ចុប្បន្នភាពសេដ្ឋកិច្ចអាស៊ីប៉ូព៌ា និងប៉ាស៊ីហ្វិក” បានបង្ហាញពីសេណារីយ៉ូពីរនៃទស្សនៈវិស័យថ្នាក់តំបន់។** ក្នុងសេណារីយ៉ូគោល បន្ទាប់ពីការធ្លាក់ចុះ នឹងមានការងើបឡើងវិញ ដែលធ្វើឱ្យកំណើន ផសស ថ្នាក់តំបន់នៅឆ្នាំ 2020 មានចំនួន 2.1 ភាគរយ ថយពី 5.8 ភាគរយនៅឆ្នាំ 2019។ ក្នុងសេណារីយ៉ូនេះ កំណើនថ្នាក់តំបន់មានកម្រិតថេរ គិតត្រឹមបំណាច់ឆ្នាំ 2021។ សេណារីយ៉ូនេះសន្មតថា ការទប់ស្កាត់ជំងឺកូវីដ 19 ធ្វើឱ្យមានការស្ដារសកម្មភាពសេដ្ឋកិច្ចជាដំបូងក្នុងប្រទេសចិន រួចទើបមានការស្ដារសកម្មភាពសេដ្ឋកិច្ចក្នុងបណ្ដាប្រទេសផ្សេងៗទៀត។ សេណារីយ៉ូដែលទាបបំផុត ព្យាករណ៍ថា បន្ទាប់ពីការធ្លាក់ចុះខ្លាំងនឹងមានការងើបឡើងយឺតៗ។ ក្នុងសេណារីយ៉ូនេះ ជំងឺកូវីដ 19 នឹងបន្តឆ្លងរាតត្បាត រយៈពេលយូរ និងប៉ះពាល់កាន់តែធ្ងន់ធ្ងរជាងការស្មាន។

**ក្នុងសេណារីយ៉ូដែលទាបបំផុត កំណើនក្នុងបណ្ដាប្រទេសកំពុងអភិវឌ្ឍន៍ក្នុងតំបន់អាស៊ីប៉ូព៌ា និងប៉ាស៊ីហ្វិក ត្រូវបានព្យាករណ៍ថានឹងមានថយចុះ** ពី 5.8 ភាគរយនៅឆ្នាំ 2019 មកត្រឹម 2.1 ភាគរយនៅឆ្នាំ 2020។ ក្នុងសេណារីយ៉ូដែលទាបបំផុត ផលិតផលនឹងថយចុះចំនួន 0.5 ភាគរយ។ កំណើនក្នុងប្រទេសចិនត្រូវបានព្យាករណ៍ថានឹងមានចំនួន 2.3 ភាគរយនៅឆ្នាំ 2020 ក្នុងសេណារីយ៉ូគោល ថយពីចំនួន 6.1 ភាគរយនៅឆ្នាំ 2019 ចំណែកក្នុងសេណារីយ៉ូដែលទាបបំផុត កំណើននេះអាចមានចំនួនត្រឹមតែ 0.1 ភាគរយ។ កំណើនក្នុងតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក (មិនរាប់បញ្ចូលប្រទេសចិន) ត្រូវបានព្យាករណ៍ថានឹងថយចុះពីចំនួន 4.8 ភាគរយនៅឆ្នាំ 2019 មកត្រឹម 1.3 ភាគរយនៅឆ្នាំ 2020 ក្នុងសេណារីយ៉ូគោល និងថយចុះដល់ចំនួន - 2.8 ភាគរយក្នុងសេណារីយ៉ូដែលទាបបំផុត។ បើសិនជាគ្មានការប៉ះទង្គិចថ្មីដែលមិនរំពឹងទុក និងវិបត្តិទីផ្សារហិរញ្ញវត្ថុអូសបន្លាយនៅពេលមានការធ្លាក់ចុះសេដ្ឋកិច្ចកាន់តែខ្លាំង ការងើបឡើងវិញនៅឆ្នាំ 2021 ត្រូវបានរំពឹងថានឹងកាន់តែមានសន្ទុះលឿន។

**នៅក្នុងប្រទេសជាច្រើន វិបត្តិហិរញ្ញវត្ថុដែលអាចមាននឹងប៉ះពាល់កាន់តែខ្លាំងលើសេដ្ឋកិច្ច។** ផលប៉ះពាល់ខ្លាំងបំផុតលើដំណើរការបច្ចុប្បន្ន និងដំណើរការនាពេលអនាគតរបស់បណ្ដាប្រទេសទាំងនេះ អាចេញពីទីផ្សារហិរញ្ញវត្ថុ ដោយសារតែវិសាលភាពនៃវិបត្តិហិរញ្ញវត្ថុ និងភាពងាយរងគ្រោះនៃវិស័យនេះ។ បណ្ដាប្រទេសកំពុងអភិវឌ្ឍន៍ក្នុងតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក មានភាពទន់ខ្សោយផ្សេងៗគ្នា។ ឧ. ប្រទេសចិន វៀតណាម ម៉ាឡេស៊ី និងថៃ ងាយរងគ្រោះដោយសារការកើនឡើងនៃបំណុលក្នុងស្រុក។ ប្រទេសកម្ពុជា ឡាវ ម៉ាឡេស៊ី ម៉ុងហ្គោលី និងប៉ាពួញូហ្គីណេ ងាយរងគ្រោះដោយសារបំណុលខាងក្រៅ ចំណែកប្រទេសម៉ាឡេស៊ី និងថៃ ងាយរងគ្រោះដោយសារការពឹងផ្អែកយ៉ាងខ្លាំងលើបំណុលរយៈពេលខ្លី។

**ស្ថានភាពសេដ្ឋកិច្ចសកលត្រូវបានរំពឹងថានឹងប្រឈមនឹងវិបត្តិក្នុងអំឡុងពេលព្យាករណ៍នេះ។** ស្ថានភាពហិរញ្ញប្បទានសកលត្រូវបានរំពឹងថានឹងមានភាពស្មុគស្មាញ និងងាយប្រែប្រួលយ៉ាងខ្លាំង។ យោងតាមអង្គការពាណិជ្ជកម្មពិភពលោក (WTO) ពាណិជ្ជកម្មពិភពលោកត្រូវបានរំពឹងថានឹងថយចុះចន្លោះពី 13 ភាគរយទៅ 32 ភាគរយនៅឆ្នាំ 2020 ហើយនឹងមានកម្រិតខ្ពស់ជាងកម្រិតនៅពេលមានការធ្លាក់ចុះនៃពាណិជ្ជកម្មនៅអំឡុងវិបត្តិហិរញ្ញវត្ថុសកលឆ្នាំ 2008-09។ ការផ្ទុះវីរុសក្លូណាបានដាក់សម្ពាធបន្ថែមទៀតលើតម្លៃទំនិញ ជាពិសេស តម្លៃថាមពលដែលនឹងធ្លាក់ចុះកាន់តែខ្លាំងដោយសារតែការផ្គត់ផ្គង់ប្រេងលើសនៅពេលដែលសមាជិកអង្គការ OPEC+ បង្កើនផលិតកម្មប្រេងឱ្យបានជាអតិបរមាឡើងវិញ។ ការធ្លាក់ថ្លៃប្រេងនៅពេលថ្មីៗនេះបង្ហាញពីក្ដីរំពឹងទុកថា តម្រូវការនឹងកាន់តែថយចុះជាងការប៉ាន់ស្មានកន្លងមក ព្រោះការផ្ទុះវីរុសក្លូណាបានកាត់បន្ថយសកម្មភាពសេដ្ឋកិច្ចសកល និងការធ្វើដំណើរ និងការដឹកជញ្ជូនតាមផ្លូវអាកាស ដែលជាវិស័យដែលត្រូវការប្រេងច្រើន។ ក្រៅពីនេះ មានការធ្លាក់ថ្លៃនៃទំនិញក្នុងឧស្សាហកម្មផ្សេងៗទៀត ដោយសារតែការឆ្លើយតបទៅនឹងការផ្ទុះវីរុសក្លូណា។ ក្នុងនោះ តម្លៃទង់ដែង ថយចុះជាង 20 ភាគរយចាប់តាំងពីដើមខែមករា។ ជារួម តម្លៃលោហធាតុត្រូវបានរំពឹងថានឹងថយចុះនៅឆ្នាំ 2020 ដែលបង្ហាញពីការថយចុះនៃតម្រូវការទំនិញឧស្សាហកម្ម ជាពិសេសទំនិញនាំចូលពីប្រទេសចិន។ ផលិតផលកសិកម្មត្រូវបានប៉ាន់ស្មានថានឹងមានតម្លៃថេរនៅឆ្នាំ 2020 បន្ទាប់ពីបានធ្លាក់ថ្លៃនៅឆមាសទីពីរក្នុងឆ្នាំ 2019 ដោយសារភាពប្រសើរឡើងនៃការផ្គត់ផ្គង់។

**តុល្យភាពនៃហានិភ័យធៀបនឹងទស្សនៈវិស័យមានទំនោរទៅភាពអវិជ្ជមាន។** ហានិភ័យសំខាន់ៗ រួមមាន លទ្ធភាពដែលជំងឺកូវីដ 19 កាន់តែអូសបន្លាយ និងមានការប៉ះពាល់កាន់តែធ្ងន់ធ្ងរ និងយូរអង្វែងលើសេដ្ឋកិច្ចសកល។ ក្រៅពីនេះទៀត ទោះបីជាមានកញ្ចប់ជួយគាំទ្រផ្នែកគោលនយោបាយធំៗក្ដី ក៏បញ្ហារំជើបរំជួលក្នុងទីផ្សារហិរញ្ញវត្ថុក្នុងបណ្ដាប្រទេសជឿនលឿន អាចបន្តកើតមានជាច្រើនខែ និងធ្វើឱ្យមានលំហូរមូលធនចេញកាន់តែច្រើនពីទីផ្សារដែលងើបឡើង និងប្រទេសកំពុងអភិវឌ្ឍន៍។ លក្ខខណ្ឌហិរញ្ញប្បទានកាន់តែតឹងនឹងកាត់បន្ថយកំណើនរបស់ទីផ្សារដែលងើបឡើង និងប្រទេសកំពុងអភិវឌ្ឍន៍។ ស្ថានភាពនេះអាចធ្វើឲ្យកាន់តែមានបញ្ហាលើចំណុចខ្សោយផ្នែកជញ្ជីតុល្យភាពនៅក្នុងប្រទេសដែលពឹងផ្អែកលើប្រទេសខាងក្រៅ និងអាចធ្វើឲ្យមានការជាប់គាំង និងវិបត្តិហិរញ្ញវត្ថុក្នុងបណ្ដាប្រទេសងាយរងគ្រោះបំផុត។ ពាណិជ្ជកម្មសកលប្រហែលជាបន្តមានបញ្ហារយៈពេលយូរ ដែលធ្វើឱ្យមានការបែកខ្ញែកសង្វាក់តម្លៃពិភពលោក និងតំបន់។ ភាពមិនប្រាកដប្រជានៃគោលនយោបាយពាណិជ្ជកម្មក៏នៅតែបង្កហានិភ័យចំពោះទស្សនៈវិស័យនេះផងដែរ។

*សម្គាល់* ៖ ប្រអប់នេះត្រូវបានរៀបរៀងឡើងដោយ Ekaterine Vashakmadze ។

**តារាង 1 ៖ ទស្សនវិស័យម៉ាក្រូសេដ្ឋកិច្ចក្រោមសេណារីយ៉ូគោល និងសេណារីយ៉ូដែលទាបបំផុត**

| កំណើន ផសស ពិត គិតតាមតម្លៃថេរ (ការប្រែប្រួលជាភាគរយធៀបនឹងឆ្នាំមុន) | 2020 | 2021 | 2022 |
|---|---|---|---|
| **សេណារីយ៉ូគោល** | | | |
| កសិកម្ម | 0.3 | 0.4 | 0.5 |
| ឧស្សាហកម្ម | -1.0 | 9.2 | 9.3 |
| សេវា | -1.7 | 5.8 | 5.8 |
| កំណើន ផសស | -1.0 | 6.0 | 6.3 |
| **សេណារីយ៉ូដែលទាបបំផុត** | | | |
| កសិកម្ម | 0.3 | 0.4 | 0.5 |
| ឧស្សាហកម្ម | -2.1 | 7.2 | 9.3 |
| សេវា | -3.9 | 7.8 | 6.1 |
| កំណើន ផសស | -2.9 | 3.9 | 6.3 |

*ប្រភព* ៖ ការព្យាកររបស់បុគ្គលិកធនាគារពិភពលោក

### នៅក្នុងសេណារីយ៉ូទាបបំផុត ផសស ពិត ត្រូវបានព្យាករណ៍ថានឹងថយចុះអវិជ្ជមាន 2.9 ភាគរយនៅឆ្នាំ 2020

**ផសស ពិត ត្រូវបានព្យាករណ៍ថានឹងថយចុះបន្តិចចំនួន 2.9 ភាគរយនៅឆ្នាំ 2020 នៅក្នុងសេណារីយ៉ូទាបបំផុត។** សេណារីយ៉ូទាបបំផុតសន្មតថា ការហាមឃាត់ការធ្វើដំណើរចេញចូល និងការរឹតត្បិតជាសកល នៅតែបន្តអនុវត្តរហូតដល់ត្រីមាសទីបីក្នុងឆ្នាំ 2020 ដោយប៉ះពាល់ជាអវិជ្ជមានពីកម្រិតមធ្យមទៅធ្ងន់ធ្ងរ ដែលធ្វើឲ្យមានបញ្ហាសន្ទនីយភាព និងក្លាយជាបញ្ហាសោធនភាពដែលប៉ះពាល់ដល់ក្រុមហ៊ុនសាជីវកម្ម និងសមតុល្យនៃការទូទាត់។ ខណៈដែលមានការព្យាករថា សេដ្ឋកិច្ចក្នុងសេណារីយ៉ូទាបបំផុត នឹងងើបឡើងយឺតៗ កំណើនពិតត្រូវបានព្យាករណ៍ថានឹងមានចំនួន 3.9 ភាគរយនៅឆ្នាំ 2021។ ទស្សនវិស័យកំណើនរយៈពេលខ្លីរបស់កម្ពុជានៅក្នុងសេណារីយ៉ូទាបបំផុតនេះ រួមបញ្ចូលការធ្លាក់ចុះខ្លាំងនៃសកម្មភាពក្នុងឧស្សាហកម្មទេសចរណ៍ និងបដិសណ្ឋារកិច្ច ដោយមានការថយចុះខ្លាំងនៃចំនួនភ្ញៀវទេសចរបរទេសរយៈពេលយូរ ដោយសារតែការអូសបន្លាយនៃការផ្ទុះជំងឺកូវីដ 19 ជាសកលក្នុងអំឡុងឆ្នាំ 2020។ សេណារីយ៉ូទាបបំផុតសន្មតពីការធ្លាក់ចុះយ៉ាងខ្លាំងនៃវិស័យឧស្សាហកម្មរបស់កម្ពុជាដោយសារតែវិបត្តិតម្រូវការ និងការធ្លាក់ចុះយ៉ាងខ្លាំងនៃការវិនិយោគផ្ទាល់ពីបរទេស ដែលបណ្ដាលមកពីភាពចលាចលរយៈពេលវែងក្នុងទីផ្សារហិរញ្ញវត្ថុ ខណៈដែលសកម្មភាពសំណង់នៅតែបន្តថយចុះក្នុងអំឡុងឆ្នាំ 2020។ យ៉ាងណាក៏ដោយ សេណារីយ៉ូទាបបំផុតមិនបានពិចារណាពីហានិភ័យហិរញ្ញវត្ថុដែលអាចកើតឡើងដោយសារតែទំនាក់ទំនងផ្នែកម៉ាក្រូហិរញ្ញវត្ថុនោះទេ។

**មានហានិភ័យជាច្រើនដោយសារតែវិស័យហិរញ្ញវត្ថុដែលមានឥទ្ធិពលខ្លាំងលើសលប់។** ភាពងាយរងគ្រោះជាច្រើនក្នុងវិស័យហិរញ្ញវត្ថុ អាចធ្វើឱ្យការប៉ះទង្គិចជំងឺកូវីដ 19 កាន់តែមានបញ្ហាថែមទៀត។ ភាពងាយរងគ្រោះទាំងនេះរួមមាន ការប្រមូលផ្ដុំឥណទានកម្រិតខ្ពស់ ហានិភ័យនៃភាគីកម្ចី កង្វះការត្រួតពិនិត្យតាមព្រំដែន និងកង្វះការត្រួតពិនិត្យផ្អែកតាមហានិភ័យ[34]។ ហានិភ័យសន្ទនីយភាពក៏នៅតែមានកម្រិតខ្ពស់ ព្រោះគ្រឹះស្ថានហិរញ្ញវត្ថុពឹងផ្អែកលើការផ្ដល់មូលនិធិពីបរទេស រួមទាំងពីធនាគារមេ (ដល់ធនាគារផ្សេងៗ)។ លំហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេសដែលប្រមូលផ្ដុំក្នុងវិស័យមួយចំនួនតូច (ធនាគារ សំណង់ និងអចលនទ្រព្យ) រួមនឹងការផ្ដល់កម្ចីដោយធនាគារដល់វិស័យសំណង់ និងអចលនទ្រព្យ បានបង្កជាហានិភ័យបន្ថែមទៀត។

## ជម្រើសគោលនយោបាយ

**ជម្រើសគោលនយោបាយក្នុងការឆ្លើយតបនឹងការផ្ទុះជំងឺកូវីដ 19 ត្រូវមានគោលបំណងដូចតទៅនេះ គឺ ទីមួយ ផ្ដល់ជំនួយសង្គ្រោះសេដ្ឋកិច្ចភ្លាមៗ និងបន្ទាន់ និងការពារសុខភាពសាធារណៈ ទីពីរ គាំទ្រការស្ដារសេដ្ឋកិច្ចឡើងវិញក្នុងរយៈពេលខ្លី និងទីបី ពង្រឹងភាពរឹងមាំនៃម៉ាក្រូសារពើពន្ធ និងសង្គមក្នុងរយៈពេលមធ្យម។** វិធានការបន្ទាន់បំផុតគឺត្រូវផ្ដល់ការគាំទ្រដល់គ្រួសារដើម្បីកាត់បន្ថយភាពក្រីក្រ។ វិធានការនេះរួមមានការប្រើប្រាស់កម្មវិធី និងជំនួយសង្គ្រោះដែលមានស្រាប់ និងការកំណត់យន្តការគាំទ្រជនក្រីក្រ និងងាយរងគ្រោះតាមរយៈជំនួយសង្គម ដើម្បីរក្សាស្ថានភាពរស់នៅរបស់ពួកគេ។ គោលនយោបាយអន្តរាគមន៍នេះកំពុងត្រូវបានអនុវត្តរួមជាមួយនឹងវិធានការឧបត្ថម្ភប្រាក់ឈ្នួល (សូមមើលប្រអប់ 1)។ ដើម្បីពង្រីកជំនួយសង្គម និងរបបធានារ៉ាប់រងសង្គមដែលមានស្រាប់របស់កម្ពុជា បន្ទាប់ពីការផ្ដល់កម្មវិធីសង្គ្រោះភ្លាមៗ ជាការសំខាន់ត្រូវពង្រឹងយន្តការដែលមានស្រាប់ ដើម្បីកំណត់អត្តសញ្ញាណជនក្រីក្រ តាមរយៈកម្មវិធីអត្តសញ្ញាណកម្មជនក្រីក្រ។ ចាំបាច់ត្រូវបន្តវិធានការឆ្លើយតបសំខាន់ៗក្នុងផ្នែកសុខភាពសាធារណៈបច្ចុប្បន្ន រួមទាំងការស្វែងរកករណីឆ្លង ការដាក់ឲ្យនៅដាច់ដោយឡែក ការធ្វើចត្តាឡីស័យដើម្បីតាមដានទំនាក់ទំនង។ ក្រៅពីនេះ ការធ្វើអនាម័យដៃ របៀបរបបក្នុងពេលក្អក និងការរក្សាគម្លាតសង្គម ត្រូវបន្តអនុវត្តជាវិធានការទប់ស្កាត់សំខាន់។ អាជ្ញាធរកម្ពុជាឆ្លើយតបបានយ៉ាងល្អទៅនឹងរលកទីមួយនៃការផ្ទុះជំងឺកូវីដ 19។ យ៉ាងណាក៏ដោយ ខណៈដែលជំងឺនេះមិនងាយផុតរលត់ទៅវិញ កម្ពុជាត្រូវត្រៀមខ្លួនក្នុងការឆ្លើយតបនឹងការផ្ទុះឡើងណាមួយនៅពេលអនាគត។

34 របាយការណ៍របស់បុគ្គលិកសម្រាប់ការពិគ្រោះ អត្ថបទទី 4 ឆ្នាំ 2019, មូលនិធិរូបិយវត្ថុអន្តរជាតិ។ សូមមើល ៖ https://www.imf.org/en/Publications/CR/Issues/2019/12/23/Cambodia-2019-Article-IV-Consultation-Press-Release-Staff-Report-and-Statement-by-the-48912

**ចាំបាច់ត្រូវមានផែនការបន្តប្រតិបត្តិការអាជីវកម្មដែលមានប្រសិទ្ធភាព និងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ដើម្បីធានានូវការផ្តល់កម្មវិធីសង្គ្រោះ និងសេវាដោយរលូន។** ផែនការនេះកំណត់ពីវិធានការត្រៀមក្នុងការកាត់បន្ថយការរំខានដល់ប្រតិបត្តិការរបស់អង្គភាព ក្នុងករណីមានវិបត្តិ តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល និងព័ត៌មានថ្មីៗ។ អាស្រ័យលើវិសាលភាព និងភាពធ្ងន់ធ្ងរនៃផលប៉ះពាល់នៃការផ្ទុះជំងឺកូវីដ 19 ការអនុវត្តផែនការទាំងនេះជាជំហានៗ ដែលប្រមូលផ្តុំមុខងារសំខាន់ៗទាំងអស់របស់រដ្ឋាភិបាល (រដ្ឋបាល ហិរញ្ញវត្ថុ និងសុខាភិបាល) ត្រូវរក្សាដំណើរការកម្រិតអប្បបរមា ដើម្បីជំរុញការផ្តល់ជំនួយស្បៀងអាហារសង្គ្រោះបន្ទាន់ ជំនួយសង្គ្រោះសេដ្ឋកិច្ច និងជំនួយសង្គ្រោះដល់សុខភាពសាធារណៈឱ្យបានរលូន។

**ប្រសិទ្ធភាពនៃការអន្តរាគមរបស់រដ្ឋាភិបាលនឹងមានសារៈសំខាន់ក្នុងការសម្រួលដល់ការស្តារសេដ្ឋកិច្ចឡើងវិញ។** ជំងឺកូវីដ 19 អាចនឹងប៉ះពាល់លើដំណើរការខាងមុខផ្នែកពាណិជ្ជកម្ម និងការវិនិយោគក្នុងតំបន់ និងទូទាំងសកលលោក ដោយរំពឹងថានឹងមានការកែប្រែខ្លាំងនៃគោលនយោបាយពាណិជ្ជកម្ម គោលនយោបាយអន្តោរប្រវេសន៍ និងលំហូរទំនិញ និងសេវា។ អាជ្ញាធរកម្ពុជាត្រូវពិចារណាពីការបង្កើនតម្រូវការក្នុងស្រុកនាពេលអនាគត ការការពារលទ្ធភាពទិញរបស់អ្នកប្រើប្រាស់ក្នុងស្រុកនៅពេលមានវិបត្តិខាងក្រៅដោយសារតែសុខភាពសាធារណៈ និង/ឬគ្រោះមហន្តរាយធម្មជាតិ និងការបង្កើនផលិតកម្មសម្រាប់ការប្រើប្រាស់ក្នុងស្រុក ដើម្បីពង្រឹងសេដ្ឋកិច្ចរបស់ខ្លួន។ ក្នុងបរិបទនេះ វិធានការអន្តរាគមន៍ដែលផ្តួចផ្តើមឡើងដោយអាជ្ញាធរកម្ពុជារួមមាន ការបន្ធូរបន្ថយពន្ធ និងការបង្កើនលទ្ធភាពរបស់អាជីវកម្មខ្នាតតូច និងសហគ្រាសគ្រួសារក្នុងការទទួលបានឥណទានដែលមានការប្រាក់ទាបដោយប្រើប្រាស់កម្មវិធីសហហិរញ្ញប្បទានរវាងធនាគារសហគ្រាសធុនតូច និងមធ្យមនៃកម្ពុជាដែលទើបតែបានបង្កើតឡើង និងអ្នកផ្តល់កម្ចីសម្រាប់ពាណិជ្ជកម្ម (ធនាគារ និងមីក្រូហិរញ្ញវត្ថុ)។ ប្រហាក់ប្រហែលគ្នានេះ មានការផ្តល់មូលធនចំនួន 50 លានដុល្លារអាមេរិកដល់ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម ដើម្បីគាំទ្រដល់ក្រុមហ៊ុនកែច្នៃកសិផល និងកសិអាជីវកម្មថ្មីៗ។ យ៉ាងណាក៏ដោយ ភាពជោគជ័យនៃវិធានការទាំងនេះពឹងផ្អែកលើការផ្តោតទៅលើក្រុមហ៊ុនខ្នាតតូច ខ្នាតមធ្យម និងខ្នាតធំប្រកបដោយប្រសិទ្ធភាព និងអាចធ្វើទៅបាន ប៉ុន្តែក្រុមហ៊ុនទាំងនោះគ្មានប្រភពហិរញ្ញប្បទានដែលមានការប្រាក់ទាប ដើម្បីបង្កើតការងារ ផ្តល់ប្រាក់ចំណេញ និងនាំចេញឡើយ។ ចំណុចនេះក៏ត្រូវរួមបញ្ចូលទាំងក្រុមហ៊ុនជាលក្ខណៈគ្រួសារ និងក្រុមហ៊ុនខ្នាតតូច ដែលធ្វើប្រតិបត្តិការក្នុងវិស័យទេសចរណ៍ លក់រាយ និងមានតម្លៃថោក ជាវិស័យដែលក្រុមហ៊ុនផ្គូវការ និងពាក់កណ្តាលផ្លូវការជាច្រើនអាចនឹងរងផលប៉ះពាល់ដោយសារជំងឺកូវីដ 19។

**វិធានការចុងក្រោយគឺការធានាភាពរឹងមាំផ្នែកសេដ្ឋកិច្ច និងសង្គមក្នុងរយៈពេលមធ្យមបន្ទាប់ពីពិភពលោកអាចគ្រប់គ្រងជំងឺកូវីដ 19 បាន។** ការផ្តោតឡើងវិញ និងការបង្កើនកិច្ចខិតខំប្រឹងប្រែង និងការពង្រឹងប្រភពដែលអាចជួបប្រទះការអាក់ខាន ឬត្រូវបានបង្វែរ ដើម្បីដោះស្រាយការផ្ទុះជំងឺកូវីដ 19 ឲ្យដំណើរការទៅមុខដោយមានកំណែទម្រង់សំខាន់ៗផ្នែករចនាសម្ព័ន្ធ និងសង្គម ពិតជាមានសារៈសំខាន់ណាស់។ ក្នុងន័យនេះ ត្រូវផ្តោតការយកចិត្តទុកដាក់ និងបង្កើនកិច្ចខិតខំប្រឹងប្រែងលើការបង្កើនភាពរឹងមាំនៃម៉ាក្រូសារពើពន្ធ ដោះស្រាយភាពងាយរងគ្រោះក្នុងវិស័យហិរញ្ញវត្ថុ ពង្រឹងភាពប្រកួតប្រជែងក្រៅប្រទេស និងការធ្វើពិពិធកម្ម ដើម្បីកាត់បន្ថយការប៉ះពាល់នៃវិបត្តិខាងក្រៅដែលអាចកើតឡើង ក៏ដូចជាការត្រៀមរួចរាល់នូវកម្មវិធីសង្គ្រោះ និងកម្មវិធីកិច្ចគាំពារសង្គម ដែលអាចដាក់ឲ្យដំណើរការ និង/ឬពង្រីកយ៉ាងរហ័សក្នុងគ្រាអាសន្ន។ ដើម្បីឱ្យសេដ្ឋកិច្ចមានភាពរឹងមាំ ចាំបាច់ត្រូវបង្កើនការសម្រួលដល់ការធ្វើធុរៈកិច្ច បរិយាកាសវិនិយោគ និងការកាត់បន្ថយតម្លៃថាមពល និងភស្តុភារបន្ថែមទៀត ដើម្បីធ្វើសមាហរណកម្មឡើងវិញជាមួយសង្វាក់តម្លៃក្នុងតំបន់ និងសកល ក្រោយអំឡុងពេលអាក់ខានដោយសារការផ្ទុះជំងឺកូវីដ 19។





អត្ថបទផ្តោតពិសេស

# គុណនេយ្យភាពរបស់គ្រូបង្រៀន និងលទ្ធផលនៃការសិក្សារបស់សិស្ស



# អត្ថបទផ្តោតពិសេស៖ គណនេយ្យភាពរបស់គ្រូបង្រៀន និងលទ្ធផលនៃការសិក្សារបស់សិស្ស[35]

## ករណីសិក្សាអំពីប្រភេទសាលារៀន

### ការពង្រឹងគណនេយ្យភាពដើម្បីកែលម្អគុណភាពអប់រំ[36]

#### សេចក្តីផ្តើម

**មានការទទួលស្គាល់ជាទូទៅថា អប់រំជាកូនសោរចាក់គន្លឹះអភិវឌ្ឍន៍មនុស្ស និងកំណើនប្រកបដោយចីរភាព។** រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តកំណែទម្រង់សំខាន់ៗ ដើម្បីលើកការអប់រំឲ្យកើនមួយកម្រិតទៀត។ ទោះបីលើកពីកម្រិតទាបក៏ដោយ ក៏ក្នុងរយៈពេលពីរទសវត្សចុងក្រោយនេះ ឱកាសកុមារទទួលការអប់រំបានកើនឡើងគួរឲ្យកត់សម្គាល់។ មានការប្រឹងប្រែងរួមគ្នាជាបន្តបន្ទាប់ដើម្បីកែលម្អគុណភាពនៃប្រព័ន្ធអប់រំ និងសេវាអប់រំ តាមរយៈការបង្កើនចំណាយ និងចាត់វិធានការសំខាន់ ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់បុគ្គលិកអប់រំ។ លទ្ធផលបង្ហាញថា ប្រាក់ខែគ្រូបង្រៀនចាប់ផ្តើមដំបូង កើនប្រមាណបីដងចាប់ពីឆ្នាំ២០១៣ ដល់ ឆ្នាំ២០១៩។

**ទោះបីជាយ៉ាងនេះក្តី ការសម្រេចបាននូវគុណភាពនៃលទ្ធផលសិក្សារបស់សិស្សនៅជាបញ្ហាប្រឈមដ៏ធំមួយ។** និយាយជារួមលទ្ធផលសិក្សារបស់សិស្សនៅទាប និងពុំបានកើនឲ្យប្រសើរតាំងពីឆ្នាំ២០១៣ដល់២០១៧ យោងលទ្ធផលវាយតម្លៃលទ្ធផលសិក្សាថ្នាក់ជាតិពីឆ្នាំ២០១៣ ដល់ ឆ្នាំ២០១៧ ។ ការវាយតម្លៃលទ្ធផលសិក្សាថ្នាក់ជាតិ មានលក្ខណៈវិទ្យាសាស្ត្រ គឺវាយតម្លៃលទ្ធផលសិក្សារបស់សិស្សថ្នាក់ទី៣ ទី៦ ទី៨ និងទី១១។ ការវាយតម្លៃបានបង្ហាញថា សិស្សនៅថ្នាក់ទី៦ និងទី៨ អាចឆ្លើយសំណួរបានប្រហែលពាក់កណ្តាលប៉ុណ្ណោះ។

**រដ្ឋាភិបាលបង្កើតសាលារៀនក្នុងទម្រង់ថ្មីចំនួនពីរ ក្នុងប្រព័ន្ធសាលារដ្ឋ គឺ សាលារៀនជំនាន់ថ្មី (NGS) និង សាលារៀនការគ្រប់គ្រងដោយផ្អែកលើលទ្ធផល (SBM)។** ការបង្កើតទម្រង់សាលារៀនពីរនេះ សំដៅលើកកម្ពស់គណនេយ្យភាពសាលារៀន និងលើកគុណភាពនៃការរៀនរបស់សិស្សឲ្យកើនខ្ពស់មួយកម្រិត។ សាលារៀនជំនាន់ថ្មី ទទួលបានការវិនិយោគបន្ថែមដែលអនុវត្តតាមស្តង់ដាគណនេយ្យភាព និងអភិបាលកិច្ច។ ការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល ផ្តោតលើការលើកកម្ពស់គណនេយ្យភាព ដោយមានសហគមន៍ចូលរួម។ សាលារៀនក្នុងទម្រង់ថ្មីទាំងពីរ បានបង្ហាញថា ការអនុវត្តប្រព័ន្ធគណនេយ្យភាពកម្រិតថ្មីនេះបង្កើនលទ្ធផលសិក្សាខ្ពស់។

**ការផ្តល់សេវាអប់រំប្រកបដោយគុណភាពមានសារៈសំខាន់ដើម្បីលើកទឹកចិត្តឲ្យសហគមន៍ចូលរួម ជាលទ្ធផលគឺ ប្រព័ន្ធអប់រំកើនទៅរកភាពល្អប្រសើរ។** ការអប់រំមានឥទ្ធិពលលើជីវិតរបស់សិស្ស និងឪពុកម្តាយ ព្រោះឪពុកម្តាយចង់ឲ្យកូនបានរៀនចប់។ នៅពេលឪពុកម្តាយបានចូលរួមលើកកម្ពស់ការសម្រេចលទ្ធផលនៃការរៀនរបស់កូន ឪពុកម្តាយនឹងចូលរួមជួយការអប់រំចេញពីចិត្ត។ ការចូលរួមយ៉ាងសកម្មរបស់ពលរដ្ឋ និងសហគមន៍ ក្នុងប្រព័ន្ធអប់រំ ជួយឲ្យគណនេយ្យភាពក្នុងការអប់រំកាន់តែប្រសើរ។ លទ្ធផលចុងក្រោយគឺ ប្រព័ន្ធអប់រំទាំងមូលនឹងប្រសើរ។

**ការខិតខំប្រឹងប្រែងលើកកម្ពស់គុណភាពអប់រំ ក៏រងការប៉ះពាល់ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩។** កូវីដ-១៩ ជាការប្រកាសអាសន្ននៃសុខភាពសាធារណៈ និងប៉ះពាល់ដល់សេដ្ឋកិច្ច និងសង្គមយ៉ាងធ្ងន់ធ្ងរ។ វិស័យអប់រំក៏មិនរួចផុតពីផលប៉ះពាល់នៃជំងឺកូវីដ-១៩ដែរ។ ការបិទសាលារៀនបានប៉ះពាល់ដល់ការរៀនសូត្ររបស់សិស្ស និងការវាយតម្លៃការសិក្សារបស់សិស្សក្នុងទម្រង់ផ្សេងៗ។ ការបង្អាក់ការរៀនសូត្ររបស់សិស្ស អាចប៉ះពាល់ដល់គុណភាពនៃការសិក្សារបស់សិស្ស និងកំណើនមូលធនមនុស្ស[37] ក្នុងជំនាន់សិស្សដែលទទួលការប៉ះពាល់ដោយសារកូវីដ-១៩។ គុណភាពនៃការរៀនត្រូវពឹងលើចំនួនម៉ោងដឹកនាំការរៀន។ ចំនួនម៉ោងរៀនដែលបាត់ដោយសារការបិទសាលារៀន ប៉ះពាល់ដល់កំណើនជំនាញ ក្នុងកម្រិតផ្សេងៗគ្នា ក្នុងចំណោមក្រុមសិស្សដែលរងផលប៉ះពាល់ ដូចជា ក្រុមមនុស្ស និងសហគមន៍ងាយរងគ្រោះ និងជួបការលំបាក។ បញ្ហាកូវីដនេះទាមទារឲ្យវិនិយោគបន្ថែមលើបច្ចេកវិទ្យា និងការកែទម្រង់វិស័យអប់រំ ដើម្បីគាំទ្រដល់ការបន្តធានាគុណភាពនៃការរៀនអំឡុងស្ថានភាពបិទប្រទេស និងស្ថានភាពផ្សេងទៀត (សូមមើលប្រអប់ S.01 សម្រាប់ចំណុចពិភាក្សាបន្ថែមអំពីផលប៉ះពាល់នៃកូវីដ-១៩ លើការខិតខំប្រឹងប្រែងនៅក្នុងកំណត់ទម្រង់វិស័យអប់រំ)។

---

35 ផ្នែកស្តីពីអត្ថបទផ្តោតពិសេសនេះ ត្រូវបានរៀបចំឡើងដោយក្រុមការងារមួយក្រោមកិច្ចសហដឹកនាំដោយលោក សូ សុខប៊ុនធឿន (អ្នកជំនាញឯកទេសជាន់ខ្ពស់ផ្នែកវិស័យសាធារណៈ) និង Donna Andrews (អ្នកជំនាញឯកទេសជាន់ខ្ពស់ផ្នែកវិស័យសាធារណៈ) ។ សមាជិកស្នូលនៃក្រុមការងាររួមមាន លោក ទុ ឃី (អ្នកពិគ្រោះយោបល់) លោក យូ សូគន្ធបញ្ញា (អ្នកពិគ្រោះយោបល់) លោក ផ្លុង ពិសិទ្ធ (អ្នកពិគ្រោះយោបល់) ណូ ហ្វាតា (អ្នកពិគ្រោះយោបល់) និងលោក លី សូដេត (សេដ្ឋវិទូជាន់ខ្ពស់)។ អ្នកនិពន្ធសូមថ្លែងអំណរគុណដល់លោក បេង ស៊ីម៉េត ចំពោះការផ្តល់យោបល់ និងដំបូន្មានដែលមានការពិចារណាខ្ពស់។ សូមអរគុណផងដែរចំពោះ“មូលនិធិស្ម័គ្រចិត្តអន្តរម្ចាស់ជំនួយ” លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការផ្តល់សេវា ដែលបានទទួលថវិកាពីប្រទេសអូស្ត្រាលី និងសហភាពអឺរ៉ុប ដែលបានផ្តល់ហិរញ្ញប្បទានដល់ការរៀបចំផ្នែកស្តីពីអត្ថបទផ្តោតពិសេសនេះ។

36 លើកលែងតែមានការកត់សំគាល់ក្រៅពីនេះ ការវិភាគនៅក្នុងផ្នែកនេះ ផ្អែកលើការរកឃើញពីការសិក្សារបស់ធនាគារពិភពលោកលើ “គណនេយ្យភាព ការលើកទឹកចិត្ត និងលទ្ធផលនៃការសិក្សា ៖ ករណីសិក្សានៃគំរូសាលាដែលបានជ្រើសរើស”។

37 មើល Simon Burgess និង Hans Henrik Sievertsen “សាលារៀន ជំនាញ និងការសិក្សា៖ ផលប៉ះពាល់នៃជំងឺកូវីដ១៩ លើការអប់រំ” គោលនយោបាយ CEPR https://voxeu.org/article/impact-covid-19-education ។

## ជំងឺរាតត្បាតកូវីដ-១៩ និងផលប៉ះពាល់លើវិស័យអប់រំ

រាជរដ្ឋាភិបាលកម្ពុជាចាត់វិធានការសំខាន់ៗ ដូចជា បិទសាលារៀន ដើម្បីទប់ស្កាត់ការឆ្លងជំងឺកូវីដ-១៩ នៅសហគមន៍។ អនុវត្តការសិក្សាពីចម្ងាយ ជាជម្រើសដ៏សំខាន់សម្រាប់សាលារៀន និងគ្រឹះស្ថានអប់រំផ្សេងទៀត។ កម្មវិធីរៀនពីចម្ងាយ មានការសិក្សាតាមអនឡាញ ទូរទស្សន៍ ឬ វិទ្យុ សម្រាប់គាំទ្រដល់ការបន្តការសិក្សារបស់សិស្សនៅតាមសាលារដ្ឋ និងឯកជន។

**ជំងឺកូវីដ-១៩ បានជះឥទ្ធិពលអវិជ្ជមានដល់ការប្រឹងប្រែងលើការកែទម្រង់វិស័យអប់រំ។** ការបិទសាលារៀនក្នុងអំឡុងពេលឆ្លងជំងឺកូវីដ-១៩ អាចមានការប៉ះពាល់ខ្លាំងថែមទៀតដល់វិស័យអប់រំក្នុងរយៈពេលមធ្យម និងវែង ប្រសិនបើពុំមានយន្តការដោះស្រាយផលប៉ះពាល់ទេ។

**ទីមួយ ដំណើរការរៀនរបស់សិស្សទំនងជាពុំបានទាន់កម្មវិធីទេ ព្រោះបាត់ម៉ោងសិក្សា ក្នុងអំឡុងពេលបិទសាលារៀន។** ទោះបីមានវិធានការបន្ធូរស្ថានការណ៍ក៏ដោយ ការសិក្សាពីចម្ងាយមានបញ្ហាប្រឈម គឺកម្រិតនៃការរៀនចេះ និងចប់កម្រិតថ្នាក់។ ឧទាហរណ៍ វីដេអូមេរៀនតាមប្រព័ន្ធអេឡិចត្រូនិកមានប្រយោជន៍សម្រាប់សិស្សក៏ដោយ ប៉ុន្តែមេរៀនបែបនេះគឺសម្រាប់មានបំណិនរៀនដោយខ្លួនឯង ឬ សម្រាប់សិស្សដែលមានឪពុកម្តាយ។ សិស្សភាគច្រើនខ្វះសំភារសិក្សាពីចម្ងាយតាមមេរៀនបែបនេះ។ ការរៀនតាមទូរទស្សន៍ និងវិទ្យុ គឺខ្វះការប្រាស្រ័យគ្នារវាងសិស្ស និងសិស្ស និងជាមួយគ្រូបង្រៀនក្នុងអំឡុងពេលរៀន។ យោងតាមបទពិសោធន៍ធ្លាប់ឆ្លងកាត់កន្លងមក ការចូលរួមរបស់ឪពុកម្តាយក្នុងដំណើរការសិក្សារបស់សិស្សមានតិចតួចណាស់ ដូច្នេះសិស្សទំនងជាមិនបានរៀនឲ្យសម្រេចលទ្ធផលដូចការរំពឹងទុកទេ។

**ទីពីរ អត្រាបោះបង់ការសិក្សារបស់សិស្សអាចកើនឡើងក្នុងរយៈពេលមធ្យម (ពីរទៅបីឆ្នាំ)។** ផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចលើសហគមន៍ រួមជាមួយនឹងការបិទសាលារៀន និងការបាត់បង់ឱកាសរៀនផង អត្រាបោះបង់ចោលការសិក្សាអាចកើនឡើងខ្ពស់។ តាមបទពិសោធន៍ដែលមាន អត្រាបោះបង់ការសិក្សារបស់សិស្សបានកើនឡើងពេលជីវភាពពលរដ្ឋក្នុងសហគមន៍ប្រឈមការលំបាក និងស្ថានភាពងាយរងគ្រោះ ហើយសិស្សដែលរៀនមិនចេះ និងរៀនមិនទាន់មេរៀន កាន់តែងាយបោះបង់សាលាថែមទៀត។

**ទីបី ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សត្រូវពន្យារពេល។** ដំណើរការវាយតម្លៃការសិក្សារបស់សិស្សថ្នាក់ជាតិឆ្នាំ ២០២០ ត្រូវពន្យារពេល។ ការពន្យារពេលនេះនឹងធ្វើឱ្យរដ្ឋាភិបាលខ្វះព័ត៌មាន យកទៅបង្កើតគោលនយោបាយលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស។

**ទីបួន ប្រសិទ្ធភាពគ្រូបង្រៀនអាចថយចុះទាបជាងមុន ក្រោយកូវីដ-១៩ ដោយសារគ្រូបង្រៀនមិនបានបន្តការងារបង្រៀន។** ប្រព័ន្ធគណនេយ្យភាពខ្វះប្រសិទ្ធភាព សមត្ថភាពគ្រូបង្រៀនខ្សោយក្នុងការដឹកនាំការរៀនពីចម្ងាយ គ្រូបង្រៀនទំនងជាមិនអាចប្រាស្រ័យទាក់ទងជាមួយឪពុកម្តាយបាន និងមិនអាចផ្តល់ការគាំទ្រពីចម្ងាយដល់សិស្សក្នុងអំឡុងពេលបិទសាលារៀនដែរ។ ដូច្នេះ គួរមានកម្មវិធីគោលនយោបាយមួយ ដើម្បីជួយគ្រូបង្រៀនឲ្យត្រៀមខ្លួនក្នុងការជួយសិស្សរៀនយឺត ឬរៀនមិនទាន់ ដោយសារការបិទសាលារៀន។

*ប្រភព៖* ជំងឺរាតត្បាតកូវីដ ១៩៖ ផលប៉ះពាល់ដល់ការអប់រំ និងគោលនយោបាយឆ្លើយតប ធនាគារពិភពលោក ខែឧសភា ឆ្នាំ ២០២០។
*គោលការណ៍ណែនាំស្តីពីការបន្តការសិក្សាតាមកម្មវិធី* "ការសិក្សាពីចម្ងាយ" និង "ការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក" សម្រាប់សិស្សមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សា ធនាគារពិភពលោក ឆ្នាំ២០២០ ។
*ឯកសារគោលគំនិតស្តីពី* "គម្រោងកែលម្អការអប់រំឧត្តមសិក្សា" ធនាគារពិភពលោក ខែឧសភា ឆ្នាំ២០២០។



**ជំពូកនេះពិភាក្សាអំពីគណនេយ្យភាពនៃសាលារៀនរដ្ឋ និងសាលារៀនជំនាន់ថ្មីពីរប្រភេទ។** អនុសាសន៍សម្រាប់លើកកម្ពស់គុណភាពអប់រំនៅកម្ពុជា បានយកបទពិសោធន៍របស់សាលាជំនាន់ថ្មី និងការគ្រប់គ្រងសាលារៀនដោយផ្អែកលើលទ្ធផល។ បន្ថែមលើនេះទៀត ជំពូកនេះក៏ផ្ដល់អនុសាសន៍ក្នុងការដោះស្រាយបញ្ហានៃផលប៉ះពាល់លើវិស័យអប់រំ ដោយសារកូវីដ-១៩។

## កិច្ចខិតខំប្រឹងប្រែងដើម្បីលើកវិស័យអប់រំឲ្យខ្ពស់មួយកម្រិត

### ១.បានពង្រីកឱកាសទទួលការអប់រំ

**វិស័យអប់រំដើរតួយ៉ាងសំខាន់ក្នុងការអភិវឌ្ឍជាតិ។** ប្រព័ន្ធអប់រំចំណេះទូទៅ កំណត់រយៈពេលសិក្សា១២ឆ្នាំ បឋមសិក្សា០៦ឆ្នាំ មធ្យមសិក្សាបឋមភូមិ០៣ឆ្នាំ និងទុតិយភូមិ០៣ឆ្នាំ។ ក្នុងឆ្នាំ២០១៨ កម្ពុជាមានសាលារៀនចំនួន១៣.១១៣ នៅទូទាំងប្រទេស និងសាលារៀនផ្ដល់សេវាកម្មអប់រំដល់សិស្សប្រមាណ០៣លាននាក់ គឺស្មើនឹង១៨,៧៥% នៃចំនួនប្រជាជនកម្ពុជាសរុប។ វិស័យអប់រំមានបុគ្គលិក១២០.១៥៥នាក់ និង៩៩.៥ភាគរយ (១១៩.៨០៤ នាក់) ជាគ្រូបង្រៀន[38]។

**នៅក្នុងការទទួលស្គាល់ភាពចាំបាច់នៃការអភិវឌ្ឍវិស័យអប់រំ រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តគោលនយោបាយជាច្រើនក្នុងទសវត្សរ៍ឆ្នាំ២០០០។** គោលនយោបាយទាំងនោះ មានផែនការយុទ្ធសាស្ត្រវិស័យអប់រំ ផែនការជាតិដើម្បីការអប់រំសម្រាប់ទាំងអស់គ្នា គោលនយោបាយជាតិស្ដីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច និងគោលនយោបាយសាលាកុមារមេត្រី។ គោលនយោបាយទាំងនេះផ្ដល់អាទិភាពដល់ការគាំពារ និងអប់រំកុមារតូច និងពង្រីកឱកាសទទួលការអប់រំសម្រាប់កុមារ និងលើកកម្ពស់ ប្រសិទ្ធផល និងគុណភាពអប់រំមូលដ្ឋាន០៩ឆ្នាំ។លទ្ធផលបានបង្ហាញថា ឱកាសទទួលបានការអប់រំ មានការរីកចម្រើន។ អត្រាសិស្សចុះឈ្មោះចូលរៀនពិត នៅកម្រិតបឋមសិក្សាកើនដល់៩៧,៨% ក្នុងឆ្នាំ២០១៨ គឺកើនឡើងពី៧៦,៤% ក្នុងឆ្នាំ២០០០ (រូប S.1)។ អត្រាសិស្សចុះឈ្មោះចូលរៀនពិតនៅមធ្យមសិក្សាបានកើនឡើងពី ១៦,៦% ក្នុងឆ្នាំ២០០០ ដល់ ៣៥,១% ក្នុងឆ្នាំ២០១១ និងដល់ ៥៩% នៅឆ្នាំ២០១៨។ អត្រាឆ្លងភូមិសិក្សានៅមធ្យមសិក្សាបឋមភូមិ កើនដល់ ៤៦,៥% ក្នុងឆ្នាំ២០១៨ (រូប S.2)[39]។

**រូប S.1៖ អត្រាសិស្សចុះឈ្មោះចូលរៀនពិតនៅបឋមសិក្សាកើនឡើងក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយ ដោយសារគោលនយោបាយរបស់រដ្ឋាភិបាល ក្នុងការពង្រីកឱកាសទទួលការអប់រំ**




*ប្រភព៖* ក្រសួងអប់រំ យុវជន និងកីឡា

### ២.ការដំឡើងប្រាក់ខែគ្រូបង្រៀន និងបុគ្គលិកអប់រំ

**រដ្ឋាភិបាលត្រូវការគ្រូបង្រៀនឲ្យផ្ដល់សេវាអប់រំ។** ជាផ្នែកមួយនៃរបៀបវារៈអាទិភាពមួយរបស់រដ្ឋាភិបាលក្នុងការបង្កើតប្រាក់ខែគ្រូបង្រៀន រដ្ឋាភិបាលបានអនុវត្តវិធានការចម្បងមួយគឺការបង្កើនការចំណាយលើវិស័យអប់រំ ពិសេសប្រាក់ខែគ្រូបង្រៀន។ ថវិកាចំណាយលើវិស័យអប់រំ ធៀបនឹងចំណាយសរុបរបស់រដ្ឋកើនឡើងពី ១០% ក្នុងឆ្នាំ២០១៤ ដល់ ប្រហែលជា ១៣% នៅឆ្នាំ២០១៩ ស្មើនឹង ២,៩% នៃ ផ.ស.ស ក្នុងឆ្នាំ២០១៩ ប្រៀបធៀបនឹង ២% ក្នុងឆ្នាំ២០១៤[40]។

**យោងតាមច្បាប់ទូទាត់ថវិកាឆ្នាំ២០២០ ខ្ទង់ចំណាយលើវិស័យអប់រំ[41] ក្នុងបរិមាណជាក់ស្ដែងកើនឡើងជិតបីដងពី ៣៤៣ លានដុល្លារអាមេរិកក្នុងឆ្នាំ២០១៤ ដល់ ៨៤៨ លានដុល្លារអាមេរិកក្នុងឆ្នាំ២០១៩[42]។** កំណើនចំណាយនេះកើតឡើងដោយសារការដំឡើងប្រាក់ខែបុគ្គលិករដ្ឋ គឺប្រហែល៨០%ចំណាយសរុប។ ក្នុងរយៈពេលដូចគ្នានេះ ប្រាក់ខែចាប់ផ្ដើមដំបូងសម្រាប់គ្រូ

**រូប S.2៖ អត្រាឆ្លងភូមិសិក្សា មធ្យមសិក្សាបឋមភូមិ**

គិតជា (%)




*ប្រភព៖* ក្រសួងអប់រំ យុវជន និងកីឡា

38 ក្រសួងអប់រំ យុវជន និងកីឡា។
39 ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០១៩-ឆ្នាំ២០២៣ ខែមិថុនា ឆ្នាំ២០១៩ ក្រសួងអប់រំ យុវជន និងកីឡា។
40 ច្បាប់ថវិកាឆ្នាំ២០២០។
41 ការចំណាយលើការអប់រំរួមមាន ចំណាយចរន្ត និងចំណាយមូលធន។ ចំណាយមូលធន សម្រាប់វិស័យអប់រំបានកើនឡើងតាំងពីឆ្នាំ ២០១៥ ។
42 ដូចគ្នា

បង្រៀនកើនឡើងប្រហែលបីដង។ សម្រាប់គ្រូបឋមសិក្សា កើនឡើង៤ដង (ពី៨៨៨ ដុល្លារ ទៅ ៣៦០០ ដុល្លារអាមេរិកក្នុងមួយឆ្នាំ)។ ប្រាក់ខែគ្រូបង្រៀនមធ្យមសិក្សាបឋមភូមិកើនបីដង (ពី ១.២៥៩ ដុល្លារ ដល់៣.៨៧៦ ដុល្លារអាមេរិកក្នុងមួយឆ្នាំ)។ ប្រាក់ខែគ្រូបង្រៀនកម្រិតមធ្យមសិក្សាទុតិយភូមិ កើនឡើង ២,៣ដង (ពី ១.៨១៤ ដុល្លារ ដល់ ៤.២២២ ដុល្លារអាមេរិក) (រូប S. 3)។

**ប្រាក់ខែគ្រូបង្រៀនមានពីរប្រភេទ ប្រាក់ខែគោល និងប្រាក់បំណាច់មុខងារ។** ឧទាហរណ៍ ប្រាក់ខែគោលសម្រាប់គ្រូសាលាបឋមសិក្សាកើនឡើងបីដង ពី ៦៨៤ ដុល្លារអាមេរិកក្នុងមួយឆ្នាំ នៅឆ្នាំ២០១៣ ដល់ ១.៨៦០ ដុល្លារអាមេរិក នៅឆ្នាំ ២០១៩។ ប្រាក់បំណាច់មុខងារ ជាកត្តាសំខាន់ធ្វើឱ្យប្រាក់ខែគ្រូបង្រៀនកើនឡើង (រូប S.3)។ របៀបនៃការបើកប្រាក់ខែជូនគ្រូបង្រៀនក៏បានកែលម្អដែរ។ កាលពីមុន គ្រូបង្រៀនបើកប្រាក់ខែមួយខែម្តង។ បច្ចុប្បន្ន ប្រាក់ខែបានបើកពីរដងក្នុងមួយខែ តាមរយៈការផ្ទេរដោយផ្ទាល់ទៅក្នុងគណនីធនាគារ។

### ៣.ទោះជាយ៉ាងណាក៏ដោយ លទ្ធផលនៃការសិក្សារបស់សិស្សមិនមានភាពប្រសើរឡើងនោះទេ

**បើទោះបីប្រាក់ខែរបស់គ្រូបង្រៀនកើនឡើងច្រើនក៏ដោយ ក៏លទ្ធផលសិក្សារបស់សិស្សពុំមានការរីកចម្រើនគួរឱ្យកត់សម្គាល់ដែរ ចាប់ពីឆ្នាំ២០១៣ដល់ឆ្នាំ២០១៧។** ការស្រាវជ្រាវមួយរបស់ក្រសួងអប់រំយុវជន និងកីឡាឆ្នាំ ២០១៨ ស្តីពី *ការអប់រំនៅកម្ពុជា៖ របកគំហើញនៃបទពិសោធន៍របស់ប្រទេសកម្ពុជាក្នុង PISA សម្រាប់ការអភិវឌ្ឍ* បានរកឃើញថា គុណផលសិក្សារបស់សិស្សនៅកម្ពុជាមិនទាន់ឈានដល់កម្រិតរំពឹងចង់បានទេ។ សិស្សកម្ពុជាអាយុ១៥ឆ្នាំ មួយភាគតូចប៉ុណ្ណោះ បានប្រឡងជាប់កម្រិតបំណិនអប្បបរមា[43] ពោលគឺ អំណាន ៨% និងគណិត ១០%។ គុណផលសិក្សារបស់សិស្សកម្ពុជាទទួលបានពិន្ទុជាមធ្យមទាបជាងពិន្ទុសិស្ស នៅប្រទេសអាស៊ាន លើបំណិនអំណាន គណិត និងវិទ្យាសាស្ត្រ។ ជាមធ្យម ពិន្ទុ PISA-D របស់កម្ពុជាគឺ ៣២១ សម្រាប់បំណិនអំណាន ៣២៥ បំណិនគណិតវិទ្យា និង ៣៣០ សម្រាប់បំណិនវិទ្យាសាស្ត្រ។ ពិន្ទុទាំងនេះទាបជាងពិន្ទុមធ្យមភាគនៅប្រទេសក្នុងតំបន់អាស៊ាន គឺ៤៣០ បំណិនអំណាន ៤៣៥ បំណិនគណិត និង ៤៣៩ បំណិនវិទ្យាសាស្ត្រ។ សិស្សកម្ពុជាតិចជាង២% មានគុណសម្បទាតាមស្តង់ដាសមត្ថភាពនៃអង្គការសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច(OECD)។ សម្រាប់បំណិនអំណាន សិស្សកម្ពុជា ប្រឡងជាប់ ក្នុងកម្រិតពិន្ទុទាបជាងមធ្យមភាគរបស់ PISA-D ខ្លាំង (៣៨៦ ពិន្ទុ)[44]។

**ការវាយតម្លៃលើសិស្សនៅថ្នាក់ជាតិ ដែលធ្វើឡើងដោយក្រសួងអប់រំយុវជន និងកីឡា បានបង្ហាញថា លទ្ធផលសិក្សារបស់សិស្សនៅថ្នាក់ទី៦ និងទី៨ ត្រូវការកែលម្អឲ្យបានច្រើនដើម្បីឆ្លើយតបទៅនឹងកម្រិតរំពឹងទុកក្នុងមុខវិជ្ជាធំៗចំនួន០៣៖ ភាសាខ្មែរ គណិតវិទ្យា និងរូបវិទ្យា[45]។** ជារួម សិស្សថ្នាក់ទី៦ និងទី៨ អាចឆ្លើយសំណួរបានត្រឹមត្រូវប្រហែលពាក់កណ្តាលតែប៉ុណ្ណោះ ក្នុងអំឡុងពេលនៃការធ្វើតេស្តស្តង់ដារ ដែលរៀបចំឡើងដោយក្រសួងអប់រំ យុវជន និងកីឡា។ លទ្ធផលនេះមិនឃើញមានភាពប្រសើរឡើងរវាងឆ្នាំ២០១៣ និងឆ្នាំ២០១៧។ ការសិក្សាបានបង្ហាញពីលទ្ធផលស្រដៀងគ្នានេះចំពោះលំដាប់ពិន្ទុ ដែល

**រូប S.3៖ ប្រាក់ខែចាប់ផ្តើមដំបូងរបស់គ្រូបង្រៀនកើនឡើងបីដងរវាងឆ្នាំ២០១៣ ដល់ ឆ្នាំ២០១៩ បណ្តាលមកពីការកើនឡើងនៃប្រាក់បំណាច់មុខងារ**

*តារាង ក ប្រាក់ខែចាប់ផ្តើមដំបូងប្រចាំឆ្នាំរបស់គ្រូបង្រៀនកម្រិតបឋមសិក្សា និងមធ្យមសិក្សា*




*តារាង ខ ប្រាក់ខែចាប់ផ្តើមដំបូងប្រចាំឆ្នាំរបស់គ្រូបង្រៀនកម្រិតបឋមសិក្សា*




*ប្រភព៖* ការចងក្រងទិន្នន័យរបស់ក្រសួងមុខងារសាធារណៈ។

*សម្គាល់៖* ប្រាក់ខែ និងប្រាក់ឧបត្ថម្ភដែលត្រូវបានចំណាយពីថវិការបស់ក្រសួងអប់រំយុវជន និងកីឡា (១) ប្រាក់ខែគោលត្រូវបានកំណត់ដោយឋានន្តរសក្តិមុខងារសាធារណៈរបស់គ្រូបង្រៀន។ គ្រូបង្រៀននីមួយៗត្រូវបានតែងតាំងទៅតាមឋានន្តរសក្តិមន្ត្រីរាជការខុសៗគ្នាទៅតាមលក្ខណវិនិច្ឆ័យដែលបានកំណត់ដោយព្រះរាជក្រឹត្យ និង (២) គ្រូបង្រៀនក៏ទទួលបានប្រាក់បំណាច់មុខងារទៅតាមមុខតំណែង និងកំរិតនៃការអប់រំ ដែលពួកគេបង្រៀន ដូចដែលឈ្មោះបានកំណត់។

43 PISA-D កំណត់កម្រិតជំនាញអប្បបរមា ជាកម្រិតដែលសិស្សមានសមត្ថភាពដោះស្រាយកិច្ចការសាលា ដែលយ៉ាងហោចទាមទារឱ្យមានសមត្ថភាព និងឥរិយាបទក្នុងការគិតដោយស្វ័យភាព។

44 ការអប់រំនៅកម្ពុជា៖ លទ្ធផលនៃបទពិសោធន៍របស់ប្រទេសកម្ពុជាក្នុងកម្មវិធីសម្រាប់វាយតម្លៃសិស្សអន្តរជាតិសម្រាប់ការអភិវឌ្ឍន៍, ក្រសួងអប់រំ យុវជន និងកីឡា, ឆ្នាំ២០១៨។

45 ការវាយតម្លៃត្រូវបានអនុវត្តដើម្បីវាយតម្លៃការសិក្សារបស់សិស្សថ្នាក់ទី៣ ទី៦ ទី៨ និងទី១១ ចាប់ពីឆ្នាំ ២០១៣ ដល់ឆ្នាំ ២០១៧។

កំណត់នៅចន្លោះពិន្ទុជាមធ្យម(៥០០ពិន្ទុ)។ក្នុងរយៈពេលដូចគ្នា មិនមានភាពខុសគ្នាគួរឱ្យកត់សម្គាល់នៅក្នុងលំដាប់ពិន្ទុរបស់សិស្សថ្នាក់ទី៨ លើមុខវិជ្ជាទាំងបី។ សម្រាប់ថ្នាក់ទី៦ សិស្សមានការរីកចម្រើនតិចតួចផ្នែកគណិតវិទ្យាក្នុងឆ្នាំ២០១៦ បើប្រៀបធៀបនឹងឆ្នាំ២០១៣ ទោះបីជាលទ្ធផលនៃមុខវិជ្ជាភាសាខ្មែរនៅតែដដែល (តារាង S.01)។

**គុណផលសិក្សារបស់សិស្សថ្នាក់ទី៨ អំពីភាពស្ទាត់នៃបំណិនអំណានភាសាខ្មែរ និងគណិតវិទ្យាមានកម្រិតទាប** បើទោះបីជាចំនួនសមាមាត្រមានការកើនឡើងតិចតួចពីឆ្នាំ២០១៤ ដល់ ២០១៧ ក៏ដោយ។ ក្នុងបំណិនអំណានភាសាខ្មែរ សិស្សពូកែស្ទាត់បំណិនអាន កើនពី ៣១% នៅឆ្នាំ២០១៤ដល់៣៤% ក្នុងឆ្នាំ២០១៧។ បំណិនគណិតវិទ្យាកើនពី១០% ក្នុងឆ្នាំ២០១៤ ដល់១២% ក្នុងឆ្នាំ២០១៧។

**តារាង S.01៖ ជាមធ្យម សិស្សកម្ពុជាអាចឆ្លើយសំណួរត្រូវបានពាក់កណ្តាលតែប៉ុណ្ណោះ**

| ថ្នាក់ | | | ៦ | | ៨ | |
|---|---|---|---|---|---|---|
| ឆ្នាំវាយតម្លៃ | | | ២០១៣ | ២០១៦ | ២០១៤ | ២០១៧ |
| មុខវិជ្ជា | ភាសាខ្មែរ | ភាគរយនៃចម្លើយត្រឹមត្រូវ | ៤៦ | ៥២ | ៥៦ | ៥៤ |
| | | លំដាប់ពិន្ទុ | ៥០៤ | ៥០៤ | ៥០០ | ៤៩៥ |
| | គណិតវិទ្យា | ភាគរយនៃចម្លើយត្រឹមត្រូវ | ៤៣ | ៤៨ | ៤៤ | ៤៧ |
| | | លំដាប់ពិន្ទុ | ៤៨៩ | ៥១៩ | ៥០០ | ៤៩៤ |
| | រូបវិទ្យា | ភាគរយនៃចម្លើយត្រឹមត្រូវ | គ្មាន | គ្មាន | ៥៣ | ៤៦ |
| | | លំដាប់ពិន្ទុ | គ្មាន | គ្មាន | ៥០០ | ៤៩៧ |

*ប្រភព៖* របាយការណ៍វាយតម្លៃលទ្ធផលសិក្សារបស់សិស្សថ្នាក់ជាតិ ក្រសួងអប់រំ យុវជន និងកីឡា។
*សម្គាល់៖* លំដាប់ពិន្ទុត្រូវបានគិតជាមួយនឹងពិន្ទុមធ្យមភាគ ៥០០ និងគម្លាតស្តង់ដារ ១០០។ N / A = គ្មាន។

**ភាគរយសិស្សប្រឡងជាប់មធ្យមសិក្សាទុតិយភូមិ (Bac II) បានកើនឡើងគួរឱ្យកត់សម្គាល់ពី៤៥% ក្នុងឆ្នាំ២០១៤ ដល់ ៦២% ក្នុងឆ្នាំ២០១៦ ពេលរដ្ឋាភិបាលរឹតបន្តឹងការប្រឡង។** អត្រាសិស្សប្រឡងជាប់មធ្យមសិក្សាទុតិយភូមិបានបង្ហាញឲ្យឃើញកាន់តែប្រសើរឡើង នៅឆ្នាំបន្តបន្ទាប់ដោយកើនពី៦២% ពីឆ្នាំ២០១៦ដល់ ៦៨% ក្នុងឆ្នាំ២០១៩។

**ការដំឡើងប្រាក់ខែមានភាពចាំបាច់ដើម្បីលើកកម្ពស់កម្រិតជីវភាពរបស់គ្រូបង្រៀន ប៉ុន្តែពុំមែនជាលក្ខខណ្ឌគ្រប់គ្រាន់ដើម្បីកែលម្អលទ្ធផលសិក្សារបស់សិស្សទេ។** បន្ថែមពីលើការលើកទឹកចិត្តជាថវិកា យន្តការគណនេយ្យភាព រួមជាមួយនឹងវិធីលើកទឹកចិត្តផ្សេងទៀតក្រៅពីថវិកា ក៏អាចមានប្រយោជន៍ដែរ។ រដ្ឋាភិបាលបានបង្កើតសាលារៀនថ្មីចំនួនពីរប្រភេទ។ សាលារៀនជំនាន់ថ្មី និងសាលារៀនគ្រប់គ្រងផ្អែកលើលទ្ធផល។ សាលារៀនទាំងពីរប្រភេទបានបង្ហាញឲ្យឃើញអំពីការលើកកម្ពស់គុណភាពនៃការរៀនរបស់សិស្ស។

**សាលារៀនជំនាន់ថ្មីអនុវត្តតាមប្រភេទស្ថាប័នថ្មីមួយ ដើម្បីធានាឲ្យមានយន្តការគណនេយ្យភាពកម្រិតខ្ពស់។** សាលារៀនជំនាន់ថ្មីបានបង្កើតឡើងក្នុងឆ្នាំ២០១៥ ជាសាលារៀនប្រតិបត្តិតាមលក្ខខណ្ឌសាលារៀនដែលមានប្រព័ន្ធគ្រប់គ្រងដាច់ដោយឡែកពីសាលារៀនរដ្ឋ។ សាលារៀនជំនាន់ថ្មីបានកើនឡើងដល់ ១១សាលារៀន ក្នុងឆ្នាំ២០១៩ ដោយមានសាលាមធ្យមសិក្សាចំនួន ០៧ និងសាលាបឋមសិក្សាចំនួន ០៤។ ការជ្រើសរើសសិស្សចូលរៀនក្នុងសាលារៀនជំនាន់ថ្មី ត្រូវឆ្លងកាត់ការប្រឡងចម្រាញ់។ ការប្រឡងចម្រាញ់នេះធ្វើឲ្យសាលារៀនជំនាន់ថ្មីធានាបានគុណភាពនៃលទ្ធផលសិក្សារបស់សិស្ស។ ឧទាហរណ៍ សាលារៀនជំនាន់ថ្មី ជ្រើសរើសសិស្សបានតែ២៣៤នាក់ក្នុងចំណោមអ្នកដាក់ពាក្យ១.២៦៤នាក់ ឱ្យចូលរៀននៅសាលារៀនជំនាន់ថ្មីនៃវិទ្យាល័យព្រះស៊ីសុវត្ថិនៅឆ្នាំ២០១៩។ ឪពុកម្តាយសិស្សដែលបានចូលរៀននៅសាលារៀនជំនាន់ថ្មីអាចផ្តល់វិភាគទានថវិកាដល់សាលារៀន និងទទួលសេចក្តីដឹងគុណពីក្រុមប្រឹក្សាភិបាលជាតិនៃសាលារៀនជំនាន់ថ្មី។ រហូតមកដល់ពេលនេះ សាលារៀនជំនាន់ថ្មីចំនួន ០៤ ក្នុងចំណោមសាលារៀនជំនាន់ថ្មីទាំង ១១ បានទទួលសិទ្ធិក្នុងការទទួលវិភាគទានពីឪពុកម្តាយសិស្ស។

**សាលារៀនគ្រប់គ្រងដោយផ្អែកលើលទ្ធផលត្រូវបានដាក់បញ្ចូលក្នុងប្រព័ន្ធសាលារៀនរដ្ឋ និងផ្តោតការយកចិត្តទុកដាក់**

**លើការកែលម្អគណនេយ្យភាព ដោយមានការចូលរួមពីសហគមន៍។** ចាប់ពីឆ្នាំ២០១៧ សាលារៀនមធ្យមសិក្សាបឋមភូមិចំនួន១០០ បានចូលក្នុងប្រភេទសាលារៀន គ្រប់គ្រងដោយផ្អែកលើលទ្ធផល។ ខុសពីសាលារៀនជំនាន់ថ្មី សាលារៀនគ្រប់គ្រងដោយផ្អែកលើលទ្ធផល ពុំមានការប្រឡងចម្រាញ់សិស្សចេញពីបឋមសិក្សាទេ។ សាលារៀនគ្រប់គ្រងដោយផ្អែកលើលទ្ធផល ផ្តល់ឱកាសស្មើភាពគ្នាដល់សិស្សគ្រប់រូបឲ្យចូលរៀន។ ការប្រឡងជ្រើសរើសសិស្សឲ្យចូលរៀននៅមធ្យមសិក្សាបឋមភូមិ គឺជ្រើសរើសសិស្សសាលារៀនកម្រង ប៉ុន្តែសិស្សប្រឡងត្រូវជាប់ឲ្យចូលរៀនទាំងអស់។ ឪពុកម្តាយអាចផ្តល់វិភាគទានជួយសាលារៀន ដោយស្ម័គ្រចិត្ត ដូចជាសម្ភារ ឬ ថវិកាសម្រាប់ប្រតិបត្តិការសាលារៀន (តារាង S.2)។

លក្ខណៈពិសេសនៃសាលារៀនពីរប្រភេទនេះ គឺស្វ័យភាពក្នុងការប្រតិបត្តិការសាលារៀន ដោយលើកកម្ពស់គណនេយ្យភាពសាលារៀន ការប្រើប្រាស់របៀបគ្រប់គ្រងផ្អែកលើគុណផល និងផ្តោតការយកចិត្តទុកដាក់សំខាន់លើការលើកកម្ពស់គុណភាពគ្រូបង្រៀន។

**តារាង S.2៖ ចរិតលក្ខណៈនៃសាលារៀនជំនាន់ថ្មី និងការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល**

| សាលារៀនជំនាន់ថ្មី | សាលារៀនអនុវត្តការគ្រប់គ្រងដោយផ្អែកលើលទ្ធផល |
|---|---|
| • បង្កើតក្នុងឆ្នាំ២០១៥ មានសាលារៀន១១ ៖ សាលាបឋមសិក្សា ០៤ និងមធ្យមសិក្សា០៧ ទទួលបានសិទ្ធិអនុវត្តកម្មវិធីសាលារៀនជំនាន់ថ្មី។<br>• ការបង្កើតសាលារៀនជំនាន់ថ្មីមាន ០៣ រូបភាព ៖ (១) សាងសង់សាលារៀនថ្មី (២) បង្កើតក្នុងសាលារដ្ឋដែលមានស្រាប់ ប៉ុន្តែបង្កើតប្រព័ន្ធគ្រប់គ្រងដាច់ និង (៣) ចុះកិច្ចសន្យាជាមួយសាលារៀនរដ្ឋដែលមានសិស្សបោះបង់ចេញទៅរៀននៅសាលាឯកជន។<br>• ការចុះឈ្មោះសិស្សចូលរៀន ៖ ការជ្រើសរើសសិស្សជាមុនតាមរយៈការប្រលងចម្រាញ់។<br>• ហិរញ្ញប្បទាន៖<br>•មួយផ្នែកធំនៃការវិនិយោគ ជារបស់រដ្ឋាភិបាល<br>•ម្ចាស់ជំនួយជាឯកជន<br><br>វិភាគទានរបស់ឪពុកម្តាយសិស្ស។ សាលារៀន០៤ ក្នុងចំណោមសាលារៀន១១ អាចទទួលវិភាគទានពីឪពុកម្តាយសិស្ស បន្ទាប់ពីសាលារៀនជំនាន់ថ្មីអនុវត្តរយៈពេល០៣ ឆ្នាំ និងមានការទទួលស្គាល់គុណភាព។ | • សាកល្បងក្នុងឆ្នាំ២០១៧ ក្រោមគម្រោងកែលម្អគុណភាពអប់រំនៅកម្រិតមធ្យមសិក្សា។<br>• បញ្ចូលក្នុងកម្មវិធីសាលារដ្ឋ ៖ អនុវិទ្យាល័យរដ្ឋចំនួន១០០ ដែលត្រូវបានជ្រើសរើស តម្រូវឱ្យអនុវត្តប្រព័ន្ធអភិបាលកិច្ច និងគណនេយ្យភាពនៃសាលារៀនអនុវត្តការគ្រប់គ្រងដោយផ្អែកលើលទ្ធផល។<br>• ការចុះឈ្មោះសិស្សចូលរៀន៖ពុំមានការប្រឡងជ្រើសរើសសិស្សជាមុនទេ។ មានធ្វើតេស្ត ដើម្បីវាស់សមត្ថភាពសិស្សមុនចូលរៀនប៉ុនណោះ។<br>• ហិរញ្ញប្បទាន៖<br>•វិនិយោគរបស់រដ្ឋាភិបាលទៅលើ ៖ (១) ប្រតិបត្តិសាលារៀន (២) លើកដំកើងសមត្ថភាពគ្រូបង្រៀន<br>•វិភាគទានរបស់ឪពុកម្តាយ ដោយស្ម័គ្រចិត្ត។ |

*ប្រភព៖* គោលនយោបាយ សាលារៀនជំនាន់ថ្មី គោលការណ៍ណែនាំប្រតិបត្តិការនៃសាលារៀនជំនាន់ថ្មី គោលការណ៍ណែនាំប្រតិបត្តិការនៃការគ្រប់គ្រងសាលារៀនដោយផ្អែកលើលទ្ធផល និងបទសម្ភាសន៍ជាមួយ តំណាងសាលារៀនជំនាន់ថ្មី និងសាលារៀនគ្រប់គ្រងដោយផ្អែកលើលទ្ធផល

## ៤.សាលារៀនជំនាន់ថ្មីអនុវត្តគោលការណ៍ថ្មីគណនេយ្យភាព ស្វ័យភាព និងគុណភាពសេវាអប់រំ

### ក.សាលារៀនជំនាន់ថ្មីបង្ហាញភាពជោគជ័យនៃលទ្ធផលសិក្សារបស់សិស្ស

**ក្រោយបង្កើតបាន០៥ឆ្នាំ សាលារៀនជំនាន់ថ្មី បានបង្ហាញលទ្ធផលខ្លះ ដោយមានវិទ្យាល័យ០២ កំពុងអនុវត្តស្តង់ដារខ្ពស់ជាងមុន។** ទិដ្ឋភាពធំ០២ ទទួលបានលទ្ធផលវិជ្ជមានគឺ (១) លទ្ធផលប្រឡងមធ្យមសិក្សាទុតិយភូមិ ៖ បច្ចុប្បន្ន មានសាលារៀនជំនាន់ថ្មីវិទ្យាល័យព្រះស៊ីសុវត្ថិ និងវិទ្យាល័យហ៊ុនសែនកំពង់ចាម មានសិស្សរៀនដល់ថ្នាក់ទី១២ ដែលបានប្រឡងមធ្យមសិក្សាទុតិយភូមិ និង (២) លទ្ធផលតេស្តអំពីសមត្ថភាពគិតកម្រិតខ្ពស់ សំដៅវាស់ សមត្ថភាពគិតឱ្យស៊ីជម្រៅ និងទូលំទូលាយ។ លទ្ធផលសិស្សប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិកើនឡើងនៅសាលារៀនទាំងពីរនៅចន្លោះឆ្នាំ២០១៨ និង ២០១៩ ចាប់ពី ៨៩% ដល់ ៩៤% សម្រាប់សាលារៀនជំនាន់ថ្មីវិទ្យាល័យព្រះស៊ីសុវត្ថិ និងកើនចាប់ពី ៧៤% ដល់ ៨៤% សម្រាប់សាលារៀនជំនាន់ថ្មីវិទ្យាល័យហ៊ុនសែនកំពង់ចាម ។ ក្នុងរយៈពេលដូចគ្នានេះ ភាគរយនៃសិស្សប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិនៅថ្នាក់ជាតិពុំមានការប្រែប្រួលទេ។ សមាមាត្រសិស្សនៅសាលារៀនជំនាន់ថ្មីទាំង២ ដែលបានប្រឡងជាប់ Bac II មានចំនួនច្រើនជាងសិស្សដែលប្រឡង

ជាប់នៅតាមសាលារដ្ឋ ជាមធ្យម។ សមាមាត្រនៃសិស្សដែលទទួលបាននិទ្ទេស A មានចំនួនច្រើនគួរឱ្យកត់សម្គាល់នៅសាលារៀនទាំងពីរនៅឆ្នាំ២០១៩ បើប្រៀបធៀបទៅនឹងសាលារដ្ឋដទៃទៀត (រូប S.05)។ លទ្ធផលសម្រេចបានខ្ពស់បែបនេះកើតឡើងដោយសារដំណើរការជ្រើសរើសសិស្សចូលរៀនបែបចម្រាញ់មុនពេលអនុញ្ញាតឱ្យសិស្សចូលរៀន (សូមអានឧបសម្ព័ន្ធ១ សេចក្តីសង្ខេបអំពីគុណសម្បត្តិ គុណវិបត្តិ និងជម្រើសគោលនយោបាយសម្រាប់ដំណើរការឆ្ពោះទៅមុខនៃគំរូសាលារៀនជំនាន់ថ្មី)។ អំណះអំណាងមួយបានលើកឡើងថា ដោយសារចូលរៀននៅសាលារៀនជំនាន់ថ្មី សិស្សត្រូវប្រឡងចម្រាញ់ ដូច្នេះមិនគួរប្រៀបធៀបគុណផលសិស្សជាមួយសាលាគ្រប់ប្រភេទបានទេ។ ទោះជាយ៉ាងណាក៏ដោយ ការកែលម្អគុណផលសិក្សារបស់សិស្សក្រោមសាលារៀនជំនាន់ថ្មី ក្រោយអនុវត្តបានជាច្រើនឆ្នាំ បានបង្ហាញនូវចំណុចខ្លាំងដូចស្ថិតិខាងក្រោម។

**ជាទូទៅ សិស្សរៀននៅសាលារៀនជំនាន់ថ្មីទាំងពីរអភិវឌ្ឍបំណិនគិតកម្រិតខ្ពស់ ដោយមានពិន្ទុជាមធ្យមភាគពី៦១%ទៅ៦៥% ក្នុងឆ្នាំ២០១៩។** លទ្ធផលតេស្តដើម្បីវាស់បំណិនគិតកម្រិតខ្ពស់បង្ហាញឲ្យឃើញការកើនឡើងនៃពិន្ទុមធ្យមភាគនៅតាមសាលារៀនជំនាន់ថ្មីទាំងពីរចាប់ពីឆ្នាំ ២០១៦ ដល់ឆ្នាំ ២០១៩។ ក្នុងសំណួរតេស្តវាស់សមត្ថភាពទាំង ០៦វិស័យ សាលារៀនជំនាន់ថ្មីវិទ្យាល័យព្រះស៊ីសុវត្ថិបានលទ្ធផលល្អចំនួន ០៤ វិស័យ ហើយសាលារៀនជំនាន់ថ្មីវិទ្យាល័យហ៊ុនសែនកំពង់ចាមបានលទ្ធផលល្អចំនួន ០៥ វិស័យ។ ពិន្ទុមធ្យមភាគរបស់សាលារៀនជំនាន់ថ្មីវិទ្យាល័យព្រះស៊ីសុវត្ថិកើនឡើង ០៧% ក្នុងរយៈពេលនេះ ហើយពិន្ទុមធ្យមភាគរបស់សាលារៀនជំនាន់ថ្មី វិទ្យាល័យហ៊ុនសែនកំពង់ចាមកើនឡើង ២៦% (តារាង S.03)។

### ខ.គណនេយ្យភាពតឹងរឹងជាងមុន ដោយអនុវត្តតាមស្តង់ដាកម្រិតថ្មីមួយរបស់ស្ថាប័ន លទ្ធផល សិក្សារបស់សិស្ស បានកើនដល់កម្រិតមួយទៀត

**ដូច្នេះ សំណួរសួរថា ហេតុអ្វីបានប្រព័ន្ធអភិបាលកិច្ច និងគណនេយ្យភាព ដែលមានប្រសិទ្ធភាពរបស់សាលារៀនជំនាន់ថ្មីអាចលើកកម្ពស់ស្តង់ដារនៃលទ្ធផលសិក្សារបស់សិស្សបានយ៉ាងដូច្នេះ? ទីមួយ រចនាសម្ព័ន្ធអភិបាលកិច្ចរបស់សាលារៀនជំនាន់ថ្មី ត្រូវបានរចនាដើម្បីពង្រឹងតួនាទីស្ថាប័នរបស់សាលារៀន។** ការពង្រឹងតួនាទីនេះធានាប្រសិទ្ធភាពនៃការផ្តល់សេវា។ ភាពខុសគ្នាពីសាលារដ្ឋដទៃទៀត របស់សាលារៀនជំនាន់ថ្មីបានបង្កើតក្រុមប្រឹក្សាភិបាលជាតិមួយដែលមានតួនាទីធានាថា (១) កម្មវិធីរបស់សាលារៀនជំនាន់ថ្មីត្រូវអនុវត្តតាមលក្ខខណ្ឌនៃតារាងសូចនាករគុណផលដែលបានព្រមព្រៀងជាមួយក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (២) ថវិកាត្រូវបានប្រើប្រាស់ត្រឹមត្រូវ និង(៣) ការធានាគុណភាព លក្ខខណ្ឌនៃការទទួលស្គាល់គុណភាពអប់រំ ត្រូវបានអនុវត្តយ៉ាងតឹងរឹងដើម្បីឲ្យសាលារៀនរក្សាឋានៈជារបស់សាលារៀនជំនាន់ថ្មី។ សាលារៀនទាំងអស់ទទួលបានឋានៈជារបស់សាលារៀនជំនាន់ថ្មី ត្រូវគោរពតាមលក្ខខណ្ឌទទួលស្គាល់គុណភាពអប់រំយ៉ាងច្បាស់លាស់ និងហ្មត់ចត់។ សាលារៀនជំនាន់ថ្មីត្រូវបំពេញតាមលក្ខណវិនិច្ឆ័យគុណភាពចំនួន២៤។ ភាពច្បាស់លាស់ និងហ្មត់ចត់នៃដំណើរការទទួលស្គាល់គុណភាពអប់រំបានលើកទឹកចិត្តឱ្យសាលារៀនអនុវត្តតាម។ សាលារៀនជំនាន់ថ្មីទទួលបានការទទួលស្គាល់គុណភាពអប់រំ មានន័យថា សាលារៀនជំនាន់ថ្មីមានសិទ្ធិទទួលថវិកាពីរដ្ឋាភិបាល និងទទួលបានការអនុញ្ញាតឱ្យទទួលវិភាគទានថវិកាពីឪពុកម្តាយសិស្ស។ កត្តាទាំងពីរនេះជាចលករធានាឲ្យសាលារៀនដំណើរការប្រកបដោយចីរភាព។

**រូប S.4៖ សិស្សសាលាជំនាន់ថ្មី ទទួលបានមធ្យមភាគល្អជាងសាលារដ្ឋក្នុងការប្រឡងមធ្យមសិក្សាទុតិយភូមិ**

*តារាង ក ភាគរយនៃនិស្សិតដែលបានប្រឡងបាក់ឌុប*




*តារាង ខ ភាគរយនៃនិស្សិតដែលបានប្រឡងបាក់ឌុបមាននិទ្ទេស A*




*ប្រភព៖ ក្រសួងអប់រំ យុវជន និងកីឡា.*

**តារាង S.3៖ សិស្សសាលារៀនជំនាន់ថ្មីមានការរីកចម្រើនការធ្វើតេស្តត្រីវិះពិចារណា**
(ការធ្វើតេស្តរួមគ្នារវាងថ្នាក់ទី៧ និងទី១០) ពីឆ្នាំ ២០១៦ ដល់ ឆ្នាំ២០១៩

| | វិជ្ជានព្វន្ត | តក្កវិជ្ជា | ចំណាត់ថ្នាក់ | អត្ថាបដិរូប | ការវិភាគបញ្ញត្តិ | ការវិភាគអត្ថបទ | ពិន្ទុសរុបមធ្យមភាគ |
|---|---|---|---|---|---|---|---|
| **សាលារៀនជំនាន់ថ្មី វិទ្យាល័យព្រះសីសុវត្ថិ** | | | | | | | |
| ទិន្នន័យដើម ថ្នាក់ទី ៧ | 64% | 57% | 60% | 59% | 44% | 71% | **59%** |
| ថ្នាក់ទី ១០ បន្ទាប់ពីធ្វើតេស្ត | 73% | 54% | 72% | 66% | 66% | 64% | **66%** |
| ការប្រែប្រួល | 9% | -3% | 12% | 7% | 22% | -7% | **7%** |
| **សាលារៀនជំនាន់ថ្មី វិទ្យាល័យហ៊ុនសែនកំពង់ចាម** | | | | | | | |
| ទិន្នន័យដើម ថ្នាក់ទី ៧ | 50% | 56% | 46% | 14% | 30% | 13% | **35%** |
| ថ្នាក់ទី ១០ បន្ទាប់ពីធ្វើតេស្ត | 74% | 49% | 73% | 69% | 66% | 33% | **61%** |
| ការប្រែប្រួល | 24% | -7% | 27% | 55% | 36% | 20% | **26%** |

*ប្រភព៖* របាយការណ៍ប្រចាំឆ្នាំរបស់សាលារៀនជំនាន់ថ្មី។

**ទីពីរ នៅកម្រិតប្រតិបត្តិប្រព័ន្ធគណនេយ្យភាពនៃសាលារៀនជំនាន់ថ្មី តម្រូវឱ្យនាយក បុគ្គលិក និងគ្រូបង្រៀនកំណត់សូចនាករគុណផលកម្រិតខ្ពស់។** ការអនុវត្តនេះធ្វើឡើងតាមរយៈកម្រងបែងចែកតួនាទី និងភារកិច្ចច្បាស់លាស់ សម្រាប់គណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន និងបុគ្គលិក។ ឧទាហរណ៍ គ្រូបង្រៀនជាប់កិច្ចសន្យា ត្រូវចុះកិច្ចព្រមព្រៀងមួយឆ្នាំម្តង ដោយបែងចែកឲ្យបំពេញតួនាទី និងភារកិច្ច ចែកក្នុងវិចារកម្មមុខងារ។ ការបន្តកិច្ចសន្យាត្រូវប្រើសូចនាករគុណផលពេញចិត្តជាគោលនៃការបំពេញតួនាទី និងភារកិច្ច។ គ្រូបង្រៀនដែលមិនបានបំពេញភារកិច្ច និងសម្រេចសូចនាករគុណផល ដូចការរំពឹងទេ ត្រូវបញ្ជូនទៅសាលាដើមវិញ (សាលារដ្ឋធម្មតា)។

**ទីបី ប្រព័ន្ធវាយតម្លៃគុណផលការងារត្រូវបានអនុវត្តសម្រាប់បុគ្គលិកទាំងអស់ រួមទាំងនាយក និងគ្រូបង្រៀន។** នៅដើមឆ្នាំសូចនាករគុណផលការងារ ត្រូវបានកំណត់សម្រាប់គ្រូបង្រៀន និងនាយកសាលាគ្រប់រូប គឺកំណត់ចំណុចដៅគុណផលដែលត្រូវសម្រេចឲ្យបាន។ សូចនាករគុណផលការងារជួយគ្រូបង្រៀនឲ្យបំបែកសូចនាករឲ្យ ទៅជាសកម្មភាពការងារលម្អិត ដើម្បីសម្រេចចំណុចដៅ។ កត្តានេះជំរុញឱ្យគ្រូបង្រៀន និងបុគ្គលិកមានទឹកចិត្តឈានទៅសម្រេចគុណផលការងារដល់កម្រិតរំពឹងទុក។ សូចនាករគុណផលការងារជួយគ្រូបង្រៀនឱ្យកែលម្អឥរិយាបថ បង្កើនការព្យាយាម ផ្តោតការយកចិត្តទុកដាក់លើគុណភាពនៃការបង្រៀន ចូលរួមរៀនក្នុងកម្មវិធីអភិវឌ្ឍវិជ្ជាជីវៈ ធ្វើបច្ចុប្បន្នភាពវិធីសាស្ត្របង្រៀន និងអភិវឌ្ឍអាជីពវិជ្ជាជីវៈ។ ការផ្លាស់ប្តូរ និងកែលម្អទាំងនេះពិតជារួមចំណែកដល់ការកែលម្អគុណភាពនៃការរៀនរបស់សិស្ស គ្រប់កាល។

**ទីបួន តម្លាភាព និងភាពត្រឹមត្រូវនៃការប្រើថវិកា ធានាឲ្យសាលារៀនជំនាន់ថ្មី វិនិយោគលើការលើកដំកើង ធនធានមនុស្ស និងផ្តល់លាភការជាហិរញ្ញវត្ថុបន្ថែមដល់គ្រូបង្រៀន។** ឧទាហរណ៍ គ្រូបង្រៀន និងបុគ្គលិកនៃសាលារៀនជំនាន់ថ្មីវិទ្យាល័យព្រះស៊ីសុវត្ថិ បានប្រាក់លាភការបន្ថែមស្មើនឹង១២% នៃថវិកាសរុបរបស់សាលា និងថវិកាអភិវឌ្ឍន៍សមត្ថភាពកើន ១៣% ក្នុងឆ្នាំ២០១៩[46]។ លាភការបន្ថែមលើប្រាក់ខែគ្រូបង្រៀនកើនពី ១.៨០០ដុល្លារ អាមេរិក ដល់ ២.៤០០ដុល្លារអាមេរិកក្នុងមួយឆ្នាំ។ លាភការបន្ថែមលើប្រាក់ខែគ្រូបង្រៀននេះលើកទឹកចិត្តឱ្យគ្រូបង្រៀនពង្រឹងវិជ្ជាជីវៈបង្រៀន មកបង្រៀនពេញម៉ោង និងបោះបង់ចោលការបង្រៀនម៉ោងឯកជនដើម្បីរកប្រាក់ចំណូលបន្ថែម។ លទ្ធផលបង្ហាញថា ម៉ោងសិក្សាសម្រាប់សិស្សបានកើនឡើងដល់ ៤០ម៉ោង ក្នុងមួយសប្តាហ៍បើប្រៀបធៀបទៅនឹងសាលារដ្ឋដទៃទៀតមាន ៣០ម៉ោង ទៅ ៣៥ម៉ោង។ ម៉ោងបន្ថែមទាំងនេះបានចូលរួមចំណែកដល់ការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សឲ្យប្រសើរជាងមុន។

## ៥.ការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផលបានលើកកម្ពស់គណនេយ្យភាពសម្រាប់សហគមន៍

### ក.លទ្ធផលសិក្សារបស់សិស្សល្អប្រសើរ បើទោះបីជាប្រភេទសាលារៀនគ្រប់គ្រងដោយផ្អែកលើលទ្ធផលទើបចាប់ផ្តើមក៏ដោយ

បើទោះបីជា ប្រភេទសាលារៀនគ្រប់គ្រងដោយផ្អែកលើលទ្ធផលទើបចាប់ផ្តើមនៅប្រទេសកម្ពុជា ក៏សាលារៀនផ្អែកលើលទ្ធផលនេះត្រូវបានទទួលស្គាល់ថា ជាសាលារៀនគំរូសហគមន៍ដែរ។ សាលារៀនផ្អែកលើលទ្ធផលនេះបានចាប់ផ្តើមក្នុង

46 ថវិកា សាលារៀនជំនាន់ថ្មី។

ឆ្នាំ២០១៧ និងបានសាកល្បងនៅអនុវិទ្យាល័យចំនួន១០០។ គម្រោងសាកល្បងសាលារៀនផ្អែកលើលទ្ធផលនេះកំពុងបង្ហាញអំពីលទ្ធផលជោគជ័យបឋម។ លទ្ធផលសិក្សារបស់សិស្សបានល្អប្រសើរដោយមានលទ្ធផលនៃវឌ្ឍនភាពរបស់សិស្សថ្នាក់ទី៧ ទី៨ និងទី៩ នៃអនុវិទ្យាល័យ។ សិស្សរៀននៅសាលាដែលអនុវត្តការគ្រប់គ្រងដោយផ្អែកលើលទ្ធផល បានកើនគុណផលនៃការសរសេរតែងសេចក្តី និងគណិតវិទ្យាហើយចំនួនសិស្សបាននិទ្ទេស F ក្នុងមុខវិជ្ជាទាំងពីរបានធ្លាក់ចុះ (រូប S.5)។ សូមអានព័ត៌មានបន្ថែមពាក់ព័ន្ធនឹងសេចក្តីសង្ខេបអំពីគុណសម្បត្តិ គុណវិបត្តិ និងជម្រើសគោលនយោបាយ សម្រាប់សាលារៀនអនុវត្តតាម គ្រប់គ្រងដោយផ្អែកលើលទ្ធផល- ឧបសម្ព័ន្ធ ១។

**តេស្តស្តង់ដារអនុវត្តដោយសាលារៀនអនុវត្តការគ្រប់គ្រងដោយផ្អែកលើលទ្ធផល លើកទឹកចិត្តសិស្សឲ្យព្យាយាមរៀនបន្ថែមទៀត។** ការផ្លាស់ប្តូរនេះមានន័យថា សិស្សលែងមានឆ្លើយសំណួរតេស្តប្រចាំខែងាយៗទៀតហើយ។ បច្ចុប្បន្ន សិស្សត្រូវឆ្លើយសំណួរតេស្តលម្អិតតាមមុខវិជ្ជាដែលត្រូវរៀនទាំងអស់។ ការអនុវត្តតេស្តបែបនេះរួមចំណែកឱ្យសិស្សប្រឡងមធ្យមសិក្សាទុតិយភូមិល្អប្រសើរ នៅតាមសាលារៀនដែលបានស្ម័គ្រចិត្តអនុវត្ត ការគ្រប់គ្រងដោយផ្អែកលើលទ្ធផល ទាំងនៅអនុវិទ្យាល័យ និងវិទ្យាល័យ។ លំនាំនៃការគ្រប់គ្រងសាលារៀនបែបនេះមិនត្រឹមតែធ្វើឲ្យលទ្ធផលសិក្សារបស់សិស្សប្រសើរទេ លំនាំនេះក៏ជួយឲ្យសាលារៀនក្បែរៗយកគំរូតាមបានដែរ។ ដោយសារលទ្ធផលវិជ្ជមាននៃសាលារៀនគោលដៅអនុវត្តការគ្រប់គ្រងដោយផ្អែកលើលទ្ធផល មានវិទ្យាល័យ១៨៦ និងសាលាបឋមសិក្សា ២៥៩ បានផ្តើមគំនិតអនុវត្តការគ្រប់គ្រងដោយផ្អែកលើលទ្ធផលដែរ[47]។

### ខ.សាលារៀនគ្រប់គ្រងដោយសហគមន៍ មានគណនេយ្យភាពចំពោះលទ្ធផលសិក្សារបស់សិស្ស

**សាលារៀនអនុវត្តការគ្រប់គ្រងដោយផ្អែកលើលទ្ធផល គឺជាសាលារៀនយកសហគមន៍ជាស្នូល/ឲ្យសហគមន៍ធ្វើម្ចាស់សាលារៀន។** សហគមន៍ផ្តល់ការគាំទ្រ និងធានាថា សេវាអប់រំដែលសាលារៀនផ្តល់ឲ្យត្រូវឆ្លើយតបនឹងតម្រូវការរបស់សហគមន៍។ គោលការណ៍គន្លឹះនេះកំណត់លក្ខណៈសម្បត្តិនៃសាលារៀនអនុវត្តន៍ការគ្រប់គ្រងដោយផ្អែកលើលទ្ធផល លេចមុខខ្ពស់ក្នុងចំណោមសាលារដ្ឋ ដែលផ្តល់សេវាអប់រំប្រកបដោយគុណភាព។ តើលក្ខណៈសម្បត្តិទាំងនោះមានអ្វីខ្លះ និងហេតុអ្វីសំខាន់ដល់ការលើកកម្ពស់គុណភាពនៃការរៀន?

**សាលារដ្ឋធម្មតាប្រឈមនឹងបញ្ហាចម្បង ០៣ គឺ ខ្វះការធានាគណនេយ្យភាពចំពោះសហគមន៍ ខ្វះផែនការអភិវឌ្ឍសាលារៀនប្រកបដោយប្រសិទ្ធភាពដែលផែនការនោះឆ្លុះបញ្ចាំងអាទិភាពរបស់សាលារៀន និងគាំទ្រដល់លទ្ធផលសិក្សារបស់សិស្ស និងការប្រើប្រាស់ការវាយតម្លៃគុណផលការងារមានកម្រិត។** បើទោះបីជាមានការប្រាស្រ័យគ្នារវាងសាលារៀន និងសហគមន៍ក៏ដោយ ក៏ការប្រតិបត្តិអំពីគណនេយ្យភាពរបស់សាលារៀនចំពោះសហគមន៍នៅមានកម្រិតដែរ។ គណៈគ្រប់គ្រងសាលារៀន និងបុគ្គលិក ត្រូវមានគណនេយ្យភាព ក្នុងការឆ្លើយតបនឹងតម្រូវការតាមឋានានុក្រមនៃស្ថាប័ន និងឲ្យសហគមន៍ចូលរួមតិចតួច។ លទ្ធផលបង្ហាញថា សេវាអប់រំមិនឆ្លើយតបឲ្យចំតម្រូវការរបស់សហគមន៍។ សាលារៀនរដ្ឋភាគច្រើនធ្វើផែនការប្រចាំឆ្នាំដែលផែនការទាំងនោះមិនបានដាក់បញ្ចូលតម្រូវការអាទិភាពពិតប្រាកដរបស់សាលារៀន។ ផែនការសាលារៀនទាំងនោះ ច្រើនផ្តោតការយកចិត្តទុកដាក់លើរចនាសម្ព័ន្ធរូបវ័ន្ត និងផ្តល់អាទិភាពតិចតួចលើការលើកកម្ពស់គុណភាពរៀនរបស់សិស្ស។ ការវាយតម្លៃ

**រូប S.5៖ សិស្សនៅសាលារៀនដែលអនុវត្ត SBM បានកែលម្អលទ្ធផលនៃការសិក្សារបស់ពួកគេលើជំនាញតែងសេចក្តី និងគណិតវិទ្យាពីឆ្នាំ២០១៨ ដល់ ឆ្នាំ២០១៩**

*តារាង A. លទ្ធផលរបស់សិស្សក្នុងមុខវិជ្ជាគណិតវិទ្យានៅថ្នាក់ទី៧ ទី៨ និងទី៩*




*តារាង B. លទ្ធផលរបស់សិស្សក្នុងមុខវិជ្ជាតែងសេចក្តី នៅថ្នាក់ទី៧ ទី៨ និងទី៩*




*ប្រភព៖* ការវាយតម្លៃនៃ SBM នៅឆ្នាំ២០១៩

*សម្គាល់៖* ប្រព័ន្ធចំណាត់ពិន្ទុ A ស្មើនឹងល្អប្រសើរ B ស្មើនឹងល្អណាស់ C ស្មើនឹងល្អ D ស្មើនឹងល្អបង្គួរ E ស្មើនឹងមធ្យម F ស្មើនឹងធ្លាក់។

47 ការវាយតម្លៃប្រចាំឆ្នាំរបស់ការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល។

គុណផលការងារនៅតាមសាលារដ្ឋមានកម្រិត បើទោះបីសាលារៀនរដ្ឋមានក្របខ័ណ្ឌវាយតម្លៃគុណផលការងារក៏ដោយ។ សូចនាករគុណផលការងារមិនបានយកមកអនុវត្តឲ្យទូលំទូលាយទេ។ សាលារៀនដែលមានប្រព័ន្ធវាយតម្លៃដែលគ្មានប្រសិទ្ធភាព នាយក និងគ្រូបង្រៀន ព្យាយាមតិចតួចបំផុតក្នុងការបំពេញការងារ។ នាយកសាលារៀន និងគ្រូបង្រៀនខ្លះ មិនបំពេញភារកិច្ចរបស់ខ្លួនក្នុងម៉ោងធ្វើការ។នាយក និងគ្រូបង្រៀនខ្លះបង្កើតឱកាសដាក់ម៉ោងលើសដើម្បីបង្រៀនបានម៉ោងបន្ថែម។ គ្រូបង្រៀនខ្លះបង្រៀនម៉ោងឯកជន ឬបង្រៀនតាមសាលារៀនឯកជនដើម្បីរកប្រាក់ចំណូលបន្ថែម។

**គណនេយ្យភាព លទ្ធផលសិក្សា/គុណភាពនៃការបង្រៀន និងការប្រើប្រាស់ការវាយតម្លៃគុណផលការងារ គឺជាលក្ខណៈសម្បត្តិរបស់សាលារៀនគ្រប់គ្រងដោយផ្អែកលើលទ្ធផល។** លក្ខណៈសម្បត្តិនេះធ្វើឲ្យសាលារៀនគ្រប់គ្រងដោយផ្អែកលើលទ្ធផលខុសពីសាលារដ្ឋទូទៅ។ គណៈកម្មការគ្រប់គ្រងសាលារៀនត្រូវបោះឆ្នោតជ្រើសរើសដោយសហគមន៍។ គណៈកម្មការនេះមានតួនាទីយ៉ាងសំខាន់ ក្នុងការធានាឲ្យមានគណនេយ្យភាពសាលារៀន។ គណៈកម្មការនេះធ្វើជាតំណាង ដើម្បីផលប្រយោជន៍សហគមន៍ ដោយតម្រូវឲ្យសាលារៀនមានគណនេយ្យភាព ក្នុងដោះស្រាយតម្រូវការរបស់សហគមន៍។ គណៈកម្មការនេះត្រូវធានាថាសាលារៀនបំពេញគុណផលការងារឲ្យស្តង់ដាររំពឹងទុក។ ផែនការសាលារៀន ទាំងផែនការប្រតិបត្តិប្រចាំឆ្នាំ និងផែនការកែលម្អសាលារៀនដែលបានកំណត់សកម្មភាពអាទិភាព ត្រូវយល់ព្រមពីគណៈកម្មការគ្រប់គ្រងសាលារៀន។ អំណាចនេះផ្តល់ឱកាសឲ្យគណៈកម្មការគ្រប់គ្រងសាលារៀន តម្រូវឱ្យសាលារៀនដាក់បញ្ចូលតម្រូវការអាទិភាពរបស់សហគមន៍ និងផ្ដល់សេវាអប់រំទៅតាមកញ្ចប់អាទិភាពនេះ។ ផែនការ ០៣ ឆ្នាំ និងផែនការប្រចាំឆ្នាំរបស់សាលារៀនគ្រប់គ្រងដោយផ្អែកលើលទ្ធផលត្រូវបានរៀបចំយ៉ាងហ្មត់ចត់ ដោយមានការពិគ្រោះយោបល់ជិតស្និទ្ធជាមួយគណៈកម្មការគ្រប់គ្រងសាលារៀន។ ការពិគ្រោះយោបល់សំដៅធានាថា សកម្មភាពអាទិភាពរបស់សាលារៀនបានឆ្លុះបញ្ចាំងអំពីតម្រូវការរបស់សហគមន៍។ ផែនការសាលារៀនគ្រប់គ្រងដោយផ្អែកលើលទ្ធផល ត្រូវបានរៀបចំឡើងឲ្យឆ្លើយតបទៅនឹងស្តង់ដារគុណផលសាលារៀន។ ស្តង់ដារគុណផលសាលារៀនផ្តល់អាទិភាពលើលទ្ធផលសិក្សារបស់សិស្ស និងគុណភាពនៃការបង្រៀន។ ស្តង់ដារគុណផលសាលារៀនសំដៅដល់ការប្រើគោលវិធីបង្រៀនថ្មី ដឹកនាំសិស្សរៀនចំណេះដឹងថ្មី ផ្ដល់សុក្រឹតការដល់គ្រូបង្រៀន និងបរិយាកាសហេដ្ឋារចនាសម្ព័ន្ធសាលារៀន។សាលារៀនគ្រប់គ្រងដោយផ្អែកលើលទ្ធផលកំណត់ចំណុចដៅនៃគុណផលការងារប្រចាំឆ្នាំរបស់នាយក គ្រូបង្រៀននិងបុគ្គលិក។សាលារៀនគ្រប់គ្រងដោយផ្អែកលើលទ្ធផលប្រើសូចនាករគុណផលការងារសម្រាប់វាយតម្លៃនាយក គ្រូបង្រៀន និងបុគ្គលិក។ គណៈកម្មការគ្រប់គ្រងសាលារៀនតាមការអនុវត្តផែនការសាលារៀនយ៉ាងជិតដិត។ ការតាមដាន និងវាយតម្លៃ ត្រូវធ្វើប្រចាំឆ្នាំ។ សាលារៀនត្រូវធានាគណនេយ្យភាពចំពោះគុណផលការងារដូចបានកំណត់ក្នុងក្របខ័ណ្ឌសូចនាករគុណផលការងារប្រចាំឆ្នាំ។

**តម្លាភាពក្នុងផែនការសាលារៀន សកម្មភាពប្រតិបត្តិសាលារៀន និងលទ្ធផលសិក្សារបស់សិស្ស បង្កើតឱកាសឲ្យសហគមន៍ចូលរួម និងទាមទារការកែលម្អ ជាពិសេស ករណីបុគ្គលិកសាលារៀនពុំបំពេញគុណផលការងារឲ្យពេញចិត្ត។** ផែនការសាលារៀន និងលទ្ធផលសិក្សារបស់សិស្សត្រូវបិទផ្សាយតាមទីសាធារណៈ ជាសកម្មភាពមួយនៃដំណើរការតម្លាភាព និងសកម្មភាពប្រតិបត្តិរបស់សាលារៀន ហើយលទ្ធផលរៀនរបស់សិស្សត្រូវផ្សព្វផ្សាយដល់សហគមន៍ជាប្រចាំ ទើបសហគមន៍មានព័ត៌មានច្បាស់លាស់។ ក្នុងករណីនាយកសាលា ឬ បុគ្គលិក ពុំបំពេញគុណផលការងារល្អ គណៈកម្មការគ្រប់គ្រងសាលារៀនប្រើអំណាចឲ្យចាត់វិធានការរដ្ឋបាល ចំពោះនាយក និងបុគ្គលិកមិនបំពេញគុណផលការងារ។ គណៈកម្មការគ្រប់គ្រងសាលារៀនអាចបញ្ជូនករណីបែបនេះទៅអាជ្ញាធរថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិពាក់ព័ន្ធ និងអាជ្ញាធរមានសមត្ថកិច្ចឲ្យចាត់វិធានការបាន។

**សាលារៀនគ្រប់គ្រងដោយផ្អែកលើលទ្ធផល ដោះស្រាយបញ្ហាលទ្ធផលសិក្សារបស់សិស្ស ដោយផ្ដល់ម៉ោងរៀនបន្ថែមសម្រាប់សិស្សរៀនយឺត និងអនុវត្តស្តង់ដារតេស្ត ប្រចាំខែយ៉ាងហ្មត់ចត់ (អនុវត្តដូចការប្រឡងមធ្យមសិក្សាទុតិយភូមិ)។** ក្នុងអំឡុងពេលប្រឡងចូលរៀននៅសាលារៀនគ្រប់គ្រងដោយផ្អែកលើលទ្ធផល សាលារៀនអាចកំណត់អត្តសញ្ញាណសិស្សរៀនយឺត រៀនមិនទាន់មិត្តភក្តិ ហើយសាលារៀនជួយសិស្សរៀនយឺតឱ្យរៀនបានរីកចម្រើន បើទោះបីជាគុណផលនៅទាបក៏ដោយ។ ម៉ោងសិក្សាបន្ថែមត្រូវបានផ្ដល់ឲ្យសិស្សរៀនយឺត។ ភាពខ្សោយ និងភាពខ្លាំងរបស់សិស្ស ត្រូវបញ្ជូនជាដំណឹងទៅឪពុកម្តាយ។ ដឹងលទ្ធផលនេះ ឪពុកម្តាយអាចជួយកូនឲ្យរៀនបន្ថែមនៅផ្ទះ។ អនុវត្តតាមវិធីនេះអាចប្រឈមនឹងបញ្ហាមួយប្រភេទ គឺការត្រៀមសំណួរតេស្ត សម្រាប់សិស្សរៀនបន្ថែមម៉ោង ដូច្នេះ គ្រូបង្រៀនមានឱកាសយកថ្លៃសំណួរតេសត្តត្រៀមប្រឡង។ ដូច្នេះសិស្សដែលបានចូលរួមរៀនថ្នាក់បំប៉នបន្ថែម មានឱកាសគិតចម្លើយមុន។ សាលាលរៀនគ្រប់គ្រងដោយផ្អែកលើលទ្ធផល បានលុបបំបាត់ទម្លាប់នេះអស់ហើយ។

**សាលារៀនអនុវត្តគ្រប់គ្រងដោយផ្អែកលើលទ្ធផល គឺកែលម្អប្រសិទ្ធភាពនៃការបង្រៀន តាមរយៈការបង្កើនសមត្ថភាពគ្រូបង្រៀន ហើយតាមលទ្ធភាពបើអាចធ្វើបាន គឺប្រើវិភាគទានរបស់ឪពុកម្តាយសិស្សផ្តល់លាភការលើកទឹកចិត្តដល់គ្រូបង្រៀនសម្រាប់ម៉ោងបន្ថែម។** សាលាលរៀនអនុវត្តការគ្រប់គ្រងដោយផ្អែកលើលទ្ធផលមួយចំនួន ប្រសិនបើមិនទាំងអស់ បានងាកមកប្រើវិភាគទានរបស់ឪពុកម្តាយ ដើម្បីផ្តល់លាភការថវិកាលើកទឹកចិត្តដល់គ្រូបង្រៀនដែលបង្រៀនម៉ោងបន្ថែម ចាប់ពី

៤០ ទៅ ៤៥ម៉ោងក្នុងមួយសប្តាហ៍។ ឧទាហរណ៍ វិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនកោះដាច់ បានកៀរគរមូលនិធិពីសហគមន៍ ដើម្បីផ្តល់លាភការថវិកាលើកទឹកចិត្តដល់គ្រូបង្រៀនដែលបង្រៀនម៉ោងបន្ថែម។ គ្រូបង្រៀនទទួលបានលាភការថវិកាប្រហែល ២.០០០ ដុល្លារអាមេរិក ក្នុងមួយឆ្នាំបន្ថែមលើប្រាក់ខែរដ្ឋ។ លក្ខណៈសម្បត្តិនៃការអនុវត្តខុសគ្នាពីសាលារដ្ឋផ្សេងទៀតត្រង់ថា ម៉ោងបង្រៀនត្រូវបន្ថយ ដោយសារសាលារៀនបង្កើនម៉ោងបង្រៀនពីរវេន។ ដូច្នេះ គ្រូបង្រៀនបានចំណាយពេលវេលារកប្រាក់ចំណូលបន្ថែមក្រៅផ្លូវការតាមរយៈការរៀនក្រៅម៉ោង និងការបង្រៀនម៉ោងឯកជន។ ការព្យាយាមជាបន្តបន្ទាប់ដើម្បីលើកកម្ពស់សមត្ថភាពគ្រូបង្រៀន និងសាលារៀនអនុវត្តការគ្រប់គ្រងដោយផ្អែកលើលទ្ធផល ផ្តល់ម៉ោងបង្រៀនពេញ និងធានាឱ្យការបង្រៀនក្នុងប្រព័ន្ធសាលារៀនកាន់តែមានប្រសិទ្ធភាព ។

## បញ្ហាប្រឈមចម្បងៗក្នុងការកែលម្អលទ្ធផលសិក្សារបស់សិស្សនៅតាមសាលារដ្ឋ

### ១.អភិបាលកិច្ចសាលារៀន និងគណនេយ្យភាពចំពោះសហគមន៍នៅតែគ្មានប្រសិទ្ធភាព

**ការពង្រឹងអភិបាលកិច្ចល្អ និងគណនេយ្យភាព ជាជំហានសំខាន់ឆ្ពោះទៅលើកកម្ពស់ប្រសិទ្ធភាពសាលារៀន។** ការធានាប្រសិទ្ធភាពនៃអភិបាលកិច្ច និងគណនេយ្យភាពជួយកសាងទំនុកចិត្តរបស់សហគមន៍មកលើសាលារៀន ដែលនាំឱ្យមានការចូលរួម និងគាំទ្រកាន់តែច្រើន និងធំធេងពីសហគមន៍។ មានសហគមន៍ចូលរួមកាន់តែសកម្ម សាលារៀនទទួលបានការគាំទ្រផ្នែកប្រតិបត្តិការ និងហិរញ្ញវត្ថុកាន់តែច្រើន ដើម្បីធានាឲ្យសិស្សរៀនកាន់តែមានប្រសិទ្ធភាព។

**ទោះជាយ៉ាងនេះក្តី អភិបាលកិច្ច និងគណនេយ្យភាពរបស់សាលារដ្ឋ មិនមានប្រសិទ្ធភាពទេ (ប្រអប់ 2)។** ទោះបីជាក្រសួងអប់រំ យុវជន និងកីឡាបានចេញសេចក្តីណែនាំស្តីពីគណៈកម្មការទ្រទ្រង់សាលារៀនកាលពីខែមករា ឆ្នាំ២០០២ សំដៅឲ្យសាលារៀនដំណើរការ និងធ្វើការជាមួយសហគមន៍ ការអនុវត្តនៅតាមសាលា មិនទាន់អាចធ្វើបាននៅឡើយទេ។ ប្រធានគណៈកម្មការទ្រទ្រង់សាលារៀនមួយចំនួន ចូលកាន់តំណែងដោយពុំមានបោះឆ្នោត ឬចូលកាន់តំណែងដោយការបោះឆ្នោតប៉ុន្តែត្រូវយល់ព្រមទទួលយកពីនាយកសាលា។ ដោយមើលឃើញការបង្កើតគណកម្មការគ្រប់គ្រងសាលារៀនរបស់សាលារៀនអនុវត្តការគ្រប់គ្រងដោយផ្អែកលើលទ្ធផលជាគំរូនៃឧទាហរណ៍សាលារៀនរដ្ឋមួយចំនួនបានប្តូររចនាសម្ព័ន្ធអភិបាលកិច្ច ដោយប្តូរពីគណកម្មការទ្រទ្រង់សាលារៀនទៅជាគណកម្មការគ្រប់គ្រងសាលារៀន។ គណកម្មការគ្រប់គ្រងសាលារៀនមានអំណាចគ្របដណ្តប់លើនាយកសាលា និងគ្រូបង្រៀនឲ្យប្រតិបត្តិគណនេយ្យភាព ដើម្បីធានាគុណផលសាលារៀន។

**យន្តការអភិបាលកិច្ច និងគណនេយ្យភាព គួរបង្កើតទំនុកចិត្តរបស់សហគមន៍ ដោយឲ្យសហគមន៍មានតួនាទី និងសម្លេងកាន់តែច្រើនក្នុងប្រតិបត្តិការសាលារៀន។** អនុសាសន៍ខាងក្រោមបានដកស្រង់ចេញពីបទពិសោធន៍របស់សាលាលរៀនអនុវត្តការគ្រប់គ្រងដោយផ្អែកលើលទ្ធផល និងសាលារៀនជំនាន់ថ្មី ។

#### ក.ការផ្តល់សិទ្ធិអំណាចដល់គណៈកម្មការគ្រប់គ្រងសាលារៀន

**បទពិសោធន៍របស់សាលាលរៀនអនុវត្តការគ្រប់គ្រងដោយផ្អែកលើលទ្ធផល បង្ហាញថា ប្រសិទ្ធភាពនៃគណៈកម្មការគ្រប់គ្រងសាលារៀនមួយ សំដៅជួយសាលារៀនឲ្យផ្តល់សេវាជូនសហគមន៍តាមសន្យា។** សាលារៀនរដ្ឋកាន់តែច្រើនមានចេតនាបញ្ចូលគណកម្មការទ្រទ្រង់សាលារៀន ក្នុងរចនាសម្ព័ន្ធអភិបាលកិច្ចរបស់សាលារៀន។ សាលារៀនមួយមានគណកម្មការគ្រប់គ្រងសាលារៀន មិនទាន់គ្រប់គ្រាន់ទេ។ គណកម្មការគ្រប់គ្រងសាលារៀន ចាំបាច់ត្រូវមានអំណាចជាតំណាងនៃសម្លេងរបស់សហគមន៍ និងត្រូវឯករាជ្យពីថ្នាក់ដឹកនាំសាលារៀន និងគណៈគ្រប់គ្រងសាលារៀន។ ដូច្នេះ សាលារៀនមានគណនេយ្យភាពឆ្លើយតបនឹងតម្រូវការរបស់សហគមន៍។ លើសពីនេះទៀត គណកម្មការគ្រប់គ្រងសាលារៀន គួរមានតួនាទីគ្របដណ្តប់លើថ្នាក់ដឹកនាំ និងគណៈគ្រប់គ្រងសាលារៀន ឲ្យប្រតិបត្តិគណនេយ្យភាពចំពោះគុណផលការងាររបស់ខ្លួន។ ការប្រតិបត្តិគណនេយ្យភាពត្រូវតែច្បាស់លាស់ និងប្រាកដប្រជា។

#### ខ.ការលើកដំកើងតម្លាភាពនៃប្រតិបត្តិការសាលារៀន

**ដូចបានរៀបរាប់ពីខាងដើមរួចហើយ គ្មានតម្លាភាពនៃប្រតិបត្តិការសាលារៀន និងគ្មានព័ត៌មានអំពីការប្រើប្រាស់មូលនិធិសាលារៀន សហគមន៍ពុំអាចជឿទុកចិត្តបានទេ។** ដូច្នេះ ការងារអាទិភាព គឺលើកដំកើងតម្លាភាពសាលារៀនឲ្យឡើងមួយកម្រិតទៀត។ ដើម្បីសម្រេចចេតនានេះ រាល់ព័ត៌មានទាក់ទងនឹងផែនការសាលារៀន ការប្រតិបត្តិសាលារៀន និងថវិកា គួរផ្សព្វផ្សាយសាធារណៈ និងឲ្យបានទៀងទាត់ដល់សហគមន៍។ ករណីសាលារៀនអនុវត្តការគ្រប់គ្រងដោយផ្អែកលើលទ្ធផល លទ្ធផលសិក្សារបស់សិស្សត្រូវផ្សព្វផ្សាយជាសាធារណៈ និងទៀងទាត់។ ការផ្សព្វផ្សាយនេះបង្កើតបរិយាកាសមួយឲ្យសាធារណៈដឹងអំពីបញ្ហា និងអំពីយុទ្ធសាស្ត្រ ក្នុងការដោះស្រាយបញ្ហា។ ចំណែកសាលារៀនជំនាន់ថ្មី តម្លាភាពជួយសាលារៀនក្នុងការលើកដំកើងប្រសិទ្ធភាពនៃការសម្រេចលទ្ធផលរំពឹងទុកតាមការសន្យារបស់សាលារៀន។

#### គ.ការលើកកម្ពស់ការធានាគុណភាព

**និតិវិធីតាមដាន ត្រូវមាននៅកម្រិតសាលារៀន ដែលទទួលភារកិច្ចធ្វើអធិការកិច្ចលើការបង្រៀន និងធានាថា សិស្សបានសម្រេចលទ្ធផលសិក្សារំពឹងទុក កំណត់តាមកម្រិតថ្នាក់រៀន។** សាលារៀនគួរបង្កើតយន្តការភ្ជាប់ការតាមដានជាមួយនឹងលទ្ធផលសិក្សារបស់សិស្ស។ ក្រោមឈ្មោះសាលារៀនអនុវត្តការគ្រប់គ្រងដោយផ្អែកលើលទ្ធផល ការប្រើប្រាស់តេស្តស្តង់ដារសម្រាប់វាយតម្លៃការសិក្សារបស់សិស្ស និងការតាមដានដំណើរការរៀនរបស់

## ហេតុអ្វីបានជាអភិបាលកិច្ចសាលារៀន និងគណនេយ្យភាពមិនមានប្រសិទ្ធិភាពនៅតាមសាលារដ្ឋ?

ការធ្វើឲ្យអភិបាលកិច្ចសាលារៀន និងគណនេយ្យភាពនៅតាមសាលារដ្ឋមានប្រសិទ្ធភាពទាបគឺ បណ្ដាលមកពីមូលហេតុចម្បងចំនួន ០៤។

១. **ភាពជាអ្នកដឹកនាំសាលាគ្មានប្រសិទ្ធភាព។** ភ័ស្ដុតាងប្រយោលបង្ហាញថា សាលារៀនដែលមានអ្នកដឹកនាំមិនល្អមានទំនោរធ្វើឲ្យប្រសិទ្ធភាពមានកម្រិតទាប។ ឧទាហរណ៍ នាយកសាលាជាច្រើនមិនត្រឹមតែគ្រប់គ្រងប្រតិបត្តិការរបស់សាលារៀនមិនបានល្អប៉ុណ្ណោះទេ ហើយថែមទាំងអត់ធ្មត់ចំពោះការបំពេញការងារមិនបានល្អរបស់គ្រូបង្រៀនថែមទៀត ដូចជាការមកធ្វើការយឺត អវត្តមានដោយគ្មានមូលហេតុ និងការត្រួតពិនិត្យមិនទៀងទាត់លើប្រសិទ្ធភាពនៃការបង្រៀន។ នាយកសាលាជាច្រើនក៏បានមើលស្រាលតួនាទីរបស់គណកម្មការទ្រទ្រង់ និងគ្រប់គ្រងសាលារៀនក្នុងការដាក់ឲ្យសាលារៀនទទួលខុសត្រូវចំពោះលទ្ធផលការងារ។

២. **ការអនុវត្តការប្រើប្រាស់ថវិកាមិនសមស្រប។** ប្រភព និងការប្រើប្រាស់ថវិកាមានសារៈសំខាន់ណាស់ដើម្បីធានាបាននូវប្រសិទ្ធភាពនៃប្រតិបត្តិការរបស់សាលារៀន។ កង្វះតម្លាភាពអាចមានផលប៉ះពាល់ពីរយ៉ាង គឺ (ក) ជម្លោះរវាងគ្រូ និងនាយកសាលាលើការចំណាយថវិកា និង (ខ) នាយកសាលាគ្មានអំណាចអនុវត្តលើបុគ្គលិក សូម្បីតែក្នុងករណីមានការប្រើប្រាស់ថវិកាមិនត្រឹមត្រូវក្ដី។ ស្ថានភាពនេះធ្វើឲ្យវិន័យគ្រូមិនល្អ និងប្រសិទ្ធភាពបង្រៀនទាប។

៣. **មិនមានការយកចិត្តទុកដាក់គ្រប់គ្រាន់ពីគ្រូបង្រៀនក្នុងការបំពេញភារកិច្ចរបស់ខ្លួន។** ទោះបីជាតួនាទី និងការទទួលខុសត្រូវរបស់គ្រូបង្រៀន បានចែងបញ្ជាក់យ៉ាងច្បាស់នៅក្នុងបទដ្ឋានរបស់គ្រូបង្រៀនក៏ដោយ ក៏ការបំពេញភារកិច្ចដែលក្រសួងអប់រំដាក់ចេញបានអនុវត្តដោយមានកម្រិត។ ទម្លាប់បង្រៀនដែលគ្មានប្រសិទ្ធភាពទាំងនេះភាគច្រើនបណ្ដាលមកពីការត្រួតពិនិត្យគុណភាពបង្រៀនមិនទៀងទាត់នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ហើយនឹងការយល់ឃើញក្នុងចំណោមគ្រូ ដែលមានប្រាក់ខែទាប ទោះបីជាប្រាក់ខែមានការកើនឡើងគួរឱ្យកត់សម្គាល់ ក្នុងរយៈពេលប្រាំមួយឆ្នាំកន្លងមកក៏ដោយ។

៤. **កង្វះការគាំទ្រដើម្បីកែលម្អទោះបីមានឆន្ទៈក៏ដោយ។** សាលារៀនខ្លះមិនបានបំពេញការងារអភិបាលកិច្ច និងគណនេយ្យភាពបានល្អក៏ប៉ុន្តែ មានឆន្ទៈចង់កែលម្អប្រសើរជាងនេះ។ សាលារៀនទាំងនេះជួបប្រទះបញ្ហាប្រឈមនៃកម្រិតចំណេះដឹង ធនធាន និងដើមទុននយោបាយ ហើយភាគច្រើនប្រឹងប្រែងសហការជាមួយសហគមន៍វិះរកវិធីកែលម្អប្រតិបត្តិការរបស់សាលារៀន។

*ប្រភព៖* របកគំហើញនៃការសិក្សារបស់ធនាគារពិភពលោក “គណនេយ្យភាព ការលើកទឹកចិត្ត និងលទ្ធផលនៃការរៀនសូត្រ ៖ ករណីសិក្សានៃគំរូសាលារៀនដែលបានជ្រើសរើស (ធនាគារពិភពលោក ឆ្នាំ 2020b)។



សិស្ស ដោយប្រើលទ្ធផលតេស្តស្តង់ដារ គឺជួយសាលារៀនឲ្យតាមដានប្រសិទ្ធភាពនៃការបំពេញគុណផលនៃការបង្រៀនរបស់គ្រូបង្រៀន និងគុណផលនៃការរៀនរបស់សិស្ស។

**ឃ.ការពង្រឹងគណនេយ្យភាពរបស់អាជ្ញាធរស្រុក-ខណ្ឌ**

**អាជ្ញាធរស្រុក-ខណ្ឌ អាចដើរតួយ៉ាងសំខាន់ក្នុងការលើកដំកើងសេវាអប់រំនៅថ្នាក់ស្រុក-ខណ្ឌ ជាពិសេស ក្នុងការដោះស្រាយបញ្ហាខ្វះ និងលើសគ្រូបង្រៀន។** ការិយាល័យអប់រំស្រុក-ខណ្ឌ ជាពិសេសការិយាល័យទទួលភារកិច្ចត្រួតពិនិត្យការប្រតិបត្តិរបស់សាលារៀនកម្រិតបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ ជាតួអង្គបង្គោល។ ភារកិច្ចពង្រាយគ្រូបង្រៀនក្នុងស្រុក-ខណ្ឌឲ្យមានប្រសិទ្ធភាព គឺជួយពន្លឿន និងជួយកាត់បន្ថយភាពស្មុគស្មាញនៃនីតិវិធីរដ្ឋបាល និងឆ្លើយតបឲ្យត្រូវនឹងតម្រូវការសហគមន៍។ លើសពីនេះទៀត ការចូលរួមយ៉ាងសកម្ម និងប្រកបដោយឆន្ទៈរបស់អាជ្ញាធរស្រុក-ខណ្ឌ គឺជួយដល់សិស្សដែលចេញពីសាលាបឋមសិក្សាដែលបំពេញគុណផលសិក្សារបស់សិស្សបានទាបឲ្យចូលរៀននៅអនុវិទ្យាល័យ ដោយបង្កើនលទ្ធផលសិក្សារួមរបស់សិស្ស។

**ង.លាភការលើកទឹកចិត្តគ្រូបង្រៀនមិនអនុវត្តតាមគោលការណ៍គុណផលការងារអាចនាំឱ្យមានគម្លាតគុណភាពអប់រំកាន់តែធំ រវាងសាលារៀនរដ្ឋ និងសាលារៀនឯកជន**

**ប្រាក់ខែ និងឋានន្តរសក្តិមុខងារ ជាឧបករណ៍សំខាន់ដែលរដ្ឋាភិបាលត្រូវប្រើដើម្បីលើកទឹកចិត្តដល់មន្ត្រីរាជការឱ្យបំពេញការងារតាមភារកិច្ច។** ចាប់ពីឆ្នាំ២០១៣ រដ្ឋាភិបាលបានដំឡើងប្រាក់ខែមន្ត្រីរាជការគុណបីដងនៃប្រាក់ខែដើម។ លាភការគ្រូបង្រៀន ដូចជាប្រាក់គរុកោសល្យ ប្រាក់តំបន់ជួបការលំបាក និងដាច់ស្រយាល ប្រាក់ ម៉ោងបន្ថែម ប្រាក់ម៉ោងបង្រៀនពីរវេន ឬប្រាក់បង្រៀនថ្នាក់ក្ដួប និងប្រាក់គ្រួសារ។ បន្ថែមលើនេះទៀត ការដំឡើងកាំឋានន្តរសក្តិមុខងារសម្រាប់គ្រូបង្រៀន ធ្វើរៀងរាល់ពីរឆ្នាំម្តង។ អនុវត្តន៍គោលការណ៍នេះ ពុំបានជួយគុណផលការងាររបស់គ្រូបង្រៀនទេ។

**ការដំឡើងប្រាក់ខែទូទៅ ពិតជាជួយលើកស្ទួយជីវភាពគ្រូបង្រៀន ប៉ុន្តែពុំមានប្រសិទ្ធភាពកែលម្អគុណភាពអប់រំប្រសិនបើពុំមានយន្តការគណនេយ្យភាពទេ។** ក្រសួងអប់រំបានណែនាំឲ្យអនុវត្តការវាយតម្លៃគុណផលការងាររបស់គ្រូបង្រៀន ប៉ុន្តែការវាយតម្លៃនេះពុំសូវមានអនុវត្តតាមសាលារៀនរដ្ឋទេ ហើយមានសាលារៀនរដ្ឋមួយចំនួនតូចស្គាល់អំពីដំណើរការ ឬ ទម្រង់នៃការវាយតម្លៃគុណផលការងារនេះ។ បន្ថែមលើនេះទៀត ការវាយតម្លៃគុណផលការងារច្រើនផ្តោតការយកចិត្តទុកដាក់លើការគោរពគោលការណ៍បង្រៀន ប៉ុន្តែពុំផ្តោតការយកចិត្តទុកដាក់ការវាយតម្លៃគុណភាពនៃការបង្រៀន ដើម្បីធានាលើកដំកើងគុណភាពនៃការរៀនរបស់សិស្សទេ។ ការវាយតម្លៃគុណផលការងារដែលខ្វះប្រសិទ្ធភាព និងការធានាគុណភាពអប់រំដែលខ្វះសង្គតិភាព គឺ ធ្វើឲ្យថយចុះគណនេយ្យភាពនៃការលើកកម្ពស់គុណភាពបង្រៀន និងរៀន។

**សាលារៀនឯកជន ជួលគ្រូបង្រៀនពីសាលារដ្ឋ ប៉ុន្តែគ្រូបង្រៀនអនុវត្តការងារតាមភារកិច្ចនៅសាលារៀនឯកជន បានប្រសើរជាង។** លទ្ធផលនៃការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សថ្នាក់ជាតិឆ្នាំ២០១៧ បង្ហាញថា សិស្ស សាលាឯកជនឆ្លើយសំណួរគណិតវិទ្យា និងភាសាខ្មែរបានត្រឹមត្រូវពីរដងច្រើនជាងសិស្សសាលារដ្ឋ (រូប S.7)។ ប្រសិទ្ធភាពអភិបាលកិច្ចប្រព័ន្ធគណនេយ្យភាព និងការធានាគុណភាពហ្មត់ចត់ លើកកម្ពស់លទ្ធផលសិក្សារបស់សិស្សបានខ្ពស់នៅតាមសាលាឯកជន

**រូប S.6៖ សិស្សថ្នាក់ទី៦ នៅតាមសាលាឯកជនមានលទ្ធផលសិក្សាល្អជាងសិស្សសាលារដ្ឋក្នុងឆ្នាំ២០១៧**

(ភាគរយនៃចម្លើយត្រឹមត្រូវ)




*ប្រភព៖* ការវាយតម្លៃលើសិស្សក្នុងស្រុក ក្រសួងអប់រំ

**រូប S.7៖ ចាប់ផ្តើមប្រាក់ម៉ោងបង្រៀនរបស់គ្រូបង្រៀននៅ** សាលាឯកជន បើប្រៀបធៀបជាមួយគ្រូបង្រៀនតាមសាលារដ្ឋសម្រាប់កម្រិតបឋម និងមធ្យមសិក្សា




*ប្រភព៖* បុគ្គលិកធនាគារពិភពលោក.

*សម្គាល់៖* ប្រាក់ខែចាប់ផ្តើមក្នុងមួយម៉ោងនៅតាមសាលាឯកជនគឺផ្អែកលើការសម្ភាសជាមួយក្រុមអប់រំសំខាន់ចំនួនពីររបស់ចំណេះទូទៅភាសាខ្មែរ។ នៅក្នុងការអនុវត្តជាក់ស្តែង សាលាឯកជនមានទំនោរផ្តល់ប្រាក់ខែចាប់ផ្តើម ហើយបានបង្កើនជាជរាបដោយផ្អែកលើលទ្ធផលការងាររបស់គ្រូបង្រៀន។

បើទោះបី គ្រូបង្រៀនទទួលប្រាក់ម៉ោងបង្រៀនទាបក៏ដោយ។ ឧទាហរណ៍ ប្រាក់ម៉ោងបង្រៀនសាលាឯកជនធំៗចំនួនពីរនៅរាជធានីភ្នំពេញ បានត្រឹម១,៩០ដុល្លារ ក្នុងមួយម៉ោង សម្រាប់គ្រូបង្រៀនកម្រិតបឋមសិក្សា និង ត្រឹម៣,៥០ដុល្លារ ទៅ ៤,០០ ដុល្លារអាមេរិក ក្នុងមួយម៉ោងសម្រាប់គ្រូបង្រៀនកម្រិតមធ្យមសិក្សា (រូប S.8)។ ប្រាក់ម៉ោងបង្រៀនសាលារដ្ឋ តាមការប៉ាន់ស្មាន គឺចាប់ពី ៣,៧៥ដុល្លារអាមេរិកក្នុងមួយម៉ោង សម្រាប់គ្រូបង្រៀននៅសាលាបឋមសិក្សា និង៤,៥០ដុល្លារក្នុងមួយម៉ោងសម្រាប់គ្រូបង្រៀនកម្រិតមធ្យមសិក្សា[48]។

**ការដំឡើងប្រាក់ខែទូទៅ ពង្រីកគម្លាត នៃគុណភាពអប់រំរវាងសាលារដ្ឋ និងសាលារៀនឯកជនកាន់តែធំ។** បច្ចុប្បន្នសាលាឯកជនក៏កំពុងរងសម្ពាធក្នុងការដំឡើងប្រាក់ខែគ្រូបង្រៀនឲ្យស្មើនឹងប្រាក់ខែរដ្ឋ។ សំពាធនេះជំរុញឲ្យការចំណាយលើតម្លៃនៃការអប់រំកាន់តែកើនឡើង។ ក្នុងទីផ្សារប្រកួតប្រជែងខ្លាំងសាលារៀនឯកជនដែលប្រើគ្រូបង្រៀនរួមជាមួយសាលារៀនរដ្ឋមានហេតុផលច្បាស់លាស់ក្នុងការដំឡើងថ្លៃសាលាឲ្យខ្ពស់ក្នុងការ លើកកម្ពស់គុណភាពអប់រំ។ ទីមួយ ដើម្បីប្រកួតប្រជែងសាលារៀនឯកជនត្រូវកសាងសមត្ថភាពគ្រូបង្រៀន។ ទីពីរ សាលារៀនឯកជនត្រូវធានាថាគុណផលការងាររបស់គ្រូបង្រៀនត្រូវសម្រេចតាមក្តីរំពឹងតាមស្តង់ដារ។ ដោយសារហេតុផលនេះ គ្រូបង្រៀនត្រូវរងសម្ពាធបំពេញការងារតាមភារកិច្ចឱ្យបានល្អនៅសាលាឯកជន។

**អន្តរាគមន៍ពុំមានប្រសិទ្ធភាព គម្លាតនៃគុណភាពទំនងជារីកធំនាពេលអនាគត។** ការអនុវត្តគោលការណ៍ នៃការដំឡើងប្រាក់បៀវត្សរ៍ដោយប្រើគុណផលការងារ ការបង្កើតប្រព័ន្ធវាយតម្លៃគុណផលការងារមានប្រសិទ្ធភាព និងការអនុវត្តគន្លងអាជីពគ្រូបង្រៀន នឹងពង្រីកប្រយោជន៍នៃការប្រើធនធានដែលត្រូវចំណាយលើការអប់រំឲ្យដល់អតិបរិមារ និងរួមចំណែកដល់ការកែលម្អប្រសិទ្ធភាពនៃការរៀនសូត្រនៅសាលារៀនរដ្ឋ។

### ក.ការដំឡើងប្រាក់ខែ និងការដំឡើងមុខងារ ត្រូវភ្ជាប់នឹងគុណផលការងារ

**ក្របខ័ណ្ឌនៃការដំឡើងប្រាក់ខែ ដោយប្រើគុណផលការងារហាក់ដូចជាពិបាកអនុវត្តក្នុងស្ថាប័នរដ្ឋ ជាពិសេស នៅសាលារៀនរដ្ឋ។** ហេតុផលទី១ បញ្ហាប្រឈមមួយក្នុងការអនុវត្តគុណផលការងារ គឺសមត្ថភាពស្ថាប័នពុំទាន់គ្រប់គ្រាន់ ក្នុងការវាយតម្លៃគុណផលការងារឲ្យយុត្តិធម៌ និងសង្គតិភាព ក្នុងវិស័យរដ្ឋទាំងមូល។ ហេតុផលទីពីរ បញ្ហាប្រឈមគឺ ប្រតិកម្មជំទាស់ចំពោះការអនុវត្តប្រព័ន្ធគុណផលការងារ ក្នុងប្រព័ន្ធរដ្ឋ។ ប្រព័ន្ធវាយតម្លៃគុណផលការងារមានប្រសិទ្ធភាពមានន័យចំពោះគ្រូបង្រៀនត្រង់ថា គ្រូបង្រៀនត្រូវគោរពស្តង់ដារបង្រៀនឲ្យបានពេញលេញ។ ការអនុវត្តប្រព័ន្ធនេះតម្រូវឱ្យគ្រូបង្រៀនបោះបង់ការងារទីពីរ ដូចជា បង្រៀនឯកជន ការបង្រៀនតាមសាលាឯកជន ឬបង្រៀនក្រៅម៉ោង។ ការបោះបង់ការងារទីពីរប៉ះពាល់ការរកប្រាក់ចំណូលបន្ថែមលើប្រាក់ខែគោល (សូមមើលប្រអប់ S.3) ។ បទពិសោធរបស់សាលារៀនជំនាន់ថ្មី និងសាលារៀនអនុវត្តការគ្រប់គ្រង់ដោយផ្អែកលើលទ្ធផលពន្យល់ថា សាលារៀនគួរបង្កើតប្រព័ន្ធគ្រប់គ្រងគុណផលការងារមួយសមស្រប និងទទួលយកបានសម្រាប់បុគ្គលិកភាគច្រើន ប្រសិនបើមិនទាំងអស់។ ចំណុចដៅនៃគុណផលការងារត្រូវតែកំណត់ឲ្យច្បាស់ អនុវត្តប្រកបដោយសង្គតិភាព និងតាមដានឲ្យយុត្តិធម៌ និងមានតម្លាភាព។

### ខ.ជំរុញអនុវត្តស្តង់ដារគ្រូបង្រៀន

**បទពិសោធរបស់សាលារៀនជំនាន់ថ្មី និងសាលារៀនអនុវត្តការគ្រប់គ្រងផ្អែកលើលទ្ធផលបង្ហាញថា ការភ្ជាប់ប្រាក់លើកទឹកចិត្ត និងការដំឡើងប្រាក់ខែជាមួយនឹងគុណផលការងារ អាចអនុវត្តបាន តាមរយៈការគាំទ្រនយោបាយរឹងមាំនៅថ្នាក់ជាតិ ប្រព័ន្ធគណនេយ្យភាពសាលារៀនប្រកបដោយប្រសិទ្ធភាព និងស្វ័យភាពសាលារៀនកាន់តែធំធេងក្នុងដំណើការគ្រប់គ្រងប្រតិបត្តិការសាលារៀន។** ទោះបីការអនុវត្តប្រព័ន្ធផ្តល់លាភការតាមគុណផលការងារមិនស្រួលក៏ដោយ ប្រសិនបើមិនធ្វើនោះទេ គឺខាតបង់ការចំណាយច្រើនជាងអនុវត្តប្រព័ន្ធផ្តល់លាភការតាមគុណផលការងារ។ ដូចបានលើកឡើងរួចមកហើយ ការដំឡើងប្រាក់ខែនឹងមានផលប៉ះពាល់តិចតួចលើគុណភាពអប់រំ ហើយលទ្ធផលសិក្សាមិនល្អនៅតែបន្តកើតឡើងយ៉ាងហោចណាស់ក្នុងរយៈពេលមធ្យមតទៅទៀត។ ដូច្នេះ ការអនុវត្តប្រព័ន្ធគ្រប់គ្រងតាមគុណផលការងារឲ្យមានប្រសិទ្ធភាព គឺចាំបាច់ណាស់ នៅតាមសាលារដ្ឋដោយត្រូវ (i) ជំរុញអនុវត្តស្តង់ដារគ្រូបង្រៀន ដែលតម្រូវឱ្យគ្រូបង្រៀនបំពេញការងារតាមវិចាភារកិច្ចពេញម៉ោង លើការងារបង្រៀន មានការបង្រៀន និងការត្រៀមមេរៀន (ii) លុបបំបាត់ទំនាស់ផលប្រយោជន៍ណាមួយ។ ករណីឧទាហរណ៍សាលារៀនជំនាន់ថ្មី មិនអនុញ្ញាតឲ្យគ្រូបង្រៀនបន្ថែមម៉ោងបង្រៀនដើម្បីយកលុយពីសិស្សឡើយ និង (iii) ដាក់ចេញនីតិវិធីរដ្ឋបាលប្រកបដោយភាពយុត្តិធម៌ និងតម្លាភាពចំពោះគ្រូបង្រៀន ដែលមានគុណផលការងារទាប។

### គ.ការបង្កើតសូចនាករគុណផលការងារឲ្យមានប្រសិទ្ធភាព (KPIs)

**សូចនាករគុណផលការងារមិនត្រឹមវាស់គុណផលការងាររបស់គ្រូបង្រៀន ឬ បុគ្គលិកទេ ប៉ុន្តែត្រូវអនុវត្តនៅកម្រិតសាលារៀន និងសម្រាប់មន្ត្រីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលទទួលខុសត្រូវតាមដានគុណផលការងាររបស់សាលារៀន។** កត្តាសំខាន់មួយដែលការអនុវត្តសូចនាករគុណផលការងារច្រើនមើលរំលងគឺលទ្ធផលសិក្សារបស់សិស្ស។

### ឃ.ការអនុវត្តគន្លងអាជីពគ្រូបង្រៀន

**ដូចអាជីពការងារផ្សេងដែរ បន្ថែមលើលាភការហិរញ្ញវត្ថុលើកទឹកចិត្ត ការអភិវឌ្ឍវិជ្ជាជីវៈជាការលើកទឹកចិត្តដ៏សំខាន់សម្រាប់**

48 ប្រាក់ម៉ោងបង្រៀនផ្អែកទៅលើការសម្ភាសជាមួយសាលាឯកជនធំៗពីរនៅក្រុងភ្នំពេញ។

## ប្រអប់ S.3

## ភស្តុតាងបង្ហាញអំពីការឆ្លើយតបរបស់គ្រូបង្រៀនចំពោះលាភការជាប្រាក់លើកទឹកចិត្ត

**គំនិតផ្តួចផ្តើមអំពីការផ្ទេរទេពកោសល្យនៅសហរដ្ឋអាមេរិក ជាកម្មវិធីពិសោធមួយ ផ្តល់ប្រាក់ឧបត្ថម្ភដល់គ្រូបង្រៀនសរុប ២ម៉ឺនដុល្លារ ក្នុងរយៈពេលពីរឆ្នាំ ត្រូវបានបង្កើតឡើងដើម្បីលើកទឹកចិត្តគ្រូបង្រៀនឲ្យផ្លាស់ទីកន្លែងបង្រៀន ពីសាលារៀនល្អទៅសាលារៀនខ្សត់ខ្សោយ[a]។** អត្រាគ្រូបង្រៀនទទួលការផ្លាស់ទីកន្លែងបង្រៀនក្នុងកម្មវិធីនេះទាប គឺគ្រូបង្រៀនប្រហែល៥% ទទួលយកប្រាក់ឧបត្ថម្ភដើម្បីការផ្លាស់ប្តូរកន្លែងបង្រៀននេះ។ គ្រូបង្រៀនដែលបានប្តូរសាលាបង្រៀនទៅសាលារៀនដែលក្រីក្រខ្លាំង នៅបន្តការបង្រៀន នៅពេលទទួលបានប្រាក់ឧបត្ថម្ភបន្ថែម។

**ការស្រាវជ្រាវដែលមានគុណភាពខ្ពស់ៗជាច្រើន ផ្តោតការយកចិត្តទុកដាក់លើប្រយោជន៍ នៃកម្មវិធីពង្រាយគ្រូបង្រៀនទៅជួយសិស្សជួបការលំបាក។** Clotfelter និងសហការី (ឆ្នាំ២០០៨) វិភាគកម្មវិធីរយៈពេលខ្លីរបស់រដ្ឋ South Carolina ដែលផ្តល់ប្រាក់លើកទឹកចិត្ត ១.៨០០ ដុល្លាដល់គ្រូគណិតវិទ្យាសាស្ត្រ និងគ្រូអប់រំពិសេស ដែលចេញទៅបម្រើការងារនៅសាលារៀនក្រខ្សត់ខ្លាំង ឬ សាលារៀនដែលសម្រេចគុណផលសិក្សាទាប។ អ្នកស្រាវជ្រាវទាំងនេះប៉ាន់ស្មានថាប្រាក់លើកទឹកចិត្តនេះកាត់បន្ថយអត្រាគ្រូបង្រៀនបោះបង់ការងារពី ៣០% មក ២៥%។ របកគំហើញនៃការស្រាវជ្រាវរបស់ Cowan និង Goldhaber ឆ្នាំ ២០១៥ បង្ហាញលទ្ធផលនៃអត្រាគ្រូបង្រៀនបោះបង់ការងារស្រដៀងគ្នានឹងការស្រាវជ្រាវខាងលើដែរ។ ការស្រាវជ្រាវនេះបានអង្កេតកម្មវិធីមួយនៅរដ្ឋវ៉ាស៊ីនតោន។ កម្មវិធីរដ្ឋវ៉ាស៊ីនតោននេះផ្តល់ប្រាក់ឧបត្ថម្ភដល់គ្រូបង្រៀនដែលមានវិញ្ញាបនបត្រស្តង់ដារគ្រូបង្រៀនបញ្ជាក់ពីក្រុមប្រឹក្សាជាតិវិជ្ជាជីវៈបង្រៀននូវថវិកា ៥,០០០ ដុល្លារអាមេរិក ចំពោះគ្រូបង្រៀនដែលទៅបម្រើការងារនៅសាលារៀនក្រខ្សត់ខ្លាំង និងបន្ថែមប្រាក់ ៥,០០០ ដុល្លារអាមេរិកទៀត ចំពោះគ្រូបង្រៀនដែលបានទទួលវិញ្ញាបនបត្រគុណភាពបង្រៀនបញ្ជាក់ពីក្រុមប្រឹក្សា។ ការស្រាវជ្រាវបែបអង្កេតនេះរកឃើញពីថយចុះដូចបានសង្កេតឃើញនេះបង្ហាញអំពីការប្រែប្រួលប្រហែល ៤,៣ ប្រហាក់ប្រែលនឹងការប៉ាន់ស្មានរបស់ Clotfelter និងអ្នកនិពន្ធផ្សេងទៀត (ឆ្នាំ ២០០៨)។

**Springer, Swain និង Rodriguez (ឆ្នាំ ២០១៦) បានវាយតម្លៃកម្មវិធីមួយនៅ Tennessee ដែលផ្តល់ប្រាក់លើកទឹកចិត្ត ៥,០០០ ដុល្លារអាមេរិកដល់គ្រូបង្រៀនដែលទទួលពិន្ទុវាយតម្លៃខ្ពស់នៅសាលារៀនដែលមានគុណផលសិក្សាទាប។** ក្រុមអ្នកស្រាវជ្រាវនេះរកឃើញថា ការទទួលប្រាក់លើកទឹកចិត្តធ្វើឲ្យអត្រាគ្រូបង្រៀនបន្តការងារបង្រៀនតាមកម្រិតថ្នាក់ និងមុខវិជ្ជាវាយតម្លៃ ក្នុងចំនួនដូចគ្នានឹងរបកគំហើញការស្រាវជ្រាវខាងដើម។ ក្រុមអ្នកស្រាវជ្រាវនេះប្រៀបធៀបការចំណាយនៃទឹកប្រាក់លើកទឹកចិត្តចំពោះ ការរក្សាចំនួនគ្រូបង្រៀនរបស់រដ្ឋ Tennessee ជាមួយនឹងការចំណាយនៃសកម្មភាពអន្តរាគមន៍ផ្សេងៗ ដូចជា សាលារៀនក្នុងរដូវក្តៅ និងការកាត់បន្ថយចំនួនសិស្សក្នុងថ្នាក់។ ការស្រាវជ្រាវនេះសន្និដ្ឋានថា ប្រាក់លើកទឹកចិត្តរបស់រដ្ឋ Tennessee ហាក់ដូចជាវិធីដែលមានប្រសិទ្ធភាពគួរសមក្នុងការបង្កើនគុណផលសិក្សារបស់សិស្ស។ ការសិក្សាមួយរបស់ Falch (ឆ្នាំ២០១០) វិភាគផលប៉ះពាល់នៃប្រាក់ឧបត្ថម្ភនៅតាមសាលារៀនន័រវេស ជាមួយនឹងការខ្វះកម្លាំងពលកម្ម ហើយបានរកឃើញអំពីការប្រែប្រួល ១,៤ នៃការផ្គត់ផ្គង់កម្លាំងពលកម្មដើម្បីឆ្លើយតបនឹងគោលដៅបង្កើនប្រាក់ខែតាមសាលារៀន។ ចំណុចដែលសំខាន់នោះគឺការប៉ាន់ស្មាននេះឆ្លុះបញ្ចាំងអំពីការរក្សាចំនួនគ្រូបង្រៀនក្នុងពេលបច្ចុប្បន្ន និងជោគជ័យក្នុងការជ្រើសរើសគ្រូបង្រៀនថ្មី ខុសពីការប៉ាន់ស្មានមុនៗ ដែលមានចំនួនខ្ពស់ជាងដែលឆ្លុះបញ្ចាំងអំពីផលប៉ះពាល់តែចំពោះការរក្សាចំនួនតែប៉ុណ្ណោះ។

**ទោះជាយ៉ាងនេះក្តី នៅបណ្តាប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួននៅអាស៊ី ប្រសិនបើគ្មានការវាយតម្លៃអំពីគ្រូពូកែ ការគាំទ្រដល់ការអភិវឌ្ឍវិជ្ជាជីវៈ និងប្រព័ន្ធគណនេយ្យភាពច្បាស់លាស់នោះទេ ការលើកទឹកចិត្តក៏មិនអាចឲ្យលទ្ធផលសិក្សារបស់សិស្សល្អឡើងបានដែរ។** នៅប្រទេសឥណ្ឌូនេស៊ី ច្បាប់ស្តីពីគ្រូបង្រៀនឆ្នាំ២០០៥ ផ្តល់ប្រាក់ឧបត្ថម្ភវិជ្ជាជីវៈចំនួន ១០០ ភាគរយនៃប្រាក់ខែគោលដល់ទៅគ្រូបង្រៀនដែលបានបញ្ចប់វិញ្ញាបនប័ត្រ។ លទ្ធផលទទួលបានគឺធ្វើឲ្យមានថវិកាចំណាយបន្ថែមលើប្រាក់ខែ ប៉ុន្តែពុំបានបង្កើនបំណិនបង្រៀនដល់គ្រូបង្រៀន ឬ លទ្ធផលសិក្សារបស់សិស្សទេ។ តាមរយៈការសង្កេតលទ្ធផលតេស្ត PISA ពីឆ្នាំ ២០០៣ ដល់ឆ្នាំ ២០១៥ ពិន្ទុមធ្យមភាគគណិតវិទ្យារបស់សិស្សឥណ្ឌូនេស៊ីមិនអាចឡើងដល់ពិន្ទុកំណត់របស់អង្គការ OECD ក្នុងរយៈពេល ៤៨ ឆ្នាំទៅមុខ និងបំណិនអំណាន ក្នុងរយៈពេល ៧៣ឆ្នាំទៅមុខទៀត។ សមិទ្ធផលដែលអាចធ្វើបាយការណ៍បានមានតែមួយមុខគត់គឺការបង្កើនប្រាក់ខែគ្រូបង្រៀនទ្វេដង បង្ហាញអំពីកម្រិតនៃការពេញចិត្តការងារខ្ពស់ជាងមុន និងភាគរយគ្រូបង្រៀនធ្វើការងារទីពីរថយចុះទាបជាងមុន[b]។

**ស្រដៀងគ្នានឹងលទ្ធផលខាងលើដែរ នៅប្រទេសប៉ាគីស្ថាន គម្រោងសាកល្បងផ្តល់ប្រាក់លើកទឹកចិត្តចំពោះការងារល្អពុំមានឥទ្ធិពលវិជ្ជមានលើពិន្ទុរៀនរបស់សិស្សទេ ហើយការដែលពុំមានឥទ្ធិពលវិជ្ជមានលើពិន្ទុតេស្តប្រហែលបណ្តាលមកពីភាពទន់ខ្សោយក្នុងរចនាសម្ព័ន្ធនៃកម្មវិធីលើកទឹកចិត្ត និង/ឬ និរគុណភាពនៃទិន្នន័យរដ្ឋបាលរបស់កម្មវិធី។** រដ្ឋាភិបាលបានសាកល្បងផ្តល់ប្រាក់លើកទឹកចិត្តដល់គ្រូបង្រៀនដោយបង្កើន (១) ១៣% នៃប្រាក់ខែគោលប្រចាំឆ្នាំ ប្រសិនបើធ្វើការនៅសាលារៀន ដែលកើនពិន្ទុប្រឡងជាមធ្យម ១០ ពិន្ទុ (បើទោះជាគ្មានការប្រែប្រួលលើការចុះឈ្មោះ និងអត្រាចូលរួមប្រឡង ៩៥% ក៏ដោយ) (២) ចំនួន ១១% ប្រសិនបើធ្វើការនៅសាលាដែលបង្កើនការចុះឈ្មោះ ១០% ដោយគ្មានការប្រែប្រួលពិន្ទុប្រលងជាមធ្យម និងអត្រាចូលរួមប្រឡង (៣) ១០% នៅតាមសាលារៀន ដែលមិនបានបង្កើនពិន្ទុប្រឡងជាមធ្យម ការចុះឈ្មោះ ប៉ុន្តែបង្កើនអត្រាចូលរួមប្រឡងដល់ ៩៩% និង (៤) ចំនួន ៩,៤% នៅតាមសាលារៀនមួយដែលមិនបានផ្លាស់ប្តូរសូចនាករណាមួយក្នុងចំណោមសូចនាករទាំងបី។ តម្លៃប្រាក់លើកទឹកចិត្តសម្រាប់គ្រូបន្ទុកថ្នាក់ មានចំនួនទ្វេដងនៃប្រាក់លើកទឹកចិត្តសម្រាប់គ្រូបង្រៀន។ លទ្ធផលបានបង្ហាញថា មានការកើនឡើងនៃអត្រាចុះឈ្មោះរបស់សិស្សចូលរៀន និងសិស្សចូលរួមប្រឡងនៅឆ្នាំទី២ និងទី៣ ប៉ុន្តែមិនមានឥទ្ធិពលវិជ្ជមានលើពិន្ទុប្រឡងទេ[c]។

**នៅប្រទេសវៀតណាម បទដ្ឋានវប្បធម៌ និងគោលនយោបាយរដ្ឋមានសារៈសំខាន់ក្នុងការលើកកម្ពស់ និងទាក់ទាញបេក្ខជនដែលមានសមត្ថភាពឲ្យចូលប្រកបវិជ្ជាជីវៈបង្រៀន។** ការងារបង្រៀនជាវិជ្ជាជីវៈមានប្រាក់ខែទាប ធៀបនឹងវិជ្ជាជីវៈផ្សេងដែលទាមទារគុណវុឌ្ឍិប្រហាក់ប្រហែល ឬទាបជាង។ គ្រូបង្រៀនដែលមានបទពិសោធន៍ដែលបម្រើការរយៈពេល ៣៩ឆ្នាំ ទទួលបានប្រាក់ខែប្រហែល ៤៣៩ ដុល្លារអាមេរិកក្នុងមួយខែ ហើយគ្រូបង្រៀនថ្មីទទួលប្រាក់ខែតិចជាង ២០០ដុល្លារក្នុងមួយខែ។ ធម្មតាគ្រូបង្រៀនជនជាតិវៀតណាមត្អូញត្អែរអំពីប្រាក់ខែទាប ខណៈពេលដែលរដ្ឋបានបន្តដំឡើងប្រាក់ខែជូនគ្រូបង្រៀន។ ទោះជាយ៉ាងនេះក្តីរបាយការណ៍បង្ហាញថា ប្រព័ន្ធអភិបាលកិច្ចរឹងមាំនៅតាមសាលារៀន ការវាយតម្លៃគ្រូបង្រៀន និងឱកាសរៀនសូត្រវិជ្ជាជីវៈក្រៅប្រព័ន្ធជាការអនុវត្តជោគជ័យដើម្បីជួយឲ្យគ្រូបង្រៀនបំពេញភារកិច្ចប្រកបដោយវិជ្ជាជីវៈ[d]។ លទ្ធផលបង្ហាញថា សិស្សជនជាតិវៀតណាម ដែលមានអាយុ ១៥ឆ្នាំ ជាមធ្យមមានលទ្ធផលសិក្សាល្អជាងពិន្ទុសិស្សកំណត់របស់អង្គការ OECD នៅលើការប្រឡង PISA ឆ្នាំ ២០១៥[e]។

*ប្រភព៖* Dee and Goldhaber 2017។

*សម្គាល់៖* ប្រអប់នេះរៀបរៀងដោយលោក ភឹម រុនសុីណារិទ្ធិ និង ណូ ហ្វាតា។

*a.* Glazerman et al. 2013. b. “Learning: To Realize Education’s Promise,” World Bank, Washington, DC, 2018. c សូមមើល Barrera-Osorio and Raju 2017. d. McAleavy, Ha, and Fitzpatrick 2018. e. World Bank 2018.

**គ្រូបង្រៀន។** គន្លងអាជីពគ្រូបង្រៀនត្រូវបានព្រាងក្នុងផែនការសកម្មភាពអនុវត្តគោលនយោបាយគ្រូបង្រៀន[49]។ ផែនទីអាជីពគ្រូបង្រៀនត្រូវសរសេរឲ្យបានច្បាស់អំពី គុណសម្បទាស្នូលសម្រាប់អភិវឌ្ឍអាជីពគ្រូបង្រៀនឲ្យខ្ពស់ និងត្រូវភ្ជាប់នឹងផែនការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន។ គន្លងអាជីពនេះគួរពិចារណាលើ (i) ការធ្វើផែនទីគ្រូបង្រៀនដែលបំពេញគុណផលទាប ដើម្បីរក្សាទុក និងពង្រាយឲ្យទៅបំពេញការងាររដ្ឋបាល (ii) ការរៀបចំផែនការសកម្មភាពស្តីពីការចូលនិវត្តន៍មុនពេលកំណត់ សម្រាប់គ្រូបង្រៀនដែលមានវ័យចំណាស់ និងបំពេញគុណផលការងារទាប និង (iii) លើកដំកើងគ្រូបង្រៀន ដែលបំពេញគុណផលការងារខ្ពស់ ដើម្បីអភិវឌ្ឍអាជីពបង្រៀនកាន់តែរីកចម្រើន និងពោរពេញដោយវិជ្ជាជីវៈ។ ការអភិវឌ្ឍអាជីពឲ្យកាន់តែរីកចម្រើនចាំបាច់ត្រូវភ្ជាប់នឹងការដំឡើងប្រាក់ខែ។

### ៣.លើសចំនួនគ្រូបង្រៀន និងខ្វះគ្រូបង្រៀនប៉ះពាល់ដល់លទ្ធផលសិក្សារបស់សិស្សយ៉ាងអវិជ្ជមាន

**ការពង្រាយគ្រូបង្រៀនប្រកបដោយប្រសិទ្ធភាពអាចសន្សំប្រាក់បានប្រហែល១០% នៃប្រាក់ខែបុគ្គលិកជារៀងរាល់ឆ្នាំ[50]។** ទាំងការលើសចំនួន និងខ្វះចំនួនគ្រូបង្រៀនបានប៉ះពាល់ស្ទើរតែគ្រប់ផ្នែកនៃការអភិវឌ្ឍវិស័យអប់រំ ហើយបង្កើនផលប៉ះពាល់នៃអភិបាលកិច្ច និងយន្តការគណនេយ្យភាពដែលកំពុងគ្មានប្រសិទ្ធភាព លើលទ្ធផលសិក្សារបស់សិស្ស។ ការខ្វះគ្រូបង្រៀន ត្រូវបន្ថែមចំនួនសិស្សឲ្យច្រើនក្នុងមួយថ្នាក់ៗ ដូច្នេះបន្ថែមបន្ទុកការងារមិនសមហេតុផលដល់គ្រូបង្រៀន និងធ្វើឱ្យប៉ះពាល់ដល់ប្រសិទ្ធភាពនៃការសិក្សារបស់សិស្ស។ សាលារៀនខ្លះនៅតំបន់ជនបទផ្ទុកសិស្សរហូតដល់ ៦០នាក់ ក្នុងមួយថ្នាក់សម្រាប់គ្រូបន្ទុកថ្នាក់មួយនាក់។ ចំនួនគ្រូបង្រៀនលើសកំណត់តាមសាលារៀននៅទីក្រុងក៏ធ្វើឱ្យធនធានគ្មានប្រសិទ្ធផលដែរ ព្រោះគ្រូបង្រៀនត្រូវយកពេលវេលាទំនេរទៅរកប្រាក់ចំណូលបន្ថែម ដោយបង្រៀនក្រៅម៉ោងយកកម្រៃបន្ថែមខណៈទទួលបានប្រាក់ខែដូចគ្នានឹងគ្រូងកំពុងបង្រៀនយ៉ាងសកម្មនៅតាមសាលារៀន[51]។ រយៈពេលពីរឆ្នាំកន្លងមកឃើញមានការខិតខំប្រឹងប្រែងបញ្ជូនគ្រូបង្រៀនពីសាលារៀន ដែលមានបុគ្គលិកលើសចំនួនទៅកាន់សាលារៀនដែលខ្វះគ្រូបង្រៀន។ ការអភិវឌ្ឍគន្លងអាជីពគ្រូបង្រៀននឹងបំពេញបន្ថែមលើកិច្ចខិតខំប្រឹងប្រែង ដើម្បីពង្រាយគ្រូបង្រៀនដែលមានចំនួនលើសតម្រូវការ។ ទោះយ៉ាងណាក៏ដោយ បញ្ហានេះនៅតែជាកត្តាប្រឈមខ្លាំង ដោយសារតែនៅតាមជនបទមានការខ្វះខាតគ្រូបង្រៀន ហើយបែរជាគ្រូបង្រៀនមានចំនួនលើសតម្រូវការនៅតាមទីក្រុងទៅវិញ[52]។

#### ក.ការលើកកម្ពស់គុណភាពនៃការបញ្ជូនទិន្នន័យទៅប្រព័ន្ធគ្រប់គ្រងព័ត៌មានធនធានមនុស្ស

**ការលើកកម្ពស់គុណភាពទិន្នន័យបុគ្គលិកក្នុង ប្រព័ន្ធគ្រប់គ្រងព័ត៌មានធនធានមនុស្ស(HRMIS) អាចជួយដោះស្រាយបញ្ហាខ្វះ និងលើសគ្រូបង្រៀន។** ប្រព័ន្ធគ្រប់គ្រងព័ត៌មានធនធានមនុស្សល្អប្រសើរ ផ្តល់ព័ត៌មានសំខាន់ៗសម្រាប់គ្រប់គ្រងការអប់រំជាទូទៅ និងជាឧបករណ៍សម្រាប់គាំទ្រដល់ផែនការបន្តសេវាកម្មអប់រំក្នុងស្ថានភាពវិបត្តិ ដូចជា ការរាតត្បាតជំងឺកូវីដ-១៩។ ទោះបីប្រព័ន្ធគ្រប់គ្រងព័ត៌មានធនធានមនុស្សដែលមានស្រាប់ត្រូវបានបង្កើតឡើងដើម្បីតាមដានតម្រូវការរបស់គ្រូបង្រៀនតាមសាលារៀនក៏ដោយ ក៏ទិន្នន័យក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មានធនធានមនុស្ស មិនបានឆ្លុះបញ្ចាំងស្ថានភាពជាក់ស្តែងអំពីតម្រូវការរបស់គ្រូបង្រៀនតាមសាលារៀនឲ្យបានទាន់ពេលនោះដែរ[53]។ ក្នុងករណីខ្លះ ទិន្នន័យពីសាលារៀនមិនត្រូវបានបញ្ជូនមក ឬបញ្ជូនមកយឺតពេល។ លទ្ធផលបង្ហាញថា ចំនួនជ្រើសរើសបុគ្គលិកថ្មីត្រូវបានផ្អែកលើការប៉ាន់ស្មានទិន្នន័យឆ្នាំមុនៗ ហើយទិន្នន័យបញ្ជូនមកឲ្យប្រព័ន្ធគ្រប់គ្រងព័ត៌មានធនធានមនុស្សមិនមានលក្ខណៈជាក់ស្តែង[54]។ ដូច្នេះ ជំហានដែលអាចធ្វើឡើង គឺ (i) បណ្តុះបណ្តាលបុគ្គលិក និងប្រធានការិយាល័យអប់រំខេត្ត និងការិយាល័យអប់រំស្រុក អំពីនិយាមស្តីពីតម្រូវការបុគ្គលិក និងវិធីគណនាចំនួនខ្វះនិងចំនួនលើសនៃគ្រូបង្រៀន (ii) ណែនាំអំពីតម្រូវការចាំបាច់របស់សាលារៀន ដែលត្រូវបញ្ជូនទិន្នន័យដែលអាចទុកចិត្តបានទៅក្នុងប្រព័ន្ធគ្រប់ គ្រងព័ត៌មានធនធានមនុស្សឱ្យទាន់ពេលវេលា និង (iii) ត្រួតពិនិត្យគុណភាពទិន្នន័យតាមរយៈយន្តការផ្ទៀងផ្ទាត់ច្បាស់លាស់។

#### ខ.លើកដំកើងតម្លាភាពលើការពង្រាយគ្រូបង្រៀនចេញថ្មី

**ការលើកដំកើងតម្លាភាពលើការពង្រាយគ្រូបង្រៀនថ្មីនៅថ្នាក់ខេត្ត ជួយកែលម្អគុណភាពនៃការជ្រើសរើសគ្រូបង្រៀន ឲ្យត្រូវកន្លែងត្រូវការគ្រូបង្រៀន។** មន្ទីរអប់រំខេត្តមានអំណាចពង្រាយគ្រូបង្រៀនទៅតាមសាលារៀន ដែលត្រូវការបំផុត។ ជាក់ស្តែង ការពង្រាយគ្រូបង្រៀននៅក្រោមសមត្ថកិច្ចរបស់មន្ទីរអប់រំខេត្តមានចន្លោះខ្វះខាតខ្លះ។ មានករណីជាច្រើនដែលគ្រូបង្រៀនទើបបណ្តុះបណ្តាលចេញថ្មី ត្រូវបញ្ជូនទៅតាមសាលារៀននៅជនបទ ប៉ុន្តែមិនបានឃើញមុខបង្ហាញខ្លួន ព្រោះ មន្ទីរអប់រំខេត្ត បញ្ជូន

---

49 ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០១៩-ឆ្នាំ២០២៣។

50 “ការកែលម្អប្រសិទ្ធភាពនៃហិរញ្ញវត្ថុសាធារណៈ “ការត្រួតពិនិត្យចំណាយសាធារណៈនៅកម្ពុជា ធនាគារពិភពលោក ឆ្នាំ២០១៩។

51 “ការគ្រប់គ្រងគ្រូបង្រៀន និងការកែលម្អការងារ ៖ បញ្ហា និងវិធីអនុវត្តដើម្បីឆ្ពោះទៅមុខ” ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១៨។

52 មើល ការត្រួតពិនិត្យចំណាយសាធារណៈនៅកម្ពុជា ធនាគារពិភពលោក ឆ្នាំ២០១៩។

53 តាមនីតិវិធី ការប៉ាន់ស្មានពីតម្រូវការរបស់គ្រូបង្រៀនចាប់ផ្តើមពីកម្រិតសាលារៀន។ ការប៉ាន់ស្មានត្រូវផ្ញើទៅការិយាល័យអប់រំស្រុក-ខណ្ឌ ទៅមន្ទីរអប់រំខេត្ត រហូតដល់នាយកដ្ឋានបុគ្គលិកនៃក្រសួងអប់រំ យុវជន និងកីឡា។ ការប៉ាន់ស្មានចំនួនគ្រូដែលត្រូវការជារៀងរាល់ឆ្នាំត្រូវបានពិភាក្សាជាមួយនឹងក្រសួងមុខងារសាធារណៈ ដើម្បីកំណត់កូតាសម្រាប់ការជ្រើសរើសគ្រូបង្រៀន។ បន្ទាប់ពីក្រសួងអប់រំ យុវជន និងកីឡាបានជ្រើសរើសគ្រូបង្រៀន និងបណ្តុះបណ្តាលពួកគេនៅវិទ្យាស្ថានជាតិអប់រំហើយ គ្រូបង្រៀនត្រូវបានបញ្ជូនទៅសាលារៀនតាមរយៈការិយាល័យអប់រំស្រុក-ខណ្ឌ ទៅមន្ទីរអប់រំខេត្ត។

54 “ការគ្រប់គ្រងគ្រូបង្រៀន និងការកែលម្អការងារ ៖ បញ្ហា និងវិធីអនុវត្តដើម្បីឆ្ពោះទៅមុខ” ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១៨។

តែឈ្មោះទៅសាលារៀនជនបទ ហើយគ្រូបង្រៀនទាំងនោះមិនមកបង្ហាញខ្លួន ប៉ុន្តែបែរជាបានផ្ទេរទៅតាមសាលារៀននៅទីក្រុងភ្លាមៗ ក្រោយពេលចាត់តាំង។ លក្ខន្តិកៈទូទៅនៃមន្ត្រីរាជការស៊ីវិលឆ្នាំ១៩៩៦ ចែងថា បុគ្គលិកអប់រំ (ទាំងជាគ្រូបង្រៀន ឬ មិនមែនជាគ្រូបង្រៀន) អាចផ្ទេរសាលាបង្រៀនបាន លុះត្រាតែបានបញ្ចប់បំពេញការងាររយៈពេល ៤ឆ្នាំជាមុនសិន។ ទោះយ៉ាងណាក៏ដោយ ក្នុងការអនុវត្តជាក់ស្តែង ការផ្ទេរសាលាបង្រៀនអាចធ្វើទៅបាន ពីព្រោះមិនមានការត្រួតពិនិត្យ ឬ តាមដានសេចក្តីសម្រេចទាំងនោះឡើយ។ យន្តការផ្លូវការក្នុងការជូនដំណឹងអំពីបញ្ហាទាំងនេះទៅថ្នាក់លើៗក៏មិនឃើញមាន ដូច្នេះនាយកសាលាមិនអាចបញ្ឈប់ទម្លាប់ផ្ទេរសាលាបង្រៀនបែបនេះបានទេ។ ការបញ្ចេញព័ត៌មានជាសាធារណៈស្តីពីការចាត់តាំង និងការផ្ទេរគ្រូបង្រៀនដោយមានហេតុផលត្រឹមត្រូវ មានសារប្រយោជន៍ក្នុងការធានា ការចាត់តាំងគ្រូបង្រៀនឱ្យបានត្រឹមត្រូវ និងដើម្បីពង្រឹងគណនេយ្យភាព។ យន្តការតវ៉ាក៏អាចបង្កើតឡើងដើម្បីប្រមូលមតិយោបល់ស្តីពីភាពមិនប្រក្រតីនៃការចាត់តាំង និងការផ្ទេរគ្រូបង្រៀន។

### គ.ការពង្រាយគ្រូបង្រៀនពីសាលារៀនលើសគ្រូបង្រៀនទៅសាលារៀនខ្វះគ្រូបង្រៀន

**គម្រោងពង្រាយគ្រូបង្រៀនពីទីក្រុងទៅតំបន់ជនបទ ត្រូវប្រឈមបញ្ហាចម្បងៗជាច្រើន។** ការផ្ទេរកន្លែងបង្រៀនត្រូវបានធ្វើឡើងដោយស្ម័គ្រចិត្ត ក៏ប៉ុន្តែហាក់ដូចជាមិនមានការលើកទឹកចិត្តគ្រប់គ្រាន់ ឬ មិនមានហេតុផលគួរឲ្យជឿជាក់គ្រប់គ្រាន់សម្រាប់គ្រូបង្រៀននៅពេលផ្លាស់សាលារៀន ទោះបីជាក្រសួងអប់រំមានគំនិតផ្តួចផ្តើមរៀបចំផ្លាស់គ្រូបង្រៀនក៏ដោយ។ នៅតាមទីក្រុងបទដ្ឋាននៃការរស់មានលក្ខណៈល្អសមរម្យ រួមមានសេវា ហេដ្ឋារចនាសម្ព័ន្ធ និងសុខភាពនៅតាមទីក្រុង ហើយគ្រូបង្រៀនមានទំនោរចង់តាំងទីលំនៅទីប្រជុំជន និងចិញ្ចឹមគ្រួសារនៅទីប្រជុំជន។ គ្រូបង្រៀនក៏មានឱកាសកាន់តែច្រើនអាចទទួលបានប្រាក់ចំណូលបន្ថែមក្នុងតំបន់ទីប្រជុំជន ដូចជា បង្រៀននៅសាលាឯកជន បង្រៀនគួរបន្ថែមម៉ោង ឬ ការបង្រៀនតាមផ្ទះ។

**ការិយាល័យអប់រំស្រុក និងនាយកសាលាអាចសហការផ្ទេរគ្រូបង្រៀនក្នុងដែនសមត្ថកិច្ច ដើម្បីធ្វើឱ្យមានតុល្យភាពដើម្បីដោះស្រាយការខ្វះខាត និងការលើសចំនួនគ្រូបង្រៀន។** យើងអាចលើកទឹកចិត្តឲ្យគ្រូបង្រៀនដែលនៅសេសសល់ទៅបង្រៀនថ្នាក់បឋមសិក្សា ដើម្បីឆ្លើយតបតម្រូវការគ្រូមត្តេយ្យកាន់តែច្រើនជាងមុន ដោយត្រូវផ្តល់ប្រាក់លើកទឹកចិត្តខ្លះ។ យើងក៏គួរអនុញ្ញាតឲ្យគ្រូបង្រៀន ដែលនៅសេសសល់ជិតដល់អាយុចូលនិវត្តន៍អាចចូលនិវត្តន៍មុនពេលកំណត់ ឬ ប្តូរទៅបម្រើការងារជាបុគ្គលិករដ្ឋបាលវិញ។

### ៤.វិនិយោគតិចតួចរបស់រដ្ឋាភិបាលសម្រាប់អភិវឌ្ឍន៍វិជ្ជាជីវៈនាយក និងគ្រូបង្រៀន

**ដើម្បីផ្តល់ជូនគ្រូបង្រៀននូវជំនាញដែលត្រូវការ ដើម្បីធានាគុណភាពនៃការបង្រៀន វិនិយោគបន្ថែមដើម្បីពង្រឹងការបណ្តុះបណ្តាលគ្រូបង្រៀន និងបង្កើនសមត្ថភាពគ្រូបង្រៀន ដែលកំពុងបម្រើការងារ។** រដ្ឋាភិបាលបានបង្កើនចំណាយលើការអប់រំយ៉ាងច្រើន ដោយផ្តោតសំខាន់លើការដំឡើងប្រាក់ខែក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ។ ទោះជាយ៉ាងនេះក្តី ក៏ការវិនិយោគនៅមានកម្រិតទាបលើការបង្កើនសមត្ថភាពគ្រូបង្រៀន។ បទពិសោធរៀនពីសាលារៀនជំនាន់ថ្មី និងសាលារៀនអនុវត្តការគ្រប់គ្រងដោយផ្អែកលើលទ្ធផលបង្ហាញថា ការវិនិយោគបន្ថែមលើការកសាងសមត្ថភាពគ្រូបង្រៀនអាចរួមចំណែកលើកដំកើងលទ្ធផលសិក្សារបស់សិស្ស[55]។ ការវិនិយោគបន្ថែមអាចមានឥទ្ធិពលលើលទ្ធផលសិក្សារបស់សិស្ស ប្រសិនបើមានការអនុវត្តយន្តការអភិបាលកិច្ច និងយន្តការគណនេយ្យភាពត្រឹមត្រូវ។

**មានគ្រូបង្រៀនដែលមានគុណភាពខ្ពស់ ជាគុណសម្បត្តិដល់ការធានាគុណភាពអប់រំខ្ពស់ ក្នុងរយៈពេលមធ្យម និងរយៈពេលវែង។** រដ្ឋាភិបាលបានអភិវឌ្ឍមជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូបង្រៀន ឲ្យទៅជាវិទ្យាស្ថានគរុកោសល្យខេត្តបាត់ដំបងដើម្បីផ្តល់ការអប់រំ និងបណ្តុះបណ្តាលរយៈពេល៤ឆ្នាំ។ ការវិនិយោគបន្ថែមត្រូវធ្វើឡើងផងដែរនៅមជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី នៅវិទ្យាស្ថានជាតិអប់រំក្នុងឆ្នាំ២០១៩។ ចំណុចសំខាន់នោះគឺត្រូវអនុវត្តឲ្យបានតឹងរឹងចំពោះការប្រឡងចូលវិទ្យាស្ថានគរុកោសល្យ ហើយបេក្ខជនយ៉ាងហោចណាស់តម្រូវឲ្យមានបរិញ្ញាប័ត្រមុនអនុញ្ញាតឲ្យប្រឡង។ វិទ្យាស្ថានគរុកោសល្យគួរសហការរួមបញ្ចូលប្រធានបទបណ្តុះបណ្តាល ដើម្បីបង្កើនធនធានដែលមានស្រាប់ជាអតិបរិមា។ យើងអាចខិតខំប្រឹងប្រែងឲ្យបានខ្លាំងជាងមុនដើម្បីបង្កើនសមត្ថភាពគ្រូ និងសិក្ខាកាមនៅសាលាគរុកោសល្យខេត្ត (PTTC) និងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ (RTTC)។ សូមមើល តារាង S.4 ស្តីពីជម្រើសគោលនយោបាយដើម្បីពង្រឹងគុណភាពអប់រំ។

**សំខាន់ដូចគ្នា គឺការអភិវឌ្ឍសមត្ថភាពនាយក និងគ្រូបង្រៀនដែលកំពុងបម្រើការងារ ព្រោះការអភិវឌ្ឍវិជ្ជាជីវៈ និងការបណ្តុះបណ្តាលនាយក និងគ្រូបង្រៀនកំពុងបម្រើការងារ មានតិចតួចណាស់។** របាយការណ៍គិតត្រឹមឆ្នាំ២០១៨ មានគ្រូបង្រៀនកំពុងបម្រើការងារចំនួន ២៧% តែប៉ុណ្ណោះ បានទទួលការបណ្តុះបណ្តាលជំនាញ[56]។

---

55 សាលាជំនាន់ថ្មី ទទួលបានការវិនិយោគចំនួន 370 ដុល្លារអាមេរិក សម្រាប់សិស្សម្នាក់ក្នុងមួយឆ្នាំសម្រាប់កម្រិតមធ្យមសិក្សា និង SBM ទទួលបាន 70 ដុល្លារអាមេរិក សម្រាប់សិស្សម្នាក់ក្នុងមួយឆ្នាំបន្ថែមពីលើប្រាក់ជំនួយសម្រាប់កែលម្អសាលារៀន (SIG) និងថវិកាប្រតិបត្តិការសាលារៀន (SOB) សម្រាប់ការវិនិយោគទូទៅក្នុងឆ្នាំ២០១៩។ ការប៉ាន់ស្មាននេះផ្អែកទៅលើការវិនិយោគនៅក្នុងប្រតិបត្តិការ SBM និងការបង្កើនសមត្ថភាពរបស់គ្រូបង្រៀន។

56 ការអប់រំនៅកម្ពុជា៖ លទ្ធផលនៃបទពិសោធន៍របស់ប្រទេសកម្ពុជាក្នុងកម្មវិធីសម្រាប់វាយតម្លៃសិស្សអន្តរជាតិសម្រាប់ការអភិវឌ្ឍន៍, ក្រសួងអប់រំ យុវជន និងកីឡា, ឆ្នាំ២០១៨។

**តារាង S.4៖ ជម្រើសគោលនយោបាយដើម្បីលើកកម្ពស់គុណភាពអប់រំ**

| ការប្រកួតប្រជែង | ជម្រើសគោលនយោបាយរយៈពេលខ្លី (១ឆ្នាំ ទៅ ២ឆ្នាំ) | ជម្រើសគោលនយោបាយរយៈពេលមធ្យម (លើសពី ៣ឆ្នាំ) |
|---|---|---|
| លទ្ធផលសិក្សារបស់សិស្សខ្សោយ គឺកើតឡើងដោយសារប្រព័ន្ធគណនេយ្យភាពសាលារៀនចំពោះសហគមន៍គ្មានប្រសិទ្ធភាព | អនុវត្តប្រព័ន្ធគណនេយ្យភាពកម្រិតមួយថ្មីសម្រាប់សហគមន៍ ដោយ (i) ការផ្តល់អំណាចឲ្យគណៈកម្មការគ្រប់គ្រងសាលា មានអំណាចលើគណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀនឲ្យមានគណនេយ្យភាពចំពោះលទ្ធផលសិក្សារបស់សិស្ស (ii) លើកដំកើងតម្លាភាព នៃប្រតិបត្តិការសាលារៀន និង (iii) លើកកម្ពស់ការធានាគុណភាពនៅសាលារៀន។<br><br>ពង្រឹងគណនេយ្យភាពនៅការិយាល័យអប់រំស្រុក ដើម្បីធានាថា សាលារៀនក្នុងដែនសមត្ថកិច្ចបំពេញការងារ ដល់កម្រិតរំពឹងចង់បាន។ កសាងសមត្ថភាពមន្ទីរអប់រំខេត្ត និង ការិយាល័យអប់រំស្រុក ឲ្យមើលការខុសត្រូវចំពោះសាលាបឋមសិក្សា និងមធ្យមសិក្សាឲ្យមានប្រសិទ្ធភាព។ | អនុវត្តស្តង់ដារប្រសិទ្ធភាពសាលារៀនតម្រូវឱ្យមន្ទីរអប់រំខេត្ត និងការិយាល័យអប់រំស្រុក និងគណគ្រប់គ្រងសាលារៀនបំពេញការងារដើម្បីបង្កើនគុណផលសាលារៀន។ |
| ដំឡើងប្រាក់ខែគ្រូបង្រៀនទូទៅ មានឥទ្ធិពលតិចតួចលើលទ្ធផលសិក្សារបស់សិស្ស។ ដំឡើងប្រាក់ខែគ្រូបង្រៀនទូទៅបែបនេះ អាចធ្វើឲ្យមានគម្លាតនៃគុណភាពអប់រំកាន់តែធំរវាងសាលារដ្ឋ និងសាលារៀនឯកជន។ | អនុវត្តប្រព័ន្ធផ្តល់លាភការតាមគុណផលការងារសម្រាប់នាយក គ្រូបង្រៀន និងបុគ្គលិកអប់រំ។ ដំឡើងប្រាក់ខែ និងមុខងារ គួរប្រើគុណផលការងារជាគោល។<br>បង្កើតសូចនករគុណផលការងារឲ្យមានប្រសិទ្ធភាព សម្រាប់វាយតម្លៃ គុណផលការងាររបស់នាយកសាលា គ្រូបង្រៀន និងបុគ្គលិកអប់រំ។ | អនុវត្តគន្លងអាជីពគ្រូបង្រៀន។ គន្លងអាជីពគ្រូបង្រៀន គួរពិចារណាលើ (i) ការលើកទឹកចិត្តឲ្យចូលនិវត្តមុនអាយុសម្រាប់គ្រូបង្រៀនវ័យចាស់ ដែលបំពេញគុណផលការងារបានទាប (ii) ការកំណត់អត្តសញ្ញាញគ្រូបង្រៀនដែលបំពេញគុណផលការងារទាប ដោយចាត់តាំងឲ្យមកធ្វើការងាររដ្ឋបាល និង (iii) ការដំឡើងមុខងារអាជីពគ្រូបង្រៀនដែលបំពេញគុណផលការងារខ្ពស់ទៅតាមគន្លងអាជីពគ្រូបង្រៀន។ |
| ការលើស និងខ្វះគ្រូបង្រៀនធ្វើឱ្យការរៀនសូត្ររបស់សិស្សពុំសូវមានប្រសិទ្ធភាព ហើយការពង្រាយគ្រូបង្រៀនត្រឹមត្រូវជួយរដ្ឋាភិបាលកាត់បន្ថយចំណាយ១០% នៃប្រាក់ខែគ្រូបង្រៀនធ្វើការងារមិនពេញលេញ។ | ការពង្រាយគ្រូបង្រៀនពីសាលារៀនលើសគ្រូបង្រៀនទៅសាលារៀនខ្វះគ្រូបង្រៀន ក្នុងដែនសមត្ថកិច្ចរបស់ការិយាល័យអប់រំ ស្រុក និង មន្ទីរអប់រំខេត្ត។ | ការលើកទឹកចិត្តគ្រូបង្រៀនកុំឲ្យផ្ទេរសាលាបង្រៀន ដោយទាមទារឱ្យបង្ហាញព័ត៌មានសាធារណៈអំពីការផ្ទេរគ្រូបង្រៀន និងមានហេតុផលត្រឹមត្រូវ និងអនុវត្តយន្តការផ្តល់យោបល់ត្រឡប់កម្រិតសាលារៀន។ |
| ខ្វះវិនិយោគលើការពង្រឹងសមត្ថភាពគ្រូបង្រៀន ហាក់ដូចជាពន្យារពេលទុកឲ្យគុណភាពអប់រំទាប ឈរជើងក្នុងរយៈពេលមធ្យមបន្តទៀត។ | បង្កើនវិនិយោគរបស់រដ្ឋាភិបាល សម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈ និងវិក្រឹតការគ្រូបង្រៀន។ | ពង្រឹងសមត្ថភាពគ្រូឧទ្ទេស និងគរុសិស្សតាមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន។ |

# សេចក្តីសន្និដ្ឋាន

ការខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការកែទម្រង់វិស័យអប់រំក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយនេះទទួលបានជោគជ័យ និងឧត្តមានុវត្តមួយចំនួន ដើម្បីពង្រឹងវិស័យនេះឲ្យកាន់តែរឹងមាំថែមទៀត។ បទពិសោធន៍របស់សាលារៀនជំនាន់ថ្មី និងសាលារៀនគ្រប់គ្រងដោយផ្អែកលើលទ្ធផល បានលើកឡើងថា ការលើកកម្ពស់គុណភាពអប់រំត្រូវផ្តោតការយកចិត្តទុកដាក់លើចំណុច ដូចខាងក្រោម៖

*អនុសាសន៍ទីមួយ ការពង្រឹងគណនេយ្យភាពនៅតាមសាលារដ្ឋ។* គណនេយ្យភាពគឺគុណសម្បត្តិសម្រាប់កែលម្អគុណភាពនៃការរៀនរបស់សិស្ស។ នៅតាមសាលារដ្ឋ គណនេយ្យភាពមិនទាន់មានប្រសិទ្ធភាពនៅឡើយទេ។ ការពង្រឹងយន្តការគណនេយ្យភាពនៅតាមសាលារៀនរដ្ឋជាការលំបាកមែន បទពិសោធន៍របស់សាលារៀនជំនាន់ថ្មី និងសាលារៀនគ្រប់គ្រងដោយផ្អែកលើលទ្ធផល បង្ហាញថា យន្តការគណនេយ្យភាពអាចអនុវត្ត ដោយជំរុញអនុវត្តសេចក្តីណែនាំអនុវត្តកម្រិតស្ថាប័ន ផ្តល់ស្វ័យភាពគ្រប់គ្រងប្រតិបត្តិការសាលារៀនទៅដល់កម្រិតសមរម្យមួយ និងអនុញ្ញាតឲ្យសហគមន៍ចូលរួមក្នុងដំណើរការប្រតិបត្តិការសាលារៀន។ គណនេយ្យភាពកម្រិតសាលារៀនក៏មានសារសំខាន់ផងដែរ ក្នុងការជួយដល់រដ្ឋាភិបាលឲ្យអនុវត្តកិច្ចខិតខំប្រឹងប្រែងកែទម្រង់គោលនយោបាយប្រកបដោយប្រសិទ្ធភាព ដើម្បីឆ្លើយតបទៅនឹងផលប៉ះពាល់នៃជំងឺកូវីដ-១៩។ ការពន្លឿនអនុម័តយន្តការគណនេយ្យភាពកម្រិតសាលារៀនមានអត្ថប្រយោជន៍ សម្រាប់អនុវត្តគំនិតផ្តួចផ្តើមកំណែទម្រង់ដែលមានស្រាប់ និងគំនិតផ្តួចផ្តើមបន្ថែមដើម្បីដោះស្រាយបញ្ហាប្រឈមបន្ថែទៀត។

*អនុសាសន៍ទី២ ភ្ជាប់ការដំឡើងប្រាក់ខែ និងក្របខ័ណ្ឌមុខងារជាមួយគុណផលការងារ។* កម្មវិធីផ្តល់លាភការលើកទឹកចិត្តដល់គ្រូបង្រៀន និងបុគ្គលិកអប់រំ ចាំបាច់ត្រូវប្រើគុណផលការងារជាគោល។ ការដំឡើងប្រាក់ខែតាមគុណផលជាការផ្តល់លាភការទឹកចិត្តដល់គ្រូបង្រៀន និងធានាលើកដំកើងជីវភាពដល់កម្រិតទទួលយកបានក្នុងការបំពេញភារកិច្ច។ ផ្ទុយទៅវិញ ការដំឡើងប្រាក់ខែជាលក្ខណៈទូទាំង ដោយពុំមានយន្តការធានាគុណផលការងារឲ្យពេញចិត្តទេ គឺអត់ប្រសិទ្ធភាព។ គម្លាតនៃគុណភាពអប់រំរវាងសាលារដ្ឋ និងឯកជនទំនងជាបន្តឃ្លាតកាន់តែធំ។ ការផ្តល់លាភការលើកទឹកចិត្តអនុវត្តតាមប្រព័ន្ធគ្រប់គ្រងគុណផលការងារសម្រាប់គ្រូបង្រៀន ជួយពង្រឹងសាលារដ្ឋឲ្យអនុវត្តមុខងារ និងការប្រព្រឹត្តិទៅឲ្យមានប្រសិទ្ធភាព និងចាំបាច់ក្នុងកិច្ចខិតខំប្រឹងប្រែងស្តារស្ថានភាពក្រោយកូវីដ-១៩។

*អនុសាសន៍ទីបី ពង្រឹងសមត្ថភាព និងគុណភាពគ្រូបង្រៀន។* រដ្ឋាភិបាលពឹងអាស្រ័យលើគ្រូបង្រៀនក្នុងការផ្តល់សេវាអប់រំ។ ប្រសិនបើកម្មវិធីបណ្តុះបណ្តាល និងវិក្រឹតការ គ្រូបង្រៀនពុំមានប្រសិទ្ធិភាព ឥទ្ធិពលអាក្រក់ប៉ះពាល់គុណភាពអប់រំរយៈពេលយូរ។ ដូច្នេះ លក្ខខណ្ឌនៃការចូលរៀនក្នុងកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀននៅតាមមជ្ឈមណ្ឌលបណ្តុះបណ្តាលខេត្ត និងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ត្រូវតែកែលម្អ និងពង្រឹងបន្ថែម។ បន្ថែមលើនេះទៀត ការបន្តពង្រឹងការអនុវត្តវិជ្ជាជីវៈបង្រៀន នឹងជួយលើកកម្ពស់គុណភាពបង្រៀនជាទូទៅ។ ជាពិសេស គ្រូបង្រៀនគួរទទួលការបណ្តុះបណ្តាល និងត្រៀមបម្រុងជួយសិស្សរៀនយឺត។ វិធីសាស្រ្តនេះជួយកាត់បន្ថយផលប៉ះពាល់នៃការបាត់បង់ឱកាសសិក្សា ដោយសារការបិទសាលារៀនក្នុងអំឡុង និងក្រោយពេលកូវីដ-១៩។

ការផ្តួចផ្តើមបន្ថែមចំនួនពីរអាចមានប្រយោជន៍ក្នុងការធានាគុណភាពអប់រំដែលរងផលប៉ះពាល់ដោយសារកូវីដ-១៩៖

- *កម្មវិធីជួយសិស្សរៀនយឺត ដោយសារការបាត់ឱកាសរៀន និងដើម្បីកាត់បន្ថយអត្រាបោះបង់សាលា។* អត្រាបោះបង់ការសិក្សាទំនងជាកើនឡើង ក្នុងរយៈពេលមធ្យមចំពោះសិស្សរៀនមិនទាន់។ កម្មវិធីជួយសិស្សរៀនមិនទាន់ សំដៅបំពេញបន្ថែមដល់ការបាត់ឱកាសសិក្សា ក្នុងកំឡុងពេលបិទសាលារៀន។
- *យន្តការត្រួតពិនិត្យយ៉ាងម៉ឺងម៉ាត់ ដើម្បីតាមដានប្រសិទ្ធភាពនៃការឆ្លើយតបរបស់សាលារៀនទៅនឹងការរាតត្បាតជំងឺកូវីដ-១៩។* លទ្ធផលសិក្សារបស់សិស្ស គួរត្រូវចាត់ទុកជាវិធានការសំខាន់មួយនៃក្របខ័ណ្ឌតាមដានការរៀនរបស់សិស្ស។ ការតាមដានការសិក្សារបស់សិស្ស ទាមទារឲ្យអនុវត្តការវាយតម្លៃការសិក្សារបស់សិស្សជាប្រចាំ ដើម្បីបញ្ជាក់អំពីវឌ្ឍនភាពនៃលទ្ធផលសិក្សារបស់សិស្ស។

កំណែទម្រង់វិស័យអប់រំមានគោលដៅវែងឆ្ងាយ។ រដ្ឋាភិបាលត្រូវការវិនិយោគ ពេលវេលា និងការប្តេជ្ញាចិត្ត ក្នុងការអនុវត្តកម្មវិធីកំណែទម្រង់ការអប់រំដើម្បីទទួលបានលទ្ធផលវិជ្ជមាន។ ទោះយ៉ាងណាក៏ដោយ ការពិតដ៏សោកសៅមួយបង្ហាញច្បាស់គឺថា គណនេយ្យភាពអន់នៅសាលារដ្ឋប៉ះពាល់ដល់គុណភាពនៃការរៀនយូរអង្វែង។ គោលដៅចម្បងនៃកំណែទម្រង់អប់រំសំដៅដោះស្រាយបញ្ហាគណនេយ្យភាពក្នុងវិស័យអប់រំ។ ដូច្នេះ ការធានាឲ្យមានសហគមន៍ចូលរួមកាន់តែសកម្ម អាចជួយដោះស្រាយបញ្ហាគណនេយ្យភាព និងធានាឱ្យកំណែទម្រង់វិស័យអប់រំរីកចម្រើនទៅមុខដោយរលូនជាងមុន។ ដូច្នេះ ការផ្តល់សេវាអប់រំប្រកបដោយគុណភាព នឹងទៅដល់សហគមន៍ដែលត្រូវការជំនួយបំផុត។

# ឧបសម្ព័ន្ធ ១ ៖ គុណសម្បត្តិ គុណវិបត្តិ និងជម្រើសគោលនយោបាយសម្រាប់គំរូសាលារៀននីមួយៗ

## ទម្រង់សាលារៀនជំនាន់ថ្មី (NGS)

| គុណសម្បត្តិ | គុណវិបត្តិ | ជម្រើសគោលនយោបាយ |
|---|---|---|
| • ការចាត់ចែងស្ថាប័នឲ្យមានប្រសិទ្ធភាព៖ ក្រុមប្រឹក្សាភិបាលជាតិ ក្រុមប្រឹក្សាភិបាលខេត្ត និង គណៈកម្មាការទ្រទ្រង់សាលារៀន ដើម្បីធានាគុណភាព។<br>• ប្រព័ន្ធវាយតម្លៃគុណផលការងារឲ្យមានប្រសិទ្ធភាព។ បុគ្គលិក/គ្រូបង្រៀន បំពេញការងារតាមវិចារកិច្ច ឲ្យមានប្រសិទ្ធភាព និងអនុវត្តតាមសូចនាករគុណផលការងារ<br>• គ្រូបង្រៀនប្រកដបដោយវិជ្ជាជីវៈ។ ការបណ្ដុះបណ្ដាលបន្ត និងអភិវឌ្ឍវិជ្ជាជីវៈ។ ឧបករណ៍បច្ចេកវិទ្យាព័ត៌មាន ក៏ត្រូវមានសម្រាប់បង្រៀនឲ្យមានគុណភាព។<br>• ឪពុកម្ដាយកាន់តែទុកចិត្ត។ តម្រូវការចូលរៀនរបស់សិស្សកាន់តែកើនឡើង។ ឧទាហរណ៍ ការប្រឡងចូលរៀននៅវិទ្យាល័យព្រះស៊ីសុវត្ថិបានទទួលអ្នកដាក់ពាក្យសុំចំនួន ១.២៦៤ សម្រាប់ការចូលរួមដែលមានតែ ២៣៤ កន្លែង។ ការវិភាគទានប្រចាំឆ្នាំរបស់ឪពុកម្ដាយចំនួន ២៨០ ដុល្លារអាមេរិកសម្រាប់សិស្សមួយនាក់ (ឆ្នាំ២០១៩)។<br>• ស្តង់ដារខ្ពស់នៃការរៀនសូត្រ ត្រូវមានឧបករណ៍បច្ចេកវិទ្យាព័ត៌មាន គោលវិធីដឹកនាំការរៀនតាមការរិះរក។<br>• ថ្នាក់រៀនមានសិស្សតិច ៣៥នាក់ក្នុងគ្រូមួយនាក់ ជាផ្នែកមួយនៃដំណើរការធានាគុណភាព។<br>• លាភការលើកទឹកចិត្តសម្រាប់គ្រូបង្រៀន។ ការបន្ថែមប្រាក់ខែ បូករួមទាំងលាភការលើកទឹកចិត្តសម្រាប់ដឹកនាំក្លឹបសិក្សា។<br>• ការកសាងសមត្ថភាពគ្រូបង្រៀន។ អាហារូបករណ៍សម្រាប់គ្រូបង្រៀន សម្រាប់ចំណាយថ្លៃសិក្សា ៣០ភាគរយ។ ទស្សនកិច្ចសិក្សាតាមសាលារៀនក្នុងតំបន់។ | • ជ្រើសរើសតែពូកែ។ សិស្សប្រឡងជាប់ទើបអាចចូលរៀន នៅសាលារៀនជំនាន់ថ្មី។<br>• ត្រូវការរដ្ឋាភិបាលវិនិយោគច្រើន។ វិនិយោគសម្រាប់សិស្សម្នាក់នៅកម្រិតអនុវិទ្យាល័យត្រូវចំណាយរហូតដល់ ៣៧០ដុល្លារក្នុងមួយឆ្នាំ។<br>• សាលារៀនជំនាន់ថ្មីត្រូវគ្រប់គ្រងដោយអង្គការមិនមែនរដ្ឋាភិបាល។ រដ្ឋាភិបាលត្រូវវិនិយោគខ្ពស់។ | • បន្តផ្ដោតការយកចិត្តទុកដាក់លើគុណភាពនៃការរៀន និងពង្រីកជាបណ្ដើរៗ។ ត្រូវការពេលដើម្បីបង្កើតទំនុកចិត្តពីឪពុកម្ដាយសិស្ស (មាន សាលារៀនជំនាន់ថ្មី ៤ ក្នុងចំណោមសាលា ១១ អាចទទួលយកវិភាគទានពីឪពុកម្ដាយសិស្ស ជាប្រភពចំណូលសំខាន់ បន្ថែមលើវិនិយោគរបស់រដ្ឋាភិបាល)<br>• បង្កើនវិភាគទានឪពុកម្ដាយសិស្សជាបណ្ដើរៗ។ ពេលឪពុកម្ដាយឲ្យតម្លៃ ចំពោះការរៀនរបស់កូន ឪពុកម្ដាយរីករាយនឹងចំណាយថវិកាដើម្បីឲ្យកូនរៀនជាមិនខាន។<br>• ពង្រឹងការគ្រប់គ្រងអភិវឌ្ឍចំណេះដឹងបន្ថែម។ ការគ្រប់គ្រងការអភិវឌ្ឍចំណេះដឹងសម្រាប់គ្រូបង្រៀនគឺគ្រប់គ្រងទាំងស្រុងនៅថ្នាក់ក្រសួង។ ការគ្រប់គ្រងបែបនេះពិបាកនឹងធានាឲ្យមាននិរន្តរភាពនៃការធានាប្រតិបត្តិការលើការគ្រប់គ្រងការអភិវឌ្ឍចំណេះដឹងឲ្យមានប្រសិទ្ធភាព |

## ទម្រង់សាលារៀនគ្រប់គ្រងដោយផ្អែកលើលទ្ធផល (SBM)

| គុណសម្បត្តិ | គុណវិបត្តិ | ជម្រើសគោលនយោបាយ |
|---|---|---|
| • ផ្ដល់ឱកាសស្មើភាពគ្នាឲ្យសិស្សចុះឈ្មោះចូលរៀន។ សិស្សរៀនខ្សោយមកពីសាលាបឋមសិក្សាកម្រង (២០% មានបំណិនអំណាន និងគណិតវិទ្យាកម្រិត) ក៏បានចូលរៀន និងបង្រៀនម៉ោងបន្ថែមជួយសិស្សរៀនយឺត។<br>• គណនេយ្យភាពចំពោះសហគមន៍។ គណកម្មការគ្រប់គ្រងសាលារៀន មានតំណាងរបស់សហគមន៍មានអំណាចទាមទារឱ្យលើកកម្ពស់គុណផលសិក្សារបស់ឲ្យប្រសើរ (លទ្ធផលប្រឡងមានផ្សាយជាទៀងទាត់ទីសាធារណៈ)។<br>• រដ្ឋាភិបាលវិនិយោគតិច។ រដ្ឋាភិបាលវិនិយោគជាមធ្យម៧០ ដុល្លារអាមេរិកសម្រាប់សិស្សមួយនាក់ក្នុងឆ្នាំ២០១៩។<br>• លទ្ធផលនៃការសិក្សាប្រសើរឡើង។ សិស្សប្រឡងជាប់តេស្តស្តង់ដារគណិតវិទ្យាកើនពី ៥៦% ក្នុងឆ្នាំ ២០១៨ ដល់ ៦៩% ក្នុងឆ្នាំ ២០១៩ ហើយតែងសេចក្ដីកើនពី ៤៩% ក្នុងឆ្នាំ២០១៨ ដល់ ៥៣% ក្នុងឆ្នាំ២០១៩។ បន្ថែមម៉ោងបង្រៀនសម្រាប់សិស្សរៀនយឺត។<br>• តេស្តស្តង់ដាររឹតបន្តឹង។ តេស្តស្តង់ដាររឹតបន្តឹង ដើម្បីពង្រឹងការប្រឹងរៀនរបស់សិស្ស។<br>• អភិវឌ្ឍសមត្ថភាពគ្រូបង្រៀន។ ផ្ដល់អាហារូបករណ៍ឲ្យគ្រូបង្រៀនទៅសិក្សាបន្តនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ (ផ្ដល់ថ្លៃសិក្សា និងប្រាក់ធ្វើដំណើរ)។ | • គ្រូបង្រៀនពុំគ្រប់គ្រាន់។ សាលារៀនគ្រប់គ្រងដោយផ្អែលលើលទ្ធផល ខ្វះគ្រូបង្រៀន ដោយសារគោលការណ៍ផ្ទេរ និងពង្រាយគ្រូពុំមានប្រសិទ្ធភាព។<br>• ការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀនមានតិច។ ថ្វីបើគ្រូបង្រៀនបានអភិវឌ្ឍសមត្ថភាព ប៉ុន្តែការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន ក៏ត្រូវបំពេញបន្ថែមទៀតដែរ។ | • បង្កើនការរៀនវិជ្ជាជីវៈបង្រៀន។<br>• ការពង្រាយគ្រូបង្រៀនពីសាលារៀនលើស គ្រូទៅសាលារៀនខ្វះបង្រៀន។ ការិយាល័យអប់រំស្រុក និងមន្ទីរអប់រំខេត្ត អាចធ្វើការរួមគ្នាជាមួយសាលារៀនក្នុងការពង្រាយគ្រូ<br>• សហការជាមួយការិយាល័យអប់រំស្រុក និងមន្ទីរអប់រំខេត្ត និងសាលាបឋមសិក្សា ដើម្បីដើម្បីជួយសិស្សរៀនយឺត។ ដោយមាន សហការជាមួយការិយាល័យអប់រំស្រុក និងមន្ទីរអប់រំខេត្ត សាលារៀនគ្រប់គ្រងដោយផ្អែកលើលទ្ធផល អាចបង្កើតកម្មវិធីដល់សាលាបឋមសិក្សាកម្រង ដើម្បីលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស។ |

## ទម្រង់សាលារៀនឯកជន

| គុណសម្បត្តិ | គុណវិបត្តិ | ជម្រើសគោលនយោបាយ |
|---|---|---|
| • ក្រុមអប់រំមានរចនាសម្ព័ន្ធល្អ។ សាលារៀនឯកជនជាច្រើនមានរចនាសម្ព័ន្ធជាក្រុមអប់រំ និងមានទីស្នាក់ការកណ្ដាលគ្រប់គ្រងរាល់ការប្រតិបត្តិការសាខា<br>• មានប្រព័ន្ធជ្រើសរើសគ្រូបង្រៀន និងប្រព័ន្ធវាយតម្លៃ។ ផ្ដល់សេវាតាមតម្រូវការ។ មានសូចនាករគុណផលការងារសម្រាប់វាយតម្លៃគុណផលការងាររបស់គ្រូបង្រៀន។<br>• ផលធៀបគ្រូបង្រៀន-សិស្សមានត្រឹម ២៥នាក់ ទៅ ៣០នាក់ សម្រាប់គ្រូមួយនាក់ក្នុងមួយថ្នាក់<br>• ប្រើការិយាល័យធានាគុណភាពរបស់សាលារៀនជាគោល។ សាលារៀនឯកជនភាគច្រើនមានអង្គភាពធានាគុណភាពអប់រំ ពុំពឹងអាស្រ័យ លើសេវាធានាគុណភាពរបស់រដ្ឋទេ។<br>• ពង្រឹងសមត្ថភាពគ្រូបង្រៀន។ អភិវឌ្ឍសមត្ថភាពគ្រូបង្រៀនជាប្រចាំ។ | • ថ្លៃឈ្នួលកើនឡើង។ ដើរឲ្យទាន់ទីផ្សារ។ ពេលគ្រូបង្រៀនសាលារដ្ឋឡើងប្រាក់ខែ សាលារៀនឯកជនក៏ដំឡើងប្រាក់ខែឲ្យទាន់តម្រូវការទីផ្សារ។<br>• ត្រូវការគ្រូបង្រៀនរបស់សាលារដ្ឋ។ គ្រូបង្រៀន ក្រៅម៉ោងបង្រៀននៅសាលាឯកជនភាគច្រើន ធ្វើការនៅសាលារដ្ឋ។<br>បញ្ហានេះប៉ះពាល់ដល់គុណភាពនៃការបង្រៀននៅសាលារដ្ឋ។<br>• ថ្លៃឈ្នួល។ សាលាឯកជនគិតថ្លៃសិក្សាពី ៥០០ ដុល្លារ ទៅ ១៥០០ដុល្លារក្នុងមួយឆ្នាំសម្រាប់សិស្សមួយនាក់ តាមប្រភេទសាលា។ | • ពិចារណាដាក់កំហិតលើសាលាឯកជន ចំពោះការជួលគ្រូបង្រៀនមកពីសាលារដ្ឋ។ គ្រូបង្រៀន ធ្វើការនៅសាលារៀនឯកជន ធ្វើការពេញម៉ោង កុំធ្វើការក្រៅម៉ោង។<br>• ក្នុងពេលអនាគត សាលារៀនឯកជនធំៗគួរមានមជ្ឈមណ្ឌលបណ្ដុះបណ្ដាលគ្រូបង្រៀន។ បច្ចុប្បន្ន គ្រូបង្រៀនទាំងអស់ទទួលការបណ្ដុះបណ្ដាលគ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូបង្រៀនរបស់រដ្ឋ សាលាគរុកោសល្យខេត្ត និងភូមិភាគ។ |

# ឧបសម្ព័ន្ធ ២ ៖ សូចនាករសំខាន់ៗនៅប្រទេសកម្ពុជាក្រោមសេណារីយ៉ូគោល

| | 2017 | 2018 | 2019e | 2020p | 2021f | 2022f |
|---|---|---|---|---|---|---|
| **ទិន្នផល និងកំណើនសេដ្ឋកិច្ច** | | | | | | |
| កំណើន ផសស ពិត គិតត្រឹមតម្លៃទីផ្សារថេរ (% ប្រែប្រួលធៀបនឹងឆ្នាំមុន) | 7.0 | 7.5 | 7.1 | -1.0 | 6.0 | 6.3 |
| ការប្រើប្រាស់ដោយឯកជន | 3.7 | 3.0 | 7.0 | 2.1 | 5.0 | 5.4 |
| ការប្រើប្រាស់ដោយរដ្ឋាភិបាល | 23.5 | 5.1 | -9.1 | 6.7 | -16.7 | 10.8 |
| ការវិនិយោគមូលធនថេរសរុប | 6.1 | 6.1 | 10.7 | 4.8 | 13.2 | 7.4 |
| ការនាំចេញ ៖ ទំនិញ និងសេវា | 5.3 | 5.3 | 7.8 | -16.0 | 7.0 | 7.5 |
| ការនាំចូល ៖ ទំនិញ និងសេវា | 4.1 | 4.1 | 6.0 | -11.0 | 6.9 | 7.1 |
| កំណើន ផសស ពិត គិតត្រឹមតម្លៃកត្តាឬមចំណែកថេរ (% ប្រែប្រួលធៀបនឹងឆ្នាំមុន) | 6.8 | 7.4 | 6.8 | -1.0 | 6.0 | 6.3 |
| កសិកម្ម | 1.7 | 1.1 | -0.5 | 0.3 | 0.4 | 0.5 |
| ឧស្សាហកម្ម | 9.7 | 11.6 | 11.3 | -1.0 | 9.2 | 9.3 |
| សេវា | 7.0 | 6.8 | 6.2 | -1.7 | 5.8 | 5.8 |
| **រូបិយវត្ថុ និងតម្លៃ** | | | | | | |
| កត្តាកំណត់បរិត្តផរណា ផសស (% ប្រចាំឆ្នាំ មធ្យមភាគតាមអំឡុងពេល) | 3.3 | 3.1 | 2.7 | 1.6 | 2.6 | 2.4 |
| រូបិយវត្ថុទូលាយ (% ផសស) | 88.2 | 100.7 | 95.2 | 109.5 | 123.7 | 139.8 |
| ការផ្តល់ឥណទានដោយធនាគារក្នុងស្រុកដល់វិស័យឯកជន (% ផសស) | 86.7 | 99.6 | 83.4 | 91.8 | 102.3 | 113.6 |
| អត្រាប្តូរប្រាក់ណូមីណល (រូបិយវត្ថុក្នុងស្រុកក្នុង ១ ដុល្លារអាមេរិក) | 4,062 | 4,067 | 4,070 | 4,081 | 4,014 | 4,054 |
| អត្រាប្តូរប្រាក់ណូមីណលដែលមានប្រសិទ្ធភាព (កំណើន = ឡើងថ្លៃ) | -0.1 | -0.7 | 1.8 | 0.5 | 2.2 | -0.5 |
| អត្រាប្តូរប្រាក់ពិតដែលមានប្រសិទ្ធភាព (កំណើន = ឡើងថ្លៃ) | 1.3 | -3.3 | 0.9 | -2.4 | 1.0 | -2.4 |
| អត្រាការប្រាក់រយៈពេលខ្លី (% ក្នុងមួយឆ្នាំ) | 11.7 | 9.7 | 8.0 | 7.8 | 7.0 | 6.8 |
| **សារពើពន្ធ** | | | | | | |
| ប្រាក់ចំណូល និងជំនួយឥតសំណង (% ផសស) | 21.9 | 23.8 | 25.4 | 16.6 | 17.3 | 20.2 |
| ចំណាយ និងការផ្តល់កម្ចីសរុប (% ផសស) | 22.7 | 23.4 | 24.9 | 25.6 | 25.0 | 24.7 |
| សមតុល្យរួម (% ផសស) | -0.8 | 0.4 | 0.5 | -9.0 | -7.6 | -4.5 |
| សមតុល្យសារពើពន្ធបឋម (% ផសស) | -0.4 | 0.8 | 0.9 | -8.5 | -7.1 | -4.0 |
| បំណុលទូទៅរបស់រដ្ឋាភិបាល (% ផសស) | 30.3 | 30.0 | 29.0 | 31.6 | 33.4 | 35.3 |
| **គណនីខាងក្រៅ** | | | | | | |
| ការនាំចេញ ៖ GNFS (ដុល្លារអាមេរិកណូមីណល % ប្រចាំឆ្នាំ) | 9.4 | 12.3 | 9.5 | -15.1 | 10.6 | 8.4 |
| ការនាំចូល ៖ GNFS (ដុល្លារអាមេរិកណូមីណល % ប្រចាំឆ្នាំ) | 7.8 | 9.3 | 9.0 | -10.3 | 10.0 | 7.4 |
| សមតុល្យគណនីចរន្ត (% ផសស) | -9.7 | -8.9 | -8.8 | -14.2 | -13.7 | -13.5 |
| ការវិនិយោគផ្ទាល់ពីបរទេស ៖ លំហូរចូលសរុប (លានដុល្លារអាមេរិក បច្ចុប្បន្ន) | 2,673.1 | 3,088.8 | 2,845.1 | 2,328.1 | 2,764.3 | 3,087.1 |
| ទុនបម្រុងអន្តរជាតិសរុប (លានដុល្លារអាមេរិក) | 12,168.7 | 14,597.8 | 18,732.8 | 16,859.5 | 17,702.5 | 19,118.7 |
| (ចំនួនខែនៃការនាំចូលទំនិញ និងសេវា) | 7.5 | 6.3 | 7.6 | 6.9 | 6.8 | 6.8 |
| ចំណាំ ៖ ផសស ធម្មតា (លានដុល្លារអាមេរិក) | 22,115 | 24,476 | 26,888 | 26,969 | 29,806 | 32,120 |
| ផសស សម្រាប់មនុស្សម្នាក់ (ដុល្លារអាមេរិកធម្មតា) | 1,376.1 | 1,500.5 | 1,624.6 | 1,606.8 | 1,751.9 | 1,863.4 |
| ចំណូលជាតិសរុបសម្រាប់មនុស្សម្នាក់ វិធីសាស្រ្ត Atlas (ដុល្លារអាមេរិកបច្ចុប្បន្ន) | 1,240.0 | 1,390.0 | | | | |

*ប្រភព* ៖ អាជ្ញាធរកម្ពុជា សូចនាករអភិវឌ្ឍន៍ពិភពលោក និងការប៉ាន់ស្មាន និងការព្យាករបស់បុគ្គលិកធនាគារពិភពលោក

*ចំណាំ* ៖ e = ប៉ាន់ស្មាន, f = ព្យាករណ៍, p = ព្យាករណ៍ (គណនា

*1/* ទំនិញ និងសេវាដែលមិនមែនជាកត្តាឬមចំណែក (GNFS)

# គន្ថនិទ្ទេស

Barrera-Osorio, F., and D. Raju. 2017. “Teacher performance pay: Experimental evidence from Pakistan.” *Journal of Public Economics* 148: 75–91.

Clotfelter, Charles T., Elizabeth Glennie, Helen F. Ladd, and Jacob L. Vigdor. 2008. “Would Higher Salaries Keep Teachers in High-Poverty Schools? Evidence from a Policy Intervention in North Carolina.” Journal of Public Economics 92 (5): 1352–70.

Cowan, James, and Dan Goldhaber. 2015. “Do Bonuses Affect Teacher Staffing and Student Achievement in High-Poverty Schools? Evidence from an Incentive for National Board Certified Teachers in Washington State.” Working Paper 2015-4, Center for Education Data & Research, University of Washington, Seattle.

Dee, Thomas S., and Dan Goldhaber. 2017. “Understanding and Addressing Teacher Shortages in the United States.” Brookings Institution, Washington, DC.

Falch, Torberg. 2010. “The Elasticity of Labor Supply at the Establishment Level.” Journal of Labor Economics 28 (2): 237–66.

Glazerman, Steven, Ali Protik, Bing-ru Teh, Julie Bruch, and Jeffrey Max. 2013. “Transfer Incentives for High-Performing Teachers: Final Results from a Multisite Randomized Experiment.” NCEE 2014-4004. National Center for Education Evaluation and Regional Assistance, Institute of Education Sciences, Washington, DC. Government of Cambodia. 2019. National Development Strategic Plan 2019–2023. Cambodia.

McAleavy, Tony., Ha, T. T., & Fitzpatrick, R. (2018). Promising Practice: Government Schools in Vietnam. Education Development Trust. Highbridge House, 16-18 Duke Street, Reading Berkshire, England RG1 4RU, United Kingdom.

Ministry of Economy and Finance. 2020. Budget Law 2020. Ministry of Economy and Finance, Phnom Penh.

———. 2020. *Cambodia Public Debt Statistical Bulletin* 9 (March). Ministry of Economy and Finance, Phnom Penh.

MAFF (Ministry of Agriculture, Fisheries and Forestry). 2020. “January 2020 Report on Agriculture, Fisheries and Forestry.” Ministry of Agriculture, Fisheries and Forestry, Phnom Penh, February 21.

———. 2020. “2019–20 Annual Report.” Ministry of Agriculture, Forestry and Fisheries, Phnom Penh.

MoEYS (Ministry of Education, Youth, and Sports). 2014. Results of Grade Six Student Achievement from the National Assessment in 2013. Phnom Penh: MoEYS.

———. 2015. Education for All 2015 National Review. Phnom Penh: MoEYS.

———. 2016. New Generation School Policy: MoEYS.

———. 2016. Results of Grade Three Student Achievement from the National Assessment in 2015. Phnom Penh: MoEYS.

———. 2017. Results of Grade Six Student Achievement from the National Assessment in 2016. Phnom Penh: MoEYS.

———. 2017. *School-Based Management Manual 2017*. MoEYS.

———. 2018. *Education in Cambodia: Findings from Cambodia’s experience in PISA for Development.* Ministry of Agriculture, Fisheries and Forestry, Phnom Penh.

———. 2018. New Generation School Operation Manual: MoEYS.

———. 2018. Results of Grade Eight Student Achievement from the National Assessment in 2017. Phnom Penh: MoEYS.

———. 2019. Budget Progress Report. Phnom Penh: MoEYS.

———. 2019. Education Strategic Plan. Phnom Penh: MoEYS.

———. 2019. Results of Grade Eleven Student Achievement from the National Assessment in 2018. Phnom Penh: MoEYS.

———. 2020. New Generation School Annual Achievement Report: MoEYS.

MoEYS (Ministry of Education, Youth, and Sports) and ERC. 2017. “Teachers and Teaching Profession in Cambodia.” Cambodia.

———. 2018. Teacher Management and Redeployment: Issues and Practical Way Forward. Cambodia.

National Bank of Cambodia. 2019. 2019 *Annual Report*. Phnom Penh: National Bank of Cambodia. https://www.nbc.org.kh/download_files/publication/annual_rep_kh/Annual_Report_2019_KHR.pdf.

Springer, Matthew G., Walker A. Swain, and Luis A. Rodriguez. 2016. “Effective Teacher Retention Bonuses: Evidence from Tennessee.” Educational Evaluation and Policy Analysis 38 (2): 199–221.

World Bank. 2015. *Educating the Next Generation: Improving Teacher Quality in Cambodia*. Washington, DC: World Bank.

———. 2015a. “Cambodian Agriculture in Transition: Opportunities and Risks.” World Bank, Washington, DC.

———. 2017. “Cambodia-Project Appraisal Document: Secondary Education Improvement Project.” World Bank, Washington, DC.

———. 2017. *Cambodia: Sustaining Strong Growth for the Benefits of All – A Systematic Country Diagnostic*. Washington, DC: World Bank.

———. 2018. “Learning: To Realize Education’s Promise. World Bank, Washington, DC.

———. 2019. “Cambodia-Improving Effectiveness of Public Finance: Cambodia Public Expenditure Review.” World Bank, Washington, DC.

———. 2020a. *East Asia and Pacific Economic Update, April 2020: East Asia and Pacific in the Time of* COVID-19. Washington, DC: World Bank.

———. 2020b. “Accountability, Incentives and Learning Outcomes: Case Study of Selected School Models.” World Bank, Washington, DC.

# ឯកសារយោងផ្សេងទៀត

Annual Reports (2013–19), Ministry of Agriculture, Forestry and Fisheries.

Annual Reports (2016–19), National Bank of Cambodia.

Balance of Payment Statistics (2019), National Bank of Cambodia.

Banking Supervision Reports (2016–18), National Bank of Cambodia.

Budget Law (2020), Royal Government of Cambodia.

Cambodian National Accounts Statistics (2019), National Institute of Statistics, Ministry of Planning.

Cambodia Public Debt Statistical Bulletin, Volume 9, March 2020, Ministry of Economy and Finance.

Cambodia Socioeconomic Surveys (2004–17), National Institute of Statistics, Ministry of Planning.

Cambodia Tourism Statistics (2017–18), Ministry of Tourism.

February 2020 report, Ministry of Industry, Science, Technology and Innovation.

East-Asian and Pacific Economic Update, April 2020, the World Bank.

IMF Article IV Staff Report (2019), International Monetary Fund.

Macro-fiscal framework for the 2020 budget.

Monetary Statistic Bulletin (2020), National Bank of Cambodia.

Monthly reports for 2020, Ministry of Agriculture, Forestry and Fisheries.

Monthly reports for 2020, Ministry of Tourism.

ក្រុមធនាគារពិភពលោក

**ធនាគារពិភពលោក**
ប្រចាំនៅប្រទេសកម្ពុជា
អគារ Exchange Square
ជាន់ទី 10 IBRD និងជាន់ទី 11 IFC
ផ្លូវលេខ 51-61 និងផ្លូវលេខ 102-106
សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ
ភ្នំពេញ ប្រទេសកម្ពុជា
វេបសាយ: www.worldbank.org/cambodia